Scanned by Pinky Berry
www.laksmie26.wordpress.com
www.pinkyberryworld.blogspot.com





# ស្នេហ៍(មិន)បោកប្រាស់
# ចង់ប្រាប់ថា LOVE YOU

ប្រែសម្រួលដោយ : Malisa

មានលក់នៅ : ផ្សារអូឬស្សី បណ្ណាគារ និងនៅតាមតូបកាសែតនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា

បោះពុម្ពដោយប្រើក្រដាស ៨០ gsm

តំលៃ : ៧០០០៛

បោះពុម្ពនៅ : ៤ វិច្ឆិកា ឆ្នាំ ២០១១

បោះពុម្ពចំនួន : ១០០០ក្បាល

លេខទូរស័ព្ទ : ០១២ ៥២ ៦៦ ៦៧



## Prince of Zodiac

ឈ្មោះ : ហាន់ គុនជេ

ឈ្មោះហៅក្រៅ : គុនជេ

ថ្ងៃខែឆ្នាំកំណើត : ១៩ ធ្នូ ១៩xx

រាសី : ធ្នូ

ក្រុមឈាម : O

អាជីព : និស្សិតផ្នែកស្ថាបត្យកម្ម ជំនាញតុបតែងផ្ទះ ឆ្នាំទី៤

ពណ៌ដែលចូលចិត្ត : សួរពណ៌ដែលមិនចូលចិត្តវិញបានអត់...ខ្ញុំស្អប់ពណ៌ផ្កាឈូក

អាហារដែលចូលចិត្ត : ស្រេចតែអារម្មណ៍នៅពេលនោះ

ទីកន្លែងដែលចូលចិត្ត : ភ្នំ សួនឧទ្យាន

របស់ដែលតែងតែដាក់ជាប់ខ្លួន : ប៊ិចគូរម៉ូត

នារីនៅក្នុងក្តីស្រមៃ : នៅមិនទាន់មានអាយជៀក្នុងរឿងនេះទេ

ទស្សនៈផ្ទាល់ខ្លួន : ខ្លួនយើងគឺខ្លួនយើង

បទសម្ភាស

សួស្តី ប្រិយមិត្តជាស្រលាញ់ទាំងឡាយ ថ្ងៃនេះយើងសូមយកនូវចំណីអារម្មណ៍ថ្មីមកជូនប្រិយមិត្ត ដោយការធ្វើបទសម្ភាសជាមួយនឹង Prince of Zodiac ម្នាក់ក្នុងចំណោម ១២ ដែលទើបនឹងទទួលបានការជ្រើសរើសនាពេលថ្មីៗនេះ ។

ប៉ុន្តែមុននឹងបានស្គាល់រាជបុត្រនៃចក្ររាសីម្នាក់នោះ យើងអាចសុំសួរប្រិយមិត្តបានទេថា តើប្រិយមិត្តចូលចិត្ត បុរសទាន់សម័យ ខ្លួយ

...ទិនសិចស៊ីក្លាយចិត្តដែរទេ? សុបថា បើចូលចិត្ត...គេម្នាក់នេះពិតជាអាចបំពេញបំណងរបស់ប្រិយមិត្តបាន ។



គេគឺកម្លោះសង្ហាដែលបានទទួលសម្លេងឆ្នោតបែបបោសយកខ្ទេចយកខ្ទីតែម្តងពីស្រីៗច្រើនឆ្នាំជាប់ៗគ្នា តែក៏លេងប្លុកសុំបោះបង់សិទ្ធិមករហូត រហូតដល់ឆ្នាំនេះ មិនដឹងថាអ្វីបណ្តាលចិត្តទើបធ្វើឱ្យគេព្រមទទួលតំណែងនេះ ។

រាជបុត្ររាសីធ្នូម្នាក់នេះមានឈ្មោះថា ហាន់ គុនដេ អនាគតស្ថាបនិកមកពីមហាវិទ្យាល័យ XXX ជាកូនប្រុសបណ្តូលចិត្តរបស់លោកឧត្តមសេនីយឯក ហាន់ គាន់អ៊ុន មេបញ្ជាការកងទ័ពជើងគោករបស់យើងសព្វថ្ងៃនេះអ្ហែង ។ ប្រហែលជាត្រូវទទួលស្គាល់ហើយថាកូនប្រុសរបស់លោកមេបញ្ជាការម្នាក់នេះពិតជាសង្ហា ឡូយ ប្រាកដមែន សុបសេចក្តីទៅ បើអ្នកនាងកញ្ញាណាគិតចង់ស្រវ៉ាចាប់បេះដូងទាន់សម័យរបស់កម្លោះសង្ហាម្នាក់នេះ សូមតាំងចិត្តប្រមូលព័ត៌មានពីកិច្ចសម្ភាសរបស់យើងឱ្យបានល្អណាំ...តិចថាយើងកាត់ទុករបស់ល្អៗ យកតែម្នាក់ឯង ។

មានអារម្មណ៍យ៉ាងម៉េចដែរ ដែលត្រូវបានជ្រើសរើសជា Prince of Zodiac?

ហាន់ គុនដេ : ខ្ញុំអាចជំរាបមិត្តអ្នកអានបានមែនទេថា ការពិតទៅក្រុមការងារបានសុំអង្វរលោយបន្តិចផង ឱ្យខ្ញុំទទួលយកតំណែងនេះជាច្រើនឆ្នាំមកហើយ តែខ្ញុំបដិសេធរហូត ចំណែកហេតុផលដែលខ្ញុំយល់ព្រមទទួលយកតំណែងនេះ សុំមិនជំរាបលំអិតទេ

គិតថាអ្វីទៅដែលធ្វើឱ្យលោកបានទទួលការជ្រើសរើស?

ហាន់ គុនដេ : ព្រោះខ្ញុំកើតចំរាសីធ្នូនោះអ្វី អម្បាញ់មិញក្រែងអ្នកនាងប្រាប់ថាខ្ញុំបានទទួលការជ្រើសរើសជា រាជបុត្ររាសីធ្នូ អ៊ំ

ជីវិតបន្ទាប់ពីក្លាយជា Prince of Zodiac មានអ្វីប្រែប្រួលខ្លះទេ?

ហាន់ គុនដេ : ខ្ញុំប្រហែលជានៅតែដូចមុនដដែល តែអ្នកដទៃអាចនឹងគិតថាខ្ញុំប្រែប្រួលអីចេះអីចុះដែលខ្ញុំក៏មិនអាចទៅហាមគំនិត





របស់ពួកគេបានដែរ

គិតថាចរិតនិស្ស័យត្រូវនឹងរាសីខ្លួនឬអត់?



ហាន់ គុនដេ : ខ្ញុំមិនសូវជាយកចិត្តទុកដាក់រឿងទ្រឹស្តីប៉ុន្មានទេ ទើបមិនដឹងថាត្រូវឬមិនត្រូវ ដូចដែលគេសរសេរថា រាសីបែបណាត្រូវតែមានចរិតនិស្ស័យបែបនោះ ។

អ្វីដែលលោកស្អប់ជាទីបំផុតក្នុងមួយជីវិតនេះ?

ហាន់ គុនដេ : កន្លែងចង្អៀត វាធ្វើឱ្យមានអារម្មណ៍ថាដូចជាត្រូវគាបសង្កត់ផ្នែកគំនិតអីចឹង ។

ស្នេហារបស់កម្លោះរាសីនេះ ឬស្នេហាតាមបែបរបស់លោកមានលក្ខណៈបែបណាដែរ?

ហាន់ គុនដេ : ខ្ញុំផ្តល់ភាពសំខាន់ចំពោះអ្វីៗគ្រប់យ៉ាងនៅក្នុងជីវិតស្មើៗគ្នាទាំងអស់ តែពេលខ្លះស្រេចតែលើអារម្មណ៍នៅពេលនោះ

បើដូររាសីបាន...លោកចង់កើតក្នុងរាសីអី ហើយព្រោះអ្វី?

ហាន់ គុនដេ : ខ្ញុំពេញចិត្តទាំងអស់ មិនថាខ្ញុំកើតនៅរាសីអីក៏ដោយ សុំឱ្យតែជាខ្លួនខ្ញុំទៅបានហើយ!

បន្ទាប់ពីនេះ តើលោកមានផែនការអ្វីសម្រាប់ជីវិតលោកខ្លះ?

ហាន់ គុនដេ : សុំទុកប្រាប់អ្នកដែលខ្ញុំនឹងរស់នៅជាមួយនាពេលអនាគត

មានអ្វីផ្តាំផ្ញើសម្រាប់មិត្តអ្នកអានរបស់យើងដែលបានបោះឆ្នោតឱ្យលោកទេ?

ហាន់ គុនដេ : អស់លោកអ្នកអស់លុយថ្លៃបោះឆ្នោតម្នាក់ប៉ុន្មានទៅ? (សើច) បើមានឱកាសខ្ញុំនឹងរកវិធីសងលុយនោះដល់អ្នកគ្រប់គ្នាវិញ (ក្រុមការងារសុំខ្សឹបប្រាប់តិចៗដោយក្តីរំភើបថា គេពិតជាបុរសដែលយកចិត្តទុកដាក់នឹងរឿងលម្អិតមែនទែន តែ...ការពិតកការបោះឆ្នោតរបស់យើងអត់មានអស់លុយទេ)



www.laksmie26.wordpress.com



## ផ្ដើមរឿង

ពេលនេះខ្ញុំទើបតែរៀនចប់ថ្នាក់ទី១១ សល់មួយឆ្នាំទៀតប៉ុណ្ណោះ ខ្ញុំនឹងបានត្រឡប់ទៅរស់នៅកូរ៉េយ៉ាងស្ងប់សុខនឹងគេវិញហើយ ។

ខ្ញុំត្រូវអ្នកផ្ទះបញ្ជូនឱ្យមករៀនថ្នាក់វិទ្យាល័យនៅអាមេរិក ដោយហេតុផលស្ដៀលភាសាអង់គ្លេសរបស់ខ្ញុំនៅខ្សោយពេក ស្ទើរតែហៅបានថាជាចំណុចអន់ប្រចាំត្រកូលក៏បានដែរ ។

ដំបូងតាអះអាងថាឱ្យខ្ញុំរៀនថ្នាក់ទី១២នៅកូរ៉េដូចធម្មតា តែម៉ាក់និងបងប្រុស (ស មីណាម) បែរជាប្រឆាំងដាច់អហង្ការថា ទោះយ៉ាងណាក៏ត្រូវតែបញ្ជូនខ្ញុំទៅរៀននៅអាមេរិកឱ្យបានដោយអ្នកទាំងពីរអត់មានសួរយោបល់ខ្ញុំសោះថា តើខ្ញុំចង់ទៅរៀននៅបរទេសឬអត់ ។

ហើយពួកគាត់ថែមទាំងសង្ឃឹម (យ៉ាងខ្សត់ខ្សោយ) ថា បើបញ្ជូនខ្ញុំឱ្យទៅរៀននៅទីនោះបីឆ្នាំ ត្រឡប់មកវិញខ្ញុំច្បាស់ជាពូកែអង់គ្លេសដល់កំពូល ប្រភេទថាជនបរទេសដែលនិយាយភាសាអង់គ្លេសច្បាស់ជារត់ពួនមិនទាន់ ពេលជួបនិយាយជាមួយខ្ញុំ...(ហេះៗ) ។

តែអ្វីដែលគួរឱ្យសោកស្ដាយជាទីបំផុតនោះគឺ ខ្ញុំមានអារម្មណ៍ថាការទៅរៀននៅអង់គ្លេសនេះមិនបានជួយជំនាញភាសាអង់គ្លេសរបស់ខ្ញុំបែរឆ្ពោះទៅរកផ្លូវល្អបន្តិចណាសោះ ។

ដោយហេតុនេះ ទើបត្រូវម៉ាក់និងបងប្រុសបង្ខំឱ្យនៅអង់គ្លេសពេលថ្ងៃសម្រាករយៈពេលយូរ ដូចជាថ្ងៃអ៊ីស្ទ័រ ថ្ងៃគ្រីស្មាស់ (ដែលជួនកាលឈប់រាប់អាទិត្យ ឬពេញមួយខែក៏មាន) ដើម្បីហ្វឹកហាត់ភាសាឱ្យស្ទាត់ ហើយអនុញ្ញាតឱ្យមកលេងផ្ទះតែពេលសាំមឺប៉ុណ្ណោះ ។

ដោយសារតែឆ្នាំនេះវាំកកង់រៀនជាតិសព្វផងពីរអាទិត្យ ធ្វើឱ្យ





ក្លាយជាឆ្នាំដំបូងដែលខ្ញុំបានត្រឡប់មកទាន់ចូលរួមថ្ងៃខួបកំណើតបងប្រុស ដូច្នេះទើបតាំងចិត្តថានឹងលួចមកស្ងាត់ៗ ដោយអត់មានប្រាប់អ្នកផ្ទះដឹងមុនឡើយ ដើម្បីឱ្យបងប្រុសភ្ញាក់ផ្អើល ។

១:៣០ ប្រទេសកូរ៉េ

ខ្ញុំឈានជើងចុះពីតាក់ស៊ី រួចមកឈរនៅខាងមាត់ទ្វាររបង (អត់យកកាបូបធ្វើដំណើរមកទេ ព្រោះខ្ជិលស្ពាយ តិចទៀតក៏ត្រូវទៅវិញដដែល) ភ្លើងនៅក្នុងផ្ទះបិទអស់រលីង សល់តែភ្លើងរបងនិងភ្លើងតាមរានហាលដែលបើកទុកតាមធម្មតាប៉ុណ្ណោះ ។

មើលទៅ...ជាតជីថ្ងៃកំណើតរបស់បងប្រុសដូចជាបញ្ចប់អស់ហើយ ។

ស្អីគេ? ម៉េចក៏ឆាប់ចប់ម្ល៉េះ? រាល់ឆ្នាំឃើញរៀបចំមួយយប់ទល់ភ្លឺតើ!

អ៊ូយ!!! ស្ដាយណាស់! ស្ដាយមែនទែន!

តែអ្ហ៎? ម៉េចបានកន្លែងចតឡាននៅមានឡានពេញអីចឹង?

ឬក៏...ជាតជីមិនទាន់ចប់?

ពេលខ្ញុំចូលទៅក្នុងផ្ទះភ្លាម ក្លិនជ្រួលរបស់ស្រាក៏អណ្ដែតកាយៗមកប៉ះច្រមុះ...ខ្ញុំសម្លឹងមើលសភាពក្នុងបន្ទប់ធំរហូតទៅដល់ម៉្ញុំអាងហែលទឹកនៅក្នុងផ្ទះ (ចាំរបស់ខ្ញុំជាអ្នកចេញម៉ូត ព្រោះដើម្បីឱ្យមានលក្ខណៈខុសប្លែកពីគេ) ហើយក៏ត្រូវដកដង្ហើមធំយូ ។

អើ...នេះជា...ផ្ទះឬក៏សមរភូមិប្រយុទ្ធ?

ស្ទើរតែគ្រប់ក្រឡាសង់ទីម៉ែត្រការ៉េសុទ្ធតែកំប៉ុងបៀរនិងដបស្រាគ្រប់ម៉ាក ថែមទាំងមានកែវស្រាដាក់ចោលអាភាត់អាភាយ ។

នៅមាត់អាងមានបងៗប្រហែលបួនប្រាំនាក់ស្រវឹងដេកលក់នៅលើកៅអីវែងដោយគ្មានរបៀប ។

គិតថាពិធីខួបកំណើតរបស់បងប្រុសនៅឆ្នាំនេះគឺប្រហែលជាជាតជីសុរា ដោយមិនបាច់ចូលច្រើនឡើយ ។



ហើយក៏ធ្វើឱ្យខ្ញុំហាក់ដូចជាច្រាកដក្នុងចិត្តថា...ប៉ាម៉ាក់មិននៅផ្ទះនិងប្រហែលជារវល់ការងារនៅកន្លែងណាមួយមិនខាន មិនអីចឹងផ្ទះយ៉ាប់យ៉ឺនដល់ថ្នាក់នេះទេ ព្រោះបើប៉ាមិនមែនសភាពនៅក្នុងផ្ទះយ៉ាប់យ៉ឺនដល់ថ្នាក់នេះទេ កុំស្មានថាមាននរណាម្នាក់ហ៊ានម៉ាក់រៀបចំខួបកំណើតនៅផ្ទះ កុំសង្ស័យថាមាននរណាម្នាក់ហ៊ាន យកស្រាមួយតំណក់ចូលមកបាន ចំណែកឯមូលហេតុដែលថា ម៉េចបានអត់ហ៊ាននោះ...ហឺៗ កុំនិយាយអីល្អជាង ។

ហើយមិនទាន់បានដើរឱ្យបានសព្វកន្លែងផង ខ្ញុំក៏មានអារម្មណ៍ថាកជើងដូចជាត្រូវដៃក្តៅៗរបស់នរណាម្នាក់ស្រវាចាប់ជាប់ ។

អឹក!

ពេលឱនមើល ក៏ឃើញពួកម៉ាកបងប្រុសម្នាក់ទៀតដែលស្រវឹងដេកលក់នៅក្រោមកៅអី ប្រហែលកំពុងមមើមមាយគិតថាកជើងខ្ញុំជាកដៃរបស់សង្សារចាស់ដែលទៅចោលគេហើយមើលទៅ ។

ដំបូងខ្ញុំស្មានថាខ្មោច តែការពិតជាខ្មោចសុរាខកស្នេហ៍សោះ ។

ខ្ញុំដកជើងចេញពីដៃរបស់ពួកម៉ាកប្រមឹកខួបរបស់បងប្រុស មុននឹងពេបមាត់ដាក់ដោយការមួម៉ៅ ហ៊ឹស! មុខមាត់ល្មមមើលដែរ តែមើលសភាពពេលនេះចុះ ខ្ញុំថាគ្រាន់ជាងអ្នកលេងតាមចិញ្ចើមថ្នល់តែបន្តិចប៉ុណ្ណោះ ។

ភ្លាមនោះ សម្លេងឱទានរបស់អ៊ំមេផ្ទះប្រចាំត្រកូលក៏បន្លឺឡើង ធ្វើឱ្យខ្ញុំត្រូវប្រញាប់បែរទៅប្រាប់ឱ្យគាត់ជួយបន្ថយសម្លេងបន្តិច មុននឹងមានអ្នកភ្ញាក់នាំតែរញ៉េរញ៉ៃ ។

"អ្ហា? អ្នកនាងតូច ហេតុអីបាន..."

"ស៊ូត! តិចៗអ៊ំ..."

"អូខេៗ អ៊ំយល់ហើយ តែម៉េចក៏អ្នកនាងតូច...ម៉ោះវិញអត់មានគេប្រាប់អ្នកប្រុសធំមុនអីចឹង? កាលពីល្ងាចព្រឹមៗថាទាក់ទងអ្នកនាងអត់បានសោះ"

យូរៗទើបប៉ាម៉ាក់យកចិត្តទុកដាក់រឿងកូនម្តង ដូច្នេះភាគច្រើនអ្នកដែលតែងសួរនាំខ្ញុំច្រើនតែជាបងប្រុស ។

"ល្អដែរ ដែលនៅនឹកឃើញគ្នា ខ្ញុំស្មានថាគាត់រវល់តែសប្បាយ

LOVE SERIES



នឹងជាតធីសុរារហូតភ្លេចប្អូនស្រីម្នាក់នេះទៅហើយ..."

"អ៊ុយ!!! ម៉េចបានអ្នកនាងដឹងថាខួបកំណើតអ្នកប្រុសធំឆ្នាំនេះជា ជាតធីសុរា?"

អ្ហា? អាដែលខ្ញុំនិយាយចម្អន់ឱ្យអ៊ំមេផ្ទះស្តាប់មិញនេះជារឿងពិតមែនឬអ្ហស?

ជាតធីសុរានេះ!!!

អ៊ូ! បងប្រុសអើយបងប្រុស...ចុះបើម៉ាក់ដឹង បែកផ្ទះមិនខាន!

"ថៃដន្យលោកប្រុសលោកស្រីអត់នៅ លោកប្រុសជាប់ប្រជុំនៅប្រទេសជប៉ុន លោកស្រីក៏រវល់ផ្សព្វផ្សាយរឿងសិទ្ធិនារីនៅតាមខេត្តជាមួយលោករដ្ឋមន្ត្រី ទម្រាំតែមកវិញ ខានស្អែកឯណោះ ចំណែកអ្នកនាងតូចវិញ អ្នកប្រុសធំគិតថានៅអាមេរិក..."

"..."

"អ្នកប្រុសធំ ឃើញគ្មានអ្នកណានៅផ្ទះ ក៏...បង្កើតអាយដៀថាឆ្នាំនេះរៀបចំជាតធីសុរាតែម្តងទៅ" អ៊ំមេផ្ទះរៀបរាប់ ព្រមទាំងងាកមើលជុំវិញខ្លួន ។

"..."

"ហើយដែលឃើញស្រវឹងយ៉ាប់យ៉ឺនរហូតដល់ដួលដេកបែបនេះព្រោះតែហ្គេមដែលលេងភាគច្រើន គឺហ្គេមសុរាហ្នឹងអ្ហែង"

"..."

ស្តាប់ចប់ ខ្ញុំនិយាយលែងចេញតែម្តង ព្រោះមិនថាមើលទៅខាងណាក៏មានអារម្មណ៍ហួសចិត្តដែរ នេះបើប៉ាម៉ាក់ដឹងវិញ ខ្ញុំមិនចង់ស្មានទេ ថាមានរឿងអីកើតឡើង ។ ហើយបើប៉ះម៉ាក់ផង...អ៊ូយ!! កុំឱ្យនិយាយអីល្អជាង គឺមានរបៀបរបបណាស់ ព្រោះម៉ាក់ជាប្រធានសមាគមអ្នកការពារសិទ្ធិស្ត្រីនៃប្រទេសកូរ៉េ ដូច្នេះទើបគាត់យកចិត្តទុកដាក់លើរឿងមុខមាត់និងសុជីវធម៌របស់សមាជិកគ្រួសារណាស់...រហូតពេលខ្លះចង់ជ្រុលទៀងផង ។

"អ្នកនាងទើបម៉ោដល់ ហត់ហើយ ឆាប់ទៅសម្រាកទៅ ស្អែកអ៊ំនឹងចាប់ជាស់អ្នកប្រុសធំប្រាប់ថាអ្នកនាងម៉ោដល់ហើយ ល្អទេ?"







“កុំអីអ៊ំ ទុកឱ្យគាត់គេងឱ្យស្វាងស្រាទៅ ហើយចុះ...គាត់គេងនៅខាងលើមែនទេអ៊ំ?”

ខ្ញុំបន់សុំកុំឱ្យអ៊ំមេផ្ទះឆ្លើយមកវិញថា បងប្រុសស្រវឹងដេកក្នុងអាងទឹករហូតដល់ងាប់ ហើមអណ្ដែតបាត់ទៅហើយអី ។

“អ៊ំ អ្នកប្រុសធំទើបនឹងឡើងទៅគេងមិញនេះអ៊ែង ឃើញមានពួកម៉ាកមុខស្អាតម្នាក់ជួយគ្រាហ៍ឡើងទៅ អ៊ំថាថ្ងៃនេះបែបស្រវឹងលក់អស់ហើយ”

ឮបែបនេះក៏អស់អារម្មណ៍ចង់ធ្វើឱ្យបងប្រុសភ្ញាក់ផ្អើលតែម្ដង ។

“ហឺ! អីចឹងខ្ញុំឡើងទៅសម្រាកសិនហើយអ៊ំ”

ហ៊ឺស! ខ្ញុំខំទិញកាដូមកឱ្យភ្ញាក់ផ្អើល តែគាត់បែរជាធ្វើឱ្យខ្ញុំភ្ញាក់ផ្អើលទៅវិញ ពិតជាបងប្រុសគួរឱ្យស្អប់មែន ។

ពេលកំពុងដើរឡើងជណ្ដើរ...ខ្ញុំក៏ក្រឡេកទៅឃើញមិត្តភក្ដិបងប្រុសពីរនាក់ (ប្រហែលជារៀនស្ថាបត្យកម្មដូចគ្នាហើយមើលទៅព្រោះក្បែរខ្លួនមានបំពង់ដាក់ម៉ូតដែលពួកនិស្សិតស្ថាបត្យកម្មប្រើ) ដេកលក់នៅខាងជើក្នុងបន្ទប់ធំ នៅក្នុងដៃកាន់ស្រាមិនព្រមលែង ។

នៅសាឡុងជិតគ្នា មានប្រុសបីបួននាក់ទៀតស្រវឹងដេកលក់ដូចងាប់ ខ្លះឱបដបស្រា ខ្លះកាន់កំប៉ុងបៀរ ធ្វើហាក់ដូចជាមួយជីវិតនេះខ្លះស្រាមិនបានអីចឹង ។

សរុបគឺ...គ្មានចំណុចណាមួយនៅក្នុងផ្ទះដែលថាគ្មានមនុស្សស្រវឹងនោះទេ ។

ពេលឡើងទៅដល់ជាន់ទីពីរ ហើយបើកទ្វារចូលទៅក្នុងបន្ទប់បងប្រុស ក៏ឃើញថា...គាត់ស្រវឹងដេកលក់ងាប់នៅលើគ្រែ នៅកំរាលព្រំមានមិត្តភក្ដិពីរនាក់ទៀតដេកលក់សន្លប់សន្លៃ ព្រមទាំងមានដបស្រាដែលដេកជួលពេញនោះ ។

ចំណែកបន្ទប់គេងសម្រាប់ភ្ញៀវបួនបន្ទប់ទៀត ពេលបើកទ្វារចូលទៅឃើញសុទ្ធតែពួកម៉ាក់គាត់ទាំងប្រុសទាំងស្រីដេកលក់ ។ ឃើញបែបនេះហើយខ្ញុំក៏ម្នីម្នាដើរទៅបន្ទប់ខ្លួនឯងភ្លាម ព្រោះ





ទ្រាំមើលតទៅទៀតមិនបាន ។

បន្ទប់គេង...

ខ្ញុំលោងដៃទៅរកចុចកុងតាក់ភ្លើងដើម្បីងូតទឹក ផ្លាស់ខោអាវហើយចូលគេង តែដល់ទីកឃើញថាពេលនេះម៉ាក់មិននៅ (អត់មានអ្នកណាចាំត្រួតពិនិត្យរឿងខ្ជិលច្រអូសរបស់ខ្ញុំ) ក៏ដូចចិត្តដើរទៅរកគ្រែ គិតថាចង់គេងទាំងខោអាវនេះតែម្ដង ។

តែ...ពេលដែលខ្ញុំទម្លាក់ខ្លួនទៅលើគ្រែភ្លាម (ស្រាប់តែខ្នងទៅប៉ះនឹងរបស់អ្វីម្យ៉ាងដែលរឹងក៏មិនរឹង ទន់ក៏មិនទន់ ធ្វើឱ្យខ្ញុំភ្ញាក់ក្រញាងស្ទុះងើបអង្គុយភ្លែត ។

ខ្ញុំខំទប់ចិត្តកុំឱ្យខ្លាច មុននឹងលោងដៃទៅចុចកុងតាក់ភ្លើងនៅក្បែរគ្រែដើម្បីមើលថា តើមានស្អីនៅក្រោមភួយហ្នឹង តែសុខៗក៏មានដៃចម្លែកមួយលូកចេញមកស្រវាចាប់កដៃខ្ញុំជាប់មុនទៅហើយ ។

ពឹប!

អឹក!!!

ឈាមនៅក្នុងខ្លួនខ្ញុំត្រជាក់ស្រេង ឬក៏បន្ទប់ខ្ញុំមានខ្មោច?

មានទាំង...សម្លេងរអ៊ូតិចៗលាន់ចេញពីក្រោមភួយ ដែលខ្ញុំអង្គុយពីលើ ធ្វើឱ្យខ្ញុំរឹតតែភ័យចង់លោះព្រលឹងលើសដើម ។

ខ្ញុំព្យាយាមទាញកដៃចេញពីដៃចម្លែកនោះ តែបែរជាត្រូវចាប់ជាប់ណែនជាងមុនទៅទៀត ហើយរាងកាយចម្លែកនោះក៏ស្ទុះក្រោកអង្គុយនិងចាប់ខ្ញុំសង្កត់ទៅលើពូក ខ្ញុំបានដឹងពីកំដៅកាយរបស់រាងកាយខ្ពស់ធំដែលទម្លាក់ខ្លួនមកលើខ្លួនខ្ញុំ វាគួរឱ្យញាប់ញ័របេះដូងជាទីបំផុត មានទាំង...ខ្យល់ដង្ហើមក្ដៅៗលាយឡំនឹងក្លិនស្រាចេញមកប៉ះនឹងកញ្ចឹង-ក ធ្វើឱ្យខ្ញុំឡើងរឹងពេញខ្លួនប្រាណ ។

ហ៊ឹៗ នេះប្រហែលជាមិនមែនខ្មោចទេ តែប្រហែលជាអាពួកម៉ាកប្រមឹកខ្ជូប កើតរោគចិត្តរបស់បងប្រុសហើយមើលទៅ ។

តែ...គ្រែងបន្ទប់ខ្ញុំចាក់សោតើអ្វី? (ពេលខ្ញុំមិននៅផ្ទះ មេផ្ទះតែងតែចាក់សោជានិច្ច ហើយមិញខ្ញុំក៏ចាក់សោចូលមកដែរ)



ឬក៏គេរៀបផែនការចង់ធ្វើអីខ្ញុំនៅក្នុងបន្ទប់នេះពេលបងប្រុសស្រវឹង? (តែម៉េចគេដឹងថាខ្ញុំត្រឡប់មកវិញថ្ងៃនេះ?)

ពេលតាំងស្មារតីបានហើយ ខ្ញុំក៏ច្រានទ្រូងគេចេញយ៉ាងខ្លាំង ដើម្បីយករួចខ្លួន មុននឹងប្រញាប់ប្រញាល់ចុះពីលើគ្រែទៅចុចកុងតាក់បើកភ្លើងយ៉ាងរហ័ស ។

ភ្លឹក...

"អ្ហា!!!" គ្រាន់តែភ្លើងភ្លឺភ្លាម ខ្ញុំក៏ស្រែកយំឡើងលាន់ខ្ទរ ពេលមើលឃើញថាអាវនិស្សិតរបស់អាចុតនោះប្រឡេះឡេវចេញជិតអស់ បង្ហាញឲ្យឃើញដើមទ្រូងដ៏ធំ ហើយចង្កេះខោរបស់គេក៏ធ្លាក់ចុះក្រោមស្ទើរតែរបូតចេញពីគូទទៀតផង ។

ហ៊ឹៗ នេះបញ្ជាក់ថាអម្បាញ់មិញបើខ្ញុំមិនរួចទេ ពិរជីនរបស់ខ្ញុំប្រហែលជាត្រូវគេជាន់ឈ្លីខ្ទេចអស់ដោយមិនបាច់សង្ស័យ ។

អាម្សៀនេះទំប្រឹងងើបអង្គុយ ហើយសម្លឹងមើលខ្ញុំហាក់ដូចជាកំពុងព្យាយាមរៀបរៀងគំនិតឲ្យច្បាស់ឡើងវិញ មើលទៅគេដូចជានៅស្រវឹង និងមីងមាំងៗ ។

តែមុនពេលគេហាមាត់និយាយអ្វីចេញមក ក៏ត្រូវខ្ញុំឡូឡាដាក់៖

"មិនបាច់និយាយអីទេ!!! ហ៊ឹស ឆ្កួតមែនទែន!!! លោកឯងគិតចង់ស៊ីខ្ញុំមែនទេ?!?" ខ្ញុំខឹងឡើងញ័រមាត់ ភ្នែកស្ទើរតែក្លាយជាអណ្ដាតភ្លើងពេលសម្លឹងមើលគេ ខណៈដែលអាម្សៀនោះមើលមកខ្ញុំដោយខ្សែភ្នែកដែលស្មានអារម្មណ៍មិនត្រូវ ។

"ស៊ី?" គេសួរធ្វើមុខព្រងើយ ទឹកមុខអត់មានបង្ហាញអាការៈភ័យតិចអីទាំងអស់ ។

"ឲ្យស្លាប់ទៅចុះ! ខ្ញុំក្មេងជាងលោកដល់ទៅបួនឆ្នាំ ថែមទាំងជាប្អូនស្រីរបស់ពួកម៉ាកលោកទៀត តែលោកនៅហ៊ានគិតចង់ធ្វើអីខ្ញុំទៅកើត អាឆ្កួត អាពេតចិត្ត ចាំមើលខ្ញុំនឹងប្រាប់ម៉ាក់ឲ្យប្ដឹងប៉ូលិសចាប់លោក ហើយទូរសព្ទហៅអ្នកកាសែតឲ្យមកសរសេរព័ត៌មានបកអាក្រាតអំពើអាក្រក់របស់លោកឲ្យមនុស្សម៉ាប្រទេសនេះបានដឹង!" ខ្ញុំនិយាយព្រមទាំងចង្អុលមុខគេដោយការមួម៉ៅក្តៅក្រហាយ ។







តែគេបែរជាដកដង្ហើមធំ ធ្វើមុខដូចជាធុញទ្រាន់នឹងរឿងអ្វីម្យ៉ាង ហើយក៏ចុះពីលើគ្រែ និងធ្វើដូចជាប្រុងដើរចូលមករកខ្ញុំដោយអាការៈអត់មានកោតញញើតនឹងសម្លេងឡូឡារបស់ខ្ញុំអីបន្តិចសោះ ។

"ឈប់និយាយពីម៉ាក់របស់នាងទៅបានទេ?"

ពេលនេះត្រចៀករបស់ខ្ញុំគ្មានឮសម្លេងអ្វីក្រៅពីសញ្ញាប្រកាសអាសន្ននៅក្នុងខួរក្បាលដែលបញ្ជាឲ្យ...រត់ ។

"អ្ហឺ!!! កុំចូលមក! លោកឯង បើហ៊ានតែចូលមកមួយជំហានទៀត ខ្ញុំនឹង..." ខ្ញុំបែរច្រឡោទៅមកមុននឹងក្រឡេកទៅឃើញកូនកាំបិតដែលដាក់នៅលើក្រដាសរ៉ាម ក៏ប្រញាប់កាន់សម្លុតកុំឲ្យគេគិតចង់ធ្វើអីច្រូតៗដាក់ខ្ញុំ "ខ្ញុំនឹងកាត់ អាហ្នឹង ជស់លោកឯងឲ្យដាច់ជាពីរ..."

តែមើលទៅពាក្យសម្លុតរបស់ខ្ញុំមិនបានការទេ ព្រោះគេនៅតែឈានជើងចូលមករកដដែល ។

ទោះជាឫកពាររបស់គេមិនបានបង្ហាញចេតនាចង់លូកលាន់ ឬធ្វើអីខ្ញុំមែន តែកែវភ្នែកភ្លឺចាំងដែលសម្លឹងមកអត់មានព្រិចនោះ ធ្វើឲ្យខ្ញុំក្ដៅមុខភាយៗដោយគ្មានមូលហេតុ ព្រមទាំងសម្លេងឧទានតិចៗដែលខ្ញុំស្ដាប់មិនច្បាស់ ធ្វើឲ្យខ្ញុំចាប់ផ្ដើមមិនប្រាកដក្នុងចិត្តថា តើគេស្វាងស្រាហើយនៅទេ ។

គ្រឹប!

"អឺយ! នាងជាន់..." មិនចាំឲ្យគេនិយាយចប់ទេ ខ្ញុំក៏ស្ទុះទៅបើកទ្វារបន្ទប់ ហើយរត់តម្រង់ទៅបន្ទប់បងប្រុសដែលនៅមិនឆ្ងាយប៉ុន្មាន តែ...ពេលខ្ញុំមួលដៃទ្វារ ក៏ដឹងថាជាប់គន្លឹះ ។

ហ៊ឹៗ ហេតុអីបានដាក់គន្លឹះទ្វារពេលកំពុងមានអាសន្នបែបនេះធ្វើអីហ្នំ?

ដោយសារតែខ្ញុំមិនអាចទម្លាយទ្វារចូលទៅហៅបងប្រុសបាន ខ្ញុំក៏ប្រើវិធីទះទ្វារយកស្លាប់រស់ មុនពេលម្សៀនោះមកដល់ ។

"អ្ហឺ!!! បងប្រុសៗ!!! ជួយខ្ញុំផង!!! ពួកម៉ាកបងចង់ចាប់រំលោភខ្ញុំ!!! បងប្រុសជួយខ្ញុំផង!!!"

បាំង!!! បាំង!!! បាំង!!!



"បងប្រុសជួយខ្ញុំផង!!!" ខ្ញុំស្រែកឡើងចង់ស្អក-ក ដៃក៏ទះទ្វារដូចមនុស្សឆ្កួត ។

ខណៈដែលអាម្សៀនោះដើរតាមមកឈរឱបដៃមើលខ្ញុំត្រង់ផ្លូវដើរ ឫកពាអត់មានខ្វល់អត់មានភ័យអីបន្តិចសោះ រួចហើយ...

យ៉ាំង!

"អ៊ើ!!! អ្នកណាធ្វើអីប្អូនខ្ញុំហ៎ា!!!" បងប្រុសបើកទ្វារមកភ្លាមបិះបុកចុងច្រមុះខ្ញុំ ។ សក់ក្បាលគាត់សើងមម៉ើងដូចមនុស្សទើបងើបពីគេង តែបែរជាគ្មានអាការៈរបស់មនុស្សស្រើងអីបន្តិចសោះ បែបស្វាងព្រោះតែសម្រែករបស់ខ្ញុំហើយ ។

ពេលនេះមិត្តភក្តិរបស់គាត់ដែលប្រហែលជាស្វាងស្រាដោយមូលហេតុដូចគ្នា ក៏នាំគ្នាដើរចេញម្តងមួយៗ ពីបន្ទប់គេងសម្រាប់ភ្ញៀវដើម្បីមកមើលថា កើតរឿងអី?

តែ...គ្រាន់តែឃើញមុខខ្ញុំភ្លាម សម្តីដំបូងរបស់គាត់បែរជា÷

"អ៎ា? ឯងម៉ោពីអង្កាល់ហ្នឹង អេនដែល? ម៉េចក៏...ម៉ោឈរនៅត្រង់នេះបាន?"

គេចង្អុលខ្ញុំដោយការភាន់ភាំង ។

"ហ៊ឹស! មិនតិតត្រេកអរ! តែបងបែរជាសួរថាហេតុអីខ្ញុំម៉ោឈរត្រង់ហ្នឹងបានទៅវិញ! បងជាបងប្រុសប្រភេទណានេះ?"

"គឺឆ្នាំនេះឯងអត់បានគេប្រាប់បងមុនថាម៉ោឯណា បងស្មានថាឯងនៅអាមេរិកតើ..."

"នៅថ្ងៃគម្រប់ខួបអី ចាប់ហើយ នេះខ្ញុំតាំងចិត្តថាម៉ោឲ្យបងឯងភ្ញាក់ផ្អើលនៅថ្ងៃកំណើតហ្នឹងណា៎ តែបែរជាម៉ោត្រូវធ្វើឲ្យភ្ញាក់ផ្អើលពីអាមិត្តពាលចិត្តរបស់បងទៅវិញ!!!"

"បានន័យថាម៉េច...ហើយមិញដែលឯងឡូឡាថាអ្នកណាចង់រំលោភឯងនោះ អ្នកណាគេហ៎ា?"

"មានអ្នកណាទៀត គឺអាពួកម៉ាកបងម្នាក់នោះ វារៀបផែនការចង់រំលោភខ្ញុំ!" ខ្ញុំចង្អុលទៅម្ចាស់ផែនការកខ្វក់នោះដោយគ្មានស្ទាក់ស្ទើរ និងចំព្យាយាមបង្ខំទឹកភ្នែកដើម្បីទាមទារភក្តីមេត្តា ។





"...!!!" បងប្រុសនិងមិត្តភក្តិគាត់ផ្សេងទៀតធ្វើមុខដូចត្រូវខ្មោចលង ធ្វើដូចសម្តីរបស់ខ្ញុំវាមិនអាចទៅរួចអីចឹង ។

ចំណែកអាម្សៀនោះវិញ គិតតែពីឈរឱបដៃមើលខ្ញុំដោយខ្សែភ្នែកដែលស្មានមិនត្រូវដូចមុនដដែល ។

ចឺ? ខ្ញុំនិយាយអីខុសអ្ហ៎? អាឆ្កួតហ្នឹងប្រុងចាប់រំលោភខ្ញុំមែនណា៎!

ដោយសារតែអម្បាញ់មិញ ខ្ញុំភ័យពេកស្ទើរតែបាត់ស្មារតី ទើបមិនសូវចាប់អារម្មណ៍មើលមុខគេប៉ុន្មាន តែពេលនេះគ្រាន់តែខ្ញុំបានឃើញមុខគេច្បាស់ៗប៉ុណ្ណោះ ខ្ញុំក៏បានយល់នូវពាក្យដែលថា មនុស្សយើងស្គាល់មុខតែមិនស្គាល់ចិត្ត តែម្តង ។

ឲ្យស្លាប់ទៅចុះ! រូបរាងមុខមាត់បែបនេះ មិនគួឲ្យជឿសោះថាមានអាការៈខាងផ្លូវចិត្ត?

តែឈប់សិន...ម្នាក់នេះដូចធ្លាប់ឃើញ?

អ៊ូយ! នឹកឃើញហើយ អាតាប៉ុនេះហើយដែលចូលចិត្តសម្លឹងខ្ញុំដោយខ្សែភ្នែកចម្លែកៗ ពេលគេមករកបងប្រុស ថែមទាំងមិនដែលហើបមាត់និយាយរកខ្ញុំឲ្យបានម្តងទៀត នៅខណៈដែលមិត្តភក្តិផ្សេងទៀតរបស់បងប្រុសមានអធ្យាស្រ័យល្អគ្រប់គ្នា ។

ហើយរយៈពេលពីរឆ្នាំកន្លងមកនេះ ខ្ញុំត្រូវបញ្ជូនឲ្យទៅរៀននៅអាមេរិក ធ្វើឲ្យលេងសូវចំណាំមុខពួកមិត្តភក្តិបងប្រុសអស់ តែពេលនេះចាប់ផ្តើមនឹកឃើញវិញខ្លះហើយ ។

"ឯងឡប់ទេដឹង អេនដែល! គុនដេ នេះឬ រៀបផែនការចង់ស៊ីឯងទៅមិនរួចទេ" បងប្រុសបែរជាឡូឡាដាក់ខ្ញុំដោយឫកពាក្តៅក្រហាយជំនួសមិត្តភក្តិ ធ្វើឲ្យខ្ញុំមានអារម្មណ៍ឈឺចិត្តតិចៗ ស្អីអីចេះ? ធម្មតាគាត់តែងតែកាន់ជើងខ្ញុំ តែហេតុអីម្តងនេះបែរជា...កាន់ជើងអាតាប៉ុឡប់ហ្នឹងទៅវិញ ហ៊ឹស?

"ហ្នឺ...ហ្នឹងបងកាន់ជើងអ្នកដទៃ ហើយចោទថាខ្ញុំកុហកផ្អុសហេតុអីបង..."

"បើដឹងថាឯងម៉ោវិញថ្ងៃនេះ បងមិនឲ្យវាទៅដេកបន្ទប់ឯងទេ"

មើលទៅ បងប្រុសដូចជាស្រឡាញ់និងទុកចិត្តពួកម៉ាកម្នាក់នេះ



ម៉ែនទែន បានជាសុខចិត្តកាន់ជើងអាម្សៀហ្នឹងខ្លាំងជាងប្អូនស្រីបង្កើតរបស់ខ្លួន ។

"អ្ហ៎! បងកំពុងតែប្រាប់ថាវាជាកំហុសរបស់ខ្ញុំដែលម៉ោដោយអត់ប្រាប់ឲ្យដឹងអីចឹងផ្អើស?"

"វាមិនមែនអីចឹងទេ បងគ្រាន់តែចង់ប្រាប់ថា បងនិង គុនដេ រាប់អានគ្នាយូរហើយ ស្គាល់ចិត្តស្គាល់ថ្លើមគ្នា ហ៊ានធានាបានថា វាគ្មានផ្លូវធ្វើអីបែបហ្នឹងដាក់ប្អូនស្រីពួកម៉ាកជាដាច់ខាត"

"តែគេ..."

"ហ៊ានធានាថាវាជាមិត្តភក្តិបងចុងក្រោយគេបង្អស់ដែលគិតចង់ធ្វើអីចូតៗបែបនោះដាក់ឯង!"

"តែគេស្រវឹង មនុស្សយើងពេលស្រវឹង...ច្រើនតែភ្លេចស្មារតី..."

"ខ្ញុំអត់មានស្រវឹងទេ..." សុខៗ អាម្សៀដែលឈរឱបដៃនោះក៏ឆ្លើយដោយសម្លេងរាបស្មើ ។

ខ្ញុំបែរខ្វាច់ទៅរកគេភ្លាម ខំប្រឹងសម្លឹងរកមើលការពិត តែបែរជាគ្មានឃើញពិរុទ្ធអ្វីទាំងអស់ ផ្ទៃមុខរបស់គេក៏រាបស្មើ គ្មានបញ្ចេញអារម្មណ៍អ្វីទាំងអស់ ។

"លោ...លោកហ៊ានកុហកផងអ្ហ៎? មិញខ្ញុំធុំក្លិនស្រាចេញពីខ្លួនលោកហើយនៅហ៊ានប្រាប់ថាអត់ស្រវឹងទៀត"

"ខ្ញុំទទួលស្គាល់ថាផឹកអស់ច្រើន តែ...អត់ស្រវឹងទេ" ទឹកមុខ និងខ្សែភ្នែកអត់មានបង្ហាញពីអារម្មណ៍អ្វីទាំងអស់ តែនៅខាងក្នុងជ្រៅនៃខ្សែភ្នែកមួយគូនោះ បញ្ចេញរស្មីឌឺដងចេញមកយ៉ាងច្បាស់ ។

"ខ្ញុំមិនជឿ! មានមនុស្សស្រវឹងឯណាព្រមសារភាពថាខ្លួនឯងស្រវឹងហ្ន៎?! លោកឯងនេះ..."

"បានហើយ អេនដែល! គុនដេ ពូកែផឹកបំផុតនៅក្នុងក្រុមបង រឿងស្រវឹងនោះទៅមិនរួចទេ ខ្លាំងណាស់វាត្រឹមតែវិលៗប៉ុណ្ណឹងអ្ហែង"

អ្ហា! ហេតុអីបានបងប្រុសដោះសាជំនួសអាម្សៀនេះមិនព្រមឈប់សោះអីចឹង?

"វាទៅមិនរួចម៉េចនឹងបាន ពេលដែលផឹកស្រាផឹកបៀរហៀរហូរ





ពេញផ្ទះដល់ថ្នាក់ហ្នឹង? សូម្បីតែបងក៏នៅស្រវឹងដូចឆ្កែដែរ ចុះទម្រាំ...គេ!" ខ្ញុំនិយាយ ព្រមទាំងដៀងភ្នែកមើលគេ ខណៈដែលបងប្រុសមានទឹកមុខរាងមិនស្រួលតិចៗហើយ ពេលឮខ្ញុំនិយាយថាពាក្យថាស្រវឹងដូចឆ្កែ នោះ ។

ហ៊ឹស! ពេលនេះខ្ញុំខឹងអាម្សៀហ្នឹងរហូតមិនចង់សូម្បីតែហាមាត់និយាយរកផង ។

គិតៗទៅ ខ្ញុំក៏នឹកច្រណែនតិចៗដែរ ដែលបងប្រុសហាក់ដូចជាផ្ដល់ភាពសំខាន់ចំពោះគេខ្លាំងជាងខ្ញុំ ។

"អូខេៗ សម្រេចថារឿងដែលវាទៅនៅក្នុងបន្ទប់របស់ឯង បងអាចពន្យល់បាន!"

"...?"

"ស្អែក បងនិង គុនដេ ត្រូវយកម៉ូដែលផ្ទះឲ្យគ្រូ ពេលនេះបងស្រវឹង បងក៏បើកបន្ទប់ឯងឲ្យវាដែលអត់ស្រវឹងចូលទៅធ្វើការបង្ហើយ រឿងវាមានតែប៉ុណ្ណឹងអ្ហែង"

"អ្ហ៎...ហ្នឹងបងកំពុងជួយដោះសាជំនួសអាពួកម៉ាករោគចិត្តជស់ បងថាគេគ្រាន់តែចូលទៅធ្វើការ មិនមែនមានផែនការចង់រំលោភខ្ញុំទេមែនទេ ហេតុអីក៏ធ្វើដាក់ខ្ញុំបែបហ្នឹង បងអត់មានបារម្ភពីខ្ញុំសោះមែនទេ បានជាឲ្យពួកម៉ាកចូលបន្ទប់ខ្ញុំងាយៗបែបនេះ?" ខ្ញុំបញ្ច្រាសទៅវិញមួយឈុតដោយការតូចចិត្ត ធ្វើឲ្យបងប្រុសចំហមាត់ប្រកែកស្ទើរមិនទាន់ ។

"ប្រាប់ហើយតើថាបងអត់ដឹងថាឯងម៉ោថ្ងៃនេះទេ!"

"អីចឹងគេចាក់សោទ្វារធ្វើអី ពេលខ្ញុំបើកចូលទៅ ខាងក្នុងបិទភ្លើងងងឹតឈឹង ហើយគេថែមទាំងគេងលើគ្រែដណ្ដប់ភួយខ្ញុំ និងព្យាយាមលួកលាន់ខ្ញុំទៀតផង"

"..."

"គេអត់មានចូលទៅអង្គុយធ្វើការដូចបងនិយាយទេ បងដឹងទេថាគេលួកលាន់ខ្ញុំដល់ណាដល់ណាហើយ!!!"

"លួកលាន់!? បានន័យថាម៉េចអ្ហ៎ា អាគុនដេ ឯងហ្នឹងអ្ហ៎!!!" បង



ប្រុសបែរទៅសួរអាម្សៀនោះដោយទឹកមុខងឿងឆ្ងល់ជាទីបំផុត ។

"ពេលបែរកពីឯងមក ខ្ញុំភាំងស្រៀង។ ក៏គិតចង់គេមួយម៉ោងសិន

រួចសឹមភ្ញាក់ធ្វើការ តែសុខៗ ប្អូនឯងក៏ចូលម៉ោរំខាន ខ្ញុំក៏..."

"ឈប់! មិនបាច់និយាយតទៀតទេ ទោះយ៉ាងណាក៏ខ្ញុំមិនជឿ

លោកជាដាច់ខាត! លោកកុហក!!!" ខ្ញុំប្រញាប់ស្រែកឱ្យគេឈប់

និយាយ ព្រោះខ្លាចអាតាប៉ុហ្នឹងរៀបរាប់រឿងរ៉ាវដ៏គួរឱ្យអាម៉ាស់ច្រើន

ជាងនេះទៀត ជាពិសេសអាពេលដែលខ្ញុំ...ត្រូវគេចាប់សង្កត់នៅលើ

គ្រែ ហ៊ឺៗ រឿងនេះមិនឱ្យអ្នកណាដឹងជាដាច់ខាត ។

ពេលនេះគេងាកមកមើលមុខខ្ញុំដោយភ្នែកពិបាកយល់ (ដូច

រាល់ដង) មិននិយាយអ្វីទាំងអស់ រួចក៏ដើរទៅរកទ្វារ ។

"ខ្ញុំថាឯងម៉ោមើលខ្លួនឯងទៅល្អជាង មីណាម ថាពេលប្អូនស្រី

ឯងភ័យនោះគួរឱ្យខ្លាចប៉ុណ្ណា!" ពេលដែលទ្វារត្រូវបើកភ្លាម ក៏ឃើញ

ថានៅក្នុងនោះមានក្រដាសមួដែលជាំគួរសមមួយផ្ទាំង (ស្មានដោយ

ភ្នែកទទេ ទំហំប្រហែលមួយម៉ែត្រការេ) មានសភាពយ៉ាប់យ៉ឺន ខ្មួចខ្មី

ស៊ើរតែទឹកមិនដល់ថា នេះគឺជាប្លង់សម្រាប់សាងសង់អ្វីម្យ៉ាង ប្រៀប

ដូចជាវាត្រូវនរណាម្នាក់ (ខ្ញុំហ្នឹងអ្ហែង) ដើរជាន់ ។

នៅក្បែរនោះមានរមូរក្រដាសពណ៌សនិងក្រដាសរ៉ាមសម្រាប់

កាត់តធ្វើជាម៉ូដែលមួយគរ កូនកាំបិត ស្កុតឋេប ជ័រកាវ និងឧបករណ៍

ផ្សេងទៀតជាច្រើន ។

ស្លាប់ហើយ! បើអីចឹងអម្បាញ់មិញ...ខ្ញុំធ្វើអីខ្លះទៅ?

រួចហើយខ្ញុំក៏ត្រូវភ្ញាក់ព្រើត ពេលសុខៗ បងប្រុសក៏ងាកខ្វាច់មក

សម្លក់ដោយការស្មើមរណ:÷

"ឯង...ជាន់កំទេចម៉ូដែលរបស់ក្រុមបងអ្ហំ អេនដែល?!?"

"គឺខ្ញុំ...គឺ..." មុខខ្ញុំឡើងស្លុយប៉ៃ ពេលឃើញទឹកមុខបងប្រុស

ហើយមិនហ៊ានសូម្បីតែមើលមុខអាម្សៀនោះផង ។

ត្រូវហើយ ខ្ញុំនៅចាំតិចៗ ថាពេលរត់ចេញពីបន្ទប់ ជើងដូចជា

មានជាន់អ្វីម្យ៉ាង តែពេលនោះខ្ញុំគ្មានចាប់អារម្មណ៍មើលស្អីទេ ព្រោះ

ពីរកផ្លូវរត់ឱ្យរួចពីកណ្តាប់ដៃអាម្សៀនោះ ។







តែ...មើលតាមសភាពការណ៍ជារួមទៅ រឿងនេះខ្ញុំដូចជាយល់ច្រឡំនឹងពួកម៉ាកបងប្រុសហើយ ។

"ឯងដឹងទេថា បង និង គុនដេ ធ្វើម៉ូដែលនេះប៉ុន្មានថ្ងៃហើយ?"

"គឺ...ខ្ញុំ..."

បងប្រុសសម្លឹងមុខខ្ញុំដែលស្លេកស្លាំង មុននឹងដកដង្ហើមធំ÷

"អូខេ! រឿងនេះជាកំហុសរបស់បង ដែលយកបន្ទប់ឯងធ្វើការដោយអត់បានប្រាប់ រឿងដែលឯងជាន់ម៉ូដែលផស់បងឡើងខ្ទេចនេះ... បង និង គុនដេ បែបត្រូវបន្ទោសខ្លួនឯងហើយ ដែលមិនបានប្រយ័ត្ននិងនឹកស្មានថាឯងប្រហែលមិនត្រឡប់ម៉ោទេ"

"បងប្រុស...គឺខ្ញុំ..." ហ៊ឺៗ ហេតុអីពេលនេះអ្នកដែលមានអារម្មណ៍ថាខុសប្រែក្លាយជាខ្លួនខ្ញុំទៅវិញ ។

"ចំណែករឿងដែលឯងប្រាប់ថា គុនដេ មានផែនការចង់ចាប់ឯងនោះ ឯងយល់ខុសស្រឡះហើយ ឯងភ្លេចហើយឬអ្ហ៎ស ថាវាគ្មានទៅដឹងថាឯងត្រឡប់ម៉ោថ្ងៃនេះផង..."

អើ មែនហើយ ថ្នាក់គាត់ដែលជាបងប្រុសបង្កើតមិនដឹងផង ចុះទម្រាំ...គេ?

"ធ្វើ...ធ្វើម៉េចខ្ញុំដឹងទៅ...បើសុខៗ ស្រាប់តែមានមនុស្សប្រុសម៉ោពីណាមិនដឹង ម៉ោគេងលើគ្រែ ជាអ្នកណាក៏ត្រូវតែផ្អើលដែរ" ខ្ញុំប្រកែកតិចដើម្បីកុំឱ្យខ្មាសគេ ទាំងការពិតដឹងខ្លួនច្បាស់ណាស់ថាខុសទាំងស្រុង ដែលមិនព្រមស្តាប់គេអធិប្បាយឱ្យច្បាស់លាស់សិនថាហេតុអីបានចូលមកគេងក្នុងបន្ទប់ខ្ញុំ ។

"តែឯងមិនគួរភ័យអីខ្លាំងក្លាដល់ថ្នាក់ហ្នឹងដែរ!"

"..."

"មិញឯងប្រាប់ថា គុនដេ មានផែនការញាំញីឯង តែតាមដែលបងមើលទៅ គឺឯងទេដែលញាំញីម៉ូដែលផស់បង ឡើងខ្ទេចបែបនេះ បងធ្វើម៉ូដែលផ្ទះសន្សំថាមពលនេះជូនគ្រូមើល មិនមែនម៉ូដែលវត្តបូរាណដែលនៅសល់តែសសរបាក់ៗបែបហ្នឹងទេ!"

"តែបងគួរតែដឹងដែរថា ខ្ញុំគ្មានចេតនាទេ!" ខ្ញុំរាងដូចចង់ខឹងឡើង



វិញគិតៗហើយ ដែលបងប្រុសនៅតែនិយាយពីកំហុសខ្ញុំមិនឈប់ ។

"ល្អហើយដែលឯងគ្មានលេតនា បើមានវិញ បងប្រហែលជាឈឺក្បាលខ្លាំងជាងនេះរាប់រយដងទៅទៀត!"

"បងប្រុស...!!!" ខ្ញុំស្រែកដោយការអន់ចិត្តចំពោះសម្តីធ្វើបាបផ្លូវចិត្តខ្ញុំរបស់បងប្រុស ហើយសម្តីបន្តមកទៀតរបស់គាត់ក៏រឹតតែធ្វើឱ្យខ្ញុំអន់ចិត្តខ្លាំងជាងមុនទៅទៀត ។

"ងាប់ហើយ! ឆ្នាំនេះឯងឱ្យកាដូថ្ងៃកំណើតបងបានគួរឱ្យពេញចិត្តមែនទែន អេនដែល!"

"..."

"ឬក៏ឯងយល់ថាជីវិតបងកន្លងមកមានក្តីសុខជ្រុលពេក វាធ្វើឱ្យទើសភ្នែកឯង ទើបឯងជួយត្រឡប់មកសាងទុក្ខឱ្យបងបែបនេះ?!"

"ហ៊ូ...ហ៊ូ បងចោទថាខ្ញុំត្រឡប់ម៉ោហើយធ្វើឱ្យបងកើតទុក្ខអីចឹងផ្អេស?" លើកនេះខ្ញុំយំហ៊ូចេញមកដោយភ្លេចការខ្មាសអៀន ដែលខ្វល់ហើយថានៅត្រង់នេះមានអ្នកណាខ្លះ (ការពិតយំរអ៊ូយដើម្បីសុំពិន្ទុនៃការអាណិត)

"ឬក៏ឯងគិតថារបស់ដែលឯងជាន់ឡើងខ្ទេចនេះ វានឹងធ្វើឱ្យជីវិតបងចម្រុងចម្រើន?"

មើលតាមរយៈទឹកមុខបងប្រុស ខ្ញុំថាអាម៉ូដែលផ្ទះស្អីគេហ្នឹងសំខាន់គួរសម មិនអីចឹងគាត់ក៏មិនមួម៉ៅដល់ថ្នាក់ហ្នឹងដែរ ។

"ហ៊ឹកៗ! បង...បង ហេតុអីបងចាំបាច់ស្តីឱ្យខ្ញុំបែបហ្នឹងធ្វើអី?" សម្លេងខ្ញុំឮដាច់ៗ ព្រោះតែអណ្តឹតអណ្តក ខណៈដែលបងប្រុសចាប់ផ្តើមមើលមកខ្ញុំដោយខ្សែភ្នែកស្រទន់វិញ ។

បងប្រុសទុកឱ្យខ្ញុំយំខ្សុញទាល់តែអស់ចិត្ត ចំណែកអ្នកផ្សេងចូលគេងអស់ហើយ នៅសល់តែ...

ខ្ញុំ បងប្រុសនិង អាតាប៉ិក្លូតនោះ!

ដំបូងខ្ញុំស្មានថាបងប្រុសចិត្តទន់បែរមកកាន់ជើងខ្ញុំ តែ...គ្រាន់តែខ្ញុំជូតទឹកភ្នែករួចរាល់ គាត់ក៏ចាប់ផ្តើមរៀបសត្តត៉ឱ្យខ្ញុំសុំទោស



អាតាប៉ិឡប់ហ្នឹងទៅវិញ ។



"អូខេ! រឿងម៉ូដែលប្រហែលជាកែកុនលែងបានហើយក្រៅពី... ណេ្អីយតាមតែវាទៅ ចំណែករឿងដែលយល់ច្រឡំគ្នាអម្បាញ់មិញ... បងថាយកល្អឯងគួរតែសុំទោស គុនដេ ព្រោះឯងឡូឡាស្រែកដេរធ្វើដូចគេជាឃាតករោគចិត្តអីចឹង ដូច្នេះអ្វីដែលឯងគួរធ្វើគឺ សុំទោស"

"តែខ្ញុំ..." ខ្ញុំធ្វើរាងស្ទាក់ស្ទើរ ។

"អេនដែល!"

"តែ..."

"ឯងជាអ្នកខុស!"

ខ្ញុំបែរយឺតៗទៅរកអាម្សៀហ្នឹង ដោយគេចមិនសម្លឹងមុខ មុននឹងហាមាត់និយាយដោយសម្លេងតតាក់តតុប...

"អើៗ អីចឹងក៏បានដែរ ខ្ញុំសុំ..."

តែ...មិនទាន់ទាំងបានខាំមាត់ពោលពាក្យសុំទោសចេញទៅផងសម្លេងមាំៗរបស់គេក៏បន្លឺកាត់មុន÷

"មិនបាច់ទេ ខ្ញុំទេដែលត្រូវសុំទោស!"

"នែ៎! ច្នួតទេដឹង គុនដេ អ្នកខុសគឺប្អូនខ្ញុំពីយ!"

អ៊ូយ! ខ្ញុំស្អប់ពួកម៉ាកម្នាក់នេះរបស់បងប្រុសមែនទែន! គេមានស្អីល្អទៅ? ហេតុអីក៏គាត់កាន់ជើងគេខ្លាំងម្លេះ?

"ខ្ញុំក៏ខុសដែរ ដែលធ្វើ 'បែបនោះ'" គេពោលដោយទឹកមុខធម្មតា ព្រមទាំងចោលភ្នែកមើលមកខ្ញុំមួយភ្លែត ។

"បែបនោះ គឺបែបណាទៅ?!?"

"បែបដែលឯងច្បាស់ជាមិនចូលចិត្ត" ចម្លើយរបស់គេមិនច្បាស់លាស់រហូតសូម្បីតែមនុស្សឆ្លាតដូចបងប្រុសក៏មិនយល់ដែរ ។

"ស្អីផស់ឯងហាំ ហាន់ គុនដេ? បែបណាអ្ហ៎ា ដែលខ្ញុំមិនចូលចិត្តនោះ ឬក៏ការពិតទៅឯង..."

"សាកសួរប្អូនឯងទៅ..."

"ឯងកុំម៉ោធ្វើអីចឹងដាក់ខ្ញុំពីយ ពេលនេះខ្ញុំកាន់តែវិលវល់ហើយ ឯងជួយនិយាយអីឱ្យវាច្បាស់ៗបន្តិចទៅមើល៍"



ហ៊ឹស! ទោះជាគេគ្មានចេតនា ថែមទាំងអត់មានស្រឹងក៏ដោយ ចុះអាដែលចាប់ខ្ញុំសង្កត់ទៅលើគ្រែ ហើយធ្វើដូចជាចង់លូកលាន់គនោះ ខ្ញុំថាវាដូចជាមិនធម្មតាទេ ។

"ហ្នឹងហើយ! បងឃើញទេ គេសារភាពហើយថាបានគិតអកុសលចំពោះខ្ញុំមែន!"

"អកុសល? ស្អីគេហ្នាំ អេនដែល ឯងនៅមិនទាន់ឈប់រករឿងរាវទៀតអ្ហ៎ ក្រែងបងប្រាប់ហើយថា..."

"ការពិត...មិញខ្ញុំលូកលាន់ប្អូនឯងអស់បន្តិចមែន"

"អិ...អី...អីគេ?!? គុនដេ...ឯង"

"ឃើញទេ ! គេសារភាពចេញមាត់ហើយ ម្ដងនេះបងនៅតែឆ្កួតកាន់ជើងគេទៀតអ្ហ៎ស?"

"ឯងកុហកខ្ញុំអ្ហ៎ គុនដេ ឯងហ្នឹងអ្ហ៎ស..." បងប្រុសនៅតែបែរទៅសួរអាម្រៀនោះដោយមិនចង់ជឿទៀត ។

"បងប្រុស! បងឆ្កួតអីហ្នឹង? គេសារភាពចេញពីមាត់គេប៉ុណ្ណឹងហើយ បងនៅតែគិតថាគេជាមនុស្សល្អទៅកើត នេះបើខ្ញុំមិនមែនជាប្អូនស្រីបង្កើត ខ្ញុំប្រហែលជាថាបងជាខ្ទើយទៅហើយ!!!"

"នែ៎! ម៉េចបានឯងមាត់ដាចយ៉ាងនេះ ខ្ទើយខ្ទុយស្អី? បងជាប្រុសដើមទ្រូង៥ហត្ថពីយ!"

"ខ្ទើយមិនចេះចង់លូកលាន់ស្រីៗទេ..." សុខៗអាម្សៀនោះក៏ពោលកាត់ សម្ដីរបស់គេធ្វើឱ្យខ្ញុំឡើងក្ដៅមុខភាយដោយគ្មានមូលហេតុ ។

"ឈប់ៗ គុនដេ កុំប្រាប់ឱ្យសោះថាឯង..." បងប្រុសបញ្ឈប់សម្ដីត្រឹមហ្នឹង ព្រមទាំងធ្វើមុខកាំង ។

ពួកម៉ាករបស់បងប្រុសម្នាក់នេះ...បើឱ្យពួកមិត្តភក្តិខ្ទើយៗរបស់ខ្ញុំជួយដាក់ឈ្មោះប្រភេទនៃភាពសង្ហាឱ្យនោះ គេប្រហែលជាស្ថិតក្នុងប្រភេទ 'សង្ហានាំឱ្យទន់ដៃទន់ជើង' ហើយមើលទៅ ។

គេមិនមែនជាមនុស្សប៉ុនតែងខ្លួនអីណាស់ណាទេ តែពេលមើលជារួមទៅ បែរជា ឡូយ ហើយនិងមានស្ទីលម្យ៉ាងរបស់ខ្លួនឯងដោយ

LOVE SERIES



រៀបរាប់មិនត្រូវ ។

ទម្រាំតែដឹងខ្លួនថាប្រឡំសម្លឹងមើលគេឡើងស្លើអស់មួយស្របក់នោះ ខ្ញុំក៏ប្រញាប់ងាកភ្នែកចេញ ពេលឃើញកែវភ្នែកមុតស្រួចមួយគូនោះសម្លឹងមកនិងបញ្ចេញស្នាមញញឹមដឹងចិត្តទៀតផង ។

ឫកពារបស់គេបែបនោះ ធ្វើឱ្យខ្ញុំទាំងខឹងទាំងអៀនរហូតត្រូវខាំមាត់ ហើយងាកមុខទៅម្ខាង មានអារម្មណ៍ញាប់ញ័រក្នុងបេះដូងយ៉ាងខ្លាំង ទាំងប្រាកដក្នុងចិត្តហើយថា ពេលនេះគេអត់បានធ្វើអីខ្ញុំទេ ក្រៅតែពី...មើល ។

"បើអីចឹងដែលឯងធ្លាប់ប្រាប់ខ្ញុំថា..."

"ខ្ញុំគិតថា...ពេលនេះកម្រិតនៃការអត់ធ្មត់របស់ខ្ញុំប្រសើរឡើងបន្តិចហើយ"

"បានន័យថាម៉េច...ដែលឯងធ្លាប់ប្រាប់ខ្ញុំថាឯងនឹងមិន..."

"ពេលនេះខ្ញុំដូរចិត្តហើយ..." គេឆ្លើយសម្លេងម៉ឺងម៉ាត់ និងបែរទៅនិយាយរឿងម៉ូដែលផ្ទុះវិញ "ចំណែកអាម៉ូដែលនេះ ខ្ញុំគិតថាធ្វើថ្មីយប់នេះគឺប្រហែលជារួច..."

ឱ្យស្លាប់ទៅចុះ! គេពីរនាក់ហ្នឹងនិយាយរឿងអីអីចេះ មើលទៅដូចជាមានអាថ៌កំបាំងអីចម្លែក?

"យប់ហ្នឹង?!? នែ៎! ហ្នឹងឯងស្រីងឬអត់ហ្នាំ ហាន់ គុនដេ ភ្លេចហើយអ្វីថាម៉ូដែលដែលយើងធ្វើ..."

"បានហើយ!" គេនិយាយកាត់ដោយសម្លេងម៉ឺងម៉ាត់ ធ្វើឱ្យបងប្រុសធ្វើមុខដូចត្រូវខ្មោចលង (ខ្ញុំក៏មិនយល់ដែរថា ហេតុអីចាំបាច់ធ្វើមុខភ្ញាក់ផ្អើលអីដល់ថ្នាក់ហ្នឹង) មុននឹងបែរមកនិយាយជាមួយខ្ញុំធ្វើព្រងើយ "ហើយមិញនេះ...រឿងនៅក្នុងបន្ទប់...ខ្ញុំមានចេតនា"

"អ្ហ៎ា?!! លោ...លោក" ខ្ញុំនិយាយតតាក់តតុបយ៉ាងទន់ហាន់ មិនប្រាកដសោះថា ខ្លួនឯងស្ដាប់ច្រឡំទេដឹង តែ...

"បែបហ្នឹងមែនទេដែលត្រូវការឱ្យខ្ញុំឆ្លើយ..." ចុងប្រយោគមើលទៅគេដូចជាចង់បញ្ឆេចបញ្ឆោខ្ញុំផង ។

ធ្វើឱ្យខ្ញុំយល់ច្បាស់ភ្លាមតែម្ដងថា អាតាប៉ុឡូប់នេះឃើញស្ទាត់





ស្ងៀមដូចមនុស្សគ្មានពិសពុលអីមែន តែការពិតទៅប្រឡឹមប៉ិនរំខានសរសៃប្រសាទជាទីបំផុត ។

"លោក!! លោកឯង..." ខ្ញុំខាំធ្មេញក្រឹត តាំងចិត្តថានឹងស៊កទៅវិញឲ្យឈឺម្ដង តែគ្រាន់តែឃើញមុខគេភ្លាម ក្នុងខួរក្បាលបែរជាភ្លេចអស់រលីង ។

"ពេលដែលខ្ញុំមិនមែនឡើយ វាក៏មិនមែនប្លែកអីដែរមែនទេ បើខ្ញុំមានលេខនា..." គេបញ្ចប់សេចក្ដីបែបស្រពេចស្រពិល រួចក៏ដើរចូលទៅប្រមូលរបស់របរនៅក្នុងបន្ទប់ធ្វើព្រងើយ ចំណែកបងប្រុសក៏ដើរតាមទៅនិយាយរឿងម៉ូដែលផ្ទះស្អីនោះជាមួយ លែងយកចិត្តទុកដាក់រឿងដែលអាតាប៉ិច្ចតនោះ ទើបតែនិយាយជាមួយខ្ញុំមិញអស់រលីង ។

បងប្រុសអើយបងប្រុស! បារម្ភពីកិច្ចការខ្លាំងជាងប្អូនស្រីបែបនេះ ខ្ញុំតូចចិត្តណាស់ ។

ដោយហេតុនេះហ្អែង...ព្រឹកស្អែកឡើង ខ្ញុំក៏សម្រេចចិត្តជិះយន្តហោះទៅអាមេរិកវិញ ទាំងដែលនៅប្រួញក្រោមខ្ញុំគិតថាចង់នៅផ្ទះឲ្យដល់ថ្ងៃចូលកងវិញ តែចុងក្រោយក៏ត្រូវជូរវាយ៉ាងទាន់ហាន់ ព្រោះចង់ឱបងប្រុស...និងដោយសារខ្ញុំក៏មិនសូវហ៊ានមើលមុខគាត់និងអាតាប៉ិនោះប៉ុន្មានហ្នឹងហ្អែង ។







## ភាគទី១
## ទឹកចិត្ត!!!

មួយឆ្នាំបន្ទាប់មក (បច្ចុប្បន្ន)

បន្ទាប់ពីរៀនចប់ហាយស្កូលនៅអាមេរិកហើយ ខ្ញុំក៏ត្រូវបានអនុញ្ញាតឲ្យមករៀនមហាវិទ្យាល័យនៅកូរ៉េតាមតម្រូវការពីមុនរបស់ខ្ញុំ ដោយខ្ញុំប្រឡងចូលមហាវិទ្យាល័យជាមួយបងប្រុសដែរ ។

តែដោយសារខ្ញុំគ្មានខួរក្បាលផ្នែកគូសវាស ខ្ញុំក៏ជ្រើសរើសរៀនផ្នែកគណនេយ្យ ទាំងការពិតទៅប៉ាខំព្យាយាមបង្ខំឲ្យខ្ញុំចូលរៀនផ្នែកស្ថាបត្យកម្មដូចបងប្រុស ដើម្បីបន្តមុខជំនួញពីគាត់ (ប៉ារបស់ខ្ញុំជាស្ថាបនិកល្បីឈ្មោះ បច្ចុប្បន្នបើកក្រុមហ៊ុនគូសប្លង់ផ្ទះនិងប្លង់គុបតែងទាំងក្នុងនិងក្រៅប្រទេស ជាពិសេសប្រទេសម្ដុំៗអាស៊ី ដូចជាហុងកុងសាំងហ្គាពួ ជប៉ុន...)

ខណៈដែលបងប្រុសក៏រាងចម្លែកៗ ដោយហាមមិនឲ្យខ្ញុំរៀនស្ថាបត្យកម្មដាច់ខាត គាត់ប្រាប់ថា អនាគតរបស់ពួកស្ថាបនិកអាចធ្លាក់ដុនដាប បើបណ្ដោយឲ្យមនុស្សដូចខ្ញុំចូលរៀនផ្នែកនេះ ។

និងដោយសារគាត់ទើបស៊ើបដឹងពីមិត្តភក្តិរបស់ខ្ញុំថា ពេលនេះខ្ញុំកំពុងសេពគប់ អ៊ូ ក្វាងមីន មិត្តជិតដិតសម័យរៀនអនុវិទ្យាល័យ ដែលពេលនេះកំពុងរៀនផ្នែកវិស្វកម្ម និងរៀននៅមហាវិទ្យាល័យជៀងពីខ្ញុំបានជាងមួយខែហើយ ។ មើលទៅបងប្រុសដូចមិនសូវពេញចិត្តនឹងការដែលខ្ញុំមានសង្សារដោយមិនពិភាក្សាអ្នកណាបែបនេះទេ ។

"បងសួរមែនទែន អេនដែល...សង្សារឯងម្នាក់នោះ គិតស្រួលបួលហើយអ្ហឺ ដែលទៅឆ្លើយយល់ព្រមសេពគប់វ៉ា?"

"បងចង់និយាយពី ក្វាងមីន អ្ហ៎?"



"អើ បងនិយាយពីវាហ្នឹងហើយ ចង់ឲ្យនិយាយពីមាន់ទាឯណា?"

បងប្រុសទាំងស្រឡាញ់និងបារម្ភពីខ្ញុំខ្លាំងណាស់ ។

"ម៉េច? បងមិនចូលចិត្តគេអ្ហ៎ ថ្នាំងទៅគេជា Prince of Zodiac ផងណា៎"

"វាចង់ព្រើនស័ព្ទនអីស្រេចតែវាទៅ តែឯងដឹងទេថា អាច្ចតហ្នឹងវាភ្លៀមប៉ុណ្ណា បងមានពួកម៉ាករៀនមហាវិទ្យាល័យជាមួយវា នៅផ្នែកវិស្វកម្ម អ្នកណាក៏ហៅវាថាបុរសឡាល់ឡាល់ឡាដែរ ប្រាប់រឿង១ឲ្យដឹង មនុស្សប្រុសនិស្ស័យបែបហ្នឹង ផ្លូវដែលល្អគឺឯងគួរតែចៀសឲ្យឆ្ងាយ រឹតតែឯងជាស្រីផង មានតែបាញ់ប្រៀបវាទេ"

"ចង់ប្រុសឡាល់ឡាល់ឡា ឬប្រុសឡៅៗក៏ដោយ ខ្ញុំបានសម្រេចចិត្តសេពគប់គេហើយ ដូច្នេះបងគ្មានសិទ្ធិអីម៉ោលូកលាន់ទេ!"

"ឯងនេះ ស្មានថាបងមិនដឹងមែនទេ ដែលឯងភ្លីភ្លើទៅយល់ព្រមសេពគប់វា ការពិតឯងគ្រាន់តែមានសង្សារបាំងមុខដើម្បីកុំឲ្យចាំម៉ាក់អូសឯងប្រជល់នឹងកូនប្រុសមិត្តភក្តិគាត់មែនទេ?"

អ៊ុយ បងប្រុសប៉ិនដឹងទាន់តែរហូត!

"មែនហើយ! បងយល់ត្រូវហើយ ខ្ញុំសេពគប់ ក្វាងមីន ព្រោះខ្ញុំខ្លាចចាំម៉ាក់ចាប់ប្រជល់...ឆាប់ហើយ គ្រង់បង គ្មានឃើញអ្នកណាបង្ខំអីសោះ តែគ្រង់ខ្ញុំ ម៉េចក៏ចាំម៉ាក់ចូលចិត្តបង្ខំម្ល៉េះហ្ន៎"

"ដោយសារតែឯងវាមិនសូវឆ្លាត ចាំម៉ាក់ក្រែងឯងទៅសេពគប់អ្នកណាផ្តេសផ្តាស ប៉ះប្រុសអន់ៗធ្វើឲ្យជីវិតឯងធ្លាក់រណ្តៅ"

"..."

អ្ហ៎! ហ្នឹង បងប្រុស ចង់ប្រាប់ថាខ្លួនឯងឆ្លាតជាងខ្ញុំ ទើបចាំម៉ាកមិនបាច់មកចាំបង្ខំមែនទេ?

"ដឹងខ្លួនទេថា វិធីកែបញ្ហាមួយៗរបស់ឯងហ្នឹងវាមហាសែនល្ងង់ណាស់ នេះប្រហែលព្រោះបងចាំតែជួយ និង បណ្តោយតាមចិត្តឯងខ្លាំងពេក ទើបចុងក្រោយឯងក៏ក្លាយជាស្រីដែលល្ងង់ ហើយគិតតែពីចិត្តខ្លួនឯងដូច្នេះ"

"អ៊ុយ! ហ្នឹងបងថាឲ្យខ្ញុំម្អែស ម៉េចក៏បងចិត្តអាក្រក់យ៉ាងនេះ?"

LOVE SERIES





"ឬក៏មិនពិត ឯងទៅឆ្លើយយល់ព្រមជាមួយអាច្ចតហ្នឹងដោយអត់មានពិភាក្សាបង សាកគិតទៅមើលថា រឿងវានឹងរញ៉េរញ៉ៃប៉ុណ្ណា នៅពេលដែលឯងសេពគប់វាដោយមិនបានស្រឡាញ់វាពិតប្រាកដនោះ ប្រយ័ត្នខ្លួនទៅ! ទៅណាម៉ោណាជាមួយវាញយៗ ថ្ងៃណាមួយត្រូវវាយកប្រៀបដោយមិនដឹងខ្លួន!"

"អើ ខ្ញុំសារភាពថាខ្ញុំមិនបានស្រឡាញ់ ក្វាងមីន តែនៅពេលដែលខ្ញុំយល់ព្រមសេពគប់គេហើយ បងក៏គួរតែសាកល្បងសម្លឹងមើលចំណុចល្អរបស់គេខ្លះផង មិនមែនគិតតែពីចំណុចអន់ៗ ម្យ៉ាងទៀត រឿងដែលបងបារម្ភខ្លាចខ្ញុំត្រូវគេយកប្រៀបលើនោះ បងឈប់បារម្ភទៅ វាគ្មានផ្លូវកើតឡើងជាដាច់ខាត"

"អើ ឯងវាចេះតែពូកែអីចឹង បានបងប្រាប់ហើយថា រាល់លើកដែលឯងកែបញ្ហាដោយខ្លួនឯងម្តងណា បងត្រូវឈឺក្បាលជាមួយឯងរាល់លើកដែរ យ៉ាងណាក៏ប្រយ័ត្នៗបន្តិចទៅណា៎!"

តាមពិត ខ្ញុំក៏ចង់ប្រាប់ការពិតឲ្យបងប្រុសដឹងថា ខ្ញុំ និង ក្វាងមីន សេពគប់គ្នាបែបណាដែរ ។

តែពេលគិតៗមើលទៅ...ខ្ញុំថាបណ្តោយឲ្យគាត់យល់ច្រឡំបែបហ្នឹងតទៀតល្អហើយ ព្រោះរឿងបែបនេះ រឹតតែមានអ្នកដឹងការពិតតិចប៉ុណ្ណា រឹតតែល្អប៉ុណ្ណោះដែរ ។

ហើយដែលសំខាន់...គឺខ្ញុំសន្យាជាមួយ ក្វាងមីន រួចហើយថា នឹងមិនប្រាប់លក្ខខណ្ឌនៃការសេពគប់គ្នាឲ្យអ្នកណាដឹងទេ ។

"តែយ៉ាងណាក៏ដោយ បងកុំយករឿងដែលខ្ញុំសេពគប់ ក្វាងមីន ដោយខ្ញុំមិនបានស្រឡាញ់គេ ទៅប្រាប់ចាំម៉ាក់ ខ្ញុំខ្លាចមែនទែន ខ្លាចពួកគាត់ដឹងការពិតហើយទៅយកកូនប្រុសមិត្តភក្តិម៉ោញាត់ឲ្យខ្ញុំ"

"ហ៊ឺយ អេនដែល ដឹងទេថាធ្វើបែបហ្នឹងវារឹតតែរញ៉េរញ៉ៃ ឯងមិនគិតខ្លះទេផ្អើសថា លោតែអាហ្នឹងវាស្រឡាញ់ឯងមែនទែន ហើយមិនព្រមឈប់ទាក់ទងឯងឆាយៗ អ្នកដែលពិបាកគឺឯង!"

ហ៊ឺយ រឿងដែល ក្វាងមីន ដូរចិត្តមកស្រឡាញ់ខ្ញុំមែនទែននោះ វាគ្មានផ្លូវទៅរួចទេ ចំណែកមូលហេតុអ្ហ៎...ការសម្ងាត់ ។



-ភី

សម្លេងខ្សឹបខ្សៀវរបស់បងប្រុសពេក ខ្ញុំក៏មិនហ៊ាននិយាយអីទៀត ចាំឱ្យគាត់និយាយខ្សឹបខ្សៀវចប់សិន ។

តែ...

"អើ គុនជេ ភ្លេ យកលេខអ្នកណាគេម៉ោហ្នឹង?"

(...)

"អ្ហា អីចឹងអ្ហ អើ ហ្នឹងជិតដល់ហើយមែនទេ...បាន។ ចាំឱ្យអ៊ំមេផ្ទះទៅបើកទ្វារឱ្យ..."

តែ...គ្រាន់តែឮថាពួកម៉ាកបងប្រុសដែលឈ្មោះ គុនជេ នោះកំពុងតែមក ខ្ញុំក៏ប្រញាប់ដាក់មេប្រូចរត់ឡើងទៅបន្ទប់ ព្រោះនៅមានអារម្មណ៍ដឹងខ្លួនខុសរឿងម្ងៃដែលផ្ទះស្ទើនោះ ហ្វូតលែងហ៊ានមើលមុខគេប៉ុន្មានឡើយ ។

ដោយសារតែប្រញាប់ខ្លាំងពេក ឬក៏មកពីរញ៉េរញ៉ៃក៏មិនដឹង ធ្វើឱ្យខ្ញុំរអិលជើងធ្លាក់ជណ្ដើរពីរកាំ ហើយគ្រេចកជើងយ៉ាងគួរឱ្យអាណោចអាធ័មបំផុត ។

វីត...

ព្រូស!

"...!"

"ហេ៎- ធ្ងន់អត់ហ្នឹង" បងប្រុសស្ទុះរត់ឡើងមកមើលដោយទឹកមុខស្លន់ស្លោ មុននឹងលើកខ្ញុំចុះជណ្ដើរទៅមុខផ្ទះភ្លាម ។

ហើយ...ពេលនោះវ៉ែអ៊ីង ឡានរបស់អាម្មៀនោះក៏បើកចូលមកចតនៅមុខផ្ទះល្មម ខ្ញុំត្រូវតែនៅមើលមុខគេដោយគេចមិនរួច ។

ពេលឡើងឡានរួចរាល់ហើយ បងប្រុសក៏ងាកមកបន្ទោសខ្ញុំ ខណៈដែលអាម្មៀនោះចេះតែបើកឡានទៅមុខដោយមិននិយាយអី គ្រាន់តែក្រឡេកមើលខ្ញុំដោយខ្សែភ្នែកដែលពិបាកកាត់យល់ (ទៀតហើយ) តាមរយៈកញ្ចក់ក្រោយម្ដងម្កាលប៉ុណ្ណោះ ។

"ឆ្កួតអីឯងហ្នឹង សុខៗស្រាប់តែរត់ឡើងបន្ទប់ ធ្វើដូចរត់គេចពីម្ចាស់បំណុល!?"





"អត់មានអីទេ អ្នកណាថាខ្ញុំរត់គេច ខ្ញុំដើរឡើងដោយមានស្មារតីជាទីបំផុត"

"ខ្ញុំថា...មូលហេតុគឺម៉ោពីខ្ញុំច្រើនជាង" សម្លេងអាម្មៀហ្នឹងនិយាយបែបប្រហើរៗឡើង តែបែរមកប៉ះចង្អិចខ្ញុំយ៉ាងខ្លាំង ។

ហ៊ឹស! ធ្វើដូចឯងដឹងច្បាស់អីចឹង តែខ្ញុំរត់គេចគេមែនហ្នឹង ។

"..."

"លើកក្រោយមិនបាច់គេចទេ ចាំខ្ញុំបន្តធ្វើជាមិនស្គាល់នាងក៏បានដែរ" គេប្រាប់ដោយសម្លេងរាបស្មើ ។

"លោកបញ្ឆោះបន្ទោកឱ្យខ្ញុំអ្ហ៎ស?"

"មិនដឹងដែរ..."

"..."

ហ៊ឹស! អាម្មៀនេះវិខានសរសៃប្រសាទមែន!

"លោកឯងចង់ធ្វើបាបអ្នកឈឺអ្ហ៎ស?"

"នាងឈឺ-កជើងតើ មានឈឺមាត់ឯណា"

ក្រឹត។!!!

តែខ្ញុំមិនទាន់បានហាមាត់ប្រកែកទៅវិញផង...

"នែ៎! ឈប់ទាំងពីរនាក់ទៅ គុនជេ ឈប់ធ្វើឱ្យនាងប្រមក់នេះខឹងទៅ ខ្ញុំឆ្អិលស្ដាប់សម្លេងឡូឡាណាស់ ឈឺក្បាលពីយ!"

"..."

ហ៊ឹស! ខ្ញុំក៏ឈឺក្បាលដែរ ដែលត្រូវមកជួបអាតាប៉ិច្ចតនេះ!

មួយខែក្រោយមក...

ដោយសារសាលប្រជុំធំមានបញ្ហាទាន់ហាន់ ធ្វើឱ្យពិធីស្វាគមន៍ទទួលពួកឆ្នាំទីមួយ ត្រូវបានប្ដូរមកធ្វើនៅអាគារផ្នែកគណនេយ្យវិញ ។

គោលបំណងនៃពិធីស្វាគមន៍ទទួលសិស្សប្អូនផ្នែកគណនេយ្យ គឺដើម្បីបង្កើតទំនាក់ទំនងល្អរវាងសិស្សប្អូននិងសិស្សច្បង ។

តែ...អាពិធីបង្កើតទំនាក់ទំនងល្អដែលថានេះ ខ្ញុំថាវាធ្វើឱ្យបរិយាកាសមើលទៅដូចជាំហាត់ទាហានទៅវិញទេ ។



ដោយចាប់ផ្ដើមតាំងពីព្រលឹម បន្ទាប់ពីសិស្សប្អូននិងសិស្សច្បងទាំងអស់ក្រោកពីដំណេក ត្រូវចាប់ឆ្នោតបែងចែកគ្នាជាក្រុម មួយក្រុម១០នាក់ បន្ទាប់ពីនោះក៏ឲ្យប្រើប្រាស់ដុសធ្មេញនិងកែវទឹកខ្ពុរមាត់តែមួយគត់ ផ្លាស់គ្នាដុសផ្លាស់គ្នាខ្ពុរមាត់ម្ដងម្នាក់មួយដុំ ។ កិច្ចការនេះ អ្នកដែលស៊យជាងគេបំផុត គឺខ្ញុំដែលចាប់ឆ្នោតបាននៅចុងកន្ទុយគេបំផុត ហើយបើនរណាមិនព្រមដុសធ្មេញតាមកតិកានេះនឹងត្រូវធ្វើតាមបញ្ជាសិស្សច្បង និង មិត្តភក្តិដែលគេសុខចិត្តធ្វើតាមកតិកា ដើម្បីជាការដាក់ទោស ។

"កតិកាសម្រាប់ហ្គេមច្រាសដុសធ្មេញរួមសម្បថនេះ គឺប្អូនៗត្រូវប្រើច្រាសដុសធ្មេញរួមជាមួយសិស្សច្បងនិងមិត្តភក្តិ នៅក្នុងក្រុមផ្លាស់គ្នាដុសម្នាក់ម្ដងមួយដុំ"

"..."

"អ្នកដែល អត់ចិត្ត មិនព្រមប្រើច្រាសរួមជាមួយសិស្សច្បងនិងមិត្តភក្តិនឹងត្រូវទទួលទោស អូខេ! ឯកភាពគ្នាតាមហ្នឹង!" សិស្សច្បងប្រុសម្នាក់ដែលមានតំណែងជាប្រធាននិស្សិត ប្រកាសប្រាប់ពីកតិកាតាមមេក្រូ មុននឹងធ្វើសញ្ញាប្រាប់ឲ្យសិស្សច្បងឯទៀតទៅយកច្រាសដុសធ្មេញនិងកែវទឹកខ្ពុរមាត់មកចែកក្រុមនីមួយៗ ។

ចំណែកពាក្យថា អត់ចិត្ត ទៅទីនេះបានន័យថា អត់មានទឹកចិត្តហ្នឹងអ្ហែង ។

វាច្បាស់ណាស់ទៅហើយថា ម្នាក់ៗសុទ្ធតែត្រូវធ្លាក់ក្នុងស្ថានភាពលំបាកលំបិននេះ តែ...ខ្ញុំដែលតាំងពីកើតមកមិនធ្លាប់ធ្លាក់ខ្លួនធ្វើអ្វីបែបនេះ ហើយថែមទាំងមិនដែលកខ្វក់ដល់ថ្នាក់ប្រើកកែវទឹកខ្ពុរមាត់រួម ដែលមិនដឹងថានឹងមាននរណាលួចខ្ពុរអីចូលក្នុងកែវ ដើម្បីធ្វើបាបអ្នកដែលនៅក្រោយគេឬក៏អត់នោះ ធ្វើឲ្យខ្ញុំសុខចិត្តទ្រាំទទួលទោសល្អជាងប្រើប្រាស់ដុសធ្មេញរួមនិងបៀមទឹកខ្ពុរមាត់ដែលនៅសល់ក្នុងកែវ បើប្រឹង្សិនមើលផង ច្បាស់ជាបានឃើញកាកស្លេសរបស់អាទា មិត្តភក្តិប្រុសៗដែលចូលចិត្តធ្វើអីប្លែកៗផ្ទុយពីមុខមាត់ឫយសង្ហារបស់វា អណ្ដែតនៅក្នុងកែវមិនខាន ហើយវាចាប់ផ្ដោត





មកឈរមុខខ្ញុំទៀត ។

ដោយហេតុនេះ ខ្ញុំសុខចិត្តទទួលទោស ល្អជាងសុខចិត្តដុសធ្មេញហើយខ្ពុរមាត់ដោយអាចទឹកស្លេសទានោះ!



"អ៊ូហ៊ូ! អីគេហ្នឹង ប្អូន អេនដែល អត់ចិត្តសោះ"

"នែ៎ ឲ្យមានចិត្តតិចមើល៍ អេនដែល!" មិត្តភក្តិប្រុសម្នាក់ដែលស្និទ្ធស្នាលនឹងខ្ញុំគួរសមដែរ ព្យាយាមញាត់ច្រាសដុសធ្មេញចូលដៃខ្ញុំឲ្យបាន ខណៈដែលខ្ញុំកំពុងធ្លាក់ក្នុងស្ថានការណ៍ លេបមិនចូល ខ្ជាក់មិនចេញ ។

"ស្អីគេ? អត់ចិត្ត នេះនាងហ៊ានខ្ពើមប្រុសសង្ហាដូចខ្ញុំផងអ៊្ហែស?" អាទាបែរមកសួរខ្ញុំដោយខ្សែភ្នែកឌឺដង ។

ខណៈនេះ ពួកមិត្តភក្តិ និង សិស្សច្បងឯទៀតចាប់ផ្ដើមស្រែកបន្ទោស (បែបលេងៗ) ខ្ញុំយ៉ាងខ្លាំង ខ្លះថា អត់ចិត្ត ខ្លះទៀតថា អត់មានទឹកចិត្ត ក៏មានដែរ ។

ក្រឹកៗ!

"អាទា...ឯង!" ខ្ញុំសម្លក់អាទាដោយការគុំគួន បើមិនមែនដោយសារតែខ្លាចវាមានចេតនាខាកស្លេសចូលកែវទឹក ប្រាកដណាស់ថាខ្ញុំសុខចិត្តបិទភ្នែកប្រើប្រាស់ដុសធ្មេញនិងកែវទឹកខ្ពុរមាត់រួមទៅហើយ ដើម្បីឲ្យអាហ្គេមឆ្កួតៗនេះវាចប់ឲ្យស្រឡះៗទៅ ។

ខ្ញុំនៅចាំបានច្បាស់ណាស់កាលពីចូលកងថ្ងៃដំបូង អាទា ក៏យកនំម៉ាចមេឡូដែលវាយកទៅត្រដុសនឹងកែងស្បែកជើងរបស់វា ហើយមកបោកឲ្យពួកមិត្តភក្តិញ៉ាំ រួចក៏មានអ្នកចាញ់កលវាញ៉ាំនំម៉ាចមេឡូរសជាតិកែងស្បែកជើង (អាទា) អស់ជាច្រើននាក់ ហើយម្នាក់នៅក្នុងចំណោមច្រើននាក់នោះ មានខ្ញុំមួយដែរ បែបនេះតើឲ្យខ្ញុំទុកចិត្តវាម៉េចបានទៅ ។

"សោកស្ដាយផងមិត្តភក្តិ ម្ដងនេះទោះជា អ៊ូ ក្វាងមីន ពាក់អាវក្រោះ ជិះសេះសម៉ោ ក៏ជួយអីនាងមិនបានដែរតើយ!"

ពេលនេះអ្នកណាៗក៏នាំគ្នាចំអន់ខ្ញុំ រឿងខ្ញុំជាសង្សារ អ៊ូ ក្វាងមីន ព្រោះដំបូងពួកមិត្តភក្តិក្នុងផ្នែកមិនដឹងថាជា អ៊ូ ក្វាងមីន ដែលធ្លាប់ជា



Prince of Zodiac ប្រចាំរាសីឆ្នូរបស់ឆ្នាំមុន តែ...កាលពីប៉ុន្មានថ្ងៃមុននេះ ពេលដែល ក្វាងមីន ចៀងចូលមកទទួលខ្ញុំ ទើបពួកគេដឹងថា ជា អ៊ី ក្វាងមីន នៃចក្ររាសីឆ្នូរ មិនមែន ក្វាងមីន នៃបក្រមាន់ទា ដូចអ្នកខ្លះយល់ច្រឡំនោះទេ ។

ចំណែកឆ្នាំថ្មីចុងក្រោយនេះ...មានអារម្មណ៍ថា...អ្នកដែលបានទទួលតំណែង Prince of Zodiac ប្រចាំរាសីឆ្នូនោះ គឺ...អ៊ី...អាតាប៉ុ ពួកម៉ាកស្និទ្ធស្នាលបណ្ដូលចេករបស់បងប្រុស...ឈ្មោះ ហាន់ គុនជេ ហ្នឹងអ៊ែង ។

អូនេ! ចប់រឿងរបស់ ពួកម៉ាកបងប្រុស ប៉ុណ្ណឹងសិនចុះ ហើយចូលមករឿងខ្ញុំវិញល្អជាង ។

"ទឹកចិត្ត!!! ទឹកចិត្ត!!!"

"..."

"ទឹកចិត្ត!!! ទឹកចិត្ត!!!"

"..."

សម្លេងស្រែកជាចង្វាក់របស់សិស្សច្បង និង ពួកមិត្តភក្តិលាន់ឮខ្ទរហឹង ហាក់ដូចជាចង់គៀបសង្កត់ឱ្យខ្ញុំព្រមធ្វើតាមកតិកា ខ្ញុំចាំបាច់ត្រូវតែទទួលទោស ដែលមិនព្រមបង្ហាញទឹកចិត្តតាមសម្រួល ។

ខ្ញុំត្រូវសិស្សច្បងនិងមិត្តភក្តិបញ្ជាឱ្យដើរទៅកន្លែងអង្គុយចាំឡានក្រុងមុខមហាវិទ្យាល័យ តែ...បន្ទាប់ពីបាន ឮបញ្ជានោះហើយ ខ្ញុំនឹកចង់ដួចចិត្តយល់ព្រមបៀមទឹកខ្លួរមាត់រសជាតិស្លែសទាវិញតែម្ដង ។

ព្រោះបញ្ជានោះវា...

"នែ! កុំអី ពួកឯងលែងខ្ញុំភ្លាម!" ខ្ញុំព្យាយាមបំរះឱ្យរួចពីដៃរបស់មិត្តភក្តិនិងសិស្សច្បង តែកម្លាំងដ៏តិចតួចរបស់ខ្ញុំហ្នឹងប្តូរទៅស៊ូនឹងកម្លាំងដ៏សោររបស់ពួកគេម្នាក់ៗបាន ។

"នាងប្រុងធ្វើខុសកតិកាឬស អេនដែល?"

"..."

"ក្រែងយើងឯកភាពគ្នាហើយអ្ហី ថាអ្នកណាមិនព្រមធ្វើតាម



កតិកា អ្នកនោះត្រូវសុខចិត្តធ្វើតាមបញ្ជារបស់សិស្សច្បងនិងមិត្តភក្តិដើម្បីជាការដាក់ទោស"



"តែ..."

"ស្ដាប់ឱ្យច្បាស់ អេនដែល នេះគឺជាការសងសឹកចំពោះកំហុសដែលនាងដណ្ដើមយក អ៊ី ក្វាងមីន ទៅគ្រប់គ្រងម្នាក់ឯង ដូច្នេះនេះជាឱកាសដំបូងនិងតែមួយគត់ដែលពួកខ្ញុំត្រូវយកមកវិញ យីកៗ!"

"..."

"អូនេ! នៅពេលនាងមិនព្រមធ្វើតាមកតិកា ពួកយើងក៏ឯកភាពគ្នាថានឹងឱ្យនាង...ទៅកន្លែងចាំឡានក្រុងជាមួយពួកខ្ញុំ ហើយក៏ឱ្យឡើងទៅសុំលេខទូរសព្ទបុរសដែលឡើងឡានក្រុងមុនគេ ហាៗៗ!"

ឡើលឡានក្រុង!!!

សុំលេខទូរសព្ទប្រុស!!!

និ...នេះជាស្អីទៅ?

ប្រុងឱ្យខ្ញុំនេះឡើងទៅសុំលេខទូរសព្ទមនុស្សប្រុសដែលឡើងឡានក្រុងមុនគេអ្ហ៎? ជាប់ហើយ...ម៉េចក៏បញ្ជាឱ្យធ្វើរឿងអត់ប្រយោជន៍បែបហ្នឹង ។

"តែ..."

ខ្ញុំមិនទាន់បានហាមាត់ប្រកែកអីផង យាយប្ញិមផ្លែកក្បាលខូចម្នាក់ក៏ដណ្ដើមនិយាយមុន...

"ដែលពួកខ្ញុំឱ្យឯងធ្វើបែបនេះ គឺមកពីទីមួយ ទេពអប្សរដូចឯងមិនដែលជិះឡានក្រុង"

"..."

"ពីរ...ឯងមិនដែលញញឹមនុស្សប្រុសទេក្នុងមួយជីវិតនេះ ព្រោះធម្មតាមានតែពួកប្រុសៗរត់តាមឯងរហូតឡើងចង់ដល់គ្នា"

"..."

"ហើយបី...នាងជាអ្នកជ្រើសរើសដោយខ្លួនឯងថាសុខចិត្តធ្វើតាមកតិកា"

"..."



"ដូច្នេះតួនាទីរបស់មនុស្សគ្មានទឹកចិត្ត គឺត្រូវព្រមធ្វើតាមបញ្ជារបស់អ្នកដែលមានទឹកចិត្ត ហាៗៗ"

"បាន! គ្រាន់តែអាឡើងជិះឡានក្រុងទៅសុំលេខទូរសព្ទប្រុស ពួកឯងស្មានថាខ្ញុំមិនហ៊ានធ្វើឬយ៉ាងម៉េច? ទោះយ៉ាងណាក៏ប្រុសម្នាក់នោះដឹងរួចហើយថា ខ្ញុំធ្វើនេះព្រោះត្រូវគេដាក់ទោស" មួយរយៈនេះជាពេលវេលាធ្វើពិធីស្វាគមន៍ទទួលសិស្សប្អូនរបស់មហាវិទ្យាល័យនានា ដូច្នេះទើបអារឿងប្លែកៗអស់នេះ មិនមែនជារឿងចម្លែកទេ ។

"..."

"ហ៊ឺៗ អ្នកណាថាពួកខ្ញុំចង់ឃើញតែប៉ុណ្ណឹងនោះមិត្តភក្តិ? ពួកខ្ញុំលួចឯកភាពគ្នាហើយថា និងថតរូបពេលនាងកំពុងសុំលេខទូរសព្ទប្រុសម្នាក់នោះយកទៅឱ្យ អ៊ី ក្វាងមីន មើលទៀតផង ហ៊ិៗៗ"

"..."

ព្រះអើយ ស្មានថាស្អី បើចង់ធ្វើណាស់ក៏អញ្ជើញតាមសប្បាយ ព្រោះទោះយ៉ាងណាក៏ ក្វាងមីន មិនឈឺក្បាលហាលថ្ងៃនឹងរឿងហ្នឹងដែរ គឺដូចបានប្រាប់ហើយអីចឹងថា រឿងដែលខ្ញុំសេពគប់ ក្វាងមីន នោះ...វាមិនមែនដូចអ្នកដទៃគិតនោះទេ ។

"ចាំមើលអ្ហា អេនដែល ប្រុសដែលឡើងឡានក្រុងមុនគេ ច្បាស់ជាភ្ញៀវ មុខបាក់ មិនបាច់សង្ស័យទេ ហ៊ីសៗ"

"បង់កន្ត្រៀ ជាត់ ម៉េចក៏ដោយ ក៏ខ្ញុំមិនខ្វល់ដែរ រឹតតែល្អទៅទៀត ក្វាងមីន មិនចាំបាច់ប្រចណ្ឌ" ខ្ញុំបន្លំធ្វើជានិយាយបែបហ្នឹង ទាំងដឹងច្បាស់ពេញក្នុងទ្រូងរួចហើយ ថា ក្វាងមីន វាគ្មានផ្លូវមកប្រចណ្ឌខ្ញុំទេ។

"ចឹស! ធ្វើជាឯងជឿជាក់...ស្រីឡប់! ឈ្លោះគ្នាជាមួយ ក្វាងមីន ពេលណា កុំម៉ោយំហៀរសំបោរកក្អាក់ឱ្យពួកយើងឃើញឱ្យសោះ!"

ចឹស! ខ្ញុំហ្នឹងឆ្លើសយំដោយសារ ក្វាងមីន គ្រាន់តែគិតក៏ទៅមិនរួចដែរ។

មួយសន្ទុះក្រោយមក ឡានក្រុងក៏ចូលមកចត...



LOVE SERIES



ការពិតទៅពេលព្រឹកៗបែបនេះ អ្នកឡើងជិះឡានក្រុងមានមិនសូវច្រើនប៉ុន្មានទេ ភាគច្រើនជាពួកនិស្សិតឆ្នាំបញ្ចប់និងពួកអ្នកតន្ត្រីដែលនៅហាត់សមរហូតដល់យប់ជ្រៅ ហើយទៅផ្ទះវិញនៅពេលព្រឹកច្រើនជាង ពេលនេះខ្ញុំបន់សុំឱ្យកន្លែងចាំឡានគ្មានមនុស្ស ។

ម្នាក់ៗចាំអ៊ុតឡើងកោងខ្លួនថាបុរសដែលនឹងក្លាយជាចំណីដំអក់ព្យរបស់ខ្ញុំគឺជានរណា តែ...ទីបំផុតអ្នកដែលស្រឡាំងជាងគេគឺរូបខ្ញុំទៅវិញ ។

"...!!!"

ព្រោះបុរសដំបូងគេដែលដើរឡើងទៅលើឡានក្រុង...
គឺអ្នកដែលខ្ញុំខំព្យាយាមគេចពីការប្រឈមមុខរហូតនោះអ្ហ៊ែង
ហាន់ គុនជេ...និស្សិតផ្នែកស្ថាបត្យកម្ម ឆ្នាំទីបួន
ម្ចាស់តំណែង Prince of Zodiac រាសីធ្នូ ឆ្នាំចុងក្រោយ ។





## ភាគទី២

## រាជបុត្រ...កំពូលរំខាន (សរសៃប្រសាទ)

ហ៊ឺ...ហេតុអីចាំបាច់ជាគេហ្ន៎?

ហើយមើលទៅមិនមែនតែខ្ញុំទេដែលពិបាកចិត្ត ពួកអស់នោះក៏មុខស្លាំងមិនខុសគ្នាដែរ បើវាខុសគ្នាគឺត្រង់ថា ខ្ញុំមុខស្លាំងព្រោះខ្មាច តែអ្នកឯទៀតមុខស្លាំងព្រោះខកបំណងដែលប្រុសម្នាក់នោះស្អាតសង្ហា ហួសនឹងធ្វើជាឧបករណ៍ក្នុងការធ្វើបាបឱ្យខ្ញុំខ្មាសគេ ។

"អឺយ! ម៉េចបានអីចឹងទៅកើត ហេតុអីបានចំសិស្សច្បង គុនដេ?"

"ហ្នឹងហើយ! ធម្មតាត្រង់គេបើកឡានមករៀនអ្វី ចុះថ្ងៃនេះម៉េចបាន...ធ្វើដូចគេឯង ម៉ោជិះឡានក្រុងទៅផ្ទះវិញបែបនេះអ្ហា"

"វាគ្មានទៅប្លែកអីត្រង់ណាទេ អ្នកណាៗក៏គេដឹងដែរថា ហាន់ គុនដេ ចូលចិត្តធ្វើអីមិនដូចគេឯងទេ មិត្តភក្តិខ្ញុំដែលរៀនស្ថាបត្យកម្មនិយាយថា ថ្ងៃមួយមានពិធីជប់លៀង គេមិនដឹងជានឹកយ៉ាងម៉េច ទៅខ្ចីអាវយឺតកញ្ចាស់ៗហែកៗ យ៉ាប់ជាងកំណាត់ជូតជើងនៅផ្ទះខ្ញុំទៅទៀត និងស្បែកជើងផ្ទាត់របស់អ្នកបើកឡានផ្ទះគេមកពាក់ តែបែរជាបើកឡានហ្វេរ៉ារី ឯងគិតមើលទៅថា វាសមនឹងគេទេ"

"អឺ...ទាំងសង្ហា ឡូយ ថែមទាំងខ្ពស់ដូចតារាបង្ហាញម៉ូតបែបហ្នឹង ពាក់អីក៏មើលទៅស្អាតដែរ តែ...រឹតតែស្អាតទៅទៀត បើសិនអត់ពាក់អីសោះនោះ ហិៗៗ"

អើ ខាំត្លាមមើមាយទៅ!

"អ៊ូយ! អេនដែល ខ្ញុំស្អប់នាងបំផុត! នាងមានសង្សារជាអតីត Prince of Zodiac រាសីធ្នូទៅហើយ ឥឡូវនៅមានឱកាសជិតស្និទ្ធនឹង Prince of Zodiac រាសីធ្នូឆ្នាំនេះទៀត"





ការពិតក៏គួរឱ្យចម្លែកដែរ ដែលជីវិតខ្ញុំមកពាក់ព័ន្ធនឹងកម្លោះដែលមានតំណែងប្រចាំរាសីធ្នូដល់ទៅពីរនាក់បែបនេះ ។

"អ៊ុយ...អាយើងនឹកស្មានថាបែបពួកខ្មៅៗ កញ្ចាស់ៗ ឬមិនអីចឹងទេក៏ពាក់ពីនតាម៉ុប តែមានឯណា បែរក្លាយជា រាជបុត្រទៅវិញ!"

ម្តងនេះជាសម្លេងរអ៊ូដោយការអស់សង្ឃឹមរបស់សិស្សច្បងស្រីម្នាក់ដែលពីដំបូងគិតថានឹងធ្វើបាបខ្ញុំឱ្យអស់ដៃនោះអ៊្ហែង ។

"បែបហ្នឹងគេហៅថាដាក់ទោស អេនដែល អ្ហ៎? ខ្ញុំថាដូចឱ្យរង្វាន់នាងទៅវិញទេ"

"ការពិតទៅល្អហើយ ដែលនាងទៅសុំលេខទូរសព្ទប្រុសមុខស្អាតនោះ បើប៉ះប្រុសរូបអាក្រក់វិញ ថតរូបទៅស្មានថា ក្វាងមីន ជឿផ្អើសថា អេនដែល ក្បត់ចិត្ត"

សម្លេងពិចារណារបស់ពួកនោះនៅតែឮមិនចេះចប់។

"អើ ត្រូវរបស់ឯង បែបគ្មានអ្នកណាជឿទេថា ស្រីស្អាតលំដាប់ អេនដែល នេះ ហ៊ានក្បត់ចិត្តទៅសុំលេខ ហាន់ គុនដេ បែបហ្នឹងល្អហើយ ហិៗៗ ប្រាប់ហើយថារឿងបង្កបញ្ហាប្រេះស្រាំបែកចាក់ គឺការងាររបស់ពួកខ្ញុំ"

អីយ៉ា មានអារម្មណ៍ថាធ្វើរឿងអាក្រក់ៗអីចឹង ខូវឱ្យវ៉ាសដល់ហើយណាំ សិស្សបង ។

"អូខេ ទោះពួកយើងច្រណែននាងប៉ុណ្ណាក៏ដោយ តែ...កតិកាគឺកតិកា ពួកយើងត្រូវខាំមាត់បញ្ជាឱ្យនាងទៅសុំលេខទូរសព្ទសិស្សច្បង ហាន់ ហើយពួកខ្ញុំនឹងតាមទៅថតរូប រួចយកទៅឱ្យ ក្វាងមីន មើល"

"តែសិស្សច្បង...ខ្ញុំ..." ខ្ញុំព្យាយាមប្រកែក តែហួសពេលហើយ ព្រោះពេលនេះត្រូវពួកសិស្សច្បងនិងពួកមិត្តភក្តិ (ខាំមាត់បង្ខំចិត្ត) អូសដៃឡើងឡានក្រុងដោយគ្មានផ្លូវជ្រើសរើស (ឯណាពីដំបូងប្រាប់ថាលបតាមទេអ្ហ៎ ) ។

ឡានក្រុងចេញដំណើរហើយ បានន័យថាខ្ញុំក៏អស់ឱកាសដូរចិត្តដែរ។

"ស្អីគេ អេនដែល នាងសំណាងល្អប៉ុណ្ណា ដែលត្រូវបញ្ជាឱ្យទៅ



សុំលេខទូរសព្ទប្រុសស្អាតដល់ថ្នាក់រាជបុត្រសុំខ្មាសនោះ ឬក៏ការពិតទៅនាងចូលចិត្តបែបកន្ត្រៀៗ ឡេៗ??" មិត្តម្នាក់បែរមកមើលដោយការងឿងឆ្ងល់ពេលឃើញខ្ញុំធ្វើមុខដូចចង់ចុះនរក ។

ហ៊ឺស...បើជាអាម្សៀនេះ ខ្ញុំសុខចិត្តសុំលេខទូរសព្ទមនុស្សគៀ ឡេវិញល្អជាង ។

"ទៅ! ទៅឈរស្ងៀមធ្វើអីទៀត ទៅបំពេញភារៈកិច្ចរបស់នាងទៅ អេនជែល!"

"គឺខ្ញុំ..." ខ្ញុំមានអារម្មណ៍ស្ទាក់ស្ទើរយ៉ាងខ្លាំង ដែលត្រូវសិស្សច្បងនិងមិត្តភក្តិព្យាយាមរុញខ្នងឱ្យទៅរកអាម្សៀនោះដែលកំពុងអង្គុយនៅកៅអីក្រោយបង្អស់ជាប់នឹងបង្អួច ។

ការពិតទៅក៏គួរឱ្យចម្លែកចិត្តមិនស្ទើរដែរ ដែលគេអត់មានសូម្បីតែបែរមកមើលពួកខ្ញុំ ទាំងដែលគេក៏ប្រហែលជាបានឮពួកអស់នេះនិយាយឈ្មោះគេខ្លាំងៗដែរនោះ ។

រហូតទាល់តែខ្ញុំក្រឡេកទៅឃើញកាសដែលនៅក្នុងរន្ធត្រចៀករបស់គេ ទើបខ្ញុំដឹងពីមូលហេតុដែលគេធ្វើជាមិនបានឮអ្វីនោះ ។

ប៉ុន្តែ...ទោះជាគេមិនបានឮសម្លេងមែន តែយ៉ាងហោចណាស់ក៏គេគួរតែឃើញខ្ញុំដែរ តែនោះគេបែរជាធ្វើដូចមិនដែលស្គាល់ខ្ញុំទៅវិញ ចំជាមនុស្សចម្លែកមែន ។

"ទៅ លឿនឡើង ឬក៏...ចង់ប្តូរចិត្តទៅសម្តែងទឹកចិត្តនៅសាលាជាមួយពួកខ្ញុំវិញ..."

"ចិត្តត្រជាក់ៗសិន បង! ខ្ញុំសុំតាំងចិត្តមួយភ្លែតមិនបានឬម៉េច?"

ឆ្កួតមែនទែន! ម៉េចបានប៉ះចំអាតាប៉ុឡូប់នេះហ្ន៎?

បើជាអ្នកដទៃវិញ ខ្ញុំគ្មានអារម្មណ៍ស្ទាក់ស្ទើរដោយសារការអៀនខ្មាសបែបនេះទេ ។

"នែ៎ សង្ហាដល់ថ្នាក់ហ្នឹងហើយ នៅចាំបាច់តាំងចិត្តស្អីទៀត បើខ្ញុំវិញអ្ហ៎ ប្រាកដជាខ្ញុំធ្វើជាទន់ជើងដួលទៅទ្រោបលើដើមទ្រូងផល់ហាន់ គុនជេ មិនខាន"

"..."







"អ្ហ៎? ឬក៏នាងសុខចិត្តទៅប្រើច្រាសដុសធ្មេញនិងកែវទឹកខ្ពុរមាត់តពី កាំង ជុនអូ (ឈ្មោះពិតរបស់អាទា) វិញ ក៏យល់ព្រម ព្រោះការពិតខ្ញុំក៏មិនចង់ឱ្យនាងមានឱកាសចូលទៅជិត គុនជេ របស់ខ្ញុំដែរ"

"គឺ..." ខ្ញុំគិតទៅដល់ច្រាសដុសធ្មេញនិងកែវទឹកខ្ពុរមាត់ដ៏កខ្វក់ព្រមទាំងមើលទៅអាម្សៀនោះដែលអង្គុយធ្វើដូចជាមិនដឹងអីទាំងអស់ដោយចិត្តជ្រួលច្របល់ ។

តែ...ក្រោយពីត្រូវរងការកៀបសង្កត់ពីគ្រប់ទិសទី ទីបំផុតខ្ញុំក៏សម្រេចចិត្តដើរទៅរកគេ ។

ចំណែកឯពួកអស់នោះក៏ទាញកាមេរ៉ាមកត្រៀមថតរូបខ្ញុំ ពេលសុំលេខទូរសព្ទពីមនុស្សប្រុសយ៉ាងរីករាយ ។

ហើយមើលទៅវាដូចជាសំណាងអាក្រក់របស់ខ្ញុំ ឬជាអ្វីក៏មិនដឹងដែរ ព្រោះពេលដែលខ្ញុំសម្រេចចិត្តថានឹងដើរទៅអង្គុយជិតគេដើម្បីសុំលេខទូរសព្ទនោះ ក៏ឃើញថា...

គេដេកលក់បាត់ទៅហើយ ។

ហ៊ឺ...សម្លាប់ខ្ញុំចោលតែម្តងទៅលោកអើយ!

ការពិតទៅខ្ញុំក៏បានដឹងខ្លះៗដែរថា ពួកនិស្សិតស្ថាបត្យកម្មនេះមិនសូវមានពេលដេកពួនប៉ុន្មានទេ ព្រោះត្រូវធ្វើកិច្ចការឱ្យលោកគ្រូរហូតដល់យប់ជ្រៅជាប្រចាំ ។

តែវានឹងប្រសើរខ្លាំងណាស់ បើគេកុំមកដេកលក់ចំពេលដែលខ្ញុំកំពុងលំបាកបែបនេះ ។

ខ្ញុំដើរយឺតៗទៅទម្លាក់ខ្លួនអង្គុយខ្លាំងៗជិតគេ ព្រមទាំងងាកមើលគេដោយចិត្តញាប់ញ័រ ដោយសង្ឃឹមថា ចេតនាអង្គុយខ្លាំងៗនោះធ្វើដើម្បីឱ្យគេភ្ញាក់ឡើងហ្នឹងអ៊ែង ។

តែ...គេនៅតែអង្គុយស្ងៀមដូចមុនអត់មានប្រែប្រួល ។

អូខេ! នៅពេលធ្វើដល់ថ្នាក់នេះហើយនៅមិនព្រមភ្ញាក់ ខ្ញុំក៏សុខចិត្តធ្វើមុខក្រាស់ដោយការស្រែកដាស់គេឱ្យភ្ញាក់ អ៊ីហ៊ី ខ្ញុំពិតជាមានសុជីវធម៌មែនទែន!

"នែ៎លោក! ភ្ញាក់ឡើង...នែ៎!"



"..." នៅតែស្ងៀមដដែល ។

"នែ៎លោក! ចង់គេងលក់ដល់ណាទៀតហ្នឹង?"

"..."

ច្បាស់មែន! ដេកលក់អីដល់ថ្នាក់ហ្នឹង? បែបមិនមែនងាប់ ព្រលឹងចេញទៅជួបព្រះឥន្ទ្រហើយទេមើលទៅ?

"អ្ហ៎! ល្មមភ្ញាក់ហើយ ហាន់ គុនដេ!!! គេងទ្រមក់ដល់ណាទៀតហ្នឹង!" ម្តងនេះមិនមែនហៅតែមាត់ទេ ខ្ញុំប្រានស្មាគេរហូតកាសម្លាងជ្រុះ ហើយក៏ឃើញថាបានការមែន ។

តែ...ជំនួសការដែលគេងាកមកតវ៉ា មួម៉ៅដាក់ខ្ញុំដែលហ៊ានដាស់គេដោយវិធីឈ្លើយៗបែបនេះ គេបែរជាគ្រាន់តែយកកាសដែលជ្រុះនៅលើភ្លៅទៅសិកចូលត្រចៀកដូចមុន បន្ទាប់មកក៏ទម្លាក់ត្របកភ្នែកចុះប្រុងលក់តទៅទៀត ។

ច្បាស់មែន! តាប៉ុនេះ...ចង់ធ្វើឱ្យខ្ញុំខឹងដល់ងាប់ឬយ៉ាងម៉េច?

"នែ៎! លោកប្រុងអត់និយាយអីមួយម៉ាត់សោះឬក៏ម៉េច?" លើកនេះខ្ញុំសុខចិត្តធ្វើមុខក្រាស់ម្តងទៀតដោយការទាញកាសម្លាងចេញ ហើយសម្លឹងមុខ ធ្វើឱ្យគេងាកមុខមកមើលខ្ញុំមួយស្របក់ មុននឹងហាមាត់និយាយដោយសម្លេងរាបស្មើ៖

"យើងធ្លាប់ស្គាល់គ្នាដែរអ្ហេស?"

អ្ហ៎ា? នេះគេបន្លំធ្វើជាមិនដែលស្គាល់ខ្ញុំអីចឹងឬ?

"នែលោក កុំមកបន្លំធ្វើជាមិនស្គាល់ឱ្យសោះ នៅពេលដែល..."

សុខៗ ខ្ញុំក៏ឈប់និយាយ ពេលនឹកឃើញរឿងមួយនោះ ។

អ្ហ៎ា នឹកឃើញហើយ ជួបគ្នាលើកចុងក្រោយបំផុត គេប្រាប់ថាបើជួបគ្នាលើកក្រោយគេនឹងធ្វើជាមិនស្គាល់ខ្ញុំ ដើម្បីកុំឱ្យខ្ញុំរត់គេចរហូតគេច-ករជើងទៀត ។

អ៊ុយ! តែពេលនេះខ្ញុំចង់ស្គាល់គេ ចង់ស្គាល់មែនទែនទៀតផង ។

ពេលនោះវិញ សម្លេងខ្សឹបខ្សៀវពីសែនសប្បាយរបស់ពួកសិស្សប្រុសដែលលបមកអង្គុយកៅអីខាងមុខតាំងពីអង្កាល់ក៏មិនដឹង ធ្វើឱ្យខ្ញុំភាំងអាក់បន្តិច ។





"ស្លាប់ហើយ! អេនជែល នេះកាចមែនទែន ពួកយើងឱ្យទៅសុំលេខទូរសព្ទ តែបែរជាទៅញ៉ែគេទៅវិញ និស្ស័យមិនល្អបែបនេះ មិនយូរប៉ុន្មានច្បាស់ជាត្រូវ ក្វាងមីន ទាត់ចោលមិនខាន យីកៗ"

"នែ៎! បើសិនជាខ្ញុំក៏ទ្រាំមិនបានដូចគ្នាដែរ បើ គុនដេ ផស់ខ្ញុំគួរឱ្យចង់ទំពារ ហើយលេបចូលពោះយ៉ាងនេះ!"

"តែ អេនជែល មាន ក្វាងមីន មួយទាំងមូលហើយ នៅចង់ម៉ៅត្របាក់ គុនដេ ផស់ខ្ញុំទៀតបែបនេះ វាមិនយកប្រៀបគ្នាឯងពេកទេអ្ហី"

ឱ្យស្លាប់ទៅចុះ! សង្ឃឹមថាតាប៉ុនេះមិនច្រឡំថាខ្ញុំដូរចិត្តមកបេតីចង់ញ៉ែគេដូចពួកសិស្សច្បងលេះតែនិយាយផ្តេសផ្តាសនោះទេ ។

"ប្រាប់ពីធុរៈរបស់នាងម៉ោល្អជាង"

ខ្ញុំលួចចម្លែកចិត្តបន្តិចដែលសុខៗ សម្លេងរាបស្មើរបស់គេប្រែជាព្រងើយកន្តើយវិញ ឬមួយក៏គេនៅតែខឹងរឿងដែលខ្ញុំចោទថាគេជាមនុស្សរោគចិត្ត ចង់លួកលាន់ខ្ញុំនោះ?

"នែ៎លោក...ប្រហែលមិនខឹងរឿងដែលខ្ញុំថាឱ្យលោកអាក្រក់ៗនោះទេមែនទេ? ឬក៏លោកនៅតែខឹងរឿងម៉ូដែលផ្ទះអីនោះ" ខ្ញុំសម្លឹងមុខគេដោយចង់ដឹងការពិត មុនពេលគេងាកមកមើលមុខខ្ញុំដោយខ្សែភ្នែកដែលពិបាកស្មានមួយសន្ទុះ រួចធ្លើយធ្វើមុខព្រងើយថា៖

"ប្រាប់ពីធុរៈនាងម៉ោ ខ្ញុំនឹងអាលគេងត"

ឱ្យស្លាប់ទៅចុះ! មិនគួរឱ្យជឿមែន ពួកម៉ាកបងប្រុសម្នាក់នេះ!

ពេលនោះខ្ញុំស្មានថាគេនិយាយលេង ដែលប្រាប់ថាលើកក្រោយនឹងធ្វើមិនស្គាល់ខ្ញុំ មិននឹកស្មានថាគេច្បាស់ធ្វើអីចឹងមែនទែនសោះ ។

អ្ហ៎! ឬក៏...ព្រោះគេទើបតែបានជាប់ឆ្នោតជា Prince of Zodiac ទើបត្រូវធ្វើឫកពាឆ្មើងឆ្មៃ ដើម្បីឱ្យសមជាអ្នកល្បីឈ្មោះ ហ៊ឺស! គួរឱ្យជ្រេញណាស់!

តែល្ហើយចុះ ពេលនេះប្រញាប់បំពេញភារកិច្ចឱ្យវាចប់ៗទៅល្អជាង មិនអីចឹងទេ ខ្ញុំទ្រាំលែងបាន ក្រោកឡើងចាប់ចោចសក់គេដាច់អស់ឥឡូវហើយ ។

"បាន! អីចឹងខ្ញុំលែងបញ្ជិតបញ្ជៀងហើយ"





"..."

"គឺខ្ញុំ...ចង់បាន...ចង់បានលេខទូរសព្ទលោក នែ! កុំអាលលក់មើល៍ នែលោក! លោក!!" និយាយមិនទាន់ចប់ស្រួលបួលផង គេក៏ផ្អែកក្បាលទីងបង្អែកកៅអី រួចបិទភ្នែកតែម្តង ។

ដំបូងខ្ញុំនឹងបិះតែលូកដៃទៅចាប់ក្បាលគេអង្រួនឱ្យបើកភ្នែកវិញទៅហើយ តែ...

"គេទៅសួរ ម៉ីណាម ទៅ" គេប្រាប់ទាំងបិទភ្នែក ។

ស្លាប់ហើយ ខ្ញុំស្អប់អាម្យៀនេះមែនទែន!

"នែ! ខ្ញុំសុំស្រួលបួល លោកគួរតែឱ្យម៉ោំ កុំធ្វើឫកពេក ស្មានថាខ្ញុំចង់បានលេខទូរសព្ទលោកណាស់អ្វើស បើកុំតែត្រូវពួកសិស្សច្បង់និងមិត្តភក្តិដាក់ទោស កុំអីក៏ខ្ញុំគ្មានផ្លូវម៉ោំធ្វើមុខក្រាស់អង្គុយអង្វរលោកបែបនេះដែរ!"

"..."

"ម៉េច? ឱ្យឬមិនឱ្យ?"

"..."

"ខ្ញុំសុំស្រួលៗ លោកគួរតែឱ្យម៉ោំ លោកក៏ដឹងដែរថាខ្ញុំត្រូវគេបង្ខំឱ្យម៉ោំសុំ មិនមែនខ្ញុំចង់បានដោយខ្លួនឯងទេ"

"នៅតែមានះដដែល..." សម្តីនិយាយចោលរបស់គេ បើស្តាប់ឱ្យច្បាស់ទៅ ទើបដឹងថាគេចង់ថាឱ្យ...ខ្ញុំ!!!

ខ្ញុំបានត្រឹមតែសម្លឹងមើលមុខសង្ហាស្អាតរបស់គេដែលបិទភ្នែក តែឆ្លើយមកវិញមួយម៉ាត់ធ្វើឱ្យខ្ញុំផ្ទុះដោយកំហឹង ។

"នែ...នែលោកថាឱ្យខ្ញុំអ្វើស អ៊ុយ លោកឯងនេះ..."

"088x..."

សុខៗ អាម្យៀនេះក៏យល់ព្រមប្រាប់លេខទូរសព្ទរបស់គេ ដោយសម្លេងរាបស្មើ ធ្វើឱ្យខ្ញុំត្រូវប្រញាប់បិទមាត់ និង ទុកកំហឹងចោលមួយភ្លែតសិន ដើម្បីស្តាប់លេខទូរសព្ទឱ្យបានច្បាស់ ។

"..."

"xxx"





"..."

"xxx"

ក្រេស!

ពេលខ្ញុំកំពុងចំស្តាប់លេខទូរសព្ទរបស់គេយ៉ាងអន្ទះសានោះ សុខៗគេក្រោកពីកៅអី ហើយឈប់ប្រាប់លេខបន្តតែម្តង ។

"..."

"ខ្ញុំជិតដល់កន្លែងត្រូវចុះហើយ ពីរលេខចុងក្រោយ នាងសាកល្បងគេរាវរកខ្លួនឯងទៅ"

"តាប៉ិច្ឆត! តែពីរលេខទៀតហ្នឹង? លោកប្រាប់ខ្ញុំរួចចាំចុះក៏បានដែរតើ" ខ្ញុំប្រញាប់ក្រោកលាដៃថ្កាង យាំងផ្លូវគេ ។

"..."

"អើ...គឺខ្ញុំចង់បានន័យថា...បើលោកជួយប្រាប់លេខពីរលេខចុងក្រោយនោះ ខ្ញុំនឹងអរគុណលោកខ្លាំងណាស់" ខ្ញុំប្រញាប់ប្តូរសម្លេងយ៉ាងរហ័សពេលឃើញទឹកមុខស្មើៗរបស់គេបង្ហាញឱ្យច្បាស់ថាមិនសូវស្រួល ដែលសុខៗត្រូវខ្ញុំជេរបែបនេះ ។

"ខ្ញុំជិតចុះហើយ" គេឆ្លើយធ្វើព្រងើយ តែខ្សែភ្នែកពោរពេញទៅដោយពាក្យថា រំខានសរសៃប្រសាទ ។

"នែ! តែពីរលេខទៀតទេ ប្រាប់ខ្ញុំម៉ោ វាមិនមែនខាតពេលដល់ថ្នាក់ចុះមិនទាន់នោះទេ!"

"ខ្ញុំប្រាប់នាងឱ្យគេរាវខ្លួនឯងទៅ..."

"ខ្ញុំធ្វើម៉េចនឹងដឹងទៅថា លេខណាជាលេខរបស់លោកនោះ? ចុះបើគេទៅលោកមិនព្រមទទួល ឱ្យធ្វើម៉េចទៅ?"

"ធម្មតាបើជាលេខចម្លែកគេម៉ោ ខ្ញុំមិនលើកទេ"

"ហ្នឹងហើយពេញទេ! បើគេទៅ លោកអត់លើក ខ្ញុំធ្វើម៉េចដឹងថាលេខមួយណាជាលេខរបស់លោក?"

"បើនាងគេចូលពេលណា ខ្ញុំនឹងផ្ញើសារមកប្រាប់"

"ហើយធ្វើម៉េចដឹងថាខ្ញុំគេទៅរកលោក បើលោកអត់ស្គាល់លេខទូរសព្ទផង់ខ្ញុំផង"



"ខ្ញុំស្គាល់"

"អ្នក? លោក...លោក..." ខ្ញុំដល់ថ្នាក់និយាយគ្រដិតតែម្តង គេប្រាប់ថាស្គាល់លេខទូរស័ព្ទខ្ញុំ?!

ច្បាស់ទេដឹង ខ្ញុំចាំបានថាខ្ញុំមិនដែលឲ្យលេខទៅគេទេ ស្លាប់ហើយ! ប្រហែលជាគេកុហកខ្ញុំឲ្យភិលមុខលេងទេដឹង ដូចអម្បាញ់មិញ គេកុហកថាមិនស្គាល់ខ្ញុំ ដល់លើកនេះមកកុហកថាស្គាល់លេខខ្ញុំទៀត តាប៉ុនេះចង់យ៉ាងម៉េចអីចេះ?

"ថ្ងៃនេះខ្ញុំជួយនាងច្រើនណាស់ហើយ" គេនិយាយតិចៗតែម្នាក់ឯង មុននឹងបែរមកមើលមុខខ្ញុំ "ដូច្នេះ...នាងគួរតែរៀនដោះស្រាយបញ្ហាដោយខ្លួនឯងខ្លះផង"

"បានន័យថាម៉េច?"

គេអត់ឆ្លើយ តែបែរជាកាត់សេចក្តីដោយការច្រានខ្លួនខ្ញុំដែលឈរពាំងផ្លូវគេយ៉ាងទន់ភ្លន់ មុននឹងដើរចុះពីឡានក្រុងទៅធ្វើព្រងើយ ។

ហើយមុននឹងឡានចេញដំណើរ គេនៅឆ្លៀតដើរមកឈរនៅត្រង់មាត់បង្អួចកន្លែងដែលខ្ញុំកំពុងឈរ រួចហើយនិយាយឡើងយ៉ាងរំខានសរសៃប្រសាទបំផុត៖

"កុំភ្លេចគេម៉ោ ខ្ញុំចាំ..."

"..."

"អ្ហ៎! លើកក្រោយមិនបាច់ឲ្យបងខ្ញុំធ្វើអត់ស្គាល់គ្នាហើយមែនទេ?" សំណួរធម្មតាៗ តែបង្កប់ទៅដោយការបញ្ឆោះសន្ធោក ធ្វើឲ្យខ្ញុំចង់តែស្ទុះលោតទៅចោចសក់ក្បាលគេ បើមិនគិតថាជាប់នៅលើឡានទេ ។

គ្រឹត....

"មិនបាច់ទេ!!!"

"ល្អ..."

ឆ្កួតមែន! តាប៉ូឡូប់នេះជំនាញរឿងធ្វើឲ្យគេមួម៉ៅមែនទែន ។

តែបើខ្ញុំត្រូវរាវរកលេខគេខ្លួនឯង បានន័យថាខ្ញុំត្រូវតែដល់ទៅ ១០០លេខឯណោះ (ចុចពីរលេខចុងក្រោយដេញតាំងពី០០ដល់ ៩៩ អ៊ុយ!)





## ភាគទី៣
## សំណាងអាក្រក់របស់ អ៊ីភ្វាងមីន

"មិនបានទេ អេនជែល! តាមបញ្ហាគឺឲ្យនាងទៅសុំលេខអ្នកដែលឡើងជិះឡានក្រុងមុនគេ ដែលនាងសំណាងល្អណាស់បានជួបនឹងគុនជេ របស់ពួកខ្ញុំ ដូច្នេះនាងត្រូវតែរកលេខរបស់គេមកឲ្យពួកខ្ញុំឲ្យបានគ្រប់ បើមិនគ្រប់ទេ នាងនឹងត្រូវទទួលទោសបន្ថែម"

"តែ..."

គ្រាន់តែត្រឡប់មកដល់សាលាវិញ ខ្ញុំក៏ត្រូវសិស្សច្បងឲ្យបំពេញភារកិច្ចនេះឲ្យសម្រេច ខណៈពេលដែលពួកមិត្តភក្តិកំពុងរង់ចាំញ៉ាំបាយរួមសម្បថ (យកម្ហូបគ្រប់យ៉ាងចាក់ចូលចានបាយជាមួយហើយច្របល់កូររួចញ៉ាំជុំគ្នា) ដែលគួរឲ្យឈឺចិត្តនោះគឺ អាបាយរួមសម្បថក្នុងចានដែកនោះ...សូម្បីតែថ្លៃអនាថាដែលដើរទាមកក៏វាមិនមើលដែរ កុំថាឡើយស៊ី ។

ថាទៅក៏ជាសំណាងល្អរបស់ខ្ញុំដែរ ដែលមិនបាច់ទៅអង្គុយញ៉ាំបាយរួមសម្បថស្អីគេនោះ មិនមែនមានតែម្ហូបគ្រប់យ៉ាងនោះទេ...តែនៅមានបេក នំប៉ាក់គី និងសូកូឡាទៀតផង ។

"ឬក៏ចង់ប្រើប្រាសជុសធ្មេញនិងទឹកខ្ពុរមាត់រួម?"

"អត់ទេ"

ដំបូង ខ្ញុំលួចគេទៅសួរបងប្រុស តែគេទៅយ៉ាងណាក៏មិនចូលដោយហេតុផលនេះអ៊ែង ទើបធ្វើឲ្យត្រូវមកអង្គុយគេរាវលេខអាម្យ៉ៀននោះស្ទើររស់ស្ទើរស្លាប់ ខណៈដែលពួកសិស្សច្បងនិងពួកមិត្តភក្តិនាគ្នាអង្គុយសើចយីកៗយ៉ាងមានសេចក្តីសុខ ព្រោះបានធ្វើបាបសិស្សប្អូនដូចជាខ្ញុំ ។ ប៉ុណ្ណឹងមិនគ្រប់ទេ ខ្ញុំនៅលបដឹងទៀតថា ការពិតយាយប៉ិ



អស់ហ្នឹងក៏ចង់បានលេខរបស់អាម្សៀហ្នឹងដែរ បានជាព្យាយាមកៀបឲ្យខ្ញុំរកលេខរបស់គេមកឲ្យគ្រប់ ។

តែការតាមរកលេខអាម្សៀនោះក៏មិនមែនជារឿងងាយដែរ ក្រៅពីខ្ញុំត្រូវចាំស្តាប់ពាក្យស្រែកជេរពីទូរសព្ទម្ចាស់ទៀត ពេលដែលខ្ញុំប្រាប់ថាគេខុស (ដោយចេតនា) ភ្លាម ខ្ញុំនៅត្រូវជួបនឹងអ្វីៗប្លែកៗ គ្រប់រូបបែបដូចជា...

'វ៉ាក! ហ្នឹង អាសេងលី មែនលេ? នេះលីយ៉ាលេខប្តីហោងស៊ីយផស់លីគេម៉ោមែនលេអ្ហ៎? ហ៊ឺស អាកួងអត់លីអរ រត់តាមប្រុសទៅហើយ នៅហិាងគេម៉ោទៀតអ្ហ៎? លីវ៉ាកៅចេង (ពូជឆ្កែ)...!"

អ៊ូយ! នៅសុខៗ ក៏ត្រូវចិនជេរថាកៅចេង គិតមើលទៅថាវ៉ាស៊ីយប៉ុណ្ណា?

ហើយនិង...

'ទីនេះមិនមែនកង់ទ័ពជើងគោកទេអ្នកនាង ម៉េចបានគេមករកគុនជេ ស្ទីហ្នឹង?'

អ៊ូ! ខ្ញុំគេទៅប៉ះនាយទាហានអ្ហ៎ សំណាងល្អណាស់ដែលគេអត់ខឹង ហើយយកកាំភ្លើងធំមកបាញ់ផ្ទះខ្ញុំនោះ ។

ហើយនិង...

'ពេងចក្ររបស់យើងអត់មានចាមីលក់ទេអ្នកនាង យើងលក់តែកណ្តូបចៀន និង ត្រីងកំប៉ុង!'

អ៊ឹម...ខ្ញុំចង់សួររក គុនជេ មិនមែនមីចារទេ ។

ហើយនិង...

'នែ៎! ម៉េចបានចេះតែគេខុសអីចឹង មិនចេះផុញខ្លួនឯងទេអ្ហ៎ ក្បាលអត់មានខួរទេអ្ហ៎ ទំនេរៗកុំភ្លេចធ្វើបុណ្យដោយខ្លាញ់ថ្លើមត្រីខ្លះផង ក្រែងលោជាតិមុខកើតម៉ោឆ្លាតជាងនេះ'

កុំមកថាឲ្យខ្ញុំមិនស្ងាត់ឆ្លាតនោះ ជីវិតខ្ញុំល្ងង់តែម្យ៉ាងគត់ គឺភាសាអង់គ្លេស ក្រៅពីនោះ...ខ្ញុំមិនបានល្ងង់ទេ ។

ខ្ញុំសាកល្បងគេហៅតដល់មួយរយលេខ លេខខ្លះអត់មានអ្នកលើក លេខខ្លះគេអត់ចូល ហើយលេខខ្លះគេទៅហើយត្រូវគេជេរមក





វិញដូចរៀបរាប់មកខាងលើ ។

តែ...ចាំហើយចាំទៀត ខ្ញុំក៏នៅតែមិនឃើញស្រមោលរបស់សារឆ្លើយតបពីអាម្សៀនោះ ។

ស្លាប់ហើយ! ខ្ញុំចង់តែបោចសក់ក្បាលពួកម៉ាកបងប្រុសម្នាក់នេះមែនទែនទេ ។



www.laksmie26.wordpress.com

មួយសន្ទុះក្រោយមក...

ទូរសព្ទខ្ញុំក៏រោទិ៍ ជាលេខមិនដែលឃើញទៀតផង ។

ជួនកាលអាចជាតាប៉ិឡប់នោះគេមកបញ្ជាក់លេខរបស់គេក៏ថាបានដែរ តែអ្ហ៎? លេខ៨ខ្ទង់ដំបូងដែលឃើញនៅលើអេក្រង់ មិនមែនជាលេខរបស់ម្សៀហ្នឹងឯណា?

អីចឹងនរណាគេតេមកអីចេះ???

...♫

(សួស្តី អេនជែល)

"អើ...អ្នកណាគេហ្នឹង?"

(បង ទីទី ណា៎ា ម៉េចលែងចាំសម្លេងបងហើយអ្ហី បងខឹងហើយ)

"ចាំបានតើ តែបងលេងដូរលេខញយបែបនេះ ខ្ញុំតាមសៅលេខទុកម៉េចនឹងទាន់ទៅ"

(មួយរយៈនេះទំនេរអត់)

"មានការងារអីអ្ហ៎បង?"

(មែនហើយ ម្តងនេះផ្សាយពាណិជ្ជកម្មឡេលាបស្បែក ថតតែត្រឹមដងខ្លួនទេ អត់បានថតមុខនាងដាក់ទូរទស្សន៍ដូចតែមុន)

ខ្ញុំ និង បងទីទី ជិតដិតគ្នាតាំងពីសម័យដែលខ្ញុំរៀនហាយស្កូលនៅអាមេរិក គេជាសាច់ញាតិរបស់មិត្តភក្តិខ្ញុំ ហើយមិត្តភក្តិខ្ញុំជាអ្នកណែនាំខ្ញុំឲ្យស្គាល់ បងទីទី ព្រោះមានពេលមួយនោះ ការងារថតពាណិជ្ជកម្មមួយមានបញ្ហាដោយសារតួឯកស្រីល្បីឈ្មោះជាច្រើននាក់ស្អាតតែមុខ តែដៃជើង...យ៉ាប់ៗ (អ្នកខ្លះជើងមានសង្វារ អ្នកខ្លះសាច់ដើមដៃយារ រូបអ្នកខ្លះកើតមុនពេញខ្នង សូម្បីតែម្យ៉ាវថ្លៃប៉ុណ្ណា



ក៏ជួយមិនរួច) ដូច្នេះក្រុមការងារក៏ ត្រូវស្វែងរកអ្នកបង្ហាញម៉ូតណាដែលមានដៃជើងស្អាតស្រឡូន គ្មានកន្លែងខ្វាស់ មកថតដើម្បីកាត់ត ។

ដូច្នោះហើយគ្រប់សាំមីកន្លងមកនេះ ខ្ញុំលួចទទួលថតផ្សាយពាណិជ្ជកម្មពី បងទីទី ព្រោះឃើញថាវាជាការងារងាយស្រួល តែបានលុយច្រើនគួរសម ដោយភាគច្រើនថតតែដៃជើងនិងខ្នងប៉ុណ្ណោះ ។

អ្នកនៅជុំវិញខ្លួនខ្ញុំ រួមទាំងអ្នកក្នុងគ្រួសារ...គ្មាននរណាដឹងទេថាពាណិជ្ជកម្មក្នុងទូរទស្សន៍ជាច្រើនឈុតចាកដែលចាក់ផ្សាយនាពេលបច្ចុប្បន្ននេះ ភាគច្រើនគឺខ្ញុំជាអ្នកសម្ដែង ជាពិសេសពាណិជ្ជកម្មណាដែលសង្កត់ធ្ងន់ទៅលើការបង្ហាញដៃជើង ។

មូលហេតុដែលខ្ញុំមិនទទួលថតឱ្យឃើញមុខ ព្រោះខ្ញុំត្រូវការសេរីភាពផ្ទាល់ខ្លួន មិនមែនដើរទៅណាមកណាមានតែអ្នកចំណាំមុខបាននោះទេ និងអ្វីដែលសំខាន់នោះគឺ បើម៉ាក់ដែលល្បីឈ្មោះរឿងមានរបៀបរបបក្បួនវិន័យដឹងថាកូនស្រីលួចទៅធ្វើជាអ្នកថតពាណិជ្ជកម្មបញ្ចេញសាច់ដៃជើងឱ្យអ្នកដទៃឃើញ ក្បាលខ្ញុំច្បាស់ជារបូតចេញពីកមិនខាន ។ ដោយហេតុនេះហើយទើបខ្ញុំប្រយ័ត្នប្រយែងណាស់ពេលទទួលសម្ដែង ខ្លាចលោធ្វើទៅធ្វើមកត្រូវម៉ាក់ដេរតាមការសែតដោយមិនដឹងខ្លួននៅថ្ងៃណាមួយ ។

"អត់បញ្ចេញសាច់ខ្លាំងពេកទេមែនទេបង?"

(អត់លេចមុខលេចក្រោយទេ តែលើកនេះសង្កត់ធ្ងន់រឿងសិចស៊ីតិចៗ តែមិនមែនខ្លាំងដូចលើកមុនៗទេ នាងមិនបាច់បារម្ភទេ នែ៎... ដៃជើងយើងស្អាតគឺត្រូវតែថតខ្លួសអាប់ជិតៗ វាជារឿងធម្មតាហើយ)

"..."

(ចំណែកគូឯកប្រុសដែលនឹងសម្ដែងគូជាមួយ បងមិនទាន់ដឹងទេថាក្រុមការងារគេជ្រើសរើសយកនរណាទេ ល្ងាចនេះប្រហែលជាដឹងហើយ តែយ៉ាងណានាងក៏បែបជាគ្មានបញ្ហាអីដែរមែនទេ?)

"ត្រូវហើយ ខ្ញុំរួមការងារជាមួយអ្នកណាក៏បាន សុំតែម្យ៉ាងគត់កុំឱ្យតែពួករពិសដៃទៅបានហើយ ខ្ញុំខ្ពិលអង្គុយចាំប្រយ័ត្នខ្លួនណាស់"





(អ្ហ៎ រឿងហ្នឹងមិនបាច់ខ្វល់ទេ យ៉ាងណាក៏បងជួយការពាររឿងនេះឱ្យនាងដែរ បើអីចឹងអាទិត្យក្រោយម៉ោងបួនល្ងាចជួបគ្នានៅស្ទូឌីយោ)

"ចាសបង អាទិត្យក្រោយជួបគ្នា"

គ្រាន់តែដាក់ទូរសព្ទពី បងទីទី ភ្លាម ទូរសព្ទក៏រលត់តែម្ដង ព្រោះអស់ថ្ម ហ៊ឹស ដោយសារតែអាតាប៉ុឡប់នោះម្នាក់គត់បានជាទូរសព្ទវាអស់ថ្មលឿនបែបនេះ ព្រោះធម្មតាប្រើបានដល់ទៅបីថ្ងៃឯណោះ ទើបសាកថ្មម្ដង ។

ល្ងាចនេះពួកសិស្សច្បងនិងមិត្តភក្តិនៅតែដេញដោលរឿងលេខទូរសព្ទរបស់អាតាប៉ុឡប់នោះមិនឈប់ តែ...មកដល់ថ្មើរនេះហើយ ខ្ញុំនៅមិនទាន់បានទទួលសារអីពីអាម្សៀនោះមួយតួអក្សរ ។

ពីរថ្ងៃក្រោយមក...

ទីបំផុតពិធីស្វាគមន៍ទទួលសិស្សប្អូនក៏កន្លងផុតទៅយ៉ាង (ប៊ិះ) រលូន តែ...មកដល់ថ្មើរនេះខ្ញុំក៏នៅមិនទាន់ដឹងថាលេខដែលខ្ញុំអង្គុយចុចឡើងចង់បាក់ម្រាមដៃ លេខណាមួយជារបស់អាម្សៀនោះទេ ព្រោះគេលេងបាត់ដំណឹងសូន្យឈឹង មិនព្រមផ្ញើសារមកសោះ ។

ពេលនោះអ្ហ៊ឹង...ក្វាងមីន ក៏បើកឡានមកចតមុខអាគារផ្នែកខណៈពេលដែលខ្ញុំក៏ត្រៀមខ្លួនរត់គេចទៅឡើងឡានគេ ដើម្បីកុំឱ្យត្រូវពួកសិស្សច្បងសួរដេញដោលរឿងលេខរបស់អាម្សៀនោះទៀត ។

តែ...ខ្ញុំមិនទាន់បានកម្រើកខ្លួនទៅណាផង ក៏ត្រូវសិស្សច្បងម្នាក់ទាញដៃឱ្យអង្គុយចុះដូចមុន ចំណែកសិស្សច្បងឯទៀតក៏ប្រញាប់រត់ស្រទៅរក ក្វាងមីន ដែលទើបតែចុះពីឡានមក ព្រមទាំងយកកាមេរ៉ាដែលកាន់ទៅជាមួយបើកឱ្យគេមើលរូបពេលខ្ញុំទៅសុំលេខទូរសព្ទរបស់អាម្សៀនោះ រួចនាំគ្នាថែមថយល្បោយយ៉ាងរករាយ ។

"នេះនែ៎ ក្វាងមីន មើលចុះសង្សារលោក មិនកើតទេ គ្រាន់តែលោកភ្លេចខ្លួនតែប៉ុន្មានថ្ងៃសោះ ក៏លួចក្បត់ចិត្តទៅសុំលេខទូរសព្ទប្រុសផ្សេង ហើយឃើញទេថា ប្រុសនៅក្នុងរូបនេះជាអ្នកណា ហាន



គុនដេ Prince of Zodiac ប្រចាំរាសីឆ្នូរបស់ឆ្នាំនេះហ្នឹងណា៎ា បែបនេះ លោកត្រូវប្រយ័ត្នឲ្យមែនទែនហើយ"

"ក្វាង់មីន កុំសុខចិត្តឲ្យសោះ អេនដែល ក្បត់ចិត្តបែបនេះ លោកបណ្ដាយឲ្យអ៊ីចឹងមិនបានជាដាច់ខាត!" សិស្សប្បុងម្នាក់ខំប្រឹងធ្វើមុខមាំៗ តែខ្ញុំមើលយ៉ាងម៉េចក៏ឃើញគួរឲ្យចង់សើចដែរ ។

"ដូរចិត្តមកសោកប់ខ្ញុំវិញក៏បានដែរ ធានាថាខ្ញុំអត់ធ្វើខ្លួនអន់ៗដូច អេនដែល អ៊ីចឹងទេ យីកៗ"

ក្វាង់មីន សើចតិចៗ ដោយមិននិយាយអ្វី មុននឹងដើរតម្រង់មករកខ្ញុំ ធ្វើឲ្យពួកសិស្សប្បុងនាំគ្នាស្រែកដោយការខកបំណង ដែលគេអត់ចាប់អារម្មណ៍ពួកនាង ថែមទាំងធ្វើល្អដាក់ខ្ញុំដូចសព្វដងទៀត ។

"អ៊ូយ ស្អីគេ? ពួកខ្ញុំទើបតែដឹងតើថាលោកស្រឡាញ់ស្រីសាវ៉ា"

"នែ៎បង ការពិតពួកបងធ្វើបាបសង្សារខ្ញុំបែបហ្នឹង ខ្ញុំក៏លួចខឹងដែរ" ម្ដងនេះ ក្វាង់មីន សើចទៅវិញ បែបស្ទើរលេងស្ទើរមែន ធ្វើឲ្យពួកសិស្សប្បុងនាំគ្នាហើកព្រឿវ ព្រោះគិតថាគេនិយាយលេង បន្ទាប់មកក៏បែរមកសួរខ្ញុំ "ល្មមទៅបានហើយនៅ អេនដែល ឬក៏...ចង់នៅឲ្យពួកបងៗធ្វើបាបតទៀត?"

"នែ៎ ចេះសួរកើត? អ្នកណាភ្លើនៅឲ្យគេធ្វើបាបនោះ..." ខ្ញុំឆ្លើយដោយសម្លេងរងើក់ ទាំងលួចក្អួតនៅក្នុងចិត្ត ដែលត្រូវធ្វើឫកជាផ្អែមល្ហែមដាក់វ៉ា ធ្វើដូចស្រឡាញ់គ្នាស្ទើរលេបអ៊ីចឹង ។

"អ៊ីចឹងទៅយើង ល្ងាចហើយខ្លាចឡានស្ទះផ្លូវ" គេនិយាយ មុននឹងលូកដៃមកយកសៀវភៅពីដៃខ្ញុំទៅកាន់ ហើយដើរនាំមុខទៅឡានគេនេះ ក្លែងបន្លំធ្វើខ្លួនជាសង្សារបានល្អគ្រប់ប្រការ ។

"យកអានេះទៅផង ក្វាង់មីន ធ្ងន់ណាស់" ខ្ញុំហុចថង់នំមួយទៀតដែលបានមកពីមិត្តភក្តិឲ្យទៅគេដែលពេលនេះជួយយួរកាំវ៉ាន់ខ្ញុំពេញដៃ (នៅតែក្លែងបន្លំធ្វើខ្លួនជាកញ្ញាទន់ភ្លន់គួរឲ្យស្រឡាញ់បន្ត) ។

"ម៉េចក៏ពីរថ្ងៃមុននេះគេអត់ចូល ទូរសព្ទមានបញ្ហាអី?"

"អស់ថ្មហ្នឹងណា៎ា ប្រើតែមួយថ្ងៃអស់ ទម្រាំសុំឪឆ្នាំងសាកពីមិត្តភក្តិបាន ជិតងាប់!" ខ្ញុំប្រាប់ ព្រមទាំងធ្វើជាងរពេលនឹកដល់មូលហេតុ







ដែលធ្វើឲ្យទូរសព្ទអស់ថ្ម នរណាក៏មិនអាចទាក់ទងខ្ញុំបានបែបនេះ ។

"អ្ហី? តែមួយថ្ងៃអស់ថ្ម ទូរសព្ទមានបញ្ហាអីទេដឹង?"

"ម៉ោពីខ្ញុំប្រើវ៉ាច្រើនពេក"

ហើយពេលច្រាកដក្នុងចិត្តថាចេញផុតឆ្ងាយពីអ្នកដទៃហើយ ការសន្ទនារវាង ខ្ញុំ និង ក្វាង់មីន ក៏ក្លាយពីបាតដៃទៅជាខ្នងជើងតែម្ដង ។

"ស្អីហ្នឹង អាពួកដែលចូលចិត្តតាមញ៉ែនាងនៅមិនទាន់ឈប់ គេម៉ោរំខានទៀតអ្ហ៎ អ៊ីចឹងដែលខ្ញុំខំប្រឹងជួយមិនអត់ប្រយោជន៍ទេអ្ហី?"

"បើឯងមិនព្រមឈប់និយាយរឿងថាជួយខ្ញុំហើយខាតពេលអត់ប្រយោជន៍ទៀតនោះ ប្រយ័ត្នទៅ ខ្ញុំនឹងយករឿងកិច្ចសន្យារបស់យើងទៅប្រាប់ចាម៉ាក់ឯង!"

"នែ៎!! នាងកុំមាត់រអិលឲ្យសោះពីយ នាងចង់ធ្វើបាបរឿងអីផ្សេងខ្ញុំមិនថាទេ តែសុំអង្វរកុំម៉ោសម្លាប់ខ្ញុំដោយសាររឿងនេះ"

"ស្ដាប់ណា៎ា ក្វាង់មីន ឯងគួរតែទន្ទេញឲ្យចាំក្នុងចិត្តថា ខ្ញុំនិងឯងគ្មាននរណាឈ្នះ ឬចាញ់ប្រៀបអ្នកណាទេ ដូច្នេះបើឯងនៅតែលួចណាត់ស្រីស្អាតតាមផាប់តាមបារ៍ ហើយរករឿងគេចពីណាត់ខ្ញុំទៀតប្រយ័ត្នខ្ញុំបើកកកាយរឿងកិច្ចសន្យារបស់យើងឲ្យអ្នកផ្ទះឯងដឹង!"

"បានហើយ នាងចេះតែសម្លុតខ្ញុំម្នាក់ទេឬយ៉ាងម៉េច ស្មានថានាងចេះបើកកកាយតែម្នាក់ឯងឬយ៉ាងម៉េច?"

"ហ៊ឺស! សុំទោសផងពីយ ក្វាង់មីន សម្លាញ់អាប់ ខ្ញុំនិងឯងវ៉ាខុសគ្នា ខ្ញុំមានបងប្រុសចាំជួយដោះសារឲ្យ តែក្បាលមួយដូចឯង ស្មានថារួចខ្លួនអ្ហ៎ បើអ្នកផ្ទះឯងដឹងថាការពិតយើងមិនមែនជាសង្សារនឹងគ្នា"

ក្វាង់មីន ដកដង្ហើមធំ រួចដូររឿងនិយាយ មុននឹងវ៉ាចូលដើមខ្លាំងជាងនេះ ។

"អូខេ! សុខចិត្តចាញ់ ខ្ញុំស្រឡាញ់នាង សម្លាញ់!" មុខឡើងស្ងួតតែសម្លេងវិញស្ដាប់យ៉ាងក៏ដឹងថាបញ្ឆោះបន្សោកដែរ ។

ពេលយើងដើរទៅជិះឡានជាមួយគ្នា សម្លេងអ៊ូរបស់ពួកសិស្សប្បុងក៏លាន់ឮចូលមកក្នុងត្រចៀកខ្ញុំរហូត ពួកនាងប្រហែលជាយល់



ថាខ្ញុំនិង ក្វាងម៉ីន ដើរដែកគ្នាផ្អែមល្ហែមហើយមើលទៅ ។

"អ៊ុយ ខ្ញុំច្រណែនគូនោះមែនទែន មិនដឹងជាគួរឱ្យស្រឡាញ់ដល់ណាទៀតទេ!"

"ហ៊ឺ ខ្ញុំសុំសង្ហាៗណ្ហា ពូកែៗ ឱ្យបានពាក់កណ្ដាល អូ ក្វាងម៉ីន នេះក៏ខ្ញុំដេកបិទភ្នែកជិតដែរ"

ពេលឡានឈប់នៅភ្លើងស្តុប សុខៗក៏មានសម្លេងរោទ៍ប្រាប់ថាមានសារចូលទូរស័ព្ទខ្ញុំ ហើយពេលយកមកមើល ក៏ឃើញថា...សារអនាមិកមួយផ្ញើមក...

'ជួបគ្នាថ្ងៃសៅរ៍នេះ'

ពេលខ្ញុំមើលលេខ ក៏ដឹងថាវាជាលេខមួយក្នុងចំណោម១០០ ដែលខ្ញុំតេរកកាលពីពីរថ្ងៃមុនហ្នឹងអ្ហែង ។

ស្លាប់ហើយ! ហេតុអីបានគេប៉ិនរំខានសរសៃប្រសាទបែបនេះ ទើបតែផ្ញើសារមកប្រាប់ថ្ងៃនេះ!!!

តែ...ដែលប្រាប់ថាជួបគ្នាថ្ងៃសៅរ៍នេះ...

បានន័យថាម៉េចអីចេះ?

ពេលមកដល់ផ្ទះភ្លាម ខ្ញុំប្រញាប់យករឿងដែលត្រូវអាម្សៀនោះធ្វើបាប មកប្រាប់បងប្រុស តែ...គាត់មិនខឹង បែរជាអស់សំណើចមិនព្រមឈប់ទៅវិញ ។

"ហាៗៗ មែនអ្ហំ បងអត់ដឹងសោះថាពេលនេះផ្នែករបស់ឯង គេមានធ្វើពិធីស្វាគមន៍ទទួលសិស្សប្អូន បងស្មានតែឯងនៅសម្ងំធ្វើរបាយការណ៍ជាមួយមិត្តភក្តិ អីចឹងតើបាន..."

"បានស្អី?"

"បានពីរថ្ងៃមុន គុនដេ គេឱ្យបងបិទទូរស័ព្ទដៃ ហាៗៗ" និយាយចប់ បងប្រុសក៏ផ្ទុះសំណើចទៀត ខុសពីខ្ញុំដែលខឹងឡើងមុខខ្មៅ ។

"ស្អីគេ!?? គេគេម៉ោប្រាប់ឱ្យបងបិទទូរស័ព្ទ ខ្ញុំស្មានថាទូរស័ព្ទបងអស់ថ្ម"

"បងមានថ្មសិគូណាហើយ អស់ងាយៗម៉េចបាន?"





ក្រឹត! តាប៉ិក្កួតហ្នឹង...ធ្វើបាបខ្ញុំទៀតហើយ!!!

"អ្ហ៎! អីចឹងគេគេឱ្យបិទ បងក៏សុខចិត្តបិទតាមគេអីចឹងទៅ ចុះបើគេបញ្ជាឱ្យបងទៅស៊ីអាចម៍ឆ្មា ក៏បងស៊ីដែរមែនទេ?"

"នែ! អាចម៍ឆ្មាស្អីឯងហ៎ា? ខឹងវាហើយម៉ោរាលដាលដល់បងបែបនេះវាត្រឹមត្រូវដែរអ្ហ៎ស"

"ឬមិនពិត ម៉េចក៏បងសុខចិត្តបិទទូរស័ព្ទងាយៗអីចឹងកើត?"

"វាប្រាប់បងថាកំពុងលេងសើចជាមួយមនុស្សម្នាក់ ឱ្យជួយបិទទូរស័ព្ទបន្តិចទៅ ហើយបងទៅដឹងថាមនុស្សម្នាក់នោះគឺឯង បងស្មានតែពួកសិស្សប្អូនស្រីៗដែលចូលចិត្តធ្វើឫកពាអៀនម៉្រិកម៉្រក់ដាក់វាតើ!"

បងប្រុសនិយាយបណ្តើរ ខំទប់សំណើចបណ្តើរ ធ្វើឱ្យខ្ញុំមានអារម្មណ៍ថាដូចកំពុងត្រូវគាត់និងពួកម៉ាកគាត់ចោមរោមធ្វើបាបអីចឹង ។

"ហ៊ឺ!!! ខ្ញុំស្អប់ពួកម៉ាកបងម្នាក់នោះមែនទែន!"

"វាចង់លេងជាមួយឯងហ្នឹងណ៎ា កុំទៅគិតអីច្រើនពេក"

"...!!!"

"ម្យ៉ាងទៀត...ឯងនេះមហាវីអាយភីបំផុតហើយដឹងទេ?"

"វីអាយភី! បានន័យថាម៉េច?"

"ធម្មតាបើមានស្រីទៅសុំលេខទូរស័ព្ទ មានតែពីរករណីប៉ុណ្ណោះដែលកើតឡើង...គឺក្រៅតែពីអត់បានលេខហើយ នៅត្រូវវ៉ាថាឱ្យបែបទន់ភ្លន់ តែឈឺចិត្តអស់ច្រើនថ្ងៃទៀត ហើយវ៉ាធ្វើដូចស្រីនោះជាខ្យល់អាកាសអត់មានរូបរាងអីចឹង តែនេះ...វាសុខចិត្តឱ្យលេខឯងដល់ទៅ៨ខ្ទង់ ហើយទុកឱ្យតាមរកពីរខ្ទង់ទៀត បែបនេះចាត់ទុកថាអស្ចារ្យណាស់ទៅហើយ"

"..."

ហ៊ឹស! ហ្នឹងអ្ហ៎ អស្ចារ្យ ខ្ញុំថាអាអស្ចារ្យនោះគឺនិស្ស័យប៉ិនរំខានសរសៃប្រសាទរបស់គេទៅវិញទេ ។

"តែឯងទៅធ្វើម៉េច បានជាវ៉ាសុខចិត្តឱ្យលេខស្រួលៗយ៉ាងនេះ?"

"ស្រួល! ស្រួលត្រង់ណាទៅ! គេលាក់ពីខ្ទង់ចុងក្រោយបែបនេះ បងនៅហ៊ាននិយាយថាស្រួលៗទៀតអ្ហ៎ សូវមែនទែនទៅចុះ បងចេះ



ទៅរាប់អានអាមនុស្សចម្លែកៗបែបហ្នឹងធ្វើជាពួកម៉ាកកើត!"

"ទោះជាចម្លែក តែវាជាមនុស្សល្អណាពីយ ហើយដែលសំខាន់...អត់ចិលស្រីដូចអ្នកខ្លះទេ"

"បងចង់និយាយពីអ្នកណា?"

"សង្សារឯងហ្នឹង!" បងប្រុសបកមកវិញភ្លាមដោយសម្លេងមិនពេញចិត្ត ព្រមទាំងដកដង្ហើមធំដោយការធុញទ្រាន់ ។

"..."

"ប្រាប់តាមត្រង់ចុះ បងខ្លាចតែឯងភ្លេចខ្លួនទៅស្រឡាញ់វាទេ"

"បងគិតជ្រុលពេកហើយ ខ្ញុំអត់មានស្រឡាញ់បែបហ្នឹងទេ"

"បងប្រាប់ទុកមុនឱ្យហើយ ឯងសេពគប់វាបាន បងមិនថាទេ តែ...បើឯងគិតចង់រៀបការជាមួយវា ត្រូវតែកន្លងសពបងសិន!!!" លើកនេះអត់លេងសើចទេ ហើយក៏ធ្វើឱ្យខ្ញុំដឹងដែរថា បងប្រុស មិនត្រឹមតែមិនចូលចិត្ត ក្វាងមីន តែគាត់ស្អប់វាតែម្តង ។

OPSOR LOVE SERIES





## ភាគទី៤
## ការសម្ងាត់របស់ អ៊ុក្វាងមីន

មួយអាទិត្យក្រោយមក

១៦:០០

ស្ទូឌីយោថតពាណិជ្ជកម្ម

ខ្ញុំបង្ខំឱ្យ ក្វាងមីន ជូនខ្ញុំមកស្ទូឌីយោ ព្រោះខ្លាចត្រូវតួឯកប្រុសធ្វើបូកពាប្រឡឹមដាក់ ព្រោះមានច្រើនដងណាស់ដែលខ្ញុំត្រូវអង្គុយទ្រាំនឹងការមកធ្វើជាស្និទ្ធស្នាលយ៉ាងមុខក្រាស់របស់ពួកអាតាប៉ុនោះ និងព្យាយាមសុំលេខទូរសព្ទខ្ញុំដោយគ្មានសុជីវធម៌ ។

ដំបូងគេមិនព្រមមកទេ ដោយអាងថាមានណាត់សំខាន់ម៉ោង ៦ល្ងាច តែចុងក្រោយចាំបាច់ត្រូវតែមក ព្រោះខ្ញុំសម្លុតថាបើមិនព្រម ខ្ញុំនឹងដូរចិត្ត មិនព្រមធ្វើតាមកិច្ចសន្យា ។

"អើ អេនជែល មកដល់ហើយ ទៀងម៉ោងល្អមែន! អ៊ុយ ក្វាងមីន ម៉ោដែរ នែ៎...ថ្ងៃនេះស្ទូឌីយោយើងមានព្រីនស៏ភាសីផ្លូម៉ោលេងដល់ទៅពីរនាក់តែម្តង" បងទីទី ចេញអាការៈអរវិករខុប ពេលឃើញ ក្វាងមីន ដើរមកជាមួយខ្ញុំ ។

"បានន័យថាម៉េចបង?"

"មានអីទៀត បងចង់និយាយពី ក្វាងមីន និង គុនជេ ហ្នឹងណ៎ា!"

"អីគេ? ថ្ងៃនេះសិស្សច្បងម៉ោទីនេះដែរអ្ហ៎?" ក្វាងមីន ធ្វើមុខស្លាំងមើលទៅវាដូចជាព្យាយាមទប់អារម្មណ៍ខ្លាំងណាស់ ខ្ញុំឃើញបែបហ្នឹងក៏នឹកឆ្ងល់តិចៗដែរ តែក៏លាក់ក្នុងចិត្តសិន ចាំសួរវាស្ងាត់ៗល្អជាង ។

"ត្រូវហើយ ព្រោះតួប្រុសដែលត្រូវថតជាមួយ អេនជែល ថ្ងៃនេះ គឺ គុនជេ ព្រីនស៏ភាសីផ្លូរបស់ឆ្នាំនេះហ្នឹងអ្ហ៎ែង"



"..."

មិនមែនតែ ក្វាងមីន ទេដែលភ្ញាក់ផ្អើល ខ្ញុំក៏មិនចាញ់គេប៉ុន្មានដែរ តែ...មូលហេតុដែល ក្វាងមីន ភ្ញាក់ផ្អើលដូចជាខុសពីខ្ញុំ...

ស្លាប់ហើយ! នេះបើគេយករឿងដែលខ្ញុំមកថតពាណិជ្ជកម្មទៅប្រាប់បងប្រុស តើខ្ញុំត្រូវធ្វើយ៉ាងម៉េចទៅ?

"ថ្ងៃនេះអត់មានតួឯកស្រីមែនទែនទេ ព្រោះមួយរយៈនេះ គុនជេ ល្បីខ្លាំងណាស់ ទើបមិនចាំបាច់ជួលតួស្រីល្បីៗមកថតនាំអស់លុយ"

"អើ..."

"តែ អេនជែល មិនបាច់គង្វល់ទេ ព្រោះកាមេរ៉ានឹងមិនថតមុខរបស់នាង ខុសតែដៃនិងជើង ថតបញ្ជិតៗតែខ្នងនិងកន្លែងផ្សេងៗទៀតដែលមិនមែនមុខ"

"គឺ..."

"អ្ហ៎ ឮថាចំណុចសំខាន់របស់ពាណិជ្ជកម្មនេះ ចេញបែបងងឹតៗបន្តិច បងព្ទូសូរអ្នកដឹកនាំប្រាប់ថាអាចនឹងប្រើសាច់រឿងមេធ្មប់ ឬមិនទេក៏ព្រាយដញ្ជក់ឈាមអីៗអស់ហ្នឹង"

"តែ..."

"សរុបទៅគឺយើងចង់បញ្ជាក់ប្រាប់ទស្សនិកជនថា ឡេម៉ាកនេះប្រើហើយធ្វើឱ្យមើលទៅមានមន្តស្នេហ៍បែបអាថ៌កំបាំងគួរឱ្យចង់ដឹងទាក់ទាញបានទាំងប្រុសស្អាតដូច គុនជេ ទៀតផង"

បងទីទី គិតតែពីរៀបរាប់ប្រាប់មិនព្រមឈប់មាត់សោះ ព្រមទាំងសើចយីកៗ រាល់ពេលដែលនិយាយដល់ឈ្មោះអាម្សៀនោះទៀតផង ធ្វើឱ្យខ្ញុំគ្មានឱកាសបានតវ៉ាអ្វីឡើយ ហើយពេលខ្ញុំរកហាមាត់សួរឱ្យអស់សង្ស័យ ក៏ត្រូវក្រុមការងារហៅគាត់ទៅបាត់ ខ្ញុំបានត្រឹមតែឱនមុខទទួលយកវាសនាកម្មដោយគ្មានផ្លូវគេចបាន ។

អូយ! នៅពេលយល់ព្រមហើយ គិតចង់សុំដកខ្លួនទាន់ហាន់ដោយសារតែមូលហេតុផ្ទាល់ខ្លួនបែបនេះ វាមើលទៅដូចជាមនុស្សគ្មានការទទួលខុសត្រូវសោះ ។

ដូច្នេះអ្វីដែលខ្ញុំគិត គឺធ្វើយ៉ាងម៉េចទើបញ៉ុកមាត់អាម្សៀហ្នឹងកុំឱ្យ







យករឿងនេះទៅប្រាប់អ្នកផ្ទះខ្ញុំ ។

អ៊ូយ! មើលទៅពេលរួចការងារថ្ងៃនេះហើយ ខ្ញុំប្រហែលត្រូវសុំជជែកជាមួយអាម្សៀនោះបន្តិចហើយ ។

តែពេលដែលខ្ញុំកំពុងរកនឹកពាក្យពិរោះៗ ទុកបញ្ចុះបញ្ចូលកុំឱ្យអាប៉ិនោះនិយាយប្រាប់អ្នកផ្ទះ សុខៗ ក្វាងមីន ក៏អូសដៃខ្ញុំទៅរកកន្លែងជជែកគ្នាស្ងាត់ៗ ក្លាមខណៈដែលក្រុមការងារខ្សឹបខ្សៀវគ្នាដោយយល់ច្រឡំថា ក្វាងមីន ប្រចណ្ឌខ្ញុំដែលត្រូវថតពាណិជ្ជកម្មជាមួយ គុនជេ ។

ក្វាងមីន អូសខ្ញុំចូលក្នុងបន្ទប់តែងខ្លួនមួយដែលគ្មានមនុស្ស ដោយអាការៈដែលខ្ញុំអាចស្មានដឹងថា គេកំពុងតែជ្រួលច្រាលក្នុងចិត្តយ៉ាងខ្លាំង រួចក៏ដាក់គន្លឹះដើម្បីកុំឱ្យនរណាបើកចូលមកបាន ។

"វាស្អីហ្នឹង អេនជែល ម៉េចមិនព្រមប្រាប់ខ្ញុំថាថ្ងៃនេះនាងត្រូវថតជាមួយសិស្សច្បង ហាន់" ក្វាងមីន សួរដោយសម្លេងពិបាកចិត្ត ខ្ញុំមិនធ្លាប់បានឃើញគេម្ហូម៉ៅជ្រួលច្រាលខ្លាំងក្លាបែបនេះទេ ។

"ស្មានថាឯងភ្ញាក់ផ្អើលតែម្នាក់ឯងទេឬយ៉ាងម៉េច ខ្ញុំក៏ទើបតែដឹងតំណាលឯងដែរ ថាត្រូវថតជាមួយគេ ហើយចុះឯងឆ្កួតអីហ្នឹងសុខៗស្រាប់តែជ្រួលច្របល់អីចឹង"

"យើងឱ្យគេដឹងមិនបានដាដាច់ខាតថាខ្ញុំនិងឯងសេពគប់គ្នា!"

"ហើយវាមានអីពាក់ព័ន្ធនឹងគេដែរ ឬក៏ឯង..."

"អើ សម្រេចថាកុំឱ្យគេដឹងដាដាច់ខាត"

"នែ ឯងឆ្កួតអីឯងហ្អា៎ អ៊ូ ក្វាងមីន ហេតុអីឯងចាំបាច់ខ្លាចគេដឹងថាយើងសេពគប់គ្នា?"

"ព្រោះខ្ញុំខ្លាចគេយល់ច្រឡំ ហើយយករឿងដែលខ្ញុំនិងឯងសេព-គប់គ្នាទៅប្រាប់បងប្អូនជីដូនមួយរបស់គេហ្នឹងណា៎!"

"បានន័យថាម៉េច? ហេតុអីឯងចាំបាច់ខ្លាចបងប្អូនជីដូនមួយគេដឹង? នែ៎ កុំប្រាប់ឱ្យសោះណា៎ ថាឯង..."

"អើ... ខ្ញុំលួចស្រឡាញ់បងប្អូនជីដូនមួយគេ ហើយពេលនេះនាងកំពុងរៀននៅបរទេស ខ្ញុំមិនចង់ឱ្យរឿងនេះឮដល់នាង វាអាចធ្វើឱ្យ

មានបញ្ហាតាមក្រោយ ឯងដឹងទេថា ខ្ញុំញៀគេជិតបានហើយ បន្ទាប់ពីខ្ញុំតាមស្និតអស់ពីឆ្នាំពេញ"



រឿងពិតដែលរបូតចេញពីមាត់របស់វាធ្វើឱ្យខ្ញុំស្រឡាំកាំងអស់ ១០នាទី...ពីឆ្នាំមិនមែនតិចតួចទេសម្រាប់មនុស្សចរិតដូច ក្វាងមីន ...នេះបញ្ជាក់ថាជាមួយស្រីម្នាក់នោះ ប្រហែលជាវាគិតមែនទែន ដោយមិនចាច់សង្ស័យ ។

"អ៊ំហ៊ុំ...មិនគួរឱ្យជឿសោះថា បុរសឡាស់ឡាស់ឡាដូចឯង ចេះស្រឡាញ់ស្មោះស្ម័គ្រនឹងគេដែរ" ខ្ញុំនិយាយរាងចំអក ពេលដែលវានៅតែធ្វើមុខមាំដាក់ខ្ញុំមិនឈប់ ។

"កុំម៉ោលេងសើចពីយ ម្នាក់នេះខ្ញុំគិតមែនទែនណាំ ដូច្នេះឱ្យគេដឹងរឿងយើងស្រលាញ់គ្នានេះមិនបានជាដាច់ខាត!"

"អ្ហ៎ ហើយចុះអាដែលឯងធ្វើខ្លួនរកីយទៅអត្តយណែនិត្យជាមួយស្រីស្អាតតាមជាប់នោះ វាមិនរឹតតែធ្ងន់ទេអ្ហី?"

"វាមិនដូចគ្នាទេពីយ អាហ្នឹងគេដឹងហើយថា ខ្ញុំគ្រាន់តែលេងសើចសប្បាយតាមនិស្ស័យមនុស្សប្រុសទេ តែ...អាដែលខ្ញុំជាមួយឯងសេពគប់គ្នាត្រឹកត្រេងបែបនេះ បើគេដឹង...ខ្ញុំកើតរឿងមិនខាន"

"ខ្ញុំថាឯងភ្លេចអីម្យ៉ាងទេដឹង ក្វាងមីន អាម្សៀនោះជាពូកម៉ាករបស់បងប្រុសខ្ញុំ ហើយបងប្រុសខ្ញុំក៏ដឹងហើយថា ខ្ញុំសេពគប់ឯង ដូច្នេះវាមិនអាចទៅរួចទេដែលគេមិនដឹងថាខ្ញុំសេពគប់ឯង"

"អើមែន វីរហើយ ខ្ញុំភ្លេចរឿងហ្នឹងឱ្យឈឹង ហើយអីចឹងឱ្យខ្ញុំធ្វើម៉េចទៅ?" ក្វាងមីន ដើរទៅដើរមកដូចកណ្ដុរជាប់អន្ទាក់ ។

"ថែ៎! ឯងឆ្កួតអីហ្នឹង អ្ហ ក្វាងមីន! ឡប់ស្មារតីហើយអ្ហី?"

"អើ! ខ្ញុំកំពុងឡប់ស្មារតីខ្លាំងជាទីបំផុត! ស្តាប់ណាំ អ្វីដែលនាងត្រូវជួយខ្ញុំពេលនេះ គឺ...នាងត្រូវប្រាប់ការពិតដល់សិស្សច្បងថា ការពិតខ្ញុំនិងនាងសេពគប់គ្នាដើម្បីបាំងមុខប៉ុណ្ណោះ មិនមែនជាសង្សារមែនទែនដូចអ្នកដទៃប្រឡូំនោះទេ"

"..."



"ប្រាប់គាត់ទៀតថា ដែលខ្ញុំនិងនាងធ្វើជាសេពគប់គ្នា ព្រោះតែខ្លាចអ្នកផ្ទះចាប់បង្ខំឱ្យរៀបការជាមួយអ្នកដែលខ្លួនអត់ស្រឡាញ់... ឯកភាពគ្នាតាមហ្នឹង"



"គ្មានផ្លូវទេ!!! ហើយឯងក៏ហាមប្រាប់រឿងនេះដល់គេដែរ!"

"ស្អីផស់នាង? ពេលនេះខ្ញុំច្លូតម្នាក់ឯងគ្រប់គ្រាន់ហើយ នាងកុំម៉ោច្លូតតាមខ្ញុំដែរបានទេ?"

"អ្នកណាដែលច្លូតនោះ? ឯងក៏គួរតែដឹងដែរថា ពេលនេះអ្នកផ្ទះខ្ញុំក៏មិនដឹងដែរថាខ្ញុំនិងឯងសេពគប់គ្នាបន្លំៗ ដូច្នេះបើឯងយករឿងនេះទៅប្រាប់អ្នកក្រៅដូចអាម្សៀនោះ ឯងមិនគិតខ្លះទេអ្ហស ថាថ្ងៃណាមួយវាអាចឮដល់ត្រចៀកប៉ាម៉ាក់ខ្ញុំ ឯងដឹងទេ...បងប្រុសផងខ្ញុំមិនហ៊ានប្រាប់ គាត់ស្មានថាឯងញៀខ្ញុំ ហើយខ្ញុំក៏ភ្លើៗអឺអើទៅ ព្រោះតែចង់យកឯងមកធ្វើអ្នកការពារ!"

"តែ សិស្សច្បង ហាន់ មិនមែនជាអ្នកមាត់រអិលទេ ពិតហើយដែលថាគាត់និយាយស្តីស្តាប់គ្នាមិនចូលត្រចៀកប៉ុន្មាន តែតាមដែលខ្ញុំដឹង គាត់មិនចូលចិត្តរវល់រឿងអ្នកដទៃទេ ដូច្នេះឯងទុកចិត្តចុះ ហើយដែលសំខាន់..." ក្វាងមីន មិនទាន់បាននិយាយចប់ផង សម្លេងទូរស័ព្ទរបស់អ្នកណាម្នាក់ក៏រោទ៍ឡើង ។

...♫

តែ...សម្លេងរោទ៍ដែលកំពុងឮនៅពេលនេះ មិនមែនទាំងរបស់ខ្ញុំនិង ក្វាងមីន ។



### ភាគទី៥
### ខ្សែរុបដ៏មហាស្រពិចស្រពិល

...♫

ខ្ញុំ និង ក្វាងមីន មើលមុខគ្នាដោយការភ្ញាក់ផ្អើល ដែលនៅសុខៗ មានសម្លេងទូរសព្ទរោទិ៍បែបនេះ ។

"ឯងចិត្តត្រជាក់ៗសិនមើល៍ អេនដែល ជួនកាល...អាចមានអ្នកណាភ្លេចទូរសព្ទនៅក្នុងនេះក៏មិនដឹង" ក្វាងមីន ព្យាយាមលួងខ្ញុំ តែ...នៅក្នុងចិត្តវិញ ខ្ញុំបែរជាមិនគិតថាយើងសំណាងល្អបែបនេះទេ ។

...♫

"អើ ខ្ញុំនៅស្ទូឌីយោ បន្ទប់ទីនេះធំគ្រាន់បើ ធ្វើឱ្យខួរក្បាលខ្ញុំស្រឡះគួរសម..."

សម្លេងគ្រលរៗ ដែលធ្លាប់ឮលាន់ចេញពីក្រោយរនាំងដែលបាំងជាប្រឡោះៗ សម្រាប់ផ្លាស់ខោអាវនិងកន្លែងតុបតែងមុខធ្វើសក់ ។

ឆ្កួតមែន! នេះបញ្ជាក់ថាមានបុគ្គលទីបីនៅក្នុងបន្ទប់នេះដែរឬ? ហើយដែលគួរឱ្យភ្ញាក់ផ្អើលជាងនោះទៅទៀត គឺ...បុរសដែលកំពុងនិយាយទូរសព្ទនៅក្រោយរនាំងបាំងនោះ...ខ្ញុំដូចជាច្បាស់ក្នុងចិត្តហើយថា គឺ...អាម្សៀនោះ!!!

ប្រាកដណាស់ ព្រោះ បងទីទី ប្រាប់ថាតួឯកប្រុសរបស់ខ្ញុំក្នុងថ្ងៃនេះគឺរូបគេ ។

ស្លាប់ហើយ! គេនៅក្នុងបន្ទប់នេះតាំងពីដំបូងម្ល៉េះ ។ បើអីចឹងបញ្ជាក់ថា...អ្វីដែលខ្ញុំនិយាយជាមួយ ក្វាងមីន អម្បាញ់មិញ...គេក៏បានឮទាំងអស់ដែរ!!!

ខ្ញុំ និង ក្វាងមីន ដើរយឺតៗទៅលបរកវាំងននមើល ហើយក៏ដឹង



ថាគឺជាគេប្រាកដមែន ។

"ប្រាប់ម៉ូយទៅថា ស្អែកនេះខ្ញុំនឹងយកគំរូទៅឱ្យមើលពេលថ្ងៃត្រង់ អើ...អើ ចាំល្ងាច ខ្ញុំនឹងតេទៅម្តងទៀត..."

ដៃគេកត់ញាប់ស្មេរទៅលើសៀវភៅតូចមួយ ។

ពេលខ្ញុំបែរទៅមើល ក្វាងមីន ក៏ឃើញថាវាកំពុងញញឹមខ្ទប ខុសពីមុនហ្នឹងដែលវាធ្វើមុខដូចស្អែកនេះងាប់ខានចាស់អីចឹង ។

"នែ ឯងឆ្កួតអីទៀតហើយ អ៊ូ ក្វាងមីន ភ័យហួតឡប់សតិអស់ហើយអ្ហ៎ស?"

"ហឺៗ ខ្ញុំទៅភ័យធ្វើអីទៀត នៅពេល...អ្នកដែលចែងឡប្បរឿងដែលខ្ញុំនិងនាងជជែកគ្នា គឺសិស្សច្បង ហាន់ រឹតតែល្អទៅទៀត ខ្ញុំមិនបាច់ឱ្យនាងទៅជួយដោះសារប្រាប់គាត់នាំតែហត់"

ស្លាប់ហើយ...ពេលនេះ ក្វាងមីន ផុតបញ្ហាហើយ!

លើកនេះនៅសល់តែខ្ញុំ...ដែលនៅតែត្រូវគិតរកវិធីដោះយករួចខ្លួនតទៅទៀត ។

រង់ចាំរហូតគេនិយាយទូរសព្ទចប់រួចរាល់...ខ្ញុំ និង ក្វាងមីន ក៏ដើរយឺតៗ កាត់រនាំងបាំងនោះចូលទៅ ហើយក៏ឃើញថាគេកំពុងអង្គុយព្រាងគំរូអ្វីម្យ៉ាងនៅលើតុ ។

ភ្លាមនោះខ្សែភ្នែករបស់ខ្ញុំក៏ឃើញកាស់ដែលសិកក្នុងរន្ធត្រចៀករបស់គេ តែ...ទោះជាឃើញបែបហ្នឹងមែន ក៏ខ្ញុំមិនហ៊ានស្មានដែរថា អាពេលដែលខ្ញុំ និង ក្វាងមីន កំពុងប្រកែកគ្នាយ៉ាងពុះកញ្ជ្រោលនោះ គេបើកចម្រៀងស្តាប់ខ្លាំងៗប៉ុណ្ណាដែរ ខ្លាំងល្មមអាចលុបបាត់សម្លេងប្រកែកគ្នារបស់ខ្ញុំ និង ក្វាងមីន ឬក៏អត់?

"លោ...លោកមកនៅក្នុងបន្ទប់នេះតាំងពីអង្កាល់?" ទោះជាដឹងថាវាជាសំណួរដែលមិនចាំបាច់ត្រូវសួរ តែពេលនេះខួរក្បាលនឹកអីឱ្យវាល្អជាងនេះលែងបានហើយ ។

"មួយសន្ទុះធំហើយ" គេបែរមកឆ្លើយធ្វើមុខព្រងើយ គ្មានបង្ហាញអាការៈចម្លែកចិត្ត ឬភ្ញាក់ផ្អើលអីបន្តិចសោះ ដែលខ្ញុំ និង ក្វាងមីន ដើរ





ចូលមកដោយមិនដឹងមុនបែបនេះ ។

"លើអីចឹង...អម្បាញ់មិញ លោកមានបានឮអីប្លែកៗខ្លះទេ?"

"..."

"យ៉ាងម៉េច សរុបថាអម្បាញ់មិញលោកមានបានឮអីខ្លះទេ" ខ្ញុំសួរបញ្ជាក់ម្តងទៀត ពេលឃើញគេនៅស្ងៀមមិនឆ្លើយ ។

"ខ្ញុំមិនសូវប្រាកដដែរ" គេឆ្លើយសម្លេងរាបស្មើ តែ...ខ្សែភ្នែកបែរជាមើលទៅមិនសូវស្មោះត្រង់ប៉ុន្មានសោះ...

ក្នុងស្ថានការណ៍បែបនេះ គេនៅតែមានមុខមករំខានសរសៃប្រសាទខ្ញុំទៀតឬ?

"មិនសូវប្រាកដយ៉ាងម៉េច សរសៃប្រសាទទទួលដឹងឮរបស់លោកមានបញ្ហាអ្វី បានជាចែកមិនដាច់ថាបានឮនិងមិនបានឮ វាខុសគ្នាយ៉ាងម៉េច?"

"អាចអីចឹងដែរ ព្រោះខ្ញុំចូលចិត្តបើកចម្រៀងស្តាប់ខ្លាំងៗ ជួនកាល...ត្រចៀកខ្ញុំអាចនឹងមានបញ្ហា" គេនិយាយបន្លឺសសម្លេងរំខានសរសៃប្រសាទខ្ញុំ ។

"ហាន់ គុនជេ! លោកឯង!"

តែខ្ញុំមិនទាន់បាននិយាយអីទៀតផង បងទីទី ក៏បើកទ្វារចូលមក៖

"អ្ហា...នាំគ្នាម៉ោពួននៅក្នុងបន្ទប់នេះអ្ហែង ពួកខ្ញុំខំតែនាំគ្នាដើររកតាំងពីយូរ គូស្រីគូប្រុសរបស់ខ្ញុំទាំងពីរ តិចទៀតទៅស្តាប់អ្នកដឹកនាំសិន រួសរាន់ទៅតែងមុខ ធ្វើសក់ត អ្ហ៎...ប៉ិះភ្លេច! អេនជែល មិនបាច់តែងមុខក៏បានដែរ គ្រាន់តែប្តូរឈុតបានហើយ ព្រោះការមេកអាប់អត់ខុសមុខទេ ចំណែក គុនជេ គ្រីសេនធើឡេ ថ្មីរបស់យើងត្រូវធ្វើទាំងពីរយ៉ាងមិនអីចឹងទេ បើអ្នកមើលអត់បានឃើញមុខស្អាតៗសង្ហាៗរបស់ប្អូនសង្ស័យឡើងស់បងលក់មិនដាច់ទេមើលទៅ"

"បាស/បាទ"

គុនជេ ឆ្លើយឱ្យតែរួចៗ ហើយខ្ញុំលួចមើលឃើញគេដកដង្ហើមធំហាក់ដូចជាធុញណាយនឹងរឿងអ្វីម្យ៉ាង ស្តាប់ហើយ! ខ្ញុំក៏មិនបានចង់រួមការងារជាមួយគេដែរ តែដោយសារយល់ព្រមជាមួយ បងទីទី







ជ្រុលហើយ ទើបមិនចង់ដកខ្លួនកណ្តាលទី នាំតែខូចកិត្តិយសខ្លួនឯង ។

ដំបូងខ្ញុំគិតចង់ថាឃាត់គេឱ្យនៅឃ្លៀវរឿងនេះឱ្យបាត់សង្ស័យ តែមិនទាន់បានហាមាត់និយាយអីផង អាម្សៀនោះក៏ដើរតាម បងទីទី ចេញទៅបាត់ ។

"ខ្ញុំថាណាំ អេនជែល យ៉ាងណាៗរឿងវាមកដល់ដំណាក់កាលនេះហើយ ឯងប្រាប់ការពិតដល់សិស្សច្បង ហាន់ ដឹងទៅ ឬមិនអីចឹងជួនកាល...គាត់អាចមិនបានបើកចម្រៀងស្តាប់ ហើយបានឮទាំងអស់ទៅហើយក៏អាចថាបានដែរ" ក្វាងមីន វិភាគបែបកាន់ជើងខ្លួនឯងជាទីបំផុត ទឹកមុខវាពេលនេះមើលទៅមានសេចក្តីសង្ឃឹមយ៉ាងខ្លាំងឃើញហើយគួរឱ្យជ្រេញមែនទែន ។

"បិទមាត់ទៅ ក្វាងមីន សួរមែនទែនចុះ តើឯងនៅឃើញខ្ញុំថាជាពួកម៉ាកខ្លះអត់ហាំ?"

"មុនហ្នឹងអាចមែន តែពេលនេះ...ក្បាលអ្នកណាសក់អ្នកហ្នឹងសិនទៅពីយ!"

"ឯង! អាពួកម៉ាកអាក្រក់!"

"ខ្ញុំអាក្រក់ព្រោះតែជួបស្នេហ៍ស្មោះវាខុសត្រង់ណា ម្យ៉ាងទៀតបើសិស្សច្បងដឹងហើយ តែអត់បានយកទៅនិយាយត នាងនិងខ្ញុំក៏នៅតែសេពគប់គ្នា ដើម្បីចាំងមុខតទៅទៀតបានតើ ឃើញទេ ថាគ្មានអីឱ្យត្រូវខ្វល់ខ្វាយសោះ..."

"តែ..."

"អេនជែល ម៉េចអត់ទាន់ចេញម៉ោទៀត ថ្ងៃនេះមានសង្សារម៉ាជាមួយ មើលទៅដូចរាងផ្តេសផ្តាសបន្តិចហើយទេដឹង" បងទីទី បើកទ្វារចូលមកតាមខ្ញុំម្តងទៀត ខ្ញុំបានត្រឹមតែញញឹមស្ងួតៗដាក់ ហើយប្រញាប់ដើរតាមគេចេញទៅភ្លាម ។

ខណៈដែលអ្នកដឹកនាំកំពុងសង្ខេបសាច់រឿង ខ្ញុំគ្មានសមាធិនឹងស្តាប់បន្តិចណាឡើយ ព្រោះរវល់តែបារម្ភជាមួយរឿងដែលកើតឡើងនៅក្នុងបន្ទប់តែងខ្លួនអម្បាញ់មិញ ។



អ៊ុយ! ហេតុអីបានខ្ញុំមានអារម្មណ៍ថាមានប្រផ្នូលមិនល្អថាគេបានឮរឿងដែលខ្ញុំ និង ក្វាងមីន ជជែកគ្នាអម្បាញ់មិញហ្នំ? រហូតដល់អ្នកដឹកនាំសង្វេបចប់ ខ្ញុំនៅតែមិនទាន់ដឹងខ្លួនទៀត ។

បន្ទាប់ពីគេតែងមុខធ្វើសក់ប្លុកខាអាវជាឈុតដែលត្រូវស្លៀកថតរូបរាល់ហើយ ខ្ញុំក៏ផ្លាស់តែឈុត ឯមុខមិនបាច់តុបតែងទេ ព្រោះការម៉ារ៉ាមិនបានថតខ្លួសតាមដែលឯកភាពគ្នា បងទីទី ក៏នាំខ្ញុំនិងគេមកអង្គុយចាំនៅក្នុងបន្ទប់សម្រាករបស់បុគ្គលិក ។

បងទីទី ចេញទៅបាត់ហើយ ពេលនេះនៅក្នុងបន្ទប់មានតែយើងពីរនាក់ ចំណែក ក្វាងមីន ពេលនេះកំពុងឈរជជែកជាមួយក្រុមការងារ គិតថាបែបធ្លាប់ស្គាល់គ្នាខ្លះដែរ ព្រោះកាលពីឆ្នាំទៅគេក៏ធ្លាប់ថតបង្ហាញម៉ូតស្ទើរតែរាល់ខែដោយសារបានទទួលតំណែងជា Prince of Zodiac ។

"មើលទៅ...រឿងដែលនាងនិយាយជាមួយសង្សារអម្បាញ់មិញបែបសំខាន់ណាស់ហើយមើលទៅ មិនអីចឹងមិនមែននាងភ្ញាក់ខ្លាំងដល់ថ្នាក់នេះទេ" សម្លេងត្រលរៗ ស្រដៀងឡូកឡឺយ ធ្វើឱ្យខ្ញុំបែរទៅមើលខ្វាច់ ។

ខ្ញុំងាកទៅជុំវិញបន្ទប់ដោយការប្រុងប្រយ័ត្ននិងដើរទៅមើលគ្រប់កន្លុកកន្លៀត ដើម្បីឱ្យប្រាកដក្នុងចិត្តថា គ្មានបុគ្គលទីបីឯណាបង្កប់ខ្លួននៅក្នុងបន្ទប់នេះដោយខ្ញុំមិនបានដឹងឡើយ ព្រោះខ្លាចខុសជាលើកទីពីរ តែ...ក៏មិនឃើញអីខុសប្រក្រតីដែរ ក្រៅពីសត្វកន្លាត ។

"អូខេ! ខ្ញុំថាលោកប្រាប់ខ្ញុំតាមត្រង់មកល្អជាង ថាតើលោកបានឮឬមិនបានឮ?" ខ្ញុំខាំមាត់សួរដោយទ្រាំលែងបាន បើគេនៅតែនិយាយស្តីខានអារម្មណ៍ខ្ញុំមិនឈប់ទៀត ថ្ងៃនេះបែបត្រូវព្រលែងខ្លះហើយ ។

"..." គេដាក់ក្រដាសសាច់រឿងទៅលើតុ លើកចិញ្ចើម ហើយអង្គុយឱបដៃ ព្រមទាំងបែរមកមើលខ្ញុំដោយគ្មាននិយាយអ្វី ឫកពាបែបនេះ គឺគ្មានអ្វីក្រៅពីមានចេតនាចង់ទាមទារសរសៃប្រសាទខ្ញុំនោះទេ ។

"ហេតុអីបានលោកមិនឆ្លើយ!" ខ្ញុំសម្លក់គេដោយចាប់ផ្ដើមអស់





ការអត់ទ្រាំ ខុសពីគេដែលមើលទៅដូចជាសប្បាយចិត្តមែនទែន ជាមួយការដែលបានធ្វើឱ្យខ្ញុំខឹងម្ល៉ោះបែបនេះ ។

"ការពិតទៅ...ខ្ញុំចង់ដឹងដែរថា បើសិនខ្ញុំប្រាប់ថាបានឮ តើនាងនឹងធ្វើយ៉ាងម៉េចតទៅទៀត"

"សរុបទៅតើលោកបានឮឬមិនបានឮ?!?"

"ជាធម្មតា...ខ្ញុំមិនមែនជាមនុស្សចូលចិត្តរវល់រឿងរបស់អ្នកដទៃទេ ដូច្នេះទោះជាខ្ញុំបានឮក៏នាងមិនបាច់ទៅភ័យកង្វល់អីដែរ"

ហេតុអីបានគេមិនព្រមប្រាប់ត្រង់ៗមកថាបានឮឬមិនបានឮហ្នំ? តាប៉ិឡប់! ហេតុអីក៏ចូលចិត្តធ្វើខ្លួនឱ្យគេពិបាកយល់បែបនេះ!

"សរុបម៉ោលោកបានឮ? ទាំងអស់?"

"បើនាងចង់ឱ្យខ្ញុំឆ្លើយបែបហ្នឹង ខ្ញុំក៏មិនជំទាស់ដែរ ហើយទោះខ្ញុំឆ្លើយថាអត់បានឮ ក៏នាងប្រហែលជាមិនជឿ ក្នុងពេលដែលនាងក៏ប្រាកដចិត្តហើយថាខ្ញុំបានឮ"

"ហានគុនជេ! លោកឯង!!!"

ដំបូងខ្ញុំចង់តែស្រែកជេរគេទៅហើយ តែ...ក៏នឹកឃើញថា ក្រៅពីរឿងនេះហើយ នៅមានរឿងមួយទៀតដែលខ្ញុំត្រូវអង្វរឱ្យគេជួយ... នោះគឺរឿងដែលខ្ញុំលួចមកថតពាណិជ្ជកម្ម ដោយហេតុនេះទើបខ្ញុំព្យាយាមទប់អារម្មណ៍ ដើម្បីកុំឱ្យខូចការច្រើនជាងនេះ ។

"ការពិតខ្ញុំជាមនុស្សមិនចូលចិត្តស្តាប់ចម្រៀងពេលធ្វើការទេ" គេដែលពាក់កាសជាប់បែបនេះ ព្រោះតែមិនចង់ឱ្យឮសម្លេងរំខាន" គេប្រាប់ដោយសម្លេងរាបស្មើ ដែលហាក់ដូចជាទទួលសារភាពតិចៗដែរថាអ្វីដែលខ្ញុំ និង ក្វាងមីន និយាយគ្នានៅក្នុងបន្ទប់តុបតែងខ្លួននោះគេបានឮទាំងអស់ ។

"លោក!!! នេះបញ្ជាក់ថា...លោកបានឮ...ទាំងអស់!!!"

"នាងគួរតែបន្ទោសខ្លួនឯងដែលនិយាយឮៗ ហួសការចាំបាច់ ព្រោះការពិតកាស់នេះរាំការពារសម្លេងរំខានពីខាងក្រៅបានប្រហែលជា៦០ភាគរយ បញ្ជាក់ថានាងនិយាយខ្លាំងៗលើសភាពចាំបាច់ដល់ទៅ៤០ភាគរយ"





"ហើយហេតុអីក៏មិនលើកចម្រៀងស្ដាប់ពេលលោកចាប់ផ្ដើមឮសម្លេងខ្ញុំ និង ក្វាងមីន ប្រកែកគ្នា?"

"សរុបទៅវាជាកំហុសរបស់ខ្ញុំមែនទេ?"

មែនហើយ ការពិតវាជាកំហុសរបស់ខ្ញុំ និង ក្វាងមីន ដែល មិនចេះប្រយ័ត្នឱ្យខ្លាំងជាងនេះ ។

អូទ នៅពេលដែលគេដឹងការពិតហើយ វាក៏ប្រហែលជាកែកុនអីមិនបានដែរ ក្រៅតែពីអង្វរគេឱ្យជួយលាក់រឿងនេះតទៅទៀត ។

"ឥឡូវយ៉ាងម៉េចក៏ដោយ សរុបថាខ្ញុំសុំអង្វរលោកកុំយករឿងនេះទៅប្រាប់អ្នកណា ជាពិសេសចាំម៉ាក់និងបងប្រុស"

"..." គេមិនឆ្លើយ អត់បញ្ចេញកាយវិការអីថាយល់ព្រមទេ តែបែរជាយកសាច់រឿងមកអានធ្វើព្រងើយ ។

"អ៊ឺ! ខ្ញុំខំសុំអង្វរលោកស្រួលហើយណា៎"

"ចុះបើខ្ញុំឆ្លើយថាអត់!" គេនិយាយដោយសម្លេងធម្មតា ភ្នែកនៅតែសម្លឹងមើលក្រដាសសាច់រឿងដែលនៅពីមុខ ដោយមិនខ្វល់ពីកាយវិការជួលច្រាលរបស់ខ្ញុំបន្តិចសោះ ។

"គួងកទាំងពីរអានសាច់រឿងរួចរាល់ហើយមែនទេ? ខ្ញុំនឹងភាលត្រៀមការម៉េកតែម្ដង..." ទ្វារបន្ទប់ត្រូវបើកម្ដងទៀត ម្ដងនេះគឺអ្នកដឹកនាំរឿងចូលមកតាមពួកយើង ។

ស្លាប់ហើយ សរុបទៅថ្ងៃនេះ ខ្ញុំនិងគេជជែកគ្នាដឹងរឿងអត់ហ្នឹង?

ហើយដោយសារតែចិត្តខ្ញុំនៅតែកង្វល់ចំពោះចម្លើយស្ទើរលេងស្ទើរមែនរបស់គេអម្បាញ់មិញ ធ្វើឱ្យខ្ញុំភ្លេចខ្លួនលបមើលគេជាញឹកញាប់ក្នុងពេលសម្ដែង ធ្វើឱ្យក្រុមការងារចំអនឱ្យថា កំពុងតែគិតចង់ក្បត់ចិត្ត ក្វាងមីន ទៅស្រឡាញ់គេ ។





## ភាគទី៦
## គំរូសំនួរចម្លើយប្រស្នា

បន្ទាប់ពីថតហើយរួចរាល់ យើងក៏បំបែកគ្នាទៅផ្ទះ ពីដំបូងខ្ញុំគិតថាទៅជាមួយ ក្វាងមីន តែ...ដល់គិតមើលម្ដងទៀត គួរតែទៅជាមួយអាម្សៀនោះល្អជាង ព្រោះបើបណ្ដោយឱ្យគេទៅដោយខ្ញុំមិនទាន់បានចម្លើយពិតប្រាកដពីគេ វាអាចនឹងមានបញ្ហានៅពេលក្រោយក៏ថាបានដែរ ហើយ ក្វាងមីន ក៏ប្រញាប់ងក់ក្បាលឯកភាពភ្លាម ព្រោះវាក៏ខ្ជិលជូនខ្ញុំទៅផ្ទះវិញស្រាប់ទៅហើយ ។

កន្លែងចតឡាន...

ខ្ញុំឈរចាំគេមួយស្របក់ធំ...រហូតដល់...

"បើនាងចង់ម៉ោនិយាយរឿងហ្នឹង មិនចាំបាច់បារម្ភទេ ធម្មតាខ្ញុំក៏មិនចូលចិត្តភីភល់រឿងអ្នកដទៃស្រាប់ទៅហើយ" គេប្រាប់ដោយសម្លេងធម្មតា ព្រមទាំងសម្លឹងមុខខ្ញុំ ហាក់ដូចជាចង់បញ្ជាក់ថា ឱ្យទុកចិត្តចុះ គេមិនយកទៅប្រាប់នរណាទេ ។

"ទោះយ៉ាងណាក៏អរគុណច្រើនដែលលោកយល់ព្រមថាមិនប្រាប់អ្នកណា តែ...នៅមានរឿងមួយទៀតដែលខ្ញុំចង់សុំអង្វរ"

"...?"

"គឺ...ខ្ញុំគិតថារឿងនេះអាចនឹងត្រូវនិយាយជាមួយគ្នាតែពីរនាក់ដូច្នេះហើយ..."

"...?"

"បើលោកមិនស្អប់ខ្ពើមទេ...សុំជួយជូនខ្ញុំទៅផ្ទះបន្តិចបានទេ ខ្ញុំនឹងបាននិយាយរឿងនេះជាមួយលោកនៅក្នុងឡាន..."



"ស្ដាប់មើលទៅដូចជាបញ្ហាច្រើនជាងសុំអង្វរ" ទោះជាសម្លេងស្ដាប់ទៅរាងចំអកបន្តិចមែន តែគេក៏យល់ព្រមបើកទ្វារឱ្យខ្ញុំឡើងទៅអង្គុយក្បែរតាមសម្រួល ។

"រឿងដែលខ្ញុំមោថតថ្ងៃនេះ ខ្ញុំនឹងអរគុណជាអនេកបើលោក... មិនយករឿងនេះទៅប្រាប់បងប្រុស" ខ្ញុំនិយាយចូលសាច់រឿងភ្លាមពេលគេកំពុងបញ្ឆេះឡាន ។

"ការពិតទៅនាងមិនចាំបាច់មកសុំអង្វរខ្ញុំទេ ព្រោះបើខ្ញុំចង់ប្រាប់មីណាម ខ្ញុំប្រហែលជាប្រាប់វាយូរណាស់ទៅហើយ"

"បានន័យថាម៉េច?"

"នាងទទួលសម្ដែងផ្សាយពាណិជ្ជកម្មដែលថតតែត្រឹមជើង និងដៃបែបនេះបួនដងហើយមែនទេ?"

"ត្រូ...ត្រូវហើយ...ម៉េចលោកដឹង?"

ស្លាប់ហើយ...គេទ្រង់ញាណដឹងឬក៏យ៉ាងម៉េច?

ឬមួយ...គេលួចតាមដានខ្ញុំ?

តែដល់ពេលអង្គុយគិតមើលទៅ ទាំងពីរយ៉ាងនេះគ្មានផ្លូវទៅរួចជាដាច់ខាត ។

បើអីចឹង...ម៉េចបានគេដឹង?

"ដំបូងខ្ញុំក៏មិនប្រាកដប៉ុន្មានដែរថាជានាងមែនអត់ តែ...បន្ទាប់ពីយើងថតជាមួយគ្នាថ្ងៃនេះហើយ ខ្ញុំក៏ច្បាស់នៅក្នុងចិត្តតែម្ដងថា អាបូនស្បែកដែលធ្លាប់បញ្ចាំងនៅក្នុងជីវីនោះ គឺជានាង"

"...?"

"ការពិតទៅដែលខ្ញុំយល់ព្រមថតផ្សាយពាណិជ្ជកម្មនេះ ព្រោះតែខ្ញុំចង់ដឹងថា...ខួរក្បាលផ្នែកចងចាំរបស់ខ្ញុំនៅធ្វើការបានល្អដូចប្រក្រតីឬអត់?"

"ខួរក្បាលផ្នែកចងចាំ"

"ពេលនាងថត ការមើលខ្លួនអាប់នៅកន្លែងណារបស់ខ្លួននាង?"

"ដៃនិងជើង" ចំណែកមុខខ្ញុំសុំអង្វរមិនឱ្យក្រុមការងារថតទេ ព្រោះមិនចង់ឱ្យអ្នកផ្ទះដឹងថាមកធ្វើអីបែបហ្នឹង ។







"ម្ដងនេះ យល់ហើយឬនៅថាម៉េចបានខ្ញុំដឹងថាជានាង?"

"...លោ...លោក...លោកលួចមើលជើងខ្ញុំផ្អើស?" ពេលនេះខ្ញុំមានអារម្មណ៍ថាខ្លួនខុសខ្លាំងណាស់ ដែលស្លៀកខោជើងខ្លីមកឡើងជិះឡានគេបែបនេះ ខ្ញុំប្រញាប់យកកាបូបមកបាំងជើងខ្លួនឯងយ៉ាងរហ័ស ដើម្បីការពារពីខ្សែភ្នែករបស់គេ ។

"ខ្ញុំមិនមែនខ្ទើយទេដែលមើលរំលងអីៗបែបនេះ"

"..."

"សរុបទៅសប្បាយចិត្តចុះ ព្រោះទោះយ៉ាងណាក៏ប្រហែលជាមានតែខ្ញុំម្នាក់គត់ដែលមើលដឹងថាជានាង"

"..."

ច្អតមែន! គេពិតប៉ុនសង្កេតល្អិតល្អន់ដល់ថ្នាក់ចំណាំដៃជើងខ្ញុំបានឬ? នេះបញ្ជាក់ថា ការពិតទៅគេគិតអកុសលមកលើខ្ញុំមែនទេ?

អ៊ូយ! ពួកម៉ាកបងប្រុសម្នាក់នេះ កើតរោគចិត្តខ្លាំងមែនទែន!

"ចំណែករឿងដែលនាង និង ក្វាងមីន លេងអីប្លែកៗបែបនោះ គិតមើលម្ដងទៀតទៅ...ខ្ញុំថាគួរតែមានចំណុចដោះដូរគ្នាបន្តិច"

"អ្ហ៎ា? ក្រែងលោកថាមិនចូលចិត្តរវល់រឿងអ្នកដទៃអ្ហ៎?"

"នាងមិនមែនជាអ្នកដទៃឯណា!" គេឆ្លើយដោយសម្លេងធម្មតា តែខ្សែភ្នែកជះពន្លឺស៊ីជម្រៅ រហូតដល់ខ្ញុំលែងហ៊ានមើលតទៀត ។

មិនដឹងថាធាតុអាកាសថ្ងៃនេះវាក្ដៅឬក៏ម៉ាស៊ីនត្រជាក់ក្នុងឡានគេមិនសូវល្អក៏មិនដឹង តែខ្ញុំមានអារម្មណ៍ថាសីតុណ្ហភាពនៅក្នុងឡានកាន់តែខ្ពស់ជាងមុន បន្ទាប់ពីបានឮចម្លើយរបស់គេមិញនេះ ។

"អូខេ! ដូរនឹងការដែលលោកជួយលាក់រឿងឱ្យខ្ញុំ លោកត្រូវការអីក៏ប្រាប់មកចុះ តែ...ត្រូវតែមិនមែនរឿងអីៗនោះ" ខ្ញុំប្រាប់គេ ព្រមទាំងផ្ញួញចិញ្ចើមខ្វល់ខ្វាយបន្តិច ព្រោះខ្លាចថាគេចង់ឱ្យខ្ញុំប្រគល់រាត្រីផ្អែមល្ហែមអីឱ្យទៅគេ ។

តែគេបែរជាសើចតិចៗ

"នាងមើលមកខ្ញុំថាជាមនុស្សបែបណា?"

"ខ្ញុំគ្រាន់តែនិយាយការពារទុកឱ្យហើយ ព្រោះលោកច្រើនតែគិត





មិនល្អមកលើខ្ញុំ"

"បើខ្ញុំគិតមិនល្អទៅលើនាងមែន ខ្ញុំមិនប្រាប់នាងឱ្យដឹងខ្លួនទេ"

ខ្ញុំងាកទៅមើលគេដោយចាប់ផ្ដើមប្រយ័ត្នប្រយែង ពេលមានអារម្មណ៍ថាដូចកំពុងត្រូវគេសម្លឹងមើលតាំងពីក្បាលដល់ចុងជើង ហាក់ដូចជាការបំភ័យខ្ញុំមុនអីចឹង ។

"អ្ហ៎ ដូចដែលលោកធ្លាប់និយាយយកប្រៀបលើខ្ញុំ ហើយអាងនេះអាងនោះ ដើម្បីដោះសារយករួចខ្លួននោះមែនទេ?"

"ខ្ញុំនៅចាំបានថា កាលនោះខ្ញុំធ្លាប់ប្រាប់នាងរួចហើយថា ខ្ញុំមានចេតនា" គេរៀបរាប់ដោយគ្មានញាប់ញ័រអីបន្តិច ។

"អ៊ឺ ហាន់ គុនដេ! ខ្ញុំអត់លេងសើចទេណា៎!"

"ខ្ញុំក៏មិនត្រូវការឱ្យនាងលេងសើចដែរ"

"..."

"ថ្ងៃនេះនាងអត់ប្រញាប់ ឬមានណាត់ឯណាទៀតដែរទេ?"

"អត់ទេ ម៉េច?"

"នាងបែបមិនថាអីទេណា បើសិនខ្ញុំសុំចៀងចូលខុនដូ..."

"តែ..."

"ខ្ញុំគ្រាន់តែចៀងចូលទៅយករបស់ដែលជាចំណែកមួយនៃការដោះដូរប៉ុណ្ណោះ"

"របស់ដែលជាចំណែកមួយនៃការដោះដូរគ្នា? ស្អីគេ?"

"សរុបទៅគឺអត់ពាក់ព័ន្ធនឹងរឿងអីៗនោះទៅបានហើយ" គេឆ្លើយទាំងញញឹម ខណៈដែលខ្ញុំបែរជាធ្វើទឹកមុខមិនត្រូវ ពេលគេឆ្លើយមកត្រង់ៗបែបនេះ ។

"..."

ដំបូងខ្ញុំគឺមានអារម្មណ៍មិនសូវសប្បាយចិត្តប៉ុន្មានទេ ពេលដែលគេបបួលខ្ញុំឡើងទៅបន្ទប់ខុនដូរបស់គេ តែ...ដោយសារឈឺបត់ជើងតូច (ខ្លាំងទៀតផង) ធ្វើឱ្យខ្ញុំចាំបាច់ត្រូវព្រមឡើងទៅជាមួយដោយគ្មានផ្លូវជ្រើសរើស ។

បន្ទាប់ពីចេញពីបន្ទប់ទឹកហើយ ខ្ញុំឃើញគេកំពុងរើរកអ្វីម្យ៉ាង



នៅក្នុងថតតុក្បែរគ្រែ ។

"លោករកអីហ្នឹង?

"របស់ដែលជាចំណែកមួយនៃការដោះដូរគ្នា"

"របស់អីផស់លោក? ចាប់ផ្ដើមមិនស្រួលចិត្តហើយណា៎"

"នាងប្រយ័ត្នជ្រុលពេកទេដឹង ឬក៏...ខ្លាចខ្ញុំធ្វើអីនាងដោយអត់ប្រាប់មុន?"

"សុខៗ លោកក៏បបួលខ្ញុំម៉ោខុនដូ បែបនេះចង់ឱ្យខ្ញុំគិតយ៉ាងម៉េចទៅវិញ?"

"វាត្រូវផស់នាងហើយ ព្រោះការពិតទៅអារបស់ដែលថានេះ ខ្ញុំយកទៅឱ្យនាងស្អែកនេះក៏បានដែរ តែ...ដែលខ្ញុំសុំនាងចូលខុនដូនេះដោយសារតែនាងតើ..."

"ដោយសារតែខ្ញុំ?" កុំប្រាប់ឱ្យសោះថាគេគិតចង់...ចងដៃចងជើងខ្ញុំនៅលើគ្រែនេះ...

"ខ្ញុំឃើញនាងញ៉ាំទឹកច្រើនមែនទែននៅស្ទូឌីយោ ហើយថែមទាំងគិតតែពីមើលខ្ញុំអត់ព្រិចភ្នែក រហូតគ្មានពេលសូម្បីតែចូលបន្ទប់ទឹក ខ្ញុំក៏គិតថានាងប្រហែលជាចង់ចូលបន្ទប់ទឹកហើយ"

"ម៉េចបានលោកដឹងថាខ្ញុំញ៉ាំទឹកអស់ច្រើន?" ហ៊ុស! ព្រោះតែលោកហ្នឹងអ្ហ៊ែង ខ្ញុំគិតច្រើនពេករហូតដល់ត្រូវផឹកទឹកអត់ឈប់ ដើម្បីរម្ងាប់ភាពញាប់ញ័រក្នុងការភិះគិតរកវិធីចរចាជាមួយ ។

"ខ្ញុំមានខ្វាក់ភ្នែកឯណា"

"នេះសម្ដែងថាពេលកំពុងថត លោកលបមើលខ្ញុំផងស?"

"បើខ្ញុំលបមើល ខ្ញុំមិនបាច់ប្រាប់នាងទេ"

"..."

"ហើយខ្ញុំក៏គិតថានាងមិនចង់ចូលបន្ទប់ទឹកតាមហ្គារ៉ាសសាំងដែរ ព្រោះតែវាគគ្រិច!"

"កុំម៉ោធ្វើឯងដឹងពេក!"

"តែក៏ត្រូវដែរមែនទេ!"

"ហើយម៉េចលោកដឹងថាខ្ញុំគិតតែពីមើលលោកអត់ព្រិចភ្នែក អ្ហ៎





ឬការពិតលោកក៏មើលខ្ញុំអត់ព្រិចដែរ?"

"..."

"ប្រាប់រឿងមួយឱ្យដឹង ដែលខ្ញុំមើលលោកអត់ព្រិចភ្នែក ព្រោះខ្ញុំកំពុងរកវិធីសុំអង្វរលោកកុំឱ្យយករឿងដែលខ្ញុំលួចមកថតពាណិជ្ជកម្ម និងរឿងដែលខ្ញុំបន្លំសោគប់ ក្នាងមីន ទៅប្រាប់អ្នកផ្ទះ កុំអីខ្ញុំក៏មិនសម្លឹងលោករហូតដូចមនុស្សឆ្កួតបែបហ្នឹងដែរ!"

"ចង់មើលក៏មើលទៅ ព្រោះយ៉ាងណាក៏ខ្ញុំអត់មានផ្លែពោះដែរ"

"..."

ស្លាប់ហើយ! អាតាប៉ិនេះប៉ិនវែខានសរសៃប្រសាទមែនទែន!

ខ្ញុំសម្លក់គេបន្តិច មុននឹងចាំគេនិយាយរឿងផ្សេងវិញ ។

ថាៗទៅ...អាម្សៀនេះក៏ជាមនុស្សដែលយកចិត្តទុកដាក់ចំពោះរឿងល្អិតល្អន់ដែរតើ ព្រោះអ្វីដែលគេនិយាយមកទាំងអស់នេះ វាត្រូវគ្រប់ប្រការទាំងអស់ ។

"នេះ ការដោះដូររបស់ខ្ញុំ" គេទាញយកស៊ីមីឯកសារពាណិសនៅក្នុងថតតុចេញមក ខណៈដែលខ្ញុំនៅតែមិនយល់ដដែលថា តើគេចង់ឱ្យខ្ញុំធ្វើអីជាការដោះដូរ ។

"...?"

ឬក៏...គេចង់ធ្វើកិច្ចសន្យាអីឱ្យខ្ញុំស៊ីញ៉េឬ?

"គ្រាន់តែជួយធ្វើគំរូសំនួរចម្លើយមួយដុំឱ្យខ្ញុំទៅបានហើយ..." គេប្រាប់ ព្រមទាំងហុចស៊ីមីពណ៌សនោះមកឱ្យខ្ញុំដែលទទួលយកមកដោយការងឿងឆ្ងល់ ។

"គ្រាន់តែធ្វើគំរូសំនួរចម្លើយម្ល៉េះស ដែលលោកចង់ឱ្យខ្ញុំជួយធ្វើជាការដោះដូរហ្នា!" មិននឹកស្មានថាការដោះដូររបស់គេវាមហាងាយដល់ថ្នាក់នេះសោះ ។

"ត្រូវហើយ..."

តែ...ដល់មកគិតមើលម្ដងទៀត ក៏ចាប់ផ្ដើមមានអារម្មណ៍ថាមិនគួរប្រហែសទេ ។

"ជាគំរូសំនួរចម្លើយស្អីទៅ?"





"នាងមិនចាំបាច់ចង់ដឹងទេ ដឹងតែថា បើមួយរយៈនេះមាននិស្សិតស្ដាបត្យកម្មណាឱ្យគំរូសំនួរចម្លើយឱ្យនាងធ្វើ ឬមកសុំយោបល់ពីនាង កុំទទួលធ្វើដាច់ខាត យល់ព្រមជាមួយខ្ញុំបានទេ?" គេសួរដោយសម្លេងទន់ភ្លន់ ព្រមទាំងសម្លឹងមុខខ្ញុំបែបរង់ចាំចម្លើយ ខ្សែភ្នែករបស់គេមានរស្មីអង្វរករលាយឡំតិចតួច រហូតខ្ញុំមានអារម្មណ៍ថា បេះដូងខ្លួនឯងកំពុងទន់ជ្រាយដោយមិនគួរអត់ឱនឱ្យ ។

ហើយដែលខ្ញុំមិនយល់នោះគឺ...ហេតុអីបានគេចាំបាច់ហាមមិនឱ្យខ្ញុំធ្វើគំរូសំនួរចម្លើយឱ្យនិស្សិតស្ដាបត្យកម្មផ្សេងទៀត?

"ចុះបើបងប្រុស លោកចង់ឱ្យខ្ញុំបដិសេធដែរអ្ហ៎ស?"

"វាមិនយកមកឱ្យនាងធ្វើទេ"

"ម៉េចបានលោកដឹង?"

"ដឹងតែខ្ញុំដឹងទៅបានហើយ" គេនិយាយដោយការជឿជាក់ចំពោះខ្លួនឯងរហូតដល់ខ្ញុំអត់ឆ្ងល់មិនបានថា ម៉េចបានគេដឹងថាបងប្រុសគ្មានផ្លូវយកគំរូសំនួរចម្លើយយកមកឱ្យខ្ញុំធ្វើ ។

"..."

"យ៉ាងម៉េច យល់ព្រមនឹងខ្ញុំបាននៅ?"

"យល់ព្រមរឿងអី?"

"រឿងដែលខ្ញុំសុំអម្បាញ់មិញនោះ"

"..."

"..."

"..."

ខ្ញុំនៅស្ងៀមមួយសន្ទុះធំ ខណៈដែលគេនៅតែមិនព្រមងាកខ្សែភ្នែកទៅណា ក្រៅពីសម្លឹងមើលមុខរបស់ខ្ញុំដោយរង់ចាំចម្លើយ ហើយមិនដឹងថាមានស្អីមកជំរុញចិត្តឱ្យខ្ញុំឆ្លើយទៅវិញដូចជាឌឺដងថា÷

"ចុះបើ...ខ្ញុំឆ្លើយថា ទេ"

"ខ្ញុំនឹងធ្វើបែបនេះ..."

មើលទៅចម្លើយរបស់ខ្ញុំដូចជាធ្វើឱ្យគេមិនពេញចិត្តប៉ុន្មានទេ ព្រោះនិយាយមិនទាន់ចប់ផង សុខៗ គេក៏ស្រាវចាប់កដៃ ហើយទាញ





ខ្លួនខ្ញុំទៅជិត ហេតុខ្ញុំបានប៉ះខ្យល់ដង្ហើមក្តៅឧណ្ហៗ និងចំហាយក្តៅ កាយចេញពីរាងកាយរបស់គេ ហើយពេលខ្ញុំព្យាយាមបំរះចេញ បែរជាធ្វើឱ្យគេរឹតតែទាញឱ្យទៅជិតថែមទៀត រួចតាមមកដោយបបូរមាត់ដ៏ក្តៅ ដាក់ចុះមកយ៉ាងទន់ភ្លន់ ខ្ញុំរើបម្រះនៅក្នុងរង្វង់ដៃគេ តែរឹតតែរើគេរឹតតែវាយលុក ទីបំផុតក៏ត្រូវបណ្តោយឱ្យគេយកប្រៀបតាមចិត្តត្រូវការ ហេតុដល់គេដកបបូរមាត់សន្សឹមៗចេញ ហើយសម្លឹងមើលខ្ញុំយ៉ាងយូរ ។ អារម្មណ៍ក្តៅគាយៗរបស់គេនៅតែជិតជាប់លើបបូរមាត ហេតុដល់ខ្ញុំត្រូវខាំមាត់ណែន ហើយក៏ដាស់ស្មារតីខ្លួនឯងឡើងវិញនិងព្យាយាមរើខ្លួនឱ្យរួចផុតពីរង្វង់ដៃ តែក៏ត្រូវគេទាញចូលទៅជិតរឹតតែខ្លាំងជាងមុខ ។

"គុនដេ...លែង..." ខ្ញុំព្យាយាមទប់សម្លេងមិនឱ្យញ័រ តែរឹតតែខំព្យាយាមទប់ខ្លួនឯងខ្លាំងប៉ុណ្ណា ខ្សែភ្នែករបស់ខ្ញុំក៏រឹតតែញាប់ញ័រខ្លាំងប៉ុណ្ណោះដែរ ហើយគេក៏រឹតតែបន្ថែមកម្លាំងឱបខ្ញុំខ្លាំងជាងមុនដែរ ។ ខ្ញុំបានត្រឹមតែរើបម្រះទៅមកក្នុងដើមទ្រូងរបស់គេដោយអស់ប្រកចេញ បន្ទាប់មកគេក៏ខ្សឹបសួរតិចៗនៅក្បែរត្រចៀក...

"ម៉េច...យល់ព្រមតាមខ្ញុំបានហើយនៅ?"





## ភាគទី៧

## គ្រោងការសម្ងាត់

គុនដេ បើកឡានជូនខ្ញុំមកដល់ផ្ទះ ហើយនៅមិនទាន់បានឈានជើងចុះពីឡានផង កដៃរបស់ខ្ញុំក៏ត្រូវគេស្រវាចាប់ជាប់។

មិនដឹងថាខ្ញុំគិតតែឯងក៏មិនដឹង តែមានអារម្មណ៍ថាពេលដែលគេដឹងខ្លួនថាពេលនេះស្ថិតក្នុងសភាពមានប្រៀបជាងនោះ ក៏ចាប់ផ្តើមធ្វើខ្លួនមិនសមរម្យដាក់ខ្ញុំកាន់តែខ្លាំងឡើងជារឿយៗ ។

"លែងខ្ញុំភ្លាម ឬក៏លោករង់ចាំឱ្យបងប្រុសម៉ោឃើញថាលោកធ្វើមិនសមរម្យដាក់ខ្ញុំយ៉ាងម៉េចខ្លះ?"

"មីណាម មិនថាអីទេ មានតែនាងទេដែលថា" គេប្រាប់ដោយមិនព្រមលែងដៃខ្ញុំ ។

"បើលោកមិនលែង ខ្ញុំនឹងស្រែកហៅបងប្រុសមែនណា!"

"នាងនៅមិនទាន់យល់ព្រមនឹងខ្ញុំទេ" គេនិយាយសម្លេងរាបស្មើ ខុសពីខ្ញុំដែលមុខឡើងក្តៅភាយៗភ្លាម ពេលគេនិយាយដល់រឿងនេះ ប្រាកដហើយ អ្នកណាទៅមានសមាធិតបគេបាន...នៅក្នុងពេលដែលគេទើបនឹងយកប្រៀបខ្ញុំរួច ។

"..."

"ម៉េច...សម្រេចថាយល់ព្រមបាននៅ?" គេសួរ ព្រមទាំងសម្លឹងមុខខ្ញុំយ៉ាងស្រទន់ ខ្សែភ្នែករបស់គេបែបហ្នឹងធ្វើឱ្យខ្ញុំមានអារម្មណ៍ដូចខ្លួនឯងកំពុងត្រូវគេដាក់មន្តសណ្តំអីចឹង ។

"..."

"..."

"..."



កណ្ដាលភាពស្ងៀមស្ងាត់ដែលបបួលឱ្យតឹងថប់ ខ្ញុំប៉ះខ្យល់ដង្ហើមក្ដៅឧណ្ហៗរបស់គេដែលនៅឆ្ងាយតែមួយចំអាម ហើយមុននឹងអ្វីៗជ្រុលលើសហ្នឹងទៅទៀតនោះ...

"បាទ! ខ្ញុំយល់ព្រម" ខ្ញុំប្រមូលអស់ភាពក្លាហានឆ្លើយចេញទៅរួចប្រញាប់ឈោសដៃចេញពីគេ ហើយរត់ចូលផ្ទះភ្លាម មកដឹងខ្លួនម្ដងទៀតក៏ដឹងថានៅក្នុងដៃខ្ញុំមានសឺមីដាក់គំរូសំនួរចម្លើយរបស់គេ ។

ខ្ញុំដើរចូលក្នុងផ្ទះដូចមនុស្សគ្មានស្មារតី ការប៉ះពាល់ក្ដៅឧណ្ហៗនិងក្លិនក្រអូបស្រាលៗរបស់គេ ហាក់ដូចជានៅអណ្ដែតជុំវិញខ្លួនរហូតធ្វើឱ្យខ្ញុំភ្លេចខ្លួនខាំបបូរមាត់ ពេលនឹកឃើញពេលដែល...

អ៊ុយ! កុំអី! តើខ្ញុំក្លាយជាក្មេងចិត្តស្រើបស្រាលហើយឬនេះ?

តែសម្លេងបងប្រុសដែលកំពុងអង្គុយនិយាយទូរសព្ទនៅបន្ទប់ធំធ្វើឱ្យខ្ញុំភ្ញាក់ពីអារម្មណ៍ស្ពងអម្បាញ់មិញ ។

មើលទៅបងប្រុសដូចកំពុងនិយាយទូរសព្ទជាមួយមីង ហោវី ជាមីងសាច់ថ្លៃរបស់ពួកខ្ញុំ ដែលបងប្រុសគោរពស្រឡាញ់និងគោរពជាងគេបំផុតក្នុងចំណោមសាច់ញាតិចាស់ៗទាំងអស់ ។

"បាទមីង...យ៉ាងណាៗក៏ជួយធ្វើគំរូសំនួរចម្លើយហ្នឹងឱ្យផង ចាំខ្ញុំហៀកសី ទៅជូន"

(...)

"ធ្លើរចហើយ ស៊ុំខានមីងជួយហៀកសីឱ្យខ្ញុំវិញផង ណាំមីង"

(...)

"បាទ ត្រូវហើយ ជាគម្រោងតែមួយគត់"

(...)

"បាទ ស៊ុំខានផងណាំមីង..."

បងប្រុស និយាយរឿងគំរូសំនួរចម្លើយជាមួយមីងតើ...

អ៊ើ...វាដូចគ្នានឹងគំរូសំនួរចម្លើយដែលអាម្សៀនោះឱ្យខ្ញុំមកធ្វើដែរអត់ហ្នឹ?

ហើយពេលបើកគំរូសំនួរចម្លើយនៅក្នុងដៃមើល ក៏មិនឃើញថា

OPSOR
LOVE SERIES





វាមានអីពិសេសត្រង់ណា គ្រាន់តែជាសំនួរចម្លើយពីការចូលចិត្តពាក់ព័ន្ធនឹងពណ៌ ស្ទីល លក្ខណៈរូបរាងរបស់គ្រឿងសង្ហារឹម និងរបស់តុបតែងផ្សេងៗនៅក្នុងផ្ទះ រួមទាំងឧបនិស្ស័យនិងឡាយស្ទាយប៉ុណ្ណោះ ។ មើលជារួមទៅ មិនមានឃើញថាវាពិសេស ឬកំណត់ចំអីមួយដល់ថ្នាក់ដែលគេត្រូវហាមមិនឱ្យខ្ញុំទៅធ្វើឱ្យនិស្សិតស្ថាបត្យកម្មឯទៀតបន្តិចណាសោះ ។

តែ...ពេលនឹកមកដល់ត្រង់នេះ បេះដូងខ្ញុំក៏ញាប់ញ័រឡើងម្ដងទៀត នឹកទៅដល់...ពេលដែលគេព្យាយាមកៀបសង្កត់ឱ្យខ្ញុំយល់ព្រមថាមិនទៅធ្វើគំរូសំនួរចម្លើយឱ្យអ្នកណាក្រៅពីគេ ។

"កើតអីហ្នឹង អេនដែល មិនស្រួលខ្លួនមែនទេ ម៉េចក៏មុខឯងតិចស្លេកតិចក្រហមបែបហ្នឹង" សម្លេងបងប្រុសដាស់ខ្ញុំឱ្យភ្ញាក់ពីអាការៈមមើស្លីម្ដងទៀត បែបនិយាយទូរសព្ទជាមួយមីង ហោវី ចប់ហើយ ។

"គ្មានអីទេ!" ខ្ញុំប្រញាប់ធ្វើទឹកមុខឱ្យធម្មតាវិញ មុននឹងឱនអានគំរូសំនួរចម្លើយនៅក្នុងដៃ ។

"ចុះឯងកំពុងអានស្អីហ្នឹង?"

"គំរូសំនួរចម្លើយ" ខ្ញុំឆ្លើយដោយសម្លេងធម្មតា ខំព្យាយាមមិននឹកដល់ម្ចាស់វានាំតែញាប់ញ័របេះដូងទៀត ។

"គំរូសំនួរចម្លើយស្អីគេ? ឯងទើបនឹងរៀនឆ្នាំទីមួយ មានការងារវិភាគហើយអ្ហ៎ស?" បងប្រុសអើតមើលដោយការចាប់អារម្មណ៍ជាពិសេស វាជារឿងធម្មតារបស់គាត់ទៅហើយដែលតែងតែចាំមើលថែយកចិត្តទុកដាក់គ្រប់រឿងរ៉ាវនោះ ។

"ទេ! មិនមែនផស់ខ្ញុំទេ ជារបស់ពួកម៉ាកបងតើ!"

"ពួកម៉ាកបង! អាណាគេ?" បងប្រុសជ្រួញចិញ្ចើមដោយការងឿងឆ្ងល់ ។

"ហាន់ គុនជេ"

"ហាន់ គុនជេ! គុនជេ ហ្នឹងឬ? ឯងកុហកបងលេងមែនទេ?" បងប្រុសលាន់មាត់សួរខ្លាំងៗហាក់ដូចជាមិនទាន់ជឿ១០០ភាគរយ ។

"ខ្ញុំកុហកបង ហើយបានអីទៅ?"



"ទៃ! សួរមែនទែនណា៎?"

"គឺមែនតើ! ហើយម៉េចក៏បងចាំបាច់ធ្វើដូចចម្លែកចិត្តអីដល់ថ្នាក់ហ្នឹង?"

"វាឱ្យឯងធ្វើដោយផ្ទាល់ដៃអ៊ំស?"

"ត្រូវហើយ ហើយគេនៅប្រាប់ទៀតថា ហាមមិនឱ្យខ្ញុំធ្វើឱ្យពួកនិស្សិតស្លាបព្រាកម្មផ្សេងទៀតដាច់ខាត"

"ដល់ថ្នាក់ហ្នឹងផងឬ? សង្ស័យលើកនេះវាលេងមែនទែនហើយពីយ" បងប្រុសងក់ក្បាលនិងធ្វើមុខស្ញើចសរសើរ ។

"អីគេលេងមែនទែន? បងនិយាយអីហ្នឹង ស្ដាប់មិនយល់សោះ?"

"ល្អហើយដែលអ្នកយកគំរូសំនួរចម្លើយនេះមកឱ្យឯងធ្វើជាវា ព្រោះបើជាអ្នកផ្សេងវិញ...បងនឹងសម្លាប់វា" បងប្រុសមានចេតនាមិនឆ្លើយសំនួរ ខ្ញុំសង្ស័យថាគាត់នឹងអាម្សៀនោះច្បាស់ជាមានរឿងអីលាក់បាំងខ្ញុំមិនខាន តែណ្ហើយ មិនប្រាប់ក៏កុំប្រាប់ ខ្ញុំមិនអង្វរទេ ។

"អ្ហ៊ី...ខ្វាំងពេកទេដឹង បងប្រុស!"

"គ្មានទៅខ្លាំងពេកអីទេពីយ បងជាបងប្រុសឯង ត្រូវតែការពារឯង បណ្ដោយឱ្យអ្នកណាម៉ោធ្វើផ្ដេសផ្ដាសម៉េចបាន"

"សួរមែនទែនទៅចុះ...អាគំរូសំនួរចម្លើយនេះគឺជាស្អីទៅ?"

"អាម្សៀនោះអត់បានប្រាប់ឯងទេអ៊ំស?"

"ត្រូវហើយ គេអត់ព្រមប្រាប់ទេ"

"វាជាគ្រោងការសម្ងាត់ បើវាព្រមប្រាប់ឯង ម៉េចគេហៅថាជាគ្រោងការសម្ងាត់"

"នេះបញ្ជាក់ថា គំរូសំនួរចម្លើយដែលគេឱ្យមកខ្ញុំធ្វើនេះដូចគ្នានឹងផស់បងដែលផ្ញើទៅឱ្យមីង ហើរ ជួយធ្វើឱ្យនោះដែរមែនទេ?"

"ក៏វាទំនងហ្នឹង គ្រាន់តែវាជាគំរូសំនួរចម្លើយដែលម្នាក់ៗត្រូវរកចំណុចដែលចង់សួរដោយខ្លួនឯង ព្រោះត្រូវការមូលបទសម្រាប់រៀបចំគម្រោងមិនដូចគ្នាទេ"

"បើអីចឹងម៉េចបានបងមិនឱ្យខ្ញុំធ្វើ ទៅឱ្យមីងធ្វើៗអី?"

"ឯងក៏ដឹងដែរថា បងនិងមីង ហើរ ជិតដិតគ្នា ម្យ៉ាងទៀតបើបងឱ្យឯងធ្វើ...បងថាវាមើលទៅដូចជាការរៀបចំផែនការបំផ្លាញអនាគតខ្លួនឯងជ្រុលពេកហើយ"







"បងនិយាយបែបហ្នឹងបានន័យថាម៉េច"

"បើឯងចង់ដឹងថាអាហ្នឹងវាសំខាន់ប៉ុណ្ណា ម៉េចក៏មិនសួរវា?"

"គេព្រមប្រាប់ខ្ញុំពីអង្គាល់?"

"អើ ទោះយ៉ាងណាឯងក៏ធ្វើឱ្យវាទៅ ប្រាប់រឿងមួយ...ថាគំរូសំនួរចម្លើយនេះ គ្មានស្រីណាម្នាក់ដែលមិនចង់ធ្វើឱ្យវាទេ"

ខុសស្រឡះ ព្រោះខ្ញុំគឺជាមនុស្សម្នាក់ដែលគ្មានថ្ងៃព្រមធ្វើជាដាច់ខាត ដរាបណាម្ចាស់វាមិនព្រមប្រាប់ថា យកមូលបទអស់នេះទៅធ្វើអ្វីនោះ តែ...ដែលខ្ញុំព្រមធ្វើឱ្យស្រួលៗបែបនេះ ព្រោះខ្ញុំនិងគេមានចំណុចដោះដូរវាងគ្នាទៅវិញទេតើ ។

"សម្រេចថាបងមិនព្រមប្រាប់ខ្ញុំមែនអ្ហ៎ ថាអាគំរូសំនួរចម្លើយនេះវាសំខាន់យ៉ាងម៉េច ទាំងអម្បាញ់មិញខ្ញុំសាកអានមើលហើយ គ្មានឃើញអីពិសេសបន្តិចសោះ!"

"ការពិតទៅ វាជាគ្រោងការដែលគ្រូឱ្យនិស្សិតទាំងអស់ធ្វើដើម្បីជ្រើសរើសយកទៅប្រកួតនៅសាំងហ្គាពួ ដែលបណ្ដោយឱ្យអ្នកក្រៅដឹងពីចំណុចទាំងនោះមិនបានដាច់ខាត ព្រោះខ្លាចគូប្រជែងយកទៅកែកុនផស់គេឱ្យល្អជាងផស់យើង"

"...?"

"ម្យ៉ាងទៀតគំរូសំនួរចម្លើយនេះ ម្នាក់ៗត្រូវចេញមុំតដោយខ្លួនឯងដូច្នេះផស់បងនិងផស់ គុនដេ មិនដូចគ្នាទេ ស្ថិតនៅលើថាវាត្រូវការមូលបទអីខ្លះយកទៅប្រើការប៉ុណ្ណោះ តែតាមដែលបងមើលទៅ...វាសួរឯងមហាល្អិតល្អន់ណាស់ពីយ"

"នេះបញ្ជាក់ថាគេប្រុងចេញមុំតបន្ទប់ឱ្យខ្ញុំអីចឹងអ៊ំស ហើយម៉េចចាំបាច់ខ្ញុំ?"

"ចង់ដឹងក៏ទៅសួរវាខ្លួនឯងទៅ ម៉ោសួរបង បងដឹងអ្ហ៎?" បងប្រុសសើចញឹមៗ មុននឹងដើរហួចឡើងជណ្ដើរទៅខាងលើយ៉ាងរីករាយខុសប្រក្រតី ។



"អ៊ីចឹងបងក៏ជ្រើសរើសចេញម្ជុំតបន្ទប់ឲ្យមីង ហើរ ដែរអ្ហ៎ស? ចុះបើគ្រាន់តែចេញម្ជុំតបន្ទប់ ហេតុអីក៏ចំណងជើងគ្រោងការណ៍នេះចាំបាច់ជាការសម្ងាត់ធ្វើអី?" ខ្ញុំស្រែកសួរតាមក្រោយ តែ...ចម្លើយរបស់បងប្រុសគឺតែធ្វើឲ្យខ្ញុំងឿងឆ្ងល់ខ្លាំងលើសដើមទៅទៀត ។

"សួរមែនទែនទៅចុះ អេនជែល! ឯងមើលមិនដឹងមែនអ្ហ៎ស ថាគុនដេ កំពុងគិតយ៉ាងម៉េចចំពោះឯង"

"អត់ដឹង!"

"អ៊ីចឹងឯងភ្លើ-តទៀតចុះ...ប្អូនស្រីសម្លាញ់" ឆ្លើយរួច គាត់ក៏ដើរឡើងទៅខាងលើធ្វើព្រងើយ ។

ឲ្យស្លាប់ទៅចុះ! ខ្ញុំត្រូវតែដឹងឲ្យបានថាចំណងជើងគ្រោងការណ៍នោះគឺជាអ្វីពិតឲ្យប្រាកដ ហេតុអីបងប្រុសនិងអាម្សៀនោះធ្វើដូចជាមានអាថ៌កំបាំងអីអ៊ីចឹង?

ពីរថ្ងៃក្រោយមក គុនដេ ក៏មករកខ្ញុំនៅផ្ទះ សុំគំរូសំនួរចម្លើយនោះវិញ ដោយមិនប្រាប់មុនអីបន្តិច ហេតុនេះហើយខ្ញុំក៏ប្រញាប់យកវាមកធ្វើបន្តឲ្យរួច ព្រោះកន្លងមកខ្ញុំមិនសូវមានសមាធិធ្វើសោះដោយសារខួរក្បាលវាឡប់វិលវល់នឹកឃើញគេជាប់ជានិច្ច ។

ពេលធ្វើរួច ខ្ញុំក៏ប្រញាប់ឲ្យគេភ្លាម ខណៈដែលបងប្រុសគិតតែពីអង្គុយញញឹម មិននិយាយមិនស្តីអី ធ្វើដូចមនុស្សកំពុងមានសេចក្តីសុខណាស់អ៊ីចឹង ចំណែកអាម្សៀហ្នឹងក៏អង្គុយបើកមើលតាំងពីទំព័រដំបូងរហូតដល់ទំព័រចុងក្រោយ ដើម្បីពិនិត្យភាពត្រឹមត្រូវ ។

"ឆ្កួតអីផស់ឯងហ្នឹង មីណាម?" គេងាកសួរបងប្រុសដែលគិតតែពីអង្គុយញញឹមខ្ចីបម្នាក់ឯងដូចមនុស្សឆ្កួត ។

"ខ្ញុំគ្រាន់តែ...អស់សំណើចនឹងមនុស្ស..."

"មនុស្សដែលថាហ្នឹងគឺខ្ញុំមែនទេ?"

"អើ ឯងហ្នឹងហើយអាឡប់!"

"..."

"សួរតាមត្រង់ នេះឯងគិតច្បាស់ហើយអ្ហ៎ដែលរើសយកប្អូនស្រីខ្ញុំ



មិនខ្លាចគ្រោងការហិនហោចទេឬម៉េច"

"..."

"ហើយនេះ...ឯងមើលភាពប្រែប្រួលរបស់ប្អូនខ្ញុំទៅ មានដៃអ្វើស្រឡាញ់ដើមឈើ តែស្អប់ពណ៌បៃតង" បងប្រុសបើកមើលគំរូដែលខ្ញុំធ្វើ ហើយរិះគន់ដោយគ្មានសុជីវធម៌ គ្មានក្រែងចិត្តខ្ញុំអីបន្តិចសោះ ។

ខ្ញុំពេបមាត់ដាក់គាត់បែបងរង់ក់ ។

វាយ៉ាងម៉េច? វាប្លែកត្រង់ណាដែលខ្ញុំចូលចិត្តដើមឈើ តែស្អប់ពណ៌បៃតងនោះ?



"ឯងជាស្ថាបនិកបែបណាហ្នឹង ម៉េចអង្គុយរិះគន់មុំយបែបនេះ?"

មុំយ? គេហៅខ្ញុំថាមុំយអ្ហ៎ស?

ឆ្កួតជាទីបំផុត! ថ្ងៃមុនគេធ្វើឆ្កួតៗដាក់ខ្ញុំ ហើយពេលនៅពីមុខបងប្រុស ធ្វើជាមិនដឹងអី ហៅខ្ញុំថាមុំយអ៊ីចឹងអ្ហ៎?

"ចុះឯងជាស្ថាបនិកបែបណាដែរ ជ្រើសរើសតែមុំយណាដែលខូចឯងចង់ធ្វើឲ្យបែបនេះ?"

"ឯងក៏ដឹងថាការងារនេះផ្តល់ផលរយៈពេលវែងចំពោះអនាគតរបស់ខ្ញុំ មិនឲ្យជ្រើសរើសយ៉ាងម៉េចបាន"

"សុំប្រាប់ថាមុំយម្នាក់នេះ ខ្ញុំហួងហែងណាស់ពីយ"

"បើហួងហែងក៏មើលថែឲ្យល្អទៅ មិនអីចឹង...ខ្ញុំអត់ធានាភាពប្រថុយប្រថានទេ"

"ក្លាហានណាស់ ហាន់ គុនដេ ដែលហ៊ាននិយាយបែបនេះជាមួយខ្ញុំ តែកុំគិតថាខ្ញុំនឹងព្រមងាយៗនោះ អាឡប់!"

"បើមិនព្រម ឯងប្រហែលមិនអង្គុយញញឹមបែបនេះទេ"

"ងាប់ហើយ! ខ្ញុំស្អប់អាត្រង់ដែលឯងឆ្លាតហួសពេកនេះអ្ហ៎ង ហាន់ គុនដេ"

គេសើចតិចៗ ដោយមិននិយាយអី ព្រមទាំងលោលខ្សែភ្នែកមកមើលខ្ញុំមួយរំពេច ធ្វើឲ្យខ្ញុំបន្លំធ្វើជាងាកទៅមើលកន្លែងផ្សេង ព្រោះតែខ្លាចគេដឹងថាការពិតទៅខ្ញុំលបមើលគេជាប់រហូត ។

បងប្រុសនិងអាតាប៉ុឡប់នេះជជែកគ្នាដោយគ្មានគិតខ្លាចក្រែង



ចិត្តខ្ញុំអីសោះ តើគេពីរនាក់នេះភ្លេចហើយមែនទេ ថាត្រង់នេះក៏មានខ្ញុំកំពុងអង្គុយម្នាក់ទៀតដែរណា៎?

"ចុះ ពួកបងពីរនាក់...និយាយគ្នាឲ្យក្រែងចិត្តខ្ញុំបន្តិចបានទេ? ហើយសម្រេចថាអត់មានអ្នកណាព្រមប្រាប់ខ្ញុំមែនអ៊្លឹស ថាគ្រោងការសម្លាប់នេះ វាជាស្អីឲ្យពិតប្រាកដទៅ?"

"..."

"..."

ទាំងបងប្រុសនិងអាម្យៀនោះព្រមព្រៀងគ្នាស្ងាត់មាត់ឈឹង បងប្រុសធ្វើមុខមិនដឹងមិនឮ ចំណែកអាម្យៀនោះក៏សម្លឹងមើលខ្ញុំដោយខ្សែភ្នែកស៊ីជម្រៅហួសនឹងស្មានយល់ ហើយទាំងអស់ហ្នឹងរឹតតែធ្វើឲ្យខ្ញុំកាន់តែងឿងឆ្ងល់ ។

"បើគ្មានអ្នកណាព្រមប្រាប់ ខ្ញុំនឹងទៅសួរអ្នកផ្សេង"

"បើនាងដឹង...នាងអាចនឹងគ្មានសមាធិធ្វើគំរូសំនួរចម្លើយរបស់ខ្ញុំក៏ថាបានដែរ" ចម្លើយរបស់គេធ្វើឲ្យបងប្រុសបែរទៅមើលគេដោយខ្សែភ្នែកចម្លែកៗ បែបជិនឬកក៏មិនមែន លេងសើចក៏មិនមែន ។

"ហេតុអីបានខ្ញុំត្រូវគ្មានសមាធិ? ចំណង់ដឹងវាស្រៀវស្រើបណាស់ទៅអ្ហី?"

"ស្រៀវស្រើបអ៊្លឹស...អ៊ឹម...គឺគួរសមដែរ" គេឆ្លើយដោយស្នាមញញឹម ហើយក៏គួរឲ្យមួម៉ៅមែនទែនដែលអាស្នាមញញឹមខ្ជួយៗរបស់គេ វាធ្វើឲ្យបេះដូងខ្ញុំលោតក្នុងក្ដាំងភ្លាមដោយគ្មានមូលហេតុ ។

"..."





# ភាគទី៨

## ហេតុការណ៍រកធំ

ព្រឹកថ្ងៃបន្ទាប់...

ពេលដែលខ្ញុំបម្រុងនឹងដើរឡើងអាគារផ្នែកដើម្បីយកកិច្ចការទៅជូនគ្រូ នៅសុខៗក៏មានសម្លេងស្រែកហៅរបស់មិត្តភក្ដិស្រីរួមថ្នាក់ម្នាក់បន្លឺឡើង ÷

"ឈប់សិន អេនជែល..."

"ម៉េច មានអីអ៊្លឹស?"

"គឺអីចេះ ជូនអីខ្ញុំមានសិស្សច្បងម្នាក់រៀននៅផ្នែកស្ថាបត្យកម្ម ហើយគាត់ផ្ញើគំរូសំនួរចម្លើយនេះមកឲ្យឯងជួយធ្វើឲ្យផង"

"គំរូសំនួរចម្លើយអ៊្លឹស?"

"អ៊ឹម ឮថានឹងយកទៅធ្វើជាមូលបទសម្រាប់ធ្វើគ្រោងការណ៍អ្វីម្យ៉ាងហ្នឹងណា៎"

"អ៊ុំ! ហើយឯងដឹងទេថាវាជាគ្រោងការអីទៅ?"

"ឮប្រាប់ថាជាគ្រោងការសម្លាប់របស់ផ្នែក ខ្ញុំក៏លែងហ៊ានសួរទៀត ដឹងតែថាគាត់បុចឈ្មោះម៉ោ ត្រូវតែឲ្យឯងជាអ្នកធ្វើប៉ុណ្ណោះ!"

"បើអីចឹងឯងជួយនាំខ្ញុំទៅជួបគាត់បន្តិចបានទេ?"

"អ៊ឹ?"

"គឺ...ខ្ញុំមានរឿងចង់សួរគេបន្តិចពីអាគំរូហ្នឹងណា៎"

ដោយសារតែខ្ញុំរវល់តែចាប់អារម្មណ៍រឿងចំណង់ដឹងគ្រោងការណ៍សម្លាប់នោះ ធ្វើឲ្យខ្ញុំភ្លេចឲ្យឈឹងថាធ្លាប់បានយល់ព្រមអ្វីមួយជាមួយអាម្យៀនោះ ។



ផ្នែកស្ដាបត្យកម្ម...

ខ្ញុំនិងមិត្តភក្ដិដើរមកឈរចាំសិស្សច្បងម្នាក់នោះនៅមុខអាគារផ្នែកស្ដាបត្យកម្ម មួយសន្ទុះក្រោយមក...គេក៏ដើរចុះមកដោយញញឹមដាក់ខ្ញុំតាំងពីចម្ងាយ ។

"ឮថា អូនដែល ចូលរៀងគំរូសំនួរចម្លើយ ចូលត្រង់ណាអ្ហ៊ុស សួរខ្ញុំម៉ោចុះ"

"គឺ...ការពិតទៅខ្ញុំអត់មានចូលរៀងគំរូសំនួរចម្លើយហ្នឹងទេ តែ... ខ្ញុំគ្រាន់តែសង្ស័យថាគ្រោងការណ៍ដែលពួកសិស្សច្បងកំពុងធ្វើហ្នឹង ...វាមានចំណងជើងអីឲ្យពិតប្រាកដទៅ?"

"សួរបែបហ្នឹងបញ្ជាក់ថាមានអ្នកយកមកឲ្យធ្វើច្រើនហើយមើលទៅ នេះបងប្រហែលជាអ្នកទី១០ហើយមែនទេ?" សិស្សច្បងម្នាក់នេះសួរដោយសម្លេងចម្អន់ ហើយខ្ញុំមិនទាន់ទាំងបានឆ្លើយអីទេវិញផង សម្លេងគ្រលរាដែលធ្លាប់ស្គាល់ក៏បន្លឺកាត់ឡើងមុន ។

"ខុសហើយ ឯងជាអ្នកទីពីរ!" សម្លេងម៉ាំៗនោះមានស្នាមញញឹមនៀយណាយតិចៗ ។

"អ្ហ៎ា គុនដេ អត់ឡើងលេកស៊ើរទេអ្ហ៊ុស?"

"បើឡើង ឯងឃើញខ្ញុំម៉ោឈរនៅត្រង់ហ្នឹងដែរអ្ហ៎?"

"ហ្នឹងឯង និង មីណាម អត់ចូលលេកស៊ើរ នៅជួយសិស្សប្អូនធ្វើម៉ូដែលទៀតហើយអ្ហ៎ អើ...ហើយម៉េចបានឯងដឹងថាខ្ញុំជាអ្នកទីពីរ"

"..."

គេមិនឆ្លើយ តែបែរជាសម្លឹងមុខខ្ញុំដោយកែវភ្នែកភ្លឺចាំង រហូតខ្ញុំត្រូវប្រញាប់ធ្វើជាសម្លឹងទៅផ្សេង ព្រោះបានដឹងច្បាស់ពីអាការៈមួម៉ៅដែលលេចឡើងនៅក្នុងខ្សែភ្នែករបស់គេ ហើយពេលនោះអ្ហ៊ែងដែលខ្ញុំទើបតែនឹកឃើញថា ធ្លាប់បានយល់ព្រមរឿងអីជាមួយគេ ។

ពេលនឹកឃើញហើយ ខ្ញុំក៏ប្រញាប់ហុចគំរូសំនួរចម្លើយនោះទៅឲ្យសិស្សច្បងម្នាក់នោះវិញយ៉ាងរហ័ស ព្រមទាំងពោលពាក្យបដិសេធយ៉ាងទន់ភ្លន់បំផុត តាមដែលអាចធ្វើទៅបាន ។

សិស្សច្បងម្នាក់នោះសម្លឹងមុខខ្ញុំនិងអារម្មៀនោះទៅមកដោយ





ការងឿងចូល់ តែគេក៏សុខចិត្តយកគំរូនោះទៅវិញតាមសម្រួល ។

តែ...មើលទៅរឿងវាដូចជាមិនទាន់ចប់ស្រួលៗទេ ព្រោះសុខៗតាប៉ុឡប់ហ្នឹងក៏មានបេតនាដើរចូលមកជិត រួចធ្វើដូចជាចង់និយាយអីម្យ៉ាង តែក៏ប្ដូរចិត្តដើរកាត់មុខខ្ញុំឡើងអាគារទៅធ្វើព្រងើយ ។

ចួតមែនទែន! តើគេកំពុងខឹងមែនទេ?



ខ្ញុំប្រញាប់រត់ទៅស្ទាក់មុខគេ ធ្វើឲ្យនិស្សិតឯទៀតបែរមកមើលនិងចាប់ផ្ដើមខ្សឹបខ្សៀវគ្នាទំនងថា ខ្ញុំប្រហែលតាមញ៉ែគេហើយមើលទៅ តែពេលនេះខ្ញុំគ្មានពេលមកចាប់អារម្មណ៍នឹងរឿងខ្សឹបខ្សៀវអត់ប្រយោជន៍អស់ហ្នឹងទេ ។

"ឈប់សិន! ហាន់ គុនដេ..."

"..." គេឈប់ដើរ ហើយមើលខ្ញុំដោយមិននិយាយអីមួយម៉ាត់ ។

"គឺខ្ញុំ..." ខ្ញុំចង់អធិប្បាយឲ្យគេយល់ថាហេតុអីបានខ្ញុំភ្លេចខ្លួនទៅទទួលធ្វើឲ្យសិស្សច្បងម្នាក់នោះ តែគេបែរជាមិនព្រមស្ដាប់ ហើយស្រវាំចាប់កដៃខ្ញុំឲ្យដើរតាមឡើងទៅជាន់ទីពីរជាមួយ ។

បន្ទាប់មកក៏រុញឲ្យចូលទៅក្នុងបន្ទប់ដាក់ម៉ូដែលផ្ទះដែលគ្មានមនុស្ស មុននឹងដាក់គន្លឹះទ្វារ ហើយងាកមកមើលខ្ញុំដោយខ្សែភ្នែកមានពន្លឺច្រេចច្រាច ។

"ខ្ញុំប្រាប់ហើយតើថាខ្ញុំភ្លេច ដោយសារខ្ញុំចង់ដឹងថាចំណងជើងគ្រោងការណ៍ពួកលោកធ្វើនោះគឺស្អី ទើបចង់មកសួរសិស្សច្បងម្នាក់នោះឲ្យដឹងរឿងតែប៉ុណ្ណឹងអ្ហ៊ែង"

"ចំណងជើងគ្រោងការណ៍នោះ យ៉ាងណាក៏នាងត្រូវតែដឹងដែរ គ្រាន់តែយូរនិងចាប់" គេនិយាយដោយសម្លេងត្រជាក់ស្រេង ខ្សែភ្នែកមុតស្រួចសម្លឹងមក ធ្វើឲ្យខ្ញុំបានដឹងពីចំហាយនៃការក្ដៅក្រហាយដែលជះចេញមកពីកែវភ្នែកមួយគូនោះ ។

ខ្ញុំក៏មិនសូវប្រាកដក្នុងចិត្តប៉ុន្មានដែរ ថាហេតុអីបានជាគេខឹងខ្លាំងបែបនេះ ទាំងការពិតទៅរឿងវាក៏មិនមែនទៅធំដុំអីផង ។

ម្លក៏...គេខ្លាចថាអ្នកដទៃបានពត៌មានពីខ្ញុំទៅដូចរបស់គេដែរ ហើយលទ្ធផលការងារចេញមកស្រដៀងគ្នាជ្រុលពេក ឮតមិនបាន



ទទួលការជ្រើសរើសយកទៅប្រកួតនៅសាំងហ្គាពួ ។

ត្រូវហើយ...ច្បាស់ជាមូលហេតុនេះហើយ បានជាគេខឹងខ្លាំងដល់ថ្នាក់នេះ ។

"ខ្ញុំគ្មានចេតនាធ្វើខុសកិច្ចសន្យាទេ ដូច្នេះសង្ឃឹមថាលោកមិន...យករឿងនោះទៅប្រាប់...អ៊ុយ!?" ខ្ញុំលាន់មាត់តិចៗ ពេលស្រាប់តែគេខិតចូលមកជិត ហើយឱនមុខចុះមកប៉ិះប៉ះមុខខ្ញុំ ព្រមទាំងសម្លឹងចំកែវភ្នែករបស់ខ្ញុំបែបអាងអំណាច ធ្វើឱ្យខ្ញុំត្រូវអត់ដង្ហើមដោយការជ្រួលច្រាលនិងប្រយ័ត្នប្រយែង ។

"ម្ដងនេះ...ខ្ញុំលើកទោសឱ្យ ព្រោះមើលទៅនាងដូចជាភ្លេចមែន ...តែបើលើកក្រោយភ្លេចទៀត...ដឹងហើយមែនទេថាខ្ញុំនឹងធ្វើយ៉ាងម៉េចចំពោះក្មេងខ្ចីដែលមិនគោរពពាក្យសម្ដីដូចនាង" ទោះជាសម្លេងគ្រលរៗនោះពួតិចៗដូចខ្សឹប តែវាធ្វើឱ្យមុខខ្ញុំក្រហមព្រឿងៗភ្លាមៗ

www.laksmie26.wordpress.com

មួយអាទិត្យក្រោយមក...

ខ្ញុំកំពុងបញ្ឆេះឡានដើម្បីបើកទៅមហាវិទ្យាល័យ ព្រោះថ្ងៃនេះមានរៀនពេលព្រឹក (ត្រូវបើកឡានទៅខ្លួនឯង ព្រោះសង្ឃឹម ក្វាងមីនវាគ្មានផ្លូវសុខចិត្តដើបពីព្រលឹមមកយកខ្ញុំទេ) តែ...ស្រាប់តែបងប្រុសក៏ដើរមកអូសខ្ញុំចុះពីឡានឱ្យទៅជជែកគ្នានៅបន្ទប់ដាក់សៀវភៅ ។

"សួរមែនទែន ឯងនិងអាច្នួតនោះសេពគប់គ្នាបែបណា?" ម្ដងនេះបងប្រុសសួរដោយសម្លេងមុតមាំ ដែលវាធ្វើឱ្យខ្ញុំលែងហ៊ានឆ្លើយបែបឌឺដងទៅវិញដូចសព្វដង ។

"ម៉េចបានសួរៗ បងសួរ...?"

"បងសួរ ឯងក៏ឆ្លើយម៉ោ!" សម្លេងរាងមាំជាងមុនបន្តិច ។

"គឺ...គឺដូចគេដូចឯង" ខ្ញុំធ្វើក្លាហានដោយការនិយាយកុហក ធ្វើមុខធម្មតា ខណៈដែលបងប្រុសធ្វើមុខដូចគ្មានជឿអីបន្តិចសោះ។

"រាល់លើកដែលឯងកុហកបង ឯងតែងភ្លេចខ្លួនយកដៃក្រពាត់ទៅក្រោយ! ដូច្នេះប្រាប់ការពិតម៉ោ!!!"

"តែ..."



"ឯងនិងវា...អត់ស្រឡាញ់គ្នាមែនទែនទេ មែនទេ?"

"..."

"បងចង់និយាយថាទាំងឯងទាំងវា...ការពិតទៅគ្មាននរណាស្រឡាញ់នរណាទេមែនទេ!!!"



"អ្ហា ម៉េចក៏បងដឹង? ឬ...អាម្សៀនោះប្រាប់បង?"

"អាម្សៀនោះ ហ្នឹងឯងកំពុងនិយាយពីអ្នកណា?"

"គុនជេ! ច្បាស់ជាគេហើយ...ហ៊ឹស! ខ្ញុំស្មានមិនខុសទេថាគេច្បាស់ជាពួកដែលមិនរក្សាពាក្យសន្យា"

"វាមិនមែនជាអ្នកប្រាប់បងទេ ហើយបងទើបតែដឹងពីមាត់ឯងហ្នឹង ថាវាក៏ដឹងរឿងនេះដែរ!"

"អ្ហា បើអីចឹងម៉េចក៏បងដឹងថា ក្វាងមីន មិនស្រឡាញ់ខ្ញុំមែនទែនដែរនោះ?"

"ឯងស្មានថារឿងងាយៗប៉ុណ្ណឹងបងមើលមិនដឹងអ្វី? ឯងពីរនាក់ហ្នឹងមើលយ៉ាងម៉េចក៏មិនដូចមនុស្សស្រឡាញ់គ្នាដែរ"

"..."

"តែឯងដឹងទេថា ចាស់ៗមិនខ្វល់ទេថាពួកឯងស្រឡាញ់គ្នាមែនឬអត់ អ្វីដែលពួកគាត់ខ្វល់គឺផលប្រយោជន៍ដែលបានមកពីការសេពគប់របស់ពួកឯងទៅវិញទេ ហើយអារឿងដែលឯងទាំងពីរបន្លំធ្វើជាសង្សារនឹងគ្នានោះ ចាស់ៗគិតមែនទែនដល់ណាដល់ណីបាត់ហើយ ហើយដែលវាយ៉ាប់ជាងនេះទៅទៀតគឺ...ពេលនេះអ្នកផ្ទះ ក្វាងមីន ត្រៀមឱ្យចាស់ៗមកស្ដីដណ្ដឹងឯងហើយ"

"អ្ហា ហ្នឹងបងឯងនិយាយលេងសើចមែនទេ?!?"

"រឿងអីចឹងៗអ្នកណាយកម៉ោលេងសើចហ៎ា ឯងក៏ដឹងដែលថាបងមិនចូលចិត្តអាឡូប់នោះទេ អីចឹងបងលេងសើចជាមួយឯងធ្វើអី"

"អ៊ូយៗៗ! ហើយឥឡូវយើងត្រូវធ្វើយ៉ាងម៉េចទៅ?"

"មុនហ្នឹង បងទាំងហាមទាំងជាស់តឿនហើយ តែឯងអត់ស្ដាប់ ឥឡូវបានម៉ោប្រាប់ឱ្យបងជួយ ប្រាប់ត្រង់ៗទៅចុះថា បើឯងជាប្រុសវិញ បងចាក់ឯងផ្អប់ជញ្ជាំងបាត់ហើយ"





"អ្នកណាទៅដឹងថាវាជ្រុលជ្រួលដល់ថ្នាក់ហ្នឹង មិនដឹងទេ! ទោះយ៉ាងណាក៏បងត្រូវតែជួយខ្ញុំ ខ្ញុំគ្មានផ្លូវព្រមរៀបការជាមួយ ក្វាងមីន ជាដាច់ខាត!"

ការពិតខ្ញុំក៏ដឹងដែរថាម៉ាក់ខ្ញុំនិងម៉ាក់ ក្វាងមីន ជិតដិតគ្នា គ្រាន់តែ...មិនស្មានថាជិតដិតគ្នាដល់ថ្នាក់ចាប់កូនប្រដល់គ្នាបែបនេះទេ ព្រោះមុនហ្នឹងមិនដែលឃើញម៉ាក់និយាយសរសើរ ឬបង្ហាញអាការៈស្រឡាញ់ចូលចិត្ត ក្វាងមីន ឱ្យខ្ញុំដឹងបន្តិចសោះ ។

"ពេលនេះអ្វីដែលឯងត្រូវធ្វើ គឺប្រញាប់តេទៅប្រាប់អាច្នុតហ្នឹង ហើយឱ្យវាចាប់ទៅប្រាប់ការពិតឱ្យប៉ាម៉ាក់វាដឹងថាការពិតឯងពីរនាក់គ្រាន់តែសេពគប់គ្នាលេង ចំណែកបងនឹងជួយអះអាងឱ្យម្នាក់ទៀត"

"ហេតុអីចាំបាច់ជាខ្ញុំ បងឆ្លាតជាងខ្ញុំ បងជួយតេទៅនិយាយជាមួយវាឱ្យបន្តិចទៅ ពេលនេះខ្ញុំវង្វេងអស់ហើយ"

"អាក្មេងចម្កួត ឯងចិត្តត្រជាក់ៗបន្តិចបានទេ...ហើយ ឱ្យទូរសព្ទម៉ោះនេះ ចាំបងតេឱ្យ"

តែ...បងប្រុសមិនទាន់បានតេទៅ ក្វាងមីន ផង...

"លោកស្រី...មិនគួរឱ្យជឿសោះថាថៃជន្យក្មេងៗស្រឡាញ់គ្នា ដោយយើងមិនបាច់ចាប់បង្ខំ ដំបូងចង់ភ្ញាក់ដែរពេលឃើញព័ត៌មានចុះផ្សាយថាមួយរយៈនេះ ក្វាងមីន ស្និទ្ធស្នាលនឹងក្មួយ អេនជែល"

នេះ...ជាសម្លេងអ៊ំស្រី (ម៉ាក់របស់ ក្វាងមីន) តើ!

ហើយពេលខ្ញុំនិងបងប្រុសបង្អើបទ្វារមើលក៏ឃើញថាម៉ាក់កំពុងនិយាយជាមួយអ៊ំស្រីយ៉ាងសប្បាយមាត់នៅក្នុងបន្ទប់ទទួលភ្ញៀវ ។

"អីយ៉ា សម័យនេះបើចាប់បង្ខំត្រង់ៗ គេច្បាស់ជាតតាំង មិនព្រមស្តាប់យើងទេ ទាល់តែរៀបផែនការបោកប្រាស់បែបនេះទើបល្អ...ហ្នឹងខ្ញុំមិនដែលនិយាយអីពីក្មួយ ក្វាងមីន ឱ្យកូនស្រីឮផង ព្រោះបើហ៊ានតែនិយាយលើកដើងចេញមុខចេញមាត់ខ្លាំងពេក ក្មេងៗច្បាស់ជាដឹងខ្លួនមុនមិនខាន..." ម៉ាក់រៀបរាប់ ព្រមទាំងសើចលោកបែបត្រូវចិត្តដែលអាចបោកប្រាស់ខ្ញុំឱ្យជឿបាន ។

ហ៊ឺសៗ ម៉ាក់ខ្ញុំចំជាមានល្បិចល្អមែន និយាយសរសើរលើកដើង



អ្នកដទៃ តែមិនលើកលែង ក្វាងមីន មួយរហូតដល់ខ្ញុំគ្មានទឹកចូល់ ហើយគិតថាខ្លួនឯងឆ្លាតមែនទែនដែលសម្រេចចិត្តសេពគប់វាដើម្បីបន្លំភ្នែកគេឯង ដោយមិនដឹងអីបន្តិចថា ការពិត ក្វាងមីន ក៏ជាម្នាក់ក្នុងចំណោមបុរសដែលម៉ាក់របស់ខ្ញុំបង់ប្រាថ្នាដែរ ។



"ចាស...លោកស្រីឆ្លាតវាងវៃមុតស្រួចរហូតមុខលំពែងសុំខ្មាសបែបនេះប្រាកដហើយថាក្មួយ អេនជែល ក៏ច្បាស់ជាឆ្លាតវាងវៃមុតស្រួចរហូតមុខលំពែងសុំខ្មាសដែលមិនខាន ដូច្នេះយើងទាំងពីរច្បាស់ជាមានចៅដែលជាឆ្លាតដូចប៉ាម៉ាក់វាហើយ!"

បើស្តាប់មិនខុសទេនោះ ខ្ញុំឮសូរម៉ាក់សើចវាងស្ងួតៗ ពេលដែលអ៊ំស្រីនិយាយថាខ្ញុំឆ្លាតវាងវៃដូចមុខលំពែង ។

ហ៊ឺសៗ អ៊ំស្រីបែបមិនដឹងទេ ថាការពិតខ្ញុំគឺជាមនុស្សអន់បំផុតរបស់ត្រកូលក្នុងរឿងឆ្លាតនេះ មិនអីចឹងមិនមែនបងប្រុសអ៊ីពីព្រឹកដល់ល្ងាចថាខ្ញុំល្ងង់អីចេះ ភ្លើអីចុះនោះទេ ។

"ចាស ត្រូវហើយ អេនជែល ខ្ញុំឆ្លាតរហូត អាញស្តាញ សុំខ្មាស ធានាថាឱអិនអេនៃភាពឆ្លាតវៃរបស់ អេនជែល ត្រូវតែបញ្ជូនទៅឱ្យចៅរបស់យើងមិនខាន!"

"បើអីចឹងខ្ញុំថាយើងនិយាយគ្នារឿងថ្លៃទឹកដោះវិញល្អទេ ហើយក្នុងឋានៈដែល ក្វាងមីន ជ្រើសរើសកូនប្រសាឱ្យខ្ញុំបានត្រូវចិត្តបែបនេះ លោកស្រីថាមកចុះ ប៉ុន្មានក៏ដោយ ខ្ញុំមិនជំទាស់ទេ"

គ្រាន់តែឮពាក្យថា ថ្លៃទឹកដោះ ខ្ញុំនិងបងប្រុសក៏ងាកមកមើលមុខគ្នាដោយការខ្វាយខ្វល់ ។

ដោយសារខ្ញុំខ្លាចម៉ាក់ចាប់ឱ្យរៀបការជាមួយ ក្វាងមីន ខ្ញុំក៏ធ្វើហាក់ដូចជាចង់ស្ទុះចេញទៅហាមឃាត់ មិនឱ្យគាត់និយាយអីជាមួយខាងនោះច្រើនជាងហ្នឹងទៀត តែ...មិនទាន់ទាំងបានធ្វើអីផង បងប្រុសក៏ចាប់ខ្ញុំជាប់ ។

"នែ! ឯងកុំអាលចេញទៅពេលហ្នឹងអី ចិត្តត្រជាក់បន្តិចមើល"

"ឱ្យខ្ញុំត្រជាក់ម៉េចបាន?!! បងមិនឮទេអ្វី ថាម៉ាក់ទារថ្លៃទឹកដោះពីអ៊ំស្រីច្រើនប៉ុណ្ណា?"



"ឯងអត្តយចុះ ហើយចិត្តត្រជាក់ៗសិន ទោះយ៉ាងណាក៏រឿងនេះមានផ្លូវចេញដែរ"

ភ្លាមនោះ គំនិតអាក្រក់ដូរជាតិមួយក៏ផុសនៅក្នុងខួរក្បាល ម្តងនេះធានាថាអ៊ំស្រីត្រូវតែបញ្ឈប់គំនិតចង់បានខ្ញុំទៅធ្វើជាកូនប្រសាមួយរយភាគរយ ។

ហ៊ឺៗៗ

ហ៊ឺៗៗ

"ហៃ ហ្នឹងក័យរហូតច្កួតអស់ហើយអ្ហ៎ សុខៗអត្តយសើចតែម្នាក់ឯង" បងប្រុសកេះហៅ ព្រមទាំងមើលខ្ញុំដោយទឹកមុខព្រួយបារម្ភ ។

"ខ្ញុំមិនមែនច្កួតទេ តែខ្ញុំកំពុងតែធ្វើឱ្យអ៊ំស្រីស្អប់ខ្ពើមរហូតលែងចង់បានខ្ញុំទៅធ្វើជាកូនប្រសាតេ!"

"ឈប់សិន អេនជែល កុំប្រាប់ឱ្យសោះថាឯងគិតប្រុង..."







## ភាគទី៩
## នារីឈឺច្រើន

"អ៊ូយ!!! ឈឺពោះ ឈឺៗ ឈឺខ្លាំងណាស់ ខ្លាំងជាទីបំផុត អ្នកណាក៏បានដែរ ជួយផង! ហ៊ឺៗៗ!"

"ហៃ អាឡប់ក្រោកភ្លាម អេនជែល ឈប់ បងប្រាប់ថាឱ្យឈប់!" បងប្រុសបន្លួយសម្លេងថាឱ្យខ្ញុំ ព្រមទាំងចាប់ទាញឱ្យខ្ញុំក្រោកពីឥដ្ឋ ។

"ស្អីបងទៀតហើយ?" ខ្ញុំបញ្ឈប់សម្លេងស្រែកថ្ងូរហណ្តោះអាសន្នមុននឹងឡើបសួរ "បងកុំធ្វើឱ្យខូចការបានទេ លេងបណ្តោយទឹកទៅតាមខ្ញុំសិនទៅ អ៊ូយ!! ឈឺពោះ ឈឺ ឈឺខ្លាំងណាស់!!!"

"ឯងស្មានថាបន្លំធ្វើឈឺហើយ ឯងអាចគេចរួចពីការរៀបការបានរហូតអ្ហ៎ស ពេលឯងចេញពីពេទ្យ ម៉ាក់ត្រូវតែចាប់ឯងការជាមួយវាដដែលហ្នឹង!"

"ហ៊ី បងមើលសិនទៅថាកន្លែងដែលខ្ញុំឈឺវានៅត្រង់ណា?" ខ្ញុំដាក់ដៃក្រោមផ្ចិត ព្រមទាំងញាក់ចិញ្ចើមដោយមានល្បិច ។

"អ្ហ៎ា?! ហ្នឹងចង់លេងល្បិចអីទៀតហើយ?"

"បងមិនដឹងអីទេ ក្មេងមីន វាជាកូនប្រុសទោល បងសាកគិតទៅមើលថាតើអ៊ំស្រីនឹងធ្វើមុខយ៉ាងម៉េច បើខ្ញុំពិបាកមានកូន ធានាថាម្តងនេះគាត់ច្បាស់ជាស្អប់រហូតលែងចង់បានខ្ញុំមិនខាន"

"ស្តាប់ឱ្យច្បាស់ណាអាប្អូនល្ងង់! ឯងធ្វើបែបនេះ រួចខ្លួនបានតែថ្ងៃនេះប៉ុណ្ណោះ ចុះថ្ងៃផ្សេងទៀតឯងធ្វើម៉េចទៅ?"

ខ្ញុំពេបមាត់ដាក់គាត់ មុននឹងបន្លំធ្វើជាដួលខ្លួនដេកលើឥដ្ឋ ញញួនដូចដង្កូវ ។

"បងចាំជាមិនដឹងអីមែន...ស្រីដែលពិបាកមានកូន គ្មានណា



ចង់បានធ្វើកូនប្រសាទេ"

មកដល់ពេលនេះទៅហើយ ខ្ញុំមិនខ្វល់ពីសម្លេងហាមរបស់បងប្រុសទេ ខ្ញុំញញឹមរាងលួចលោមដាក់គាត់ដែលមើលទៅដូចជាមិនយល់ស្របនឹងផែនការនេះ រួចហើយក៏បញ្ចេញសម្លេងថ្ងូចថ្ងូរដ៏គួរឱ្យអាណិតថែមទៀត ។

"អ៊ូយ!!! ឈឺមែនទែន ឈឺពោះណាស់ ជួយផង!!!"

"អាចូត! ហ្នឹងឯងលេងមែនទែនឬ? ឯងភ្លេចហើយអ្ហេថាម៉ាក់ក៏នៅទីនេះដែរ ម៉ាក់ដឹងខ្លាំងជាងដឹងទៅទៀត ថាសុខភាពរបស់ឯងរឹងប៉ុនខ្លាំងជាងដំរីសារទៅទៀត ចំណុចខ្សោយនៅក្នុងខ្លួនឯងមានតែមួយគត់គឺ ល្ងង់!"

"...?!?"

"បងថា...រឿងបែបនេះកុហកទៅមានតែកាន់តែយ៉ាប់ លើកឧទាហរណ៍ងាយៗ ដែលឯងនិង ក្វាងមីន រៀបផែនការបន្លំធ្វើជាសេពគប់គ្នាដើម្បីបោកប្រាស់កុំឱ្យចាស់ៗចាប់ពូកឯងរៀបការ ឥឡូវយ៉ាងម៉េច ធ្វើចុះធ្វើឡើងដើរម៉ាជាន់ជាន់ខ្លួនឯង ទីបំផុតជាប់អន្ទាក់ចាស់ៗទៅវិញ!"

មិនខ្វល់ មិនខ្វល់ និង មិនខ្វល់!

ទោះយ៉ាងណាក៏ខ្ញុំនៅតែធ្វើតាមវិធីចម្លែកៗរបស់ខ្ញុំនេះអ្ហែង បងប្រុសហាមមិនបានទេ ។

"ឈឺពោះ! ឈឺ! អ៊ូយ!!!"

ហើយវាក៏បានការមែន ព្រោះគ្រាន់តែឮសម្រែកស្រែករកជំនួយរបស់ខ្ញុំ ម៉ាក់ក៏បើកទ្វារចូលមកភ្លាម ដោយកាយវិការភ័យភ្ញាក់ផ្អើលយ៉ាងខ្លាំង ។

"ស្លាប់ហើយ! កូយ អេនជែល ហេតុអីបានគេងរួញខ្លួនដូចខ្មុកឡើងនៅលើគ្រែបែបហ្នឹង?"

"អ៊ូយ! ខ្ញុំឈឺពោះណាស់អ៊ំស្រី ឈឺដូចត្រូវគេចាក់នឹងកាំបិតអ៊ីចឹង អ៊ូយ! ឈឺ មែនទែន..."

"មីណាម រស់តែឈរធ្វើអីកូន ឆាប់ដឹកប្អូនទៅពេទ្យភ្លាមទៅ!"



OPSOK LOVE SERIES

"បាទម៉ាក់!" បងប្រុស ដើរមកលើកខ្ញុំ ព្រមទាំងធ្វើទឹកមុខធុញទ្រាន់ ខណៈដែលខ្ញុំនៅតែបញ្ចេញសម្លេងថ្ងូចថ្ងូរ ធ្វើដូចមនុស្សជិតស្លាប់ដដែល ដើម្បីឱ្យដូចមែនទែន ។



មន្ទីរពេទ្យ...

ដោយសារតែថ្ងៃនេះ ខ្ញុំមករដូវល្មម គ្រូពេទ្យក៏សន្និដ្ឋានថាមូលហេតុដែលខ្ញុំឈឺពោះយ៉ាងទាន់ហន់និងខ្លាំងក្លាបែបនេះ ព្រោះស្បូនមិនស្ងួតរឹងមាំនិងអាចមានដំបៅ ទើបត្រូវចាក់ថ្នាំផ្សះ ថ្នាំបំប៉ន និង ថ្នាំគេងលក់ឱ្យខ្ញុំ បន្ទាប់មកត្រូវរង់ចាំមើលអាការៈពីរថ្ងៃទៀតថាតើបានធូរស្រាលខ្លះឬអត់ ។

ប្អូនម៉ោងតមក...

គ្រាន់តែខ្ញុំបើកភ្នែកភ្លាម សម្លេងស្រួយស្រែសរបស់អ៊ំស្រីក៏ធ្វើឱ្យខ្ញុំមានចង់ឈឺមែនទែនតែម្តង ។

"ស្លាប់ហើយ...កូយ អេនជែល ហ្នឹងអ៊ំទើបតែដឹងទេថាក្មួយសុខភាពមិនស្ងួវល្អ មិញគ្រូពេទ្យប្រាប់ថាអាចមានជម្ងឺដំបៅស្បូនទៀតផងមែនទេ?"

"ចាស ត្រូវហើយអ៊ំស្រី ខ្ញុំនេះរាងកាយមិនស្ងួវរឹងប៉ុងទេ តិចឈឺនេះ តិចឈឺនោះរហូត មិញគ្រូពេទ្យឱ្យប្រាប់ខ្ញុំថា សភាពរាងកាយដូចខ្ញុំនេះមើលទៅដូចជាពិបាកមានកូនណាស់..." ខ្ញុំនិយាយដោយសម្លេងសោកសៅ ខណៈដែលអ៊ំស្រីមុខឡើងស្លេកដូចមាន់ស្លោរចាក់ទៅហើយ ហ៊ីៗ ។

"ការពិតកូនស្រីខ្ញុំមិនធ្លាប់មានអាការៈបែបនេះទេ នេះមិនដឹងថា...ឈឺជម្ងឺអីពិតប្រាកដទេ..." ម៉ាក់និយាយ ព្រមទាំងមើលខ្ញុំនិងបងប្រុសដែលអង្គុយនៅក្បែរគ្រែដោយខ្សែភ្នែកក្រឡេក ។

តែគាត់ក៏នៅតែជួយលេងចាកល្បោនបន្លំភ្នែកអ៊ំស្រីតទៅទៀត ដោយមុខក្រាស់ មិនខ្វល់ពីខ្សែភ្នែកក្តៅគគុករបស់ម៉ាក់បន្តិចណាឡើយ ។





ហួតទីបំផុត អ៊ំស្រីទ្រាំស្តាប់តទៅទៀតលែងបាន ក៏សុំត្រឡប់ទៅវិញ ចំណែកម៉ាក់ក៏ប្រញាប់ស្ទុះតាមទៅឃ្លាំជាមួយនិងនៅតែចោលខ្សែភ្នែកអាឃាតដាក់ខ្ញុំនិងបងប្រុស មុនចេញពីបន្ទប់ ។

អំឡុងពេលគេងមើលទូរទស្សន៍ ឯបងប្រុសក៏ទៅផ្ទះផ្ញូតទឹកផ្លាស់ខោអាវនោះ ក្មាងមីន ក៏គេមករកខ្ញុំដើម្បីនិយាយរឿងអ្វីម្យ៉ាង តែ... គ្រាន់តែខ្ញុំប្រាប់វារឿងចាស់ៗ វាក៏ឧទានឡើងខ្លាំង ÷

(អ្ហ៎ា! ម៉ាក់ខ្ញុំប្រុងទៅស្តីដណ្តឹងនាង?)

"ការពិតឯងកុំបារម្ភអីខ្លាំងពេក ព្រោះពេលនេះខ្ញុំថាម៉ាក់ឯងបែបលែងចង់ឲ្យខ្ញុំធ្វើកូនប្រសាហើយ!"

(ចឹអ្ហ៎ា?)

"ព្រោះខ្ញុំកុហកម៉ាក់ឯងថា ពេទ្យប្រាប់ថាខ្ញុំអាចពិបាកមានកូន"

(ស្រីឆ្កួត! មូលហេតុចម្លែកៗបែបនេះចេះតែនឹកឃើញទៅកើត ហើយម៉ាក់ខ្ញុំគាត់ថាម៉េចដែរ?)

"ក៏...មើលទៅរាងភាំងៗដែរ ហើយខ្ញុំក៏មិនទាន់ប្រាកដក្នុងចិត្តដែរថា ម៉ាក់ឯងនៅតែចង់បានខ្ញុំធ្វើជាកូនប្រសាទៀតអត់ ព្រោះអត់ឃើញនិយាយអីមួយម៉ាត់សោះ"

(ខ្ញុំថាប្រហែលជាពិបាក តែ...ខ្ញុំសួរឯងរឿងមួយបានទេ?)

"រឿងអី?"

(ខ្ញុំឃើញមួយរយៈនេះឯងដូចជាស្និទ្ធស្នាលនឹងសិល្បប្បាង គុនដេសូរមែនទែនចុះ ឯង...គិតយ៉ាងម៉េចចំពោះគេ?)

"ឆ្កួតទេដឹង! ខ្ញុំទៅគិតស្អីចំពោះគេ?"

(អ្ហ៎ា អីចឹងបានន័យថាខ្ញុំយល់ច្រឡំខ្លួនឯងទេអ្ហ៎ ឥឡូវធ្វើម៉េចទៅ ខ្ញុំស្មានថាឯងក៏ស្រឡាញ់គេដែរ...)

"ស្អីផស់ឯង អ្ហ៊ូ ក្មាងមីន?"

"អើ...បាំតិចទៀតខ្ញុំគេរកឯងម្តងទៀត ខ្ញុំត្រូវចូលរៀនហើយខ្លាចពូកម៉ាក់ជេរពីយ បាយ!)

ម៉េចបានសុខៗ ក្មាងមីន និយាយអីចម្លែកៗបែបហ្នឹង?

ហើយហេតុអីបានវាគិតថាខ្ញុំមានចិត្តលើអាម្សៀនោះ?





ហើយមើលទៅអាម្សៀនោះជាមនុស្សអាយុវែងណាស់ ព្រោះគ្រាន់តែខ្ញុំនឹកដល់ភ្លាម សុខៗ ក៏អើតក្បាលចូលមកដោយមានរបស់របរស្ងួតសុខទុក្ខនៅក្នុងដៃ ។

ដោយសារតែមិញនេះខ្ញុំនឹកដល់គេ ធ្វើឲ្យពេលនេះខ្ញុំប្រញាប់លាក់ទឹកមុខមិនឲ្យគេឃើញដោយការប្រែខ្លួនគេងបែរខ្នងដាក់ ទោះជាដឹងថា ការធ្វើបែបនេះវាគ្មានសុជីវធម៌ក៏ដោយ ។

មួយស្របក់ធំ ខ្ញុំក៏មានអារម្មណ៍ដូចជាមានមនុស្សម្នាក់ដើរទៅយកភួយមកដណ្តប់ឲ្យ ហើយដើរទៅបិទទូរទស្សន៍ ធ្វើដូចខ្ញុំគេងលក់មែនទែនអីចឹង ។

តែ...ពេលធ្វើអ្វីគ្រប់យ៉ាងរួចរាល់ និងដើរទៅអង្គុយលើសាឡុង...

"មិនដែលដឹងសោះថានាងមានបញ្ហារឿងពិបាកមានកូន"

សម្លេងរាបស្មើបន្លឺឡើងលាយឡំនឹងការចម្អន់ ។

"..."

តាប៉ុឡូប់! ហេតុអីបានគេចូលចិត្តធ្វើអីដែលពិបាកយល់ម្ល៉េះ? គេដឹងហើយថាខ្ញុំបន្លំធ្វើជាគេងលក់ដើម្បីគេចមុខគេ តែក៏នៅតែធ្វើដូចខ្ញុំហ្នឹងគេងលក់មែនទែនអីចឹង ហើយបន្ទាប់ពីនោះក៏មកអង្គុយបបួលខ្ញុំជជែកដូចជាត្រូវការប្រាប់ថា ការពិតដឹងថាខ្ញុំបន្លំធ្វើជាគេងហើយ ។

"ជួនកាលអាចម៉ោពីការម្ហូបម៉ៅធុញថប់ ពូជអំបុរ ឬមិនទេក៏..."

គេនិយាយវិភាគអាការៈរបស់ខ្ញុំ ធ្វើហាក់ដូចជាខ្លួនឯងហ្នឹងជាគ្រូពេទ្យមើលជម្ងឺខ្ញុំអីចឹង ។

"...!!!"

ម្តងនេះខ្ញុំក៏ស្ទុះក្រោកអង្គុយ ហើយបែរទៅមើលគេដោយខ្សែភ្នែកមួម៉ៅ អាតាប៉ុនេះដូចជាកាន់តែវង្វាន់សរសៃប្រសាទខ្លាំងឡើងៗហើយ!!!

មើលតាមទឹកមុខ ខ្សែភ្នែក និងសម្លេង ខ្ញុំប្រាកដក្នុងចិត្តណាស់ថា គេប្រហែលជាដឹងតាមបងប្រុសហើយ អារឿងដែលខ្ញុំប្រឌិតថាពិបាកមានកូន តែគេក៏នៅតែមកអង្គុយវិភាគអាការៈរបស់ខ្ញុំដូចជាមានចេតនាចង់ចំអកឡកឡឺយខ្ញុំ ។



តែ...ដោយសារតែពេលនេះគេកាន់សន្ធឹកលឿនជាង ទើបធ្វើឱ្យខ្ញុំខាំមាត់មិនបែរទៅតមាត់ជាមួយដូចសព្វដង ហើយបានត្រឹមតែខាំធ្មេញក្រឹតៗ ។

"..."

"ដែលមិនតមាត់ហ្នឹង ព្រោះខ្លាចខ្ញុំធ្វើខុសពាក្យសន្យាឬម៉េច?"

"..."

"ប្រាកដហើយតើ រឿងថតពាណិជ្ជកម្ម បើខ្ញុំចង់ប្រាប់ មីណាមខ្ញុំប្រាប់តាំងពីយូរណាស់ទៅហើយ"

"ហ្នឹងលោកសម្លុតខ្ញុំអ្ហ៎?"

"ខ្ញុំប្រាប់ថាខ្ញុំអត់ប្រាប់អ្នកណាទេ ហ្នឹងហៅថាសម្លុតផ្អ៎ស?"

"..."

"ការពិតបើមិនចង់រៀបការជាមួយ ក្វាងមីន នាងគួរតែប្រាប់ការពិតដល់អ្នកផ្ទះទៅថា អ្នកទាំងពីរមិនមែនសេពគប់គ្នាមែនទែនទេ រឿងវានឹងចប់"

"បើប្រាប់ការពិតហើយ ម៉ាក់ចាប់ខ្ញុំទៅរៀបការជាមួយអ្នកផ្សេងវិញ ឱ្យខ្ញុំធ្វើម៉េចទៅ?"

"ហើយចុះបើអ្នកដទៃនោះជាខ្ញុំវិញ នាងថាម៉េចដែរ?"

"...?!?"

ខ្ញុំបែរទៅមើលគេដោយការភ្ញាក់ផ្អើល បេះដូងលោតក្នុងខ្លាំងខុសចង្វាក់ ដឹងខ្លួនវិញគេក៏ដើរចូលមកឈរក្បែរបាត់ទៅហើយ ។

មុខរបស់គេរំកិលចូលមកជិត ហើយបបូរមាត់ប៉ិះនឹងប៉ះបបូរមាត់ខ្ញុំ ខ្ញុំយកចុងម្រាមដៃប៉ះបបូរមាត់គេដើម្បីហាម មុនពេលអ្វីៗវាទៅជ្រុលខ្លាំងជាងនេះ ។

"ខ្ញុំកំពុងឈឺ..." ខ្ញុំនិយាយហាមតិចៗ តែគេទាញដៃខ្ញុំចេញ ។

"ឈឺខូចហ្នឹងអ្ហ៎..." គេនិយាយមុននឹងព្រមថយចេញ ។

"ចង់យ៉ាងម៉េចក៏ដោយ ការដែលខ្ញុំម៉ោគេងនៅលើគ្រែអ្នកជម្ងឺបែបនេះ ត្រូវតែគិតថាខ្ញុំជាអ្នកជម្ងឺ!"

"កុំស្មានថាខ្ញុំចង់លូកលាន់នាងដោយគ្មានហេតុផល"

LOVE SERIES



"អ្ហ៎! ហ្នឹងបញ្ជាក់ថារាល់លើកដែលលោកចូលចិត្តលូកលាន់ខ្ញុំសុទ្ធតែមានហេតុផលឬ?"

"ពេលខ្លះក៏អត់ដែរ"

ខ្ញុំងើបមុខមើលគេដោយមិនគួរឱ្យជឿ ចម្លើយធម្មតាៗ បែបត្រង់ទៅត្រង់មករបស់គេ ធ្វើឱ្យខ្ញុំទាល់ និយាយលែងចេញ ។

"នាងឆ្លើយនៅក្នុងគំរូសំនួរថាថ្នាក់ដៃស្ដាំ តែមិញនាងបែរជាលើកម្រាមចង្អុលខាងឆ្វេងមកប៉ះមាត់ខ្ញុំ បែបហ្នឹងពិតមានដែលខ្ញុំបានទៅ វាការពិតឬអត់?"

"ហាន់ គុនជេ! លោក...មនុស្សឡប់! លោកគួរតែដឹងថានៅក្នុងស្ថានការណ៍អាសន្នបែបហ្នឹង ខ្ញុំគ្មានពេលម៉ោគិតថាគួរត្រូវប្រើដៃខាងណាបិទមាត់លោកទេ!"

"មនុស្សយើងពេលធ្លាក់ក្នុងស្ថានការណ៍អាសន្ន តែងតែលើកដៃខាងដែលខ្លួនឯងថ្នឹកបំផុតឡើងទេអ្ហ៎?"

"..."

"ឬក៏...មិញវាមិនទាន់អាសន្នមែនទែន?" គេស្ទាក់មុខប្រងើយខណៈដែលខ្ញុំខឹងឡើងមុខក្រហមអស់ហើយ ។

ក្រឹតណាស់...

"លោក!!!"

"ឬក៏...ដៃខាងស្ដាំរបស់នាងត្រូវខ្ញុំចាប់ជាប់ហើយ...តែ ខ្ញុំចាំបានថាដៃខ្ញុំមិនបានចាប់ដៃនាងទេ..."

"ហាន់គុនជេ!"

គេធ្វើព្រងើយ គ្មានញាប់ញ័រភ័យព្រួយអីបន្តិចសោះ ។

"ការពិត ខ្ញុំគិតថាមានរឿងខ្លះគួរតែប្រាប់ឱ្យនាងបានដឹងមុន..." សុខៗ គេក៏ដូររឿងនិយាយ ។

"..."

"អាទិត្យមុន ប្អូនជីដូនមួយខ្ញុំទើបតែយល់ព្រមសេពគប់ ក្វាងមីន តែបញ្ហាគឺប្អូនខ្ញុំម្នាក់នេះប៉ិនប្រច័ណ្ឌណាស់"

"..."





"គេបានឮដំណឹងពីមិត្តភក្តិនៅក្លឹប ក៏គិតថានាង និង ក្វាងមីន ជាសង្សារមែនទែន"

"..."

"ក្វាងមីន អង្វរឱ្យខ្ញុំជួយឃ្លៀវ ខ្ញុំក៏ប្រាប់ទៅប្អូនខ្ញុំថា ការពិតទៅ ...យើងកំពុងសេពគប់គ្នា..."

"ស្អីគេ!!!"

"តែដែលខ្ញុំមិនបានសេពគប់នាងចេញមុខចេញមាត់ ព្រោះតែខ្ញុំទើបនឹងបានទទួលតំណែង Prince of Zodiac ទើបមិនចង់ឱ្យនាងបាត់បង់ពេលវេលាផ្ទាល់ខ្លួន"

"..."

"បញ្ហាគឺអាទិត្យក្រោយ ប្អូនខ្ញុំនឹងមកលេងសម្រាកនៅក្លឹបប្រហែលពីរអាទិត្យ..."

"..."

"ដូច្នេះ...ប្រហែលជាត្រូវរំខាននាងជួយធ្វើខ្លួនឱ្យវាស៊ីគ្នាទៅនឹងអ្វីដែលខ្ញុំនិយាយហ្នឹងបន្តិចផង"

"បានន័យថា...លោកចង់ឱ្យខ្ញុំបន្លំធ្វើជាសង្សាររបស់លោកដើម្បីឱ្យប្អូនស្រីលោកឈប់យល់ច្រឡំនឹង ក្វាងមីន មែនទេ?"

"ហ្នឹងបានខ្ញុំសួរថា ចុះបើអ្នកផ្សេងនោះជាខ្ញុំវិញ នាងថាម៉េចដែរ"

"ចុះបើខ្ញុំឆ្លើយថា អត់!"

"បើនាងយល់ព្រម ចប់រឿងហ្នឹងខ្ញុំនឹងសុខចិត្តប្រាប់ថា ចំណងជើងគ្រាងការណ៍សម្ងាត់នោះគឺជាអ្វី?"





## ភាគទី១០
## សំណួរមិន

"...!"

ឯាប់ហើយ ហេតុអីក៏គេយករឿងដែលខ្ញុំកំពុងចង់ដឹងជាទីបំផុតមកជន្លលេងបែបហ្នឹង?

"ការពិត...ខ្ញុំក៏ចាប់ផ្ដើមដឹងខ្លះៗហើយថា គ្រោងការណ៍នោះគឺជាអ្វី" ខ្ញុំធ្វើជាឆ្លើយដូចដឹង តែមិននិយាយ ទាំងការពិតវិញ នៅស្មានមិនត្រូវសូម្បីតែបន្តិច ។

"នាងក៏បដិសេធ ព្រោះដឹងព្រាលៗហើយថាគ្រោងការណ៍នោះគឺជាអ្វី"

"គឺទំនងហ្នឹងអ៊ែង"

"ការពិត...បើនាងដឹងខ្លះហើយ ហេតុអីក៏នៅតែចង់បដិសេធខ្ញុំទៀត" សម្លេងគ្រលរៗបែបហ្នឹង រួមទាំងខ្សែភ្នែកដែលបង្កប់អត្ថន័យស៊ីជម្រៅ ធ្វើឱ្យខ្ញុំចាប់ផ្ដើមមានអារម្មណ៍ថា ពីមួយថ្ងៃទៅមួយថ្ងៃគេកាន់តែគ្រោះថ្នាក់ចំពោះបេះដូងរបស់ខ្ញុំហើយ ។

ហើយមិនដឹងហេតុអីបានខ្ញុំមានអារម្មណ៍ថាសម្ដីរបស់គេមានយីពីតដ៏អ្វីម្យ៉ាងបង្កប់នៅក្នុងនោះ ។

មើលទៅគេដូចជាចង់ប្រាប់ខ្ញុំដោយប្រយោលថា ចំណងជើងគ្រោងការណ៍នោះ គឺជាអ្វីដែលត្រូវការប្រាប់ខ្ញុំ ដែលពេលគិតមកដល់ត្រង់នេះ...ខ្ញុំក៏ចាប់ផ្ដើមមិនហ៊ានសុបថាវាគឺជាអ្វី ។

ក្នុងចិត្តខ្ញុំលបភ័យថា...ការពិតចំណងជើងគ្រោងការណ៍នោះអាចមិនស៊ីជម្រៅ ឬក៏មែនទិកដូចដែលខ្ញុំធ្លាប់លួចគិតឡើយ...ព្រោះបងប្រុសបែរជាយកឱ្យមីង ហើរ ធ្វើជាអាយជៀក្នុងការបញ្ចេញមុខ ។



ដោយហេតុនេះ ទើបខ្ញុំមិនសូវយល់ថា ហេតុអីក៏បងប្រុសជ្រើសរើសយកមីង ហើយ ខណៈដែល គុនដេ...យកខ្ញុំ?

ទាំងចំណងជើងគ្រោងការណ៍តែមួយដូចគ្នា តែបែរជាឲ្យអ្នកដែលមាននិស្ស័យ និង វ័យខុសគ្នាដាច់ ធ្វើទៅវិញ ។

"ហើយលោកក៏ឈប់ទាក់ទងខ្ញុំដែរ មែនទេ?"

"ចង់និយាយបន្ទាប់ពីផុតពីអាទិត្យដែលថានោះហ្នឹងម្ដេះស?"

"អ៊ឹម" មើលទៅខ្ញុំដូចជាមិនដឹងខ្លួនផង ថាភ្លេចខ្លួនសម្លឹងមើលគេដោយខ្សែភ្នែកដែលពេញទៅដោយក្ដីសង្ឃឹមខ្លាំងប៉ុណ្ណា ។

"..."

"..."



គេនៅស្ងៀមមួយស្របក់ មុននឹងបែរមកមើលមុខខ្ញុំដោយខ្សែភ្នែកដែលស្មានចិត្តមិនត្រូវដូចសព្វដង ។

"មិនដឹងដែរ"

"ខ្ញុំចាប់ផ្ដើមលែងប្រាកដចិត្តហើយថាគួរយល់ព្រមអត់"

"កុំគិតថាវាជាការបង្ខំឲ្យសោះ តែឲ្យគិតទៅថាវាជាសំនូរបិទ..."

"..."

"ដែលត្រូវការចម្លើយតែមួយគត់ គឺ...យល់ព្រម"

"..."

ទៀតហើយ! ហ្នឹងគេប្រុងមិនគិតបើកឱកាសឲ្យខ្ញុំបានធ្វើចិត្តរឹងដាក់គេខ្លះទេអី?

តែ...មិនដឹងហេតុអីបានខ្ញុំមានអារម្មណ៍ថាតូចចិត្តនឹងគេតិចៗ ដែលមកសុំសេពគប់ខ្ញុំដោយមូលហេតុថា ចង់ជួយប្អូនស្រីជីដូនមួយ មិនមែនព្រោះមានចិត្តមកលើខ្ញុំទេ ។

ពីរថ្ងៃបន្ទាប់មក...

មើលទៅដូចជាផែនការដំបៅស្បូនរបស់ខ្ញុំប្រើការបានល្អហួសការស្មាន ព្រោះ ក្មាងមីន ត្រូវម៉ាក់វាបញ្ជាឲ្យឈប់សេពគប់ខ្ញុំយ៉ាងរហ័សដូចផ្លេកបន្ទោរ ប៉ុណ្ណឹងមិនគ្រប់គ្រាន់ទេ ពេលនេះបណ្ដាមិត្តភក្ដិម៉ាក់ដែលមានកូនប្រុស ក៏រត់ចេញពីជីវិតខ្ញុំអស់រលីង គ្មានអ្នកណាហ៊ានយកកូនប្រុសមកបង្ហួតម៉ាក់ទៀតទេ ហាសៗ! ។



តែ...មើលទៅរឿងមិនមែនចប់ស្រួលៗដូចគិតនោះទេ ព្រោះពេលនេះខ្ញុំឮដំណឹងថា ម៉ាក់ចាប់ផ្ដើមដើរកែរពាក្យមានជាមួយមិត្តភក្ដិ និង អ្នកស្គាល់ខ្លាំងមែនទែន គេជឿខ្លះ មិនជឿខ្លះ តែយ៉ាងហោចណាស់ក៏ជួយបន្ថយកម្លាំងកុំឲ្យវាល្បីខ្លាំងពេកដែរ ។

ឯាប់ហើយ ម៉ាក់ដូចជាតស៊ូជ្រុលពេកហើយ ។

តែនៅក្នុងខ្សែភ្នែកបងប្រុសវិញ បែរជាឃើញថាវាគ្មានអ្វីគួរឲ្យបារម្ភទេ ។

"ឯងមិនបាច់ខ្វល់ច្រើនទេ ម៉ាក់ខំស្រាវស្រទេញរឿងឯងតែម៉ារយៈតិចទៅមានការងារច្រើន ក៏លែងមានពេលពីរល់ជាមួយឯងហើយ សម្រេចថាពេលនេះឯងកុំទៅដើររកអ្នកណាម៉ោសេពគប់ តិចកើតរឿងឡើងទៀត"

"សោកស្ដាយផង ពេលនេះខ្ញុំទៅយល់ព្រមសេពគប់អ្នកថ្មីម្នាក់ទៀតហើយ"

"អ្ហា ហ្នឹងឯងនៅមិនទាន់រាងទៀតម្ដេះស?"

"រាងច្អតស្អី ម្ដងនេះគេបង្ខំខ្ញុំទេ!" អត់ទេ ការពិតមិនមែនបង្ខំទេ តែជាការដូរដោះលាយឡំសុំអង្វររាងខ្ញុំនិងគេ ។

"អ្នកណា?"

"ហាន់ គុនដេ!"

បងប្រុស ងក់ក្បាលដោយមិននិយាយអី មុននឹងក្រោកឡើងដើរទៅបន្ទប់ដាក់សៀវភៅធ្វើព្រងើយ ។

"នែ៎...បងអត់មានបញ្ចេញយោបល់អីខ្លះទេអី?"

"បងគ្មានអីចំមេនទេ ឯងនេះយ៉ាងម៉េចហ្នុំ? បងអ៊ី ឯងឡូឡា ដល់បងអត់និយាយឯងក៏តាមម៉ោដេញដោល"

"សួរមែនទែន បងអត់បារម្ភពីខ្ញុំខ្លះទេម្ដេស ចុះបើម៉ាក់ដឹងថាខ្ញុំសេពគប់គេ ស្រាប់តែចាប់ខ្ញុំឲ្យរៀបការជាមួយគេនោះ?"

"បើបងជាឯង បងនឹងរៀបការ!"

"បានន័យថាម៉េច?"



"ទ័រ...ហ្នឹងឯងភ្លើ ឬក៏គិតថាបងជាវចនានុក្រមភាសាកូរ៉េអ្វីបានជាចង់ឱ្យបងប្រែពីកូរ៉េមកកូរ៉េឱ្យឯងស្ដាប់រាល់តែលើកបែបនេះ"

"ម៉ោពីបងនិយាយមិនច្បាស់លាស់"

"មិនច្បាស់លាស់ត្រង់ណា?"

"..."

"អូខេៗ បងនឹងនិយាយឱ្យវាចំៗតែម្ដងក៏បានដែរ...បើបងជាឯង បងនឹងព្រមធ្វើប្រពន្ធវាភ្លាមហ្មង!"

"និយាយអត់សុភាព!"

"..."

"ការពិតទៅ...រឿងដែលខ្ញុំនិងគេសេពគប់គ្នា ដោយសារគេប្រាប់ឱ្យខ្ញុំជួយធ្វើសង្សារគេ ដើម្បីកុំឱ្យប្អូនស្រីគេយល់ខុសនឹង ក្វាងមីន" មិនដឹងជាមានអីមកបណ្ដាលចិត្តឱ្យខ្ញុំប្រាប់ការពិតដល់បងប្រុសតែម្ដង អាចដោយសារតែខ្ញុំកំពុងនឹកតូចចិត្តនឹងអាម្សៀនោះផងក៏មិនដឹង ។

"អ្ហាក ហ្នឹងវាអត់បានសេពគប់ឯងមែនទែនទេអ្ហេស?"

ឆាប់ហើយ រឹតតែបងប្រុសនិយាយបញ្ជាក់បែបនេះទៀត វារឹតតែធ្វើឱ្យខ្ញុំមានអារម្មណ៍ថាខ្លួនឯងកំពុងធ្លាក់ក្នុងស្ថានភាពស្រឡាញ់គេតែម្នាក់ឯងយ៉ាងម៉េចមិនដឹងទេ ។

"អត់ទេ ព្រោះតែសង្សារ ក្វាងមីន បានដំណឹងពីមិត្តភក្តិនៅកូរ៉េថាខ្ញុំនិងវាសេពគប់គ្នា ហើយពួកម៉ាកកំពូលស្នេហ៍ផស់បងក៏កុហកថាការពិតគឺខ្ញុំនិងគេទេដែលសេពគប់គ្នា ដើម្បីឱ្យ ក្វាងមីន រួចខ្លួន"

"អ្ហ៎...ការពិតវាធ្វើព្រោះចង់ជួយសាច់ញាតិវាអីចឹងអ្ហ៎?"

អ៊ុយ បងប្រុស មកបញ្ជាក់ន័យឱ្យខ្ញុំរឹតតែតូចចិត្តដល់ណាទៀត?

"គឺទំនងហ្នឹងអ្ហែង"

"អ្ហឺ បើវាសុំអង្វរឱ្យឯងជួយ ឯងក៏ជួយៗវាបន្តិចទៅ..."

"..."

"តែឯងវិញ ហេតុអីបានសុខៗទៅយល់ព្រមជួយវា កុំប្រាប់ថាគិតផ្ដេសផ្ដាសចង់យកវាមកទុកការពារខ្លួនទៀត"



"អ្នកណាថា? ដែលខ្ញុំយល់ព្រមជួយគេនោះ ព្រោះតែគេសន្យាថានឹងយល់ព្រមប្រាប់ចំណាងជើងគ្រោងការណ៍សម្ងាត់ឱ្យខ្ញុំដឹងតើ"



"ហេ៎- ហើយឯងក៏ជឿវា"

"បានន័យថា ការពិតទៅគេបោកប្រាស់ខ្ញុំអ្ហេស?"

"ហ៊ើយ...ហ្នឹងឯងមិនយល់អ្វីដែលបងនិយាយមែនអ្ហ៎?"

"មែន!"

"ឯងមើលមិនធ្លុះអ្ហេសថាវាកំពុងតែចង់ធ្វើអី?"

"..."

ម្ដងនេះខ្ញុំនៅស្ងៀម មិនហ៊ានឆ្លើយថា មែន ព្រោះខ្លាចត្រូវបងប្រុសបន្ថែមថាភ្លើ នាំឱ្យឈឺចិត្តលេងម្ដងទៀត ។

"ឯងស្រឡាញ់វាអត់?"

"..."

ខ្ញុំស្ងាត់ម្ដងទៀត ពេលប៉ះសំនួរចំចំណុចប៉ុកៗតែម្ដង ការពិតទៅខ្ញុំដូចជាប្រាកដក្នុងចិត្តហើយ ខ្ញុំក៏ស្រឡាញ់គេខ្លះៗដែរ តែ...បើលោតែគេមិនបានស្រឡាញ់ខ្ញុំដូចដែលខ្ញុំយល់នោះ ឱ្យខ្ញុំធ្វើម៉េចទៅ មិនត្រូវខូចចិត្តទាល់តែឆាប់ទេអ្ហី?

"ខ្ញុំថាបងប្រាប់ខ្ញុំម៉ោល្អជាង ថាការពិតទៅគេកំពុងគិតប្រុងធ្វើអីឱ្យប្រាកដ?"

"ស្អី បងបង្ហើបដល់ថ្នាក់ហ្នឹងហើយ ឯងនៅមិនដឹងទៀតឬ?"

"..."

អើ សុំទោសផងចុះដែលកើតមកល្ងង់ ។



## ភាគទី១១

## បង់មបន...ឆ្ពោះទៅរកការធ្វើជាគូស្នេហ៍ (ក្លែងក្លាយ)???

ថ្ងៃបន្ទាប់មក...

ព័ត៌មានដែលខ្ញុំឈប់សេពគប់ ក្វាងមីន បានផ្សព្វផ្សាយពេញមហាវិទ្យាល័យ ហើយសម្លេងខ្សឹបខ្សៀវក៏រឹតតែឮច្រើនឡើងនៅពេលថ្ងៃនេះមានបុរសថ្មីម្នាក់មកឈរនៅអាគារផ្នែកគណនេយ្យ ។

"អុំយ!!! ទុំះ សិស្សច្បង គុនជេ មែនទេ រូបពិតសង្ហាដូចឃើញនៅក្នុងរូបថតមែន"

"ឡូយមែនទែន...គ្រាន់តែឈរស្ពាយកាបូបក៏ឡូយអស់ស្ទះដែរ តែ...គេមកធ្វើអីនៅកន្លែងយើងហ្នឹង តាមធម្មតាខ្ញុំឮថានៅតែអាគារផ្នែករបស់គេទេ..."

"ស្លាប់ហើយ!!! ខ្ញុំសុំស្លាប់ អេនដែល ជាលើកទីពីរហើយ...លើកមុនជាសង្សារ អ៊ូ ក្វាងមីន លើកនេះធ្វើឫកដូចជាសង្សារសិស្សច្បងទៀត ដូចជាជ្រុលពេកហើយអ្វីយាយប៉ិមួយនេះ"

"សង្ស័យដូងជតា អេនដែល ត្រូវធាតុនឹងព្រេនស័រាសីធ្ងហើយ..."

"គួរឱ្យច្រណែនមែន សង្ស័យជាតិនេះខ្ញុំត្រូវធ្វើបុណ្យដោយផ្លែព្រូញឱ្យច្រើនៗហើយ ដើម្បីឱ្យជាតិក្រោយកើតម៉ោមានសង្សាររាសីធ្ង ហ៊ាៗ"

អ៊ុំ នេះសម្ដែងថាជាតិមុនខ្ញុំធ្វើបុណ្យដោយផ្លែព្រូញច្រើនហើយ (បញ្ឆិ) យាយប៉ិអស់នោះចំជាប៉ិនគិតមែន ។

ទោះស្ដាប់មើលទៅដូចជាកំប្លែង តែការទៅពិតខ្ញុំគ្មានអារម្មណ៍សើចអីបន្តិចសោះ មានអារម្មណ៍ឈឺចិត្តគ្រប់ពេលនឹកឃើញថា ការពិតខ្ញុំនិងគេសេពគប់គ្នាដើម្បីបន្លំភ្នែកប្អូនស្រីជីដូនមួយគេប៉ុណ្ណោះ មិនមែនសេពគប់គ្នាមែនទែន ដូចអ្នកឯទៀតយល់នោះទេ ។



ពេលដែលឃើញគេឡើងជណ្ដើរមក ខ្ញុំក៏គិតថាធ្វើជាមើលមិនឃើញគេ ហើយបន្លំដើរគេចទៅជិះឡានខ្លួនឯងតែម្ដង ល្អដែរទេ ។

តែ...ទីបំផុតក៏សម្រេចចិត្តចាំនៅកន្លែងដើម ហើយប្រយោគដំបូងដែលគេនិយាយ ធ្វើឱ្យខ្ញុំប៉ិះស្លាក់ទឹកមាត់ខ្លួនឯង ភ្លេចរឿងគួរឱ្យសោកសៅនោះភ្លាមតែម្ដង ។

"មិញពេលដើរចូលមក ខ្ញុំឮសូរមិត្តភក្តិនាងម្នាក់និយាយថាខ្ញុំឡប់សតិដល់ថ្នាក់ស្រឡាញ់ស្រីដំបៅស្បូន" គេនិយាយធ្វើព្រងើយ តែក្នុងខ្សែភ្នែកមានបង្កប់ស្នាមអស់សំណើច ។

ក្រឹត!

ខ្ញុំចាំបាច់ត្រូវទប់សំណើច និង ធ្វើទឹកមុខឱ្យធម្មតា ។

នេះបើមិនមែនប៉ះពាល់ចំខ្លួនឯងទេ ខ្ញុំបែបសើចចំអកឱ្យគេបាត់ទៅហើយ តែនេះ...ហ៊ានតែសើច មានតែឡូងម៉ោខ្លួនឯងវិញ ។

"រឹតតែសើចរឹតតែឡូងម៉ោខ្លួនឯងវិញ" គេធ្វើជានិយាយបន្ដើរៗដោយបំណងល្អ ។

ង៉ក់!

ហ្នឹងហើយ! ឡូងមកវិញខ្លាំងទៀតផង តែ...វាគួរឱ្យអស់សំណើចមែនណាំ ។

"..."

"ថ្ងៃនេះខ្ញុំអត់បានយកឡានម៉ោ តាំងចិត្តថាម៉ោសុំដោយសារឡាននាង..."

"ហើយម៉េចក៏លោកចាំបាច់ម៉ោសុំដោយសារឡានខ្ញុំ ឡានខ្លួនឯងក៏មានហេតុអីមិនយកម៉ោ?"

"ភ្លេចហើយអ្វី ថាយល់ព្រមរឿងអីជាមួយខ្ញុំ?" គ្រាន់តែគេរំលឹករឿងកិច្ចសន្យា ខ្ញុំក៏មានអារម្មណ៍ឈឺចិត្តម្ដងទៀត ។

"ក្រែងពេលនោះលោកប្រាប់ថាមួយអាទិត្យទៀតអ្វី បានប្អូនស្រីរបស់លោកម្នាក់ហ្នឹងត្រឡប់មកវិញ?"

"យើងគួរតែចាប់ផ្ដើមមុនឱ្យហើយ ដល់ពេលចូលសមរភូមិមែន



ទេនកុំឱ្យភ័យ..."

"ថ្ងៃនេះតែម្ដងផ្អេស?"

"មិនមែនថ្ងៃនេះ តែគឺពេលនេះតែម្ដង" និយាយចប់ គេក៏ទាញយកកូនសោឡានពីដៃខ្ញុំ ហើយស្រវាចាប់កដៃខ្ញុំដើរទៅរកឡានធ្វើព្រងើយ ។

ដំបូងខ្ញុំគិតថាគេនឹងបើកទ្វារឱ្យខ្ញុំចូលអង្គុយ តែបែរជាប្រាប់ឱ្យខ្ញុំបើកខ្លួនឯង ព្រមទាំងអធិប្បាយថា÷

"ខ្ញុំនឹងធ្វើតែរឿងណាដែលខ្ញុំគិតថានឹងធ្វើទៅបានរហូតចប់ចុងចប់ដើម តែអ្វីដែលធ្វើបានតែដំបូងៗ ដូចជាការបើកទ្វារឡានឱ្យគ្នានេះប្រហែលមិនធ្វើទេ ព្រោះដល់យូរទៅចាប់ផ្ដើមខ្ជិល ទីបំផុតក៏នឹងត្រូវយកម៉ោប្រៀបធៀបថា មុនពេលសេពគប់គ្នា និងក្រោយពេលសេព-គប់គ្នា មានអីប្រែប្រួលយ៉ាងម៉េចខ្លះមិនខាន"

ថាៗទៅ...ក៏ត្រូវផស់គេដែរ អាពួកដែលសេពគប់គ្នាថ្មីៗ ធ្វើផ្អែមល្ហែម យកចិត្តយកថ្លើមគ្នាសព្វបែបយ៉ាង នៅជុំវិញខ្លួនស្ទើរតែក្លាយជាពណ៌ផ្កាឈូក តែដល់យូរទៅ ម្នាក់ៗចាប់ផ្ដើមធុញ ជ្រក់ជ្រេញពេលណាក៏ចូលពាក្យថា ដូរព្រីខ្នងដៃទៅបាតជើង បែបហ្នឹងសឹងគ្រប់គ្នា ។

"លោកគិតល្អិតល្អន់ស៊ីជម្រៅបែបហ្នឹងគ្រប់តែរឿងផ្អេស?"

"ធម្មតា...ខ្ញុំជាមនុស្សដែលនិយាយអីហើយត្រូវតែបំបែកន័យតែចំពោះនាង...មិណាម ធ្លាប់ប្រាប់ហើយថា បើខ្ញុំធ្វើតាមទម្លាប់ នឹងធ្វើឱ្យនិយាយជាមួយនាងមិនដឹងរឿង"

អ្ហា? បងប្រុសបន្ទំថាឱ្យខ្ញុំតើ ហើយស្អីហ្នឹង មានយករឿងខ្ញុំទៅនិយាយឱ្យពួកម៉ាកស្ដាប់ទៀត យ៉ាប់មែនទែន!

"ខ្ញុំមិនមែនជាមនុស្សពិបាកយល់ដល់ថ្នាក់ហ្នឹងទេ! ខ្ញុំមិនយល់តែរឿងដែលលោកនិយាយខ្លះៗប៉ុណ្ណោះ" តែដែលប្រាកដបំផុតនោះគឺខ្ញុំមិនយល់សោះ...ថាតើគេគិតយ៉ាងម៉េចចំពោះខ្ញុំ ។

"..."

"ថ្ងៃមុនខ្ញុំអានបទសម្ភាសរបស់លោក...តើជាការពិតទេដែលលោកទទួលតំណែងនេះព្រោះមានហេតុផលផ្ទាល់ខ្លួន?" ខ្ញុំសួរ ព្រម

ទាំងផ្អៀងខ្លួនលូកដៃទៅយកនំនៅកៅអីក្រោយមកបើកញ៉ាំ ព្រោះពេលនេះនៅមុខមហាវិទ្យាល័យឡានស្ទះសម្បើមណាស់ ។



"នាងបានអានបទសម្ភាសនោះមែនឬក៏អត់ ខ្ញុំចាំបានថាខ្ញុំឆ្លើយឃ្លៀវហើយ"

ឃ្លៀវត្រង់ណាទៅ? គេឆ្លើយថាសុំអត់ជម្រាបលំអិតថាហេតុផលនោះគឺអ្វីផង បែបហ្នឹងផ្អេហៅថាឃ្លៀវនោះ?

"ដែលខ្ញុំសួរគឺបានន័យថាហេតុផលដែលលោកលាក់នោះគឺអ្វី?"

"វាជាហេតុផលតូចតាច តែសំខាន់ខ្លាំងណាស់" គេឆ្លើយដោយសម្លេងមហាធម្មតា តែខ្សែភ្នែកបែរជាជះរស្មីស៊ីជម្រៅដែលខ្ញុំនៅតែមិនអាចស្មានយល់អត្ថន័យដដែល ។

"ការពិតទៅ អាតំណែងកម្លោះក្នុងក្ដីសុបិនផស់លោកហ្នឹង ខ្ញុំនៅមិនទាន់ប្រាកដសោះ ថាតើវាជាសុបិនល្អឬក៏អាក្រក់?"

"បើនាងប្រាប់ថាជាសុបិនល្អ ខ្ញុំនឹងគិតថានាងជាមនុស្សក្លែងក្លាយ"

"..."

"ការពិតទៅ ហេតុផលដែលខ្ញុំទទួលយកតំណែង ព្រោះតែ...ខ្ញុំភ្លេចខ្លួនបន្តិច"

"ភ្លេចខ្លួន?"

"ជាធម្មតា ខ្ញុំតែងសម្រេចចិត្តអ្វីតាមគំនិតខ្លួនឯងជាគោល តែសម្រាប់រឿងនេះ...ខ្ញុំបែរជាសម្រេចចិត្តតាមគំនិតអ្នកដទៃ"

"..."

"ហើយអ្នកដទៃដែលថានោះ គឺជាមនុស្សដែលខ្ញុំ...មិនសូវស៊ីខ្សែជាមួយទៀតផង"

"..."

"ទើបវាក្លាយជាហេតុផលតូចតាច តែសំខាន់ខ្លាំងណាស់"

"..."

"ការពិតពេលនេះ ខ្ញុំក៏នៅមានអារម្មណ៍មួយម៉ោនឹងខ្លួនឯងតិចតួចដែរដែលសម្រេចចិត្តទទួលយកតំណែងនេះ ព្រោះមែនទែនទៅ



រាល់ថ្ងៃនេះខ្ញុំក៏នៅតែមិនសូវស៊ីខ្សែនឹងមនុស្សម្នាក់ហ្នឹងដដែល"

"ខ្ញុំមិនយល់ទេ ជួយពន្យល់ឲ្យបាច្បាស់លាស់ស្រួលយល់ជាងហ្នឹងបន្តិចបានទេ?"

"ការពិតក៏មិនមែនអ្នកណាផ្សេងដែរ តែជាមនុស្សសំខាន់"

"ម្តងនេះរឹតតែលែងយល់ខ្លាំងជាងមុនទៅទៀត"

"បើខ្ញុំចង់ឲ្យនាងយល់ពេលណា ខ្ញុំនឹងឆ្លើយបែបធ្វើឲ្យនាងយល់បានស្រួលដោយខ្លួនឯង"

"..."

ហ៊ឺ...វាខានសរសៃប្រសាទមែនទែន!

"នាងឃ្លាន?" គេក្រឡេកមើលថង់នំក្នុងដៃខ្ញុំដែលពេលនេះស្រកអស់កន្លះថង់ហើយ ព្រមទាំងសម្លឹងខ្ញុំដោយខ្សែភ្នែកគរាំតិចៗដែលញ៉ាំតែម្នាក់ឯង មិនបបួលគេញ៉ាំផង ។

"តិចតួច...ហើយខ្ញុំក៏អត់ហៅលោកញ៉ាំដែរ ទាល់តែលោកយល់ព្រមប្រាប់ថា ព្រោះតែអ្វីបានលោកសុខចិត្តទទួលតំណែង Prince of Zadiac"

"គ្មានត្រូវជាស្អីនឹងខ្ញុំសោះ តែបែរជាចង់ដឹងរឿងរបស់ខ្ញុំទាំងអស់" គេនិយាយធ្វើមុខព្រងើយ តែអ្នកស្តាប់ដូចខ្ញុំបែរជាមុខក្រហមសឹងតែដល់ស្លឹកត្រចៀក ។

"ដែលចង់ដឹងព្រោះថាប៉ុន្មានថ្ងៃទៀត ខ្ញុំត្រូវសម្តែងជាគូស្នេហ៍បណ្តោះអាសន្នឲ្យលោកទេតើ មិនអីចឹង ខ្ញុំក៏មិនចង់ដឹងដែរ"

"ចង់ដឹងអី សួរបាន!"

"..."

"តែអត់សន្យាទេ ថានឹងឆ្លើយ!"

"បើអីចឹង ខ្ញុំអត់សួរវិញល្អជាង ព្រោះបើសួរទៅ លោកក៏លាក់មិនព្រមប្រាប់ដដែល"

"បើមិនបានជាស្អីនឹងគ្នាមែនទែនផង ហេតុអីខ្ញុំត្រូវប្រាប់នាង"

"បានន័យថាបើជាស្អីជាមួយលោកមែនទែន លោកនឹងយល់ព្រមប្រាប់មែនទេ?"

"គឺវាគួរតែបែបហ្នឹងអ៊ែង" គេឆ្លើយ ព្រមទាំងសម្លឹងមើលខ្ញុំដោយខ្សែភ្នែកដែលពិបាកស្មានយល់ដូចសព្វដង តែ...អាខ្សែភ្នែកដែលពិបាកយល់នេះហើយ ធ្វើឲ្យខ្ញុំមុខឡើងក្រហមច្រើនដងហើយ ។

"..."



ដោយសារតែថ្ងៃនេះឡានស្ទះខ្លាំងពេក ព្រោះថ្នល់ខាងមុខត្រូវបិទអស់ពីរផ្លូវ ដើម្បីរៀបចំពិធីបុណ្យអ្វីម្យ៉ាងរបស់អ្នកនៅម្តុំហ្នឹង គេក៏សម្រេចចិត្តបត់ឡានចូលផ្សារទំនើបបណ្តោះអាសន្នសិន ចាំឲ្យថ្នល់ស្រឡះបន្តិចសឹមបើកចេញទៅ ។

នៅក្នុងផ្សារមានមនុស្សច្រើនណាស់ ក៏មានអ្នកស្គាល់គេច្រើនលើសពីការគិតរបស់ខ្ញុំទៅទៀត ព្រោះមុនបានតំណែង Prince of Zodiac ក៏មានអ្នកស្គាល់ច្រើនរួចស្រេចទៅហើយ ព្រោះជាកូនប្រុសរបស់លោកមេបញ្ជាការទ័ពជើងគោក ។

ខ្ញុំមានអារម្មណ៍រាងអៀនៗដែរ ពេលដឹងថាខ្លួនឯងកំពុងស្ថិតនៅក្រោមខ្សែភ្នែករបស់អ្នកដទៃ ខុសពីគេដែលធ្វើមិនដឹង និងធ្វើដូចអ្វីៗគ្រប់យ៉ាងនៅជុំវិញខ្លួនគ្មានអ្វីប្លែក ។

តែខ្ញុំក៏មានអារម្មណ៍ធុញទ្រាន់តិចតួចដែរ ពេលបានឮសម្លេងមនុស្សនិយាយបង្កើរៗមកជាទំនងថា ស្បូនមានដំបៅ ឬក៏មិនងាយមានកូន អីៗអស់ហ្នឹង ។

"សម្រេចថាពេលនេះ នារីក្នុងក្តីស្រមៃរបស់ខ្ញុំគឺជានារីដែលស្បូនមានដំបៅអ៊ំ" គេងាកមកនិយាយ ព្រមទាំងលើកចិញ្ចើមបន្តិចដោយមានចេតនាចង់លេងនឹងខ្ញុំ ។

"ម៉េច...ឬក៏លោកស្អប់ខ្ពើម?"

"បើស្អប់ខ្ពើម ព្រមដើរជាមួយអ្វី?" គេឆ្លើយទាំងញញឹម មុននឹងដើរនាំមុខខ្ញុំចូលទៅក្នុងភោជនីយដ្ឋានជប៉ុន ហើយជ្រើសរើសអង្គុយតុនៅកណ្តាលចំតែម្តង ។

"នែ៎ ម៉េចក៏លោកមិនរកតុណាកៀនៗ ចាំងៗ បន្តិចទៅ គ្មានអារម្មណ៍អៀនទេអ្វី ដែលមានតែអ្នកសម្លឹងមើលបែបនេះ?"



"អត់ទេ! អ្នកណាចង់មើលឲ្យគេមើលទៅ!"

ស្លាប់ហើយ អាម្សៀនេះធ្វើខ្លួនគ្មានខ្វល់អីទាំងអស់!

"តែយើងអត់បានសេពគប់គ្នាមែនទែនទេ ពីរអាទិត្យទៀត ឈប់ទាក់ទងគ្នាហើយ" និយាយផងឈឺចិត្តផង ហេតុអីបានរឿងរ៉ាវខ្ញុំនិងគេជារឿងកុហកបែបនេះ ។

"នៅចាំបានថា ខ្ញុំអត់ទាន់បានប្រាប់ថាយើងនឹងឈប់ទាក់ទងគ្នាអញ្ចាល់ទេ!"

"បើអីចឹង...កំណត់រយៈពេលគ្នាតែម្តងទៅថា យើងនឹងឈប់ទាក់ទងគ្នាពេលណា...ពីរអាទិត្យល្អដែរទេ?"

"..."

"..."

"..."

តែ...សុខៗ គេក៏ស្ងាត់អស់មួយសន្ទុះ មុននឹងមើលខ្ញុំដោយកែវភ្នែកភ្លឺចាំង ហាក់ដូចជាមិនពេញចិត្តនឹងអ្វីម្យ៉ាង ធ្វើឲ្យខ្ញុំត្រូវប្រញាប់និយាយបន្តដើម្បីកុំឲ្យស្ថានការណ៍វាមើលទៅកាន់តែគួរឲ្យខ្លាចខ្លាំងជាងនេះ...

"សម្រេចថាលោកអត់ដូរគុទេមែនទេ?"

"ខ្ញុំជាមនុស្សមិនចូលចិត្តធ្វើអីស្អាក់ស្ទើរ បើសម្រេចចិត្តថាធ្វើហើយ ត្រូវតែធ្វើឲ្យដល់ទីបំផុត"

"បានន័យថា ទោះគ្រាន់តែជាការសេពគប់គ្នាបែបបន្លំៗមែន តែលោកក៏នៅតែព្យាយាមធ្វើឲ្យវាដូចមែនទែនដែរអីចឹងមែនទេ?"

"..." ការដែលគេមិនឆ្លើយ វាស្មើនឹងការទទួលស្គាល់តិចៗថា ខ្ញុំយល់បានត្រឹមត្រូវគ្រប់យ៉ាងពាក់ព័ន្ធនឹងពិធីការរបស់គេហើយ ។

"សួរតាមត្រង់ ធ្វើបែបហ្នឹង...លោកអត់មានគិតខ្លះទេអ្វីថា អ្នកផ្សេងមានអារម្មណ៍យ៉ាងម៉េចនោះ?"

"អ្នកផ្សេងដែលថាហ្នឹង...គឺនាងមែនទេ?"

"..."

"កុំហៅខ្លួនឯងថាអ្នកផ្សេង"

"..."

"ហើយខ្ញុំក៏ចង់ប្រាប់អ្វីនាងម្យ៉ាងដែរ"



"..."

"កុំបញ្ចេញអាការៈឲ្យខ្ញុំចាប់បានថានាងកំពុងតែគិតអីឲ្យសោះ ព្រោះបើខ្ញុំចាប់បាន...ធានាថានាងទប់ទល់នឹងខ្ញុំមិនរួចទេ"

ខ្ញុំព្យាយាមសម្លឹងមុខគេដើម្បីស្វែងរកអត្ថន័យពីសម្តីដែលគេនិយាយ តែ...បែរគ្មានឃើញអ្វីក្រៅពីភាពទទេស្អាត ។

"ដែលលោកនិយាយស្តីឲ្យខ្ញុំវិលខ្វូរបែបនេះ ព្រោះតែលោកត្រូវការសងសឹករឿងដែលខ្ញុំធ្លាប់ចោទប្រកាន់លោក ហើយនិងរឿងដែលខ្ញុំធ្លាប់ជាន់ម៉ូតូដែលជាសលោកខ្ទេចនោះមែនទេ?"

"..."

"ម៉េច...ដែលអត់ឆ្លើយ ព្រោះតែខ្ញុំនិយាយត្រូវទៀតមែនទេ?"

"ទេ!"

"...?"

"ដែលខ្ញុំស្ងាត់...ព្រោះខ្ញុំកំពុងគិតថា តើលើកក្រោយខ្ញុំត្រូវនិយាយជាមួយនាងយ៉ាងម៉េចឲ្យស្រួល...ដើម្បីកុំឲ្យអន្លុយចាំប្រែពាក្យរ៉ៅកូរ៉េឲ្យនាងស្តាប់ម្តងទៀត..."

"...!"



## ភាគទី១២
## កូនប្រសាស្រីរូបស្រស់

ព្រឹកថ្ងៃបន្ទាប់...

អ្វីដែលខ្ញុំមិនយល់ថាហេតុអីបានជាម្សិលមិញគេជ្រើសរើសអង្គុយគុនៅចំកណ្ដាលហាង ពេលនេះខ្ញុំហាក់ដូចជាដឹងច្បាស់បន្តិចម្ដងៗហើយ ។

វាព្រោះតែគេមានចេតនាធ្វើឱ្យកើតព័ត៌មានជាមួយខ្ញុំហ្នឹងអ្ហែង ព្រោះកាសែតសង្គមដែលតែងតែចុះផ្សាយព័ត៌មានខ្សឹបខ្សៀវរបស់ពួកអ្នកមាន មហាសេដ្ឋី និងតារាល្បីទាំងឡាយក្នុងស្ថាប័នយោធា និងប៉ូលិស បានចុះផ្សាយពីខ្ញុំនិងគេពេលទៅញ៉ាំបាយជាមួយគ្នានៅភោជនីយដ្ឋានជប៉ុនកណ្ដាលផ្សារទំនើបល្បីឈ្មោះ ព្រមទាំងសរសេរចំអន់លេង ហើយថែមទាំងធ្វើឱ្យអ្នកអានដូចខ្ញុំឈឺអួលមិនស្ទើរទេ ។

'លោកមេទ័ពត្រៀមទៅស្ដីដណ្ដឹងកូនប្រសាស្រីរូបស្រស់ហើយ
តែ ហាន់គុនជេ លេងបណ្ដើរស្រីស្រស់រាងស៊ិចស៊ី
បង្ហាញដល់អ្នកសារព័ត៌មាន កាត់មុខបែបនេះ
តើមានចេតនាសាកចិត្តលោកមេទ័ពឬក៏អត់ប្រុសសង្ហា?!?'

ខ្ញុំបត់កាសែតទុក ហើយឡើងទៅបន្ទប់ គិតថាចង់គេងសម្រួលចិត្តបន្តិចសិនទៅមហាវិទ្យាល័យ តែ...ក្នុងខួរក្បាលពេលនេះបែរជាមានតែពាក្យថា កូនប្រសាស្រីរូបស្រស់ អណ្ដែតទៅមករហូតខ្ញុំវិលមុខមែនទែន ។

ដាប់ហើយ ក្នុងពេលដែលគេមានអ្នកដែលត្រូវរៀបចំឱ្យរួចទៅ



ហើយ ម៉េចក៏មករវល់នឹងខ្ញុំធ្វើអី?

វិនាទីនោះអ្ហែង...សំនួរក៏ផុសនៅក្នុងចិត្តខ្ញុំ...

បើគេមាននារីដែលអ្នកផ្ទះសម្លឹងទុកហើយបែបនេះ អាចទៅរួចទេថាដែលមកសុំឱ្យខ្ញុំជួយធ្វើជាសង្សារ ដើម្បីគេចពីការចាប់ប្រដល់ដូចខ្ញុំ និង ក្វាងមីន ធ្លាប់ធ្វើ ហើយរឿងដែលធ្វើឱ្យប្អូនស្រីគេឈប់សង្ស័យ ក្វាងមីន នោះក៏ជាហេតុផលមួយដែរ ចូលន័យព្រួញមួយបាញ់បានសត្វពីរហ្នឹងអ្ហែង ។

ហើយចុះបើវាបែបហ្នឹងមែន តើខ្ញុំត្រូវធ្វើយ៉ាងម៉េចទៅ?

ខ្ញុំស្រឡាញ់គេបាត់ទៅហើយ ខណៈពេលដែលនៅមិនដឹងផងថាតើគេស្រឡាញ់ខ្ញុំវិញឬក៏អត់នោះ? ។

ហើយ...នៅក្នុងបទសម្ភាសនោះ...គេឆ្លើយយ៉ាងច្បាស់លាស់ថា នៅមិនទាន់បានចាប់អារម្មណ៍ស្រីណាទាំងអស់ ។

គុក...គុក!

"អេនជែល នៅក្នុងបន្ទប់អត់ហ្នឹង? គុនជេ ម៉ោរក!"

"..."

"នែ៎! អេនជែល គេងលក់ឬស?"

"អ្ហឺ ខ្ញុំកំពុងគេង"

"តែពេលនេះឯងភ្ញាក់ហើយ អីចឹងរៀបចំខ្លួនឱ្យរៀបរយ ហើយចុះម៉ោជួបវាបន្តិច ឮប្រាប់ថាមានរឿងសំខាន់ចង់និយាយជាមួយ"

"ហ៊ឹស! បែបរឿងកូនប្រសាស្រីរូបស្រស់ហើយមើលទៅ!"

"ឯងនិយាយស្អីហ្នឹង ស្ដាប់មិនយល់! មកមើលទៅដឹង?"

"អ្ហឺៗ តិចទៀតខ្ញុំចុះទៅ!" ខ្ញុំបញ្ចប់សេចក្ដី ហើយបន្លំពន្យារមួយសន្ទុះទៀត ព្រោះការពិតខ្ញុំផ្ទួតទឹកស្មៀកពាក់រួចរាល់ហើយ ។

បន្ទប់ទទួលភ្ញៀវ...

"លោកម៉ោធ្វើអីទាំងព្រឹក?" ខ្ញុំសួរដោយសម្លេងគោះកើយ ហើយមានចេតនាដើរទៅអង្គុយនៅសាឡុងដែលនៅឆ្ងាយពីគេបំផុតដើម្បីជាការគោរព ។





"ខ្ញុំចៀងមកទទួលទៅសាលាជាមួយគ្នា" គេឆ្លើយហាក់ដូចជាមិនដឹងពីអាការៈតវ៉ារបស់ខ្ញុំ ។

"តែថ្ងៃនេះខ្ញុំគិតថាអាចនឹងអត់ទៅ"

"នាងមិនមែនជាមនុស្សដែលរៀនចាប់ឆេះទេ ដូច្នេះមិនគួរគេចសាលាឡើយ!"

ហ្នឹងគេបន្ទំថាខ្ញុំល្ងង់តើ ហ៊ឹស! ត្រូវហើយ អ្នកណាទៅឆ្លាតដូចកូនប្រសាស្រីរូបស្រស់ ម្នាក់នោះរបស់គេដែលឆ្លាតវាងវៃដល់ថ្នាក់អ្នកផ្ទះចង់ឱ្យគេរៀបការជាមួយនោះ ។

"បើខ្ញុំល្ងង់ លោកមករស់ជាមួយខ្ញុំធ្វើអី?"

"សម្រេចថាអត់ទៅសាលា?" គេនៅតែសួរដោយចិត្តត្រជាក់ដូចមើលមិនដឹងថាខ្ញុំកំពុងមួម៉ៅខ្លាំងប៉ុណ្ណា ។

"ថ្ងៃនេះខ្ញុំអត់ស្រួលខ្លួន!" ខ្ញុំនិយាយម៉ាត់ៗ មុខមាំ ។

"ប្រហែលមិនមែនស្បូនមានដំបៅទេ?"

"នែ៎ លោក! កុំម៉ៅចំអក!!!" ខ្ញុំបែរទៅស្រែកដាក់គេ រហូតដល់ត្រូវបងប្រុសបន្ទោស...

"វាថីឯង មួម៉ៅសម្បើមម្ល៉េះ គុនដេ គ្រាន់តែនិយាយលេងសោះ"

ទៀតហើយ បងប្រុសកាន់ជើងគេទៀតហើយ!!!

"បើបងកាន់ជើងគេបែបនេះ ម៉េចបងមិនដេញខ្ញុំចេញពីផ្ទះហើយយកគេមកធ្វើប្អូនប្រុសតែម្តងទៅ!"

"ចុំម? ឯងកើតឆ្កួតអីហ្នឹង? ក្រញូវទាំងព្រឹកហ្នឹង ថ្ងៃហ្នឹងម៉ោរដូវទេដឹង?"

ខ្ញុំខាំមាត់ណែន មិនចង់និយាយអីឱ្យខ្លួនឯងត្រូវមួម៉ៅខ្លាំងជាងនេះទៀតទេ ក៏សម្រេចចិត្តបែរខ្លួនប្រុងទៅបន្ទប់វិញ តែ...

"ហ្នឹងម្តេសអ្នកជម្ងឺ អត់មានឃើញដូចអីបន្តិច!" គេឈានជើងវែងៗមកស្រវាចាប់កដៃខ្ញុំជាប់ មុននឹងបែរទៅមើលបងប្រុស "សុំខ្ចីខ្លួនប្អូនស្រីបន្តិច មីណាម ចាំព្រលប់ៗយកម៉ោឱ្យវិញ"

"អឺ យកទៅ ខ្ញុំលើកឱ្យ តែបើវានៅតែក្រញេវក្រញូវបែបនេះ មិនបាច់យកមកឱ្យវិញទេ"



"បងប្រុស!!!"

"ហ៊ុ...បងថាឯងកុំទៅសម្រេចរឿងស្អីពីការស្រមើស្រមៃល្ងង់ៗផស់ឯងហ្នឹងល្អជាង"

"...ហ្នឺ...ហ្នឹងម៉េចបានបងដឹង ខ្ញុំមិនទាន់និយាយអីមួយម៉ាត់ផង"



"ឯងបែរមកមើលមុខបង ហើយឆ្លើយម៉ោមើល៍ថាបងជានរណា ...បងនេះបងប្រុស បងប្រុសឯងពីយ បងនៅជាមួយនិងមើលថែឯងច្រើនជាងចាំនិងម៉ាក់ទៅទៀត..."

ត្រូវហើយ ចាំម៉ាក់មានការងាររវល់ជានិច្ច គ្មានពេលមើលថែយកចិត្តទុកដាក់ពួកខ្ញុំប៉ុន្មានទេ រាល់ថ្ងៃនេះមានតួនាទីឱ្យលុយតែម្យ៉ាងគត់ ដោយហេតុនេះអ្ហែង ទើបបងប្រុសដឹងរឿងផ្ទាល់ខ្លួនរបស់ខ្ញុំច្បាស់ជាងចាំម៉ាក់ទៅទៀត ។

"តែ..."

"ឈប់គិតផ្តេសផ្តាសនឹងការស្រមើស្រមៃល្ងង់ៗផស់ឯងហ្នឹងទៅ ហើយក៏ប្រញាប់ទៅជាមួយវាទៅ កុំឱ្យហួសពេលទាន់"

"..."

"ល្ងង់ៗដូចឯង បងក៏យល់ដូច គុនដេ ដែរថា គួរតែទៅរៀន ហើយម៉ោផ្ទះរៀនឡើងវិញទៀត"

"..."

"ព្រោះមុខដូចឯង គ្មានបញ្ញាយល់អ្វីដោយខ្លួនឯងទេ បើគ្មានគ្រូជួយដឹកនាំ"

"..."

ដោយហេតុផលនេះ ខ្ញុំក៏ចាំបាច់ទៅមហាវិទ្យាល័យជាមួយគេដោយខានមិនបាន ដោយមានបងប្រុសជួយញញ្ញប្រាននឱ្យខ្ញុំឡើងឡាន ។

តែ...នៅតាមផ្លូវ គេអត់មាននិយាយរឿងនោះឡើយ អត់មានអធិប្បាយពន្យល់រឿងពិតមាននោះឱ្យខ្ញុំបានសប្បាយចិត្តឡើយ រហូតដល់ខ្ញុំក្លាយជាអ្នកដេញដោលសួរមុន÷

"ស្រីម្នាក់នោះជានរណា...?"



"ចង់និយាយពីនរណាមួយ?"

"បានន័យថាមានច្រើននាក់..."

"ច្រើននាក់ឯណា មានតែម្នាក់ទេ" គេឆ្លើយដោយសម្លេងរាបស្មើ តែទឹកមុខបែរជាមានលាយឡំស្នាមញញឹម ។

"លោកមានហេតុនាឆ្លើយឱ្យខ្ញុំរីលាស់មែនទេ? ដឹងថាខ្ញុំមិនសួរ ច្ឆោតក៏តាំងចិត្តឆ្លើយឱ្យយកទៅគិតច្រើនដំណាក់កាល ដើម្បីដោះខ្លួនអីចឹងឆ្អិស?"

"នាងមិនសួរឆ្លោតមែនហ្នឹងអ្អែង មិនអីចឹងប្រហែលជាស្មានគំនិតខ្ញុំត្រូវទាំងអស់តាំងពីយូរណាស់ហើយ"

"សម្រេចថាដែលលោកមកសុំឱ្យខ្ញុំបន្លំធ្វើជាសេពគប់លោក ដើម្បីបំភ័ន្តភ្នែកប្អូនជីដូនមួយនោះជារឿងពិត មិនមែនយកខ្ញុំទៅធ្វើជារនាំងការពារស្រីដែលអ្នកផ្ទះលោករកឱ្យនោះទេ មែនទេ?"

"ឬក៏នាងចង់ឱ្យខ្ញុំធ្វើបែបនោះ?" គេសួរបកមកវិញ ដោយអត់អធិប្បាយបន្ត ដែលរាំស្មើនឹងការប្រាប់ខ្ញុំបែបបង្កើរៗដែរថា មិនមែនដូចខ្ញុំយល់ឃើញនោះទេ ។

"យ៉ាងណាក៏ខ្ញុំនៅតែសង្ស័យដែរថា ស្រីម្នាក់នោះជានរណា?"

"នាងស្មានទាល់តែស្លាប់ក៏គ្មានថ្ងៃត្រូវដែរ" គេឆ្លើយធម្មតា តែកែវភ្នែកមុតស្រួចបែរជាបង្កប់នូវស្នាមញញឹមមានល្បិចទៅវិញ ។

"ហើយលោកស្រឡាញ់នាងម្នាក់នោះអត់?"

"នាងចង់ឱ្យខ្ញុំស្រឡាញ់អត់?"

"បើខ្ញុំប្រាប់ថាហាមមិនឱ្យលោកស្រឡាញ់នាងម្នាក់នោះ ទាំងការពិតវិញលោកកំពុងស្រឡាញ់នាងម្នាក់នោះ លោកព្រមធ្វើតាមដែរឬម៉េច?"

"ពិតប្រាកដណាស់ថា...ទេ!"

"..."

"ម្យ៉ាងទៀត...ខ្ញុំស្រឡាញ់នាងម្នាក់នោះយូរហើយ"

"យូរប៉ុណ្ណា?" សួរទៅទាំងដឹងច្បាស់ថា ខ្លួនឯងច្បាស់ជាត្រូវឈឺចាប់នឹងចម្លើយរបស់គេមិនខាន ។



គេរកទឹកមួយភ្លែត មុននឹងឆ្លើយ៖

"ប្រហែល...បួនឆ្នាំហើយ" ខ្សែភ្នែករបស់គេមើលទៅស្រទន់ល្ហួតដល់ខ្ញុំអត់មិនច្រណែនស្រីម្នាក់នោះមិនបាន ស្រីដែលគេលួចស្រឡាញ់ដល់ទៅបួនឆ្នាំ ។



"បើលោកស្រឡាញ់នាងម្នាក់នោះយូរដល់ថ្នាក់ហ្នឹង ម៉េចក៏មិនតាមចែ៉នាង"

"ម៉េចដឹងថាខ្ញុំមិនបានចែ៉?"

ខ្ញុំរាងអាក់បន្តិច ចម្លើយរបស់គេធ្វើឱ្យខ្ញុំឈឺចាប់កាន់តែខ្លាំងឡើងពេលដឹងថាគេត្រូវចែ៉នារីម្នាក់នោះ ព្រមទាំងមកបន្លំធ្វើជាសង្សារខ្ញុំទៀត ។

"បើលោកចែ៉ មកដល់ពេលនេះគួរតែជាសង្សារគ្នាទៅហើយ"

"ខ្ញុំគ្មានឱកាសចែ៉ទេ ព្រោះពេលមួយរយៈនោះ នាងម្នាក់ហ្នឹងមិនបាននៅក្បែរ"

"បានន័យថាពេលនេះលោកកំពុងចែ៉ ព្រោះនាងម្នាក់នោះមកក្បែរវិញហើយ?"

"គឺទំនងហ្នឹងអ្អែង!"

"លោកស្រឡាញ់គេដល់ថ្នាក់ហ្នឹង ពេលដឹងថាគេទៅបរទេស ម៉េចមិនទៅតាម?"

"ការពិតខ្ញុំគិតចង់ធ្វើបែបហ្នឹងដែរ តែ...បញ្ហារាំនៅត្រង់...ខ្ញុំមិនសូវចូលចិត្តម៉ាក់របស់នាងម្នាក់នោះប៉ុន្មានទេ"

"..."

"ដូច្នេះទើបខ្ញុំត្រូវប្រើពេលវេលាកែប្រែខ្លួនបន្តិចបន្តួច ដើម្បីឱ្យខ្លួនឯងទទួលយកបានក្នុងការដែលត្រូវទៅធ្វើជាកូនប្រសាររបស់ស្ត្រីម្នាក់ដែល...មាននិស្ស័យចម្លែកៗបែបនោះ"

"..."

"ខ្ញុំព្យាយាមទៅម៉ោផ្ទះរបស់នាងម្នាក់នោះឱ្យបានញឹកញាប់ ដើម្បីឱ្យស៊ាំនឹងសម្លេងនិងអាកប្បកិរិយាចម្លែកៗរបស់ម៉ាក់គេ"

"ហ្នឹងលោករៀបផែនការជាដំណាក់កាលបែបហ្នឹងដែរឬ? មើលទៅ



ដូចជាខំប្រឹងដល់ហើយ..."

"ច្បាស់ជាហើយ! ព្រោះគ្រប់ពេលដែលខ្ញុំឃើញមុខគាត់ ខ្ញុំមានអារម្មណ៍ថាអ្វីៗជុំវិញខ្លួនចង្អៀតមែនទែន"

"តែក៏នៅតែខំទ្រាំ!"

"គឺខ្ញុំស្រឡាញ់នាងម្នាក់នោះ!?"

"..."

"ស្រឡាញ់ខ្លាំងត្រូវតែទ្រាំឲ្យខ្លាំង"

គេបញ្ជាក់ម្តងទៀត សម្តីរបស់គេមិនខុសអ្វីពីមុខកាំបិតដែលកំពុងចាក់ចូលមកក្នុងចិត្តខ្ញុំឡើយ ។

ឆ្កួតមែន! ពេលនេះខ្ញុំច្រណែននារីម្នាក់នោះខ្លាំងណាស់ រហូតមានអារម្មណ៍ដូចខ្លួនឯងជាតួធ្លាស់ក្នុងខ្សែភាពយន្តអ៊ីចឹង រឹតតែបានដឹងពីការខំពុះពារ និងការស៊ូទ្រាំរបស់គេដែលប្រគល់ឲ្យនាងម្នាក់នោះហើយ ទ្រូងខ្ញុំរឹតតែអួលណែនឡើង ។

ហើយមិនដឹងថាមានស្អីបណ្តាលចិត្តឲ្យខ្ញុំក្លាហានហ៊ាននិយាយនូវពាក្យសម្តីដែលមិនគួរនិយាយចេញមកនៅក្នុងស្ថានការណ៍បែបនេះ តែពេលនេះខ្ញុំមិនអាចហាមឃាត់ការច្រណែនឈ្នានីសដែលឆាបឆេះក្នុងចិត្តបានទេ ។

"ចុះបើ...ខ្ញុំសុំអង្វរកុំឲ្យស្រឡាញ់នាងម្នាក់នោះ តើលោកថាយ៉ាងម៉េចដែរ?"

"..."

"..."

"ទោះអង្វរយ៉ាងណាក៏ប្រហែលជាលែងទាន់ហើយ ខ្ញុំស្រលាញ់ស្រីម្នាក់នោះតាំងពីបួនឆ្នាំមុនម្ល៉េះ" គេងាកមកញញឹម ខណៈដែលខ្ញុំអង្គុយខ្លួនរឹងត្អឹកចំពោះចម្លើយដ៏សែនត្រង់ទៅត្រង់មក ។

"បើអ៊ីចឹងមិញ...ម៉េចក៏លោកសួរ...ថាខ្ញុំចង់ឲ្យលោកស្រឡាញ់នាងម្នាក់នោះដែរអត់?"

"គឺខ្ញុំមិនស្មានថានាងឆ្លើយថា ទេ ហ្នឹងណា៎"

"បានន័យថាលោកស្មានថាខ្ញុំឆ្លើយថា ចង់ មែនទេ?"



"ក្រែងហ្នឹងគឺជាចម្លើយដែលនាងគួរឆ្លើយអ្ហ៎?"

"..."



ឆ្កួតមែន! ក្រែងនៅក្នុងបទសម្ភាសគេប្រាប់ថានៅមិនទាន់មានអាយដៀពាក់ព័ន្ធរឿងស្នេហានោះអ្ហ៎ ។

បញ្ជាក់ថា...ការពិតគេមានអ្នកនៅក្នុងចិត្តរួចហើយ គ្រាន់តែមិនប្រាប់អ្នកណា ព្រោះខ្លាចក្លាយជារឿងអឺកធឹក ទើបកុហកថាគ្មានអាយដៀក្នុងរឿងហ្នឹងមែនទេ?



## ភាគទី១៣
## មនុស្សប៊ិនច្រណែន

យ៉ាប់មែនទែន ដែលពេលនេះខ្ញុំចាប់ផ្ដើមចង់ឃើញមុខស្រីម្នាក់នោះមែនទែនហើយ ចង់ដឹងខ្លាំងណាស់ថា ស្រីដែលគេស្រឡាញ់នោះជាមនុស្សបែបណា?

តែ...បើអីចឹង...ដែលគេធ្លាប់យកប្រៀបលើខ្ញុំកាលពីពេលមុននោះ ឱ្យអធិប្បាយថាយ៉ាងម៉េចទៅ?

គិតមកដល់ត្រង់នេះ គ្របកភ្នែករបស់ខ្ញុំក៏ក្ដៅកាយដោយគួរឱ្យស្អប់ ខ្ញុំព្យាយាមទប់អារម្មណ៍ដ៏ទន់ជ្រាយដែលកំពុងតែចង់ធ្លាយចេញមកនៅចំពោះមុខគេ ឱ្យវាប្រសើរឡើងវិញ តែ...ដល់ទឹកឃើញទឹកមុខរបស់គេពេលដែលនិយាយពីស្រីម្នាក់នោះ ក៏មានអារម្មណ៍ថាខ្លួនឯងលែងទប់ទល់បានទៀតហើយ ទើបត្រូវបែរមុខទៅផ្សេងដើម្បីលាក់ទឹកភ្នែកមិនឱ្យគេឃើញ រហូតដល់....

"នាងកើតអីហ្នឹង...យំអ្ហ៎?" គេងាកមកមើលខ្ញុំ ព្រមទាំងធ្វើមុខស្លាំង ខ្សែភ្នែកក្រាក់ផ្អើលរហូតមើលទៅមិនដូចពេលដែលគេតែងតែគ្រប់គ្រងអារម្មណ៍របស់ខ្លួនឯងបានល្អនោះសោះ ។

គេបត់ឡានចូលទៅចតនៅចិញ្ចើមថ្នល់ ហើយព្យាយាមបង្ខំឱ្យខ្ញុំបែរមុខមកនិយាយជាមួយ ។

"កើតអី នៅសុខៗម៉េចបានយំ"

"..."

"..."

"..."

"អត់ស្រួលខ្លួនអ្ហ៎ស?"



"..."

"..."

"..."

"បើអត់ឆ្លើយ ខ្ញុំនឹងស្មានហើយ"



"អញ្ជើញស្មានតាមសប្បាយ តែលោកគ្មានផ្លូវស្មានត្រូវទេ!!!" ខ្ញុំនិយាយបណ្ដើរ ហឹតសំបោរបណ្ដើរ ។

ហ៊ឹស! មនុស្សឆ្កួត បើអត់ស្រឡាញ់ខ្ញុំ ហេតុអីមកផ្ដល់ក្ដីសង្ឃឹមឱ្យខ្ញុំធ្វើអី? អាក្រក់ជាទីបំផុត!

"ហ្នឹងគិតប្រុងសងសឹកខ្ញុំមែនទេ?"

"ហ្នឹងហើយ!" ខ្ញុំតំហាក តែគេអត់ខឹង ហើយមើលខ្ញុំ រួចនិយាយសម្លេងស្មើធម្មតាដូចអត់មានកើតទុក្ខអី ។

"មិនដឹងសោះ ថានាងជាពួកគុំគួន មុខហ្នឹងមិនសមទេ"

"..."

ងាប់ហើយ ហ្នឹងគេដឹងអត់ ថាខ្ញុំកំពុងតែខឹងគេ!

"សង្ស័យខ្ញុំត្រូវទៅឱ្យ មីណាម ជួយបង្ហាត់ម្ដងទៀតទាក់ទងនឹងវិធីដែលត្រូវនិយាយជាមួយនាងឱ្យយល់បានងាយហើយមើលទៅ"

"...?"

"អ្វីដែលខ្ញុំនិយាយមិញ សរុបទៅនាងមិនយល់សោះមែនទេ?"

"ម៉េចក៏មិនយល់! លោកប្រាប់ខ្ញុំថាលោកមានអ្នកដែលលោកស្រឡាញ់រួចហើយ វាមានទៅពិបាកយល់ត្រង់ណា?"

"នាងអត់យល់មែន!" គេសរុបសេចក្ដីដោយខ្លួនឯង ។

"..."

"សរុបទៅ ខ្ញុំជាមូលហេតុធ្វើឱ្យនាងយំ?"

"..."

"ខ្ញុំស្មានត្រូវទៀតហើយមែនទេ បាននៅស្ងៀម"

"ហេតុអីខ្ញុំត្រូវយំព្រោះមនុស្សឆ្កួតដូចលោក និយាយស្អីក៏ពិបាកយល់ ឡប់សតិអីក៏ខ្លាំងម្លេះ!" ខ្ញុំនិយាយទាំងកំហឹង ខណៈដែលគេលូកដៃមកជូតទឹកភ្នែកឱ្យ ធ្វើឱ្យខ្ញុំមានអារម្មណ៍ថាខ្លួនឯងដូចកូនក្មេងគេ



ង់កម្នាក់នៅក្នុងខ្សែភ្នែករបស់គេអីចឹង ។

ម្រាមដៃក្តៅឧណ្ហៗរបស់គេជូតទឹកភ្នែកចេញពីថ្ពាល់ខ្ញុំយឺតៗ មុនទឹងរំកិលចុះមកប៉ះបបូរមាត់ ព្រមទាំងប្រើខ្សែភ្នែកដ៏យ៉ាងទន់ភ្លន់ មុនទឹងរំកិលចុះមកប៉ះបបូរមាត់ ព្រមទាំងប្រើខ្សែភ្នែកដ៏ មុតស្រួចសម្លឹងជ្រៅមកក្នុងកែវភ្នែកខ្ញុំ រួចហើយក៏និយាយដោយសម្លេងដែលស្អកតិចៗ ÷

"ព្រោះនាងស្រឡាញ់ខ្ញុំ..."

តែ...សម្តីរបស់គេបែរជាធ្វើឱ្យខ្ញុំរឹតតែមានអារម្មណ៍ថាខ្លួនឯង គ្រាន់តែជាស្រីក្លើម្នាក់ ដែលច្ចួតទៅលង់ស្នេហ៍គេ បណ្តោយឱ្យគេមើលដឹងពីអារម្មណ៍បានយ៉ាងងាយ រហូតដល់ក្លាយជាមនុស្សគ្មានតម្លៃក្នុងខ្សែភ្នែកគេ ។ ខ្ញុំមិនអាចទ្រាំឱ្យគេពង្វក់បែបនេះទៀតបានទេ ទីបំផុតខ្ញុំក៏សម្រេចចិត្តបើកទ្វារឡាន ហើយឈានជើងចុះភ្លាម ។

តែ...ដើរទៅមិនបានប៉ុន្មានជំហានផងក៏ត្រូវគេដើរតាមមកចាប់ដៃជាប់ ខ្សែភ្នែករបស់ខ្ញុំម៉ាបន្តិចខណៈពេលងើបសម្លឹងមើលគេទាំងស្នាមទឹកភ្នែកនៅមិនទាន់ស្ងួត ។

"ខ្ញុំថាលោកកុំម៉ោខាតពេលជាមួយខ្ញុំអី សុំអញ្ជើញលោកយកពេលទៅនៅជាមួយនារីម្នាក់នោះ ដែលលោកដាក់ចិត្តស្រឡាញ់តាំងពីប៉ុន្មានឆ្នាំនោះវិញទៅល្អជាង"

"ខាតពេលត្រង់ណា យ៉ាងណាក៏ខ្ញុំត្រូវទៅសាលាស្រាប់ហើយ"

"ខ្ញុំបានប្រាប់ហើយថា ថ្ងៃនេះខ្ញុំអត់ទៅរៀនទេ តែលោកនិងបងប្រុសក៏ចេះតែបង្ខំ ឃើញខ្ញុំល្ងង់ខ្លាំងណាស់ឬយ៉ាងម៉េច បាននាំគ្នាម៉ោសម្រេចក្តីថាខ្ញុំអានអក្សរខ្លួនឯងមិនបាន ទាល់តែឱ្យគ្រូពន្យល់!"

"នាងចូលចិត្តតែគិតខ្លួនឯង រួចអីអើខ្លួនឯងជានិច្ច ហើយថែមទាំងគិតខុសទៀត"

"អ៊ំ...ទាល់តែគិតដូចលោកបានថាត្រូវមែនទេ? ត្រូវហើយ! ខ្ញុំវាក្លើ ល្ងង់ រហូតសត្វលាសុំចាញ់ ព្រោះតែអីចឹងហើយបានខ្ញុំត្រូវលោកពង្វក់មិនឈប់ឈរបែបនេះ"

ពេលដែលខ្ញុំកំពុងតែវាត់គេដូចដែលធ្លាប់ធ្វើ ខួរសញ្ញាដៃរបស់គេក៏រោទិ៍...តាមដែលចាប់សេចក្តីបាន ហាក់ដូចជាគេហ្នឹងមានណាត់





ជជែកការងារជាមួយគ្រូនៅមហាវិទ្យាល័យ ហើយមើលទៅគេដូចជាយឺតអស់ជិតពីរម៉ោងហើយ ធ្វើឱ្យខ្ញុំចាប់ផ្តើមមានអារម្មណ៍ថាខ្លួនឯងខុសភ្លាមដែលជាមូលហេតុធ្វើឱ្យគេត្រូវខាតបង់ការងារទៀតហើយ ។ ដោយហេតុនេះរឿងដែលកំពុងប្រកែកគ្នាក៏ចាំបាច់ត្រូវតែបញ្ចប់...រួចហើយគេក៏ជូនខ្ញុំទៅអាគារផ្នែក និងប្រញាប់ទៅជួបគ្រូភ្លាមដែរ ។



ខ្ញុំដើរចូលអាគារផ្នែកដោយស្ថានភាពផ្លូវចិត្តយ៉ាប់យ៉ឺនជាទីបំផុត ចង់រកកន្លែងស្ងាត់ៗ ទៅលួចយំតទៀតតែម្នាក់ឯងឱ្យអស់ចិត្ត តែ...

"ឯងមើលព័ត៌មាននេះ សរុបថាសិស្សច្បង ហាន់ មានសង្សាររួចហើយអ្ហ៎ស? អីចឹងបានជាពេលម៉ោសាលាអត់ឃើញមានសម្លឹងមើលនរណាម្នាក់សោះ ការពិតព្រោះតែមានសង្សារហើយហ្នឹងអ្ហ៎ង"

"ហ្នឹងហើយ! ដំបូងខ្ញុំនឹកស្មានថាគេមកញ៉ែ អេនដែល?"

"ប្រហែលជាមានរឿងយល់ច្រឡំអីទេដឹង? ជួនកាលអាចជាបងប្អូនគ្នាធម្មតា ព្រោះអីសិស្សច្បងជាមិត្តជិតដិតរបស់បងប្រុសអេនដែល"

"អី...និយាយដល់បងប្រុស ការពិតខ្ញុំក៏លួចពេញចិត្តបងប្រុសគេដែរតើ ពួកយើងគួរតែសាកល្បងទៅស្និទ្ធស្នាលនឹង អេនដែល ក្រែងលោបានទៅជិតដិតនឹងបងប្រុសគេ!"

ច្បាស់មែន! ម៉េចខ្ញុំចាំបាច់មកឮឱ្យទើសត្រចៀកបែបនេះទៀតហ្ន៎?

ខ្ញុំសម្រេចចិត្តដើរចេញមកវិញ ដើម្បីហៅតាក់ស៊ីទៅផ្ទះ ព្រោះច្បាស់នៅក្នុងចិត្តមែនទែនហើយ ថាថ្ងៃនេះប្រហែលជាគ្មានសមាធិធ្វើអីទៀតទេ ក្រៅតែពី ខ្ញុំយំកាន់ទុក្ខឱ្យភាពល្ងង់ខ្លៅរបស់ខ្លួន ។

តែ...សុខៗក៏មានឡានស្ព័តមួយបើកមកឈប់ពីមុខ ហើយពេលកញ្ចក់ខាងអ្នកបើកទម្លាក់ចុះ ក៏ដឹងថាតីជា ក្វាងមីន ។

"នែ៎! ម៉ោឈរកន្លែងហ្នឹងធ្វើអី?"

អ៊ូយ! នេះអារម្មណ៍ខ្ញុំអណ្តែតអណ្តូងដល់ថ្នាក់ចាំមិនបានសូម្បីតែឡាន ក្វាងមីន ផងឬ?

www.laksmie26.wordpress.com





## ភាគទី១៤

## ដោះស្រាយចម្ងល់... ហេតុផលតូចតាច តែសំខាន់ខ្លាំងណាស់

ខ្ញុំសម្រេចចិត្តឡើងឡានមកជាមួយ ក្វាងមីន និង សុំអង្វរឱ្យជូនទៅផ្ទះ ហើយគេក៏យល់ព្រមតាមសម្រួល ។

"កើតអី មុខអត់មានរាសីសោះ?"

តែ...ពាក្យថា រាសី ធ្វើឱ្យខ្ញុំរឹតតែនឹកឃើញអាម្សៀនោះ ។

"ក្វាងមីន!"

"មានការអី?"

"ខ្ញុំ...លង់ស្នេហ៍គេ!"

"អ្ហា ឯងហ្នឹងម្ល៉េស...ណាគេ?"

"មនុស្សក្បែរខ្លួន"

"ណាគេ? ខ្ញុំស្គាល់អត់?"

"ឯងទាយមិនត្រូវទេ បើកឡានទៅ ខ្ញុំចង់នៅស្ងាត់តែម្នាក់ឯង ហើយក៏ចង់យំទៀតផង!"

ក្វាងមីន ដូចជាចង់និយាយអីជាមួយខ្ញុំ តែក៏ត្រូវដូរចិត្តវិញ ពេលឃើញទឹកមុខខ្ញុំកំពុងតែយំបយ៉ឺនខ្លាំងមែនទែន ។

"..."

"ឯងមានអីចង់និយាយជាមួយខ្ញុំមែនទេ មិញឃើញធ្វើស្ទាក់ស្ទើរ"

"នាងនៅចាំរឿងដែលម៉ាក់នាងនិងម៉ាក់ខ្ញុំចង់ចាប់យើងពីរនាក់រៀបការបានអត់?"

"ខ្ញុំមិនមែនខួរក្បាលត្រីកន្ធាយបីចេះតែភ្លេចអីងាយៗរបៀបហ្នឹងទេ!"

"ការពិតវាមិនមែនដូចនាងគិតទេ"

"អ្ហឺ បានន័យថាម៉េច?"



"ពួកគាត់គ្រាន់តែចង់រកវិធីធ្វើឱ្យយើងឈប់ទាក់ទងគ្នា"

"ស្អីគេ?"

"គឺយ៉ាងនេះ...សុខៗពួកគាត់ក៏ទៅស៊ើបដឹងថាយើងសេពគប់គ្នា ដើម្បីគេចពីការចាប់ឱ្យទៅរៀបការជាមួយអ្នកដទៃ ទើបរួមគំនិតគ្នារៀបផែនការបោកប្រាស់ថានឹងចាប់យើងពីរនាក់រៀបការមែនទែនតែម្តង ដើម្បីឱ្យយើងភ័យនឹងអាលចាប់ឈប់សេពគប់គ្នា រកតែឯងទៅកុហកថាស្ងួនមានដំបៅអីទៀតនោះ ម៉ាក់ខ្ញុំកើយហ្នឹង"



"ដើម្បី?"

"គឺដើម្បីឱ្យខ្ញុំនិងឯងបានទៅរៀបការជាមួយមនុស្សដែលគាត់រកមកឱ្យហ្នឹងណា៎"

បានន័យថា...ពេលនេះម៉ាក់នៅតែដំណើរការបញ្ឆោតខ្ញុំឱ្យទៅចូលអន្ទាក់អាពាហ៍ពិពាហ៍របស់គាត់ទៀតមែនទេ?

អ៊ូយ! ខ្ញុំចង់ដួតងាប់ហើយ ។

"បានន័យថា...យើងត្រូវពួកគាត់បោកម្ល៉េស?"

"ត្រឹមត្រូវ!"

"ឯងទៅដឹងរឿងនេះមកពីណា?"

"ខ្ញុំជួលអ្នកបម្រើឱ្យវាលួចស្តាប់ពេលម៉ាក់ខ្ញុំនិយាយទូរសព្ទជាមួយម៉ាក់នាងហ្នឹងណា៎"

"ហើយឥឡូវឯងធ្វើម៉េចទៅ?"

"គឺមានធ្វើម៉េច ខ្ញុំកំពុងគិតថាចង់ប្រាប់ម៉ាក់ត្រង់ៗតែម្តង ថាខ្ញុំមានអ្នកដែលខ្ញុំស្រឡាញ់ហើយ ដើម្បីឱ្យរឿងវាចាប់ចប់"

"ហើយម៉ាក់ឯងយល់ព្រមដែរម្ល៉េស?"

"ព្រម!"

"ម៉េចបានស្រួលម្ល៉េះ?"

"ខ្ញុំលើកសំណូមពរថា បើម៉ាក់ឈប់រៀបផែនការចាប់គូឱ្យខ្ញុំ ខ្ញុំនឹងឈប់ដើរលេងយប់ ឈប់នាំស្រីទៅដេកអូតែល"

"បោកដហើយម្ល៉េថាឯងធ្វើបាន?"

"ការពិត ខ្ញុំតាំងចិត្តប្រុងឈប់ស្រាប់ទៅហើយ!"





"...?"

"ព្រោះខ្ញុំតាំងចិត្តថានឹងធ្វើដើម្បីសង្សារតាំងពីដំបូងម្ល៉េះ" ទឹកមុខរីករាយរបស់ ក្វាងមីន ធ្វើឱ្យខ្ញុំអត់រញ្ជួយចិត្តមិនបាន ។

"ដឹងអីទេ ក្វាងមីន?"

"អ្វី?"

"ឯងធ្វើឱ្យខ្ញុំច្រណែនម្នាក់ទៀតហើយ"

"ច្រណែនអី?"

"ពេលនេះខ្ញុំច្រណែនអ្នកដែលមានសេចក្ដីសុខគ្រប់គ្នា!" ខ្ញុំនិយាយដោយធុញទ្រាន់នឹងជីវិត ខណៈដែល ក្វាងមីន បែរមកមើលខ្ញុំដោយភ្នែកដែលពោរពេញទៅដោយសំនួរមួយភ្លែត ។

"...?"

ប្រាកដហើយ អ្នកដែលសមបំណងក្នុងសេចក្ដីស្នេហាដូចវា មកយល់ពីអារម្មណ៍របស់អ្នកខកស្នេហ៍ដូចខ្ញុំម៉េចបាន?

"តែសង្សារឯងឈប់យល់ច្រឡំហើយនៅរឿងដែលឯងនិងខ្ញុំសេពគប់គ្នាបន្លំៗនោះ?"

"នៅ!"

"បញ្ជាក់ថា...ខ្ញុំត្រូវនៅជួយឯងសម្ដែងធាកល្ខោនថាជាសង្សាររបស់ គុនជេ ដដែលមែនទេ?"

"ប្រាកដហើយ! ឬក៏ឯងមិនពេញចិត្ត?"

"ខ្ញុំពេញចិត្ត តែគេ...ពេញចិត្តអត់ខ្ញុំម៉េចដឹង?"

"ឯងនិយាយស្អីហ្នឹង? ហ្នឹងកុំនិយាយថាដែលឯងប្រាប់ថាខកស្នេហ៍នោះ...គឺបង គុនជេ ណា៎"

"អើ..."

"ឯងខកស្នេហ៍ធ្វើអីអ្នកាស់?"

"ព្រោះគេមានអ្នកដែលគេប្រុងរៀបការជាមួយរួចហើយ"

"ឯងយល់ខុសអីទេដឹង? តាមដែលខ្ញុំមើលទៅ ដូចជាគេកំពុងតែស្រឡាញ់ឯងតើ!"

"ឯងនៅតែគិតអីចឹងមែនទេ? ខ្ញុំក៏ធ្លាប់គិតអីចឹងដូចគ្នាដែរ តែ





ការពិតទាំងឯងនិងខ្ញុំយល់ខុសទាំងអស់"

"អេនដែល...ការពិត...ខ្ញុំថាចង់លួចគេប្រាប់ឯងច្រើនដងហើយតែ..." ក្វាងមីន មិនទាន់បាននិយាយអីផង សម្លេងជាន់ហ្វ្រាំក៏បន្លឺឡើងតាមដោយសម្លេងម៉្យាំងមកបុកគូទឡាន ក្វាងមីន យ៉ាងខ្លាំង ។

ឡានដែលបើកខាងក្រោយ អ្នកបើកប្រហែលជារវល់តែនិយាយទូរសព្ទ ទើបជាន់ហ្វ្រាំមិនទាន់ ក៏ស្ទុះមកបុកគូទឡាន ក្វាងមីន របូតកំពិតច្រើនគួរសម ។

ដោយហេតុនេះ រឿងដែល ក្វាងមីន កំពុងចង់ប្រាប់ខ្ញុំនោះក៏ត្រូវបញ្ចប់តែត្រឹមប៉ុណ្ណឹង ។

តែ...ខ្ញុំគ្មានចិត្តចង់ស្ដាប់ឮអីទាំងអស់ ។

មានតែរឿងមួយគត់ដែលខ្ញុំចង់ដឹងក្នុងពេលនេះគឺ...ស្រីម្នាក់នោះ ជាអ្នកណា ។

អ្នកដែលតាប៉ិក្វួតនោះ លួចស្រឡាញ់ដល់ទៅបួនឆ្នាំមានមុខមាត់យ៉ាងម៉េចទៅ? ស្អាតជាងខ្ញុំអត់ ហឺៗ ។

មួយអាទិត្យក្រោយមក...

គុនជេ មិនបានទាក់ទងមករកខ្ញុំឡើយ ចាប់តាំងពីថ្ងៃដែលយើងមានរឿងនៅថ្ងៃនោះ មានតែសារខ្លីៗដែលគេផ្ញើមកប្រាប់ថា...

'កំពុង ជាប់រវល់ រួចនឹងគេទៅ'

តែរហូតដល់ថ្ងៃនេះទៅហើយ...គេក៏នៅតែមិនឃើញគេមកទៀត ចង់សួរបងប្រុសក៏មិនបាន ព្រោះគាត់ក៏បាត់ទៅជាមួយអាម៉ៀនោះដែរ ពេលនេះនៅមិនទាន់ឃើញមកផ្ទះវិញផង ហើយពេលគេទៅគាត់ក៏អាងថា ជាប់ការងារបន្ទាន់នៅសាលា ។

ហ៊ឺៗ...ខ្ញុំតូចចិត្តណាស់!

ការពិតពេលគេទៅរកបងប្រុស ខ្ញុំចង់សួរពីអាម៉ៀនោះថាតើនៅសាលាជាមួយដែរមែនទេ តែក៏មិនហ៊ាន ទីបំផុតក៏ត្រូវមកអង្គុយ



ពិបាកចិត្តតែម្នាក់ឯងបែបនេះ ។

ក្រៅពីនេះនៅមានរឿងដែលសុំឱ្យខ្ញុំជួយបន្លំធ្វើជាសង្សារទៀត តែពេលនេះសង្សារ ក្វាងមីន មកយូរថ្ងៃហើយ ក៏នៅតែមិនឃើញគេទាក់ទងមកប្រាប់ពីរឿងនេះ ។

អាចទៅរួចដែលថា...គេអាចប្ដូរចិត្តទៅសុំឱ្យអ្នកផ្សេងជួយធ្វើជំនួសខ្ញុំបាត់ទៅហើយ មែនទេ?

មិនអីចឹង គេអាចទៅសុំឱ្យស្រីដែលគេប្រាប់ថាស្រឡាញ់យូរមកហើយនោះ មកជួយធ្វើជំនួសខ្ញុំក៏ថាបានដែរ ។

ឬអាចមកពី...ថ្ងៃមុនដែលខ្ញុំធ្វើខ្លួនដូចកូនក្មេងខូញយំហៀរសំបោរនៅចំពោះមុខគេដោយមិនព្រមប្រាប់ពីមូលហេតុឱ្យច្បាស់លាស់ គេក៏ខ្លាចរអា លែងចង់ភ័រវល់នឹងខ្ញុំទៀត ។

អ៊ុយ! តើខ្ញុំគិតតែពីអន្ដុយតិតផ្ដេសផ្ដាសអីហ្នឹង?

OPSOK LOVE SERIES

ល្ងាចថ្ងៃនោះ...

បងប្រុសដើរចូលមកក្នុងផ្ទះក្នុងសភាពស្រងៀងនឹងខ្មោចចៅហ្វ្រមបី ហើយហ្នឹងអ្វែងដែលធ្វើឱ្យខ្ញុំដឹងថា ពេញមួយអាទិត្យដែលគាត់ព្យាយាមប្រាប់ខ្ញុំមករហូតថារវល់ការងារនៅមហាវិទ្យាល័យ មិនមែនជារឿងហួសការពិតទេ ។

ហើយខ្ញុំក៏បានតែលួចសង្ស័យមក្នុងចិត្តថា អាម្សៀនោះក៏ប្រហែលជាជាប់រវល់ការងារនៅមហាវិទ្យាល័យដូចបងប្រុសដែរ មិនមែនបាត់មុខព្រោះ...

ព្រោះស្រីម្នាក់នោះទេ ហ៊ឺៗ...

បងប្រុស ទម្លាក់ខ្លួនគេងលើសាឡុង ព្រមទាំងបិទភ្នែកដោយការនឿយហត់ សភាពទ្រុឌទ្រោមដូចមនុស្សខ្វះការដេកពួន ។

"ហ្នឹងបងទៅធ្វើការអី ម៉េចបានជាដល់ថ្នាក់នេះ?"

"បង និង គុនជេ ត្រូវគ្រូបញ្ជាឱ្យធ្វើម៉ូដែលព្រលានយន្ដហោះយកទៅប្រកួតនៅសាំងហ្គាពួ ហើយឯងដឹងទេថាហេតុអីបានជាយូរទាំងឈម្មតា គុនជេ ធ្វើការរហ័សណាស់"



...



"គ្រូបញ្ជាឱ្យវាទៅអង្គុយធ្វើម៉ូដែលនៅក្នុងបន្ទប់តូចចង្អៀត ដើម្បីឱ្យវាស៊ាំ ព្រោះបន្ទប់ប្រកួតនៅសាំងហ្គាពួចង្អៀតណាស់ ហើយម៉ូដែលខ្លះត្រូវយកទៅដំឡើងនៅទីនោះ ហើយវាមានបងប្រុ រអ៊ូដូចមនុស្សកំពុងធុញទ្រាន់ជាទីបំផុត ។ ហ៊ុយ...បងចង់ឆ្កួតងាប់!"

"..."

មែនហើយ អាម្សៀនោះស្អប់កន្លែងចង្អៀត (ដឹង ព្រោះអានបទសម្ភាស) ។

ពុទ្ធោ...ការពិត...ដោយសារអីចឹងទេតើ អាឯងនឹកស្មានថាលួចទៅរកស្រីឯណា?

"ហើយក៏មិនដឹងជាវាកើតឆ្កួតអី ពេលធ្វើការ វាក៏ធ្វើមុខពិបាកចិត្តដូចទៅឈ្លោះជាមួយអ្នកណាម៉ោអីចឹង បងមើលមុខវាមិនចំពីរថ្ងៃហើយ ហើយប្រាំថ្ងៃទៀតវាក៏ធ្វើការតែម្នាក់ឯង មិននិយាយមិនស្ដីអីទាំងអស់"

ហ៊ឺស! ស្អីទៀតហើយ...គេបែបពិបាកចិត្តព្រោះមិនអាចឆ្លៀតពេលទៅរកស្រីម្នាក់នោះបានហើយ ។

"ដំបូងខ្ញុំស្មានថាពួកបងបាត់ទៅព្រោះទៅធ្វើអាគ្រោងការណ៍សម្ងាត់ស្អីនោះតើ!"

"អ៊ុយ! អាហ្នឹងការងារមួយ ធ្វើនៅផ្ទះម្នាក់ឯងបាន អត់បញ្ហាទេ"

"..."

"ហើយនេះ...វាមិនទាន់ប្រាប់ឯងទៀតផ្ដេសថាគ្រោងការណ៍នោះគឺស្អី"

"នៅ"

ហើយគេក៏គ្មានថ្ងៃប្រាប់ខ្ញុំដែរទាល់តែចប់ការកិច្ចសង្សារក្លែងក្លាយពីរអាទិត្យស្អីគេនោះ តែនេះវា...ហួសកំណត់ធ្វើជាសង្សារច្រើនថ្ងៃហើយ ហេតុអីបានគេស្ងាត់ឈឹងបែបនេះ ។

"អើ បងស្មានតែឯងដឹងហើយ ឃើញមុនហ្នឹងទៅណាម៉ោណាជាមួយវារហូត បងស្មានថាឯងពីរនាក់ជាគូស្នេហ៍ទើបនឹងរៀបការ

ហើយថ្មីៗទៀតផង"



"បងនិយាយជ្រុលពេកហើយ គេមានអ្នកដែលគេស្រឡាញ់រួចហើយ បងមិនដឹងទេអ្ហ៎ស?"

"ដឹង..."

"អ្នកណាគេ?"

"បើសាមីខ្លួនវាមិនព្រមប្រាប់ ឯងចង់ឱ្យបងអត់សុជីវធម៌ដណ្ដើមប្រាប់គាត់មុនវាឬយ៉ាងម៉េច?"

"ស្អីគេ? ឥឡូវហ្នឹងចេះលាក់ខ្ញុំផងអ្ហ៎?"

"ខ្លួនឯងនៅចេះលាក់បងបាន?"

"...?"

"ឯងលាក់បងរឿង ក្វាងមីន ហើយនៅហ៊ានមកសុំអង្វរឱ្យបងជួយពេលម៉ាក់ចង់ចាប់ឯងការជាមួយវាទៀត ឯងភ្លេចហើយអ្ហ៎?"

"បងរំលឹកធ្វើអីទៀត ពេលនេះខ្ញុំកំពុងតែពិបាកចិត្តផង"

"ពិបាកចិត្តអី ឆ្លងរោគពិបាកចិត្តពី គុនដេ ម្នាក់ទៀតហើយអ្ហ៎?"

"ខ្ញុំមានអារម្មណ៍ដូចកំពុងត្រូវគេបោកប្រាស់ម៉េចមិនដឹងទេ?"

"គុនដេ ហ្នឹងអ្ហ៎ស?" បងប្រុសសួរ ខណៈដែលខ្ញុំងក់ក្បាល ព្រមទាំងបញ្ជូនខ្សែភ្នែកសុំជំនួយទៅរកគាត់ ដែលមើលទៅថា ថ្ងៃនេះដូចជាមិនងាយបានគេងទេ ។

តែ...បន្ទាប់ពីប្រាប់រឿងដែលខ្ញុំវិភាគឃើញទាំងអស់ទាក់ទងនឹងព័ត៌មានខ្សឹបខ្សៀវនោះ បងប្រុសបិះនឹងភ្លេចខ្លួនធាក់ខ្ញុំមួយជើង កុំតែសំណាងល្អនឹកឃើញទាន់ថាខ្ញុំជាប្អូនស្រី មិនមែនប្អូនប្រុស ។

"អ្ហ៎!!! ការពិតគឺឯងគិតតែម្នាក់ឯងបែបនេះអ្ហែង អាឆ្កួត! ចេះតែគិតទៅកើត នេះហើយគេហៅថាកម្មពៀរទាន់ហន់នោះ!"

"យ៉ាងម៉េច ខ្ញុំមានដែលធ្វើបាបអ្នកណា?"

"គឺរឿងដែលឯងកុហកអ្នកដទៃថាសេពគប់អាឡូប់នោះហ្នឹង"

"..."

"ព្រោះតែឯងធ្លាប់ប្រឌិតរឿងបោកប្រាស់អ្នកផ្សេង ទើបពេលនេះឯងត្រូវម៉ោអង្គុយប្រយ័ត្នខ្លាចគេបោកប្រាស់ឯងវិញ"



"..."

"ការពិតបងមិនចង់និយាយអីបែបហ្នឹងដាក់ឯងទេ តែសួរមែនទែនចុះ ពេលវានៅស្ងាត់ៗតែពីរនាក់ឯង វាចូលចិត្តធ្វើមិនសមរម្យដាក់ឯងមែនទេ?"



"មែ...មែនហើយ"

"ធម្មតាវាមិនមែនជាមនុស្សបែបហ្នឹងទេ"

"បងចង់ប្រាប់អីខ្ញុំអ្ហ៎ស?"

"ហ្នឹងឯងមើលមិនធ្លុះមែនអ្ហ៎ស ថាវាមានចិត្តលើឯង?"

"តែគេប្រាប់ថា...គេមានមនុស្សដែលគេស្រឡាញ់ហើយ និងស្រឡាញ់យូរហើយទៀតផង"

"ម៉េចក៏ឯងមិនចេះគិតកាន់ជើងខ្លួនឯងខ្លះអីចឹង?" សម្ដីបង្ហាញផ្លូវរបស់បងប្រុស ធ្វើឱ្យខ្ញុំមុខក្រហមភ្លាមតែម្ដង ។

"បងឡប់ទេដឹង?"

"ចាំម៉ូដែលដែលឯងជាន់ខ្ទេចកាលពីឆ្នាំទៅបានអត់?"

"អឺ...អ៊ឹម ចាំបាន" និយាយដល់រឿងហ្នឹង ខ្ញុំនៅតែមានអារម្មណ៍ថាខុសឆ្គងចំពោះគេនិងបងប្រុស គ្រប់ពេលដែលនឹកឃើញ ។

"ដោយសារតែឯង បងនិងវាត្រូវរៀនយឺតមួយឆ្នាំ ព្រោះបញ្ជូនកិច្ចការទៅដាក់អត់ទាន់ ត្រូវទៅរៀនមុខវិជ្ជានោះជាមួយសិស្សប្អូន"

"អ្ហា...ហើយហេតុអីបងមិនប្រាប់ខ្ញុំថាវាធ្ងន់ធ្ងរដល់ថ្នាក់ហ្នឹង"

ងាប់ហើយ ខ្ញុំមិនដឹងមែនថាគ្រាន់តែអាម៉ូដែលមួយហ្នឹងអាចធ្វើឱ្យបងប្រុសនិងអាម៉ៀនោះត្រូវរៀនយឺតមួយឆ្នាំ អ៊ុយ! ហើយកាលនោះខ្ញុំក៏ជេរស្ដីគេសព្វបែបយ៉ាង គេមិនដាល់ខ្ញុំផ្អប់ដង្ហោំងលោថា បុណ្យគុណណាស់ទៅហើយ ។

"ប្រាប់ទៅ ឯងជួយឱ្យបងរៀនចប់លឿនបានអ្ហ៎ស?"

"..."

"ប្រាប់រឿងមួយឱ្យដឹង បើមិនមែនព្រោះតែវាស្រឡាញ់ឯង...ឯងលួតក្បាលចេញពីស្មាបាត់ទៅហើយ..."

"..."



"ឃើញវាស្ងៀមៗបែបហ្នឹងមែន តែបើរឿងការងារ វារៀបផែនការត្រូវចាំចាំៗខ្លាំងណាស់ ខុះលើសអត់បានទេ ហើយឯងលេងទៅដាន់ខ្ទេចអស់បែបហ្នឹងហើយ តែវាអត់មានថាអី បញ្ជាក់ថា...ឯងមិនមែនធម្មតាទេ..."

"ខ្ញុំថាបងកុំម៉ោធ្វើជានិយាយលើកទឹកចិត្តខ្ញុំអីល្អជាង ស្រីម្នាក់នោះគ្មានផ្លូវជាខ្ញុំដាច់ខាត"

"មើលវា? ប្រាប់ដល់ថ្នាក់ហ្នឹងហើយនៅមិនជឿទៀត ទាល់តែប្រាប់ឱ្យអស់ហ្មង់ផ្អើសបានជឿ"

"..."

"ការពិតពីដំបូងដែលបងធ្លាប់ពន្យុះឱ្យវាញៀងឯង ព្រោះឃើញថាវាដូចជាពេញចិត្តឯងដែរ តែវាបែរជាប្រាប់បងថា វាគ្មានផ្លូវម៉ោញៀឯងទេ ព្រោះវាមិនចង់មានម៉ាក់ក្មេកដូចម៉ាក់យើងដែលទាំងចែបចែប្រអូពីរ ហើយនិងចូលចិត្តធ្វើខ្លួនលេចធ្លោឱ្យមានព័ត៌មានជាប់រហូតបែបនេះទេ"

"បានន័យថា...គេមិនចូលចិត្តម៉ាក់បែបខ្លាំងមែនទែនអីចឹងអ្ហ៎?"

"កុំថាតែវា បងនិងឯងក៏នៅអា...មែនទេ?"

"មែ...មែនហើយ" អ៊ូយ! និយាយដើមម៉ាក់ខ្លួនឯងបែបនេះបាបខ្លាំងទេ?

ត្រូវហើយ! ម៉ាក់ចែបចែប្រ ហើយអូពីរលេខមួយដូចម៉ាក់ ក្មាងមីនអត់ខុស អ្នកណានៅជាមួយមានតែឈឺក្បាល ឈឺក្បាល និងឈឺក្បាល ។

"តែដឹងទេថា ថ្នាក់វាមិនចូលចិត្តម៉ាក់ តែវានៅតែព្យាយាមយកចិត្តម៉ាក់..."

"យកចិត្តយ៉ាងម៉េច?"

"បើឱ្យស្មាន...បងថាដែលឆ្នាំនេះនៅសុខៗវាឆ្លតទៅព្រមទទួលអាតំណែង Prince of Zodiac ស្អីហ្នឹង ក៏ប្រហែលព្រោះតែម៉ាក់ដែរ"

"ព្រោះតែម៉ាក់??? ចុះក្រែងថាគេមិនចូលចិត្តម៉ាក់ផ្អើស?"

"មិនចូលចិត្តម៉ាក់ តែបែរជាស្រឡាញ់កូនស្រីម៉ាក់ ហើយថែម

OPSOK LOVE SERIES



ទាំងស្រឡាញ់ខ្លាំងទៀតផង យ៉ាងណាក៏ត្រូវតែខំមាត់យកចិត្តដែរ"

"ហើយវាពាក់ព័ន្ធអីនឹងការយកចិត្តម៉ាក់?"

"ប្រហែលមើលឃើញថាម៉ាក់ជាមនុស្សអូពីរៗ និងចូលចិត្តអ្នកមានឈ្មោះល្បី មានមុខតំណែង ហើយដែលសំខាន់នោះ គឺការដែលវាបានទទួលតំណែងនេះ គឺធ្វើឱ្យវាអាចទៅជួយការងារនៅសមាគមម៉ាក់បានទៀតផង ព្រោះបើអត់មានមុខតំណែងអី រួចទៅជួយការងារផ្សព្វផ្សាយអីនៅសមាគមនោះ វាមើលទៅចម្លែកៗ ថាហេតុអីសុខៗម៉េចបានអើតក្បាលម៉ោជួយ? បែបមានមូលហេតុអីបង្កប់ម៉ោជាមួយទេដឹង?" សម្ដីរៀបរាប់របស់បងប្រុស ធ្វើឱ្យខ្ញុំនឹកឃើញដល់ថ្ងៃមុនពេលដែលខ្ញុំនិងគេនិយាយគ្នានៅក្នុងឡាន...

'ការពិតពេលនេះខ្ញុំក៏នៅតែមានអារម្មណ៍មួម៉ៅខ្លួនឯងតិចតួចដែរ ដែលសម្រេចចិត្តទទួលយកតំណែងនេះ ព្រោះមែនទែនទៅរាល់ថ្ងៃនេះខ្ញុំក៏នៅតែមិនស៊ីខ្សែមនុស្សម្នាក់នោះដដែល'

"អីចឹងតើបានពេលនោះគេនិយាយបែបហ្នឹង ការពិតព្រោះរាល់ថ្ងៃនេះ គេត្រូវទៅជួយការងារម៉ាក់នៅសមាគមជាញឹកញាប់ដោយសភាពទើសទាល់ ហ្នឹងអ្ហ៎ង"

ហ៊ឺ...ពេលនេះខ្ញុំមានអារម្មណ៍មួម៉ៅខ្លួនឯងតិចៗទៀតហើយ ដែលមានអារម្មណ៍ត្រេកអរ និង ផ្កាយ៉ូងយ៉ាងចម្លែកដែលបានដឹងថាការពិតនារីដែលគេប្រាប់ថាស្រឡាញ់មកយូរហើយម្នាក់នោះគឺជារូបខ្ញុំខុសពីដំបូងដែលខ្ញុំរាល់តែគិតពិបាកចិត្តសព្វបែបយ៉ាង ។

តែ...អាហ្នឹងផ្អើស 'ហេតុផលតូចតាច តែសំខាន់ខ្លាំងណាស់' របស់គេនោះ?

"ចុះម៉េចក៏គេមិនប្រាប់តាំងពីដំបូង ទុកឱ្យខ្ញុំយល់ច្រឡំទៅកើត"

"អ្ហ៎ា? ហើយដែលឡើងឡានទៅជាមួយគ្នាថ្ងៃនោះ វាអត់មានប្រាប់រឿងហ្នឹងឱ្យឯងដឹងខ្លះទេផ្អើស?"

"បើគេប្រាប់...ខ្ញុំពិបាកចិត្តអីចឹងអ្ហ៎?"





"អ្ហ៎! នេះបញ្ជាក់ថាមូលហេតុមួយទៀតក្រៅពីអាបន្ទប់ចង្អៀតៗ ដែលធ្វើឱ្យវាធ្វើការយឺតនោះ គឺមកពីឯងមែនទេ?"

"..."

"សួរតាមត្រង់ ឯងនៅចង់រវាងការងារពួកបងដល់ណាទៀត?"

"បងម៉ោបន្ទោសខ្ញុំក៏អត់ត្រូវដែរ គេក៏ខុសដូចគ្នាដែលមិនព្រមប្រាប់ការពិតដល់ខ្ញុំ"

"..."

"ចុះអាព័ត៌មានដែលថាចាំរបស់គេរកនារីម្នាក់ទុកឱ្យហើយនោះ វាយ៉ាងម៉េចទៅវិញ?"

"ហ៊ឺ...នៅល្ងង់សមជាប្អូនស្រីបងដូចមុនដដែល" បងប្រុសនិយាយដោយការនឿយណាយ ។

"..."

"អាហ្នឹងបានប្រាប់ថាមុខដូចឯងនេះ តាមវាមិនទាន់ទេ"

"បានន័យថាម៉េច?"

"បានហើយប្អូនស្រី ពេលនេះបងខ្ជិលធ្វើខ្លួនជាវចនានុក្រមគូរ៉េ-គូរ៉េឱ្យឯងណាស់ហើយ!"

"តែ..."

"សរុបទៅ បើឯងចង់ដឹងក៏ទៅសួរវាខ្លួនឯងទៅ បងងងុយណាស់...ចង់គេង"

"នែ! ឈប់សិន...បងកុំអាលគេង!"

"..."

"បងប្រុស...ភ្ញាក់ឡើង ម៉ោនិយាយជាមួយខ្ញុំសិន!"

"..."

"បងប្រុស! បងប្រុស!"

"...ZZZ!"

អ៊ូយ...ហេតុអីបានមកគេងលក់អីចំពេលដែលខ្ញុំចង់ដឹងបែបនេះហ្ន៎? យ៉ាប់មែន!





## ភាគទី១៥
## គ្រោងការណ៍សម្ងាត់ I Love U

ព្រឹកថ្ងៃបន្ទាប់...

គួរឱ្យចម្លែកណាស់ដែលថ្ងៃនេះ គុនជេ មករកខ្ញុំដល់ផ្ទះទាំងព្រលឹម ដំបូងខ្ញុំស្មានថាមកនិយាយរឿងការកិច្ចធ្វើសង្សារក្លែងក្លាយ តែបែរជាយកគំរូបន្ទប់គេងសម័យទំនើប...ទាំងធ្វើទៅកុំព្យូទ័រនិងគូរដោយដៃមកឱ្យខ្ញុំមើលទៅវិញ ។

"អីគេ...? យកម៉ោឱ្យខ្ញុំមើលធ្វើអី?"

"គ្រោងការណ៍ដែលខ្ញុំសុំព័ត៌មានពីនាងនោះអ្ហ៎!"

"អ្ហ៎...អាគ្រោងការណ៍សម្ងាត់ដែលលោកនិងបងប្រុសខំលាក់អត់ព្រមប្រាប់ខ្ញុំហ្នឹងផ្អេស"

"តាមដែលបានសន្យា...បើនាងយល់ព្រមដោះដូរជាមួយខ្ញុំ ខ្ញុំនឹងប្រាប់ចំណងជើងគ្រោងការណ៍សម្ងាត់នោះ ដូច្នេះ..."

"ឈប់សិន ហេតុអីសុខៗលោកព្រមប្រាប់ខ្ញុំងាយៗបែបនេះ?" ខ្ញុំប្រញាប់ស្រែកឃាត់មុនពេលគេនិយាយអីបន្ត ជាហេតុធ្វើឱ្យគេងាកខ្ទាច់មកមើលមុខខ្ញុំ ដូចជាមិនចង់ជឿនឹងត្រចៀកខ្លួនឯងថាបានឮសម្តីបែបនេះចេញពីមាត់របស់ខ្ញុំ ល្មមខ្ញុំត្រូវប្រញាប់អធិប្បាយប្រាប់មុនពេលគេយល់ច្រឡំគិតថាខ្ញុំមិនចង់ដឹង ។

"...???"

"មិនមែនខ្ញុំមិនចង់ដឹងទេ គ្រាន់តែ..."

"គ្រាន់តែអី..."

"គ្រាន់តែខ្ញុំកំពុងសង្ស័យថា ព្រោះតែលោករកអ្នកជំនួសមកជួយធ្វើជាសង្សារបានហើយមែនទេ? ទើបលោកខ្ជិលរវាងដោយការយល់

ព្រមប្រាប់ឈ្មោះគ្រោងការណ៍ ដើម្បីគាស់ខ្ញុំទម្លាក់ឲ្យផុតពីជីវិត"



ខ្ញុំលួចមើលឃើញគេដែលធ្វើមុខទៀយណាយ មុននឹងសួរដាយសម្លេងល្វើយ៖

"ក្រែង មីណាម ជួយឃ្លៀរហើយតើអ្វី? ម៉េចក៏នាងនៅតែយល់អីខុសបែបនេះទៀត?"

ទោះដឹងការពិតពីបងប្រុសហើយថាអ្នកដែលគេលួចស្រឡាញ់បួនឆ្នាំមកនេះគឺខ្ញុំក៏ដោយ តែខ្ញុំចង់បានការអះអាងចេញពីមាត់គេខ្លាំងជាង ។

"ខ្ញុំអត់ទាន់បានជួយអីលោក ហើយសុខៗលោកក៏ព្រមមកប្រាប់ខ្ញុំស្រួលៗ ទាំងពីកាលមុនហ្នឹងលោកទំនិយាយគេចមិនព្រមប្រាប់មករហូត ទើបខ្ញុំគិតថា..."

"ការពិត...បើនាងចង់ជួយ ខ្ញុំក៏មិនថាអីដែរ"

"..."

"បើចង់ជួយមែនទែននោះ...ក៏..."

"..."

"ជួយធ្វើរហូតទៅល្អជាង កុំធ្វើតែពីរអាទិត្យ"

ហ្អឺ...ហ្នឹងគេកំពុងសុំខ្ញុំសោតប់មែនទេ? ខ្ញុំឮមិនខុសទេមែនទេ? គេប្រាប់ឲ្យខ្ញុំជួយធ្វើជាសង្សារគេរហូតទៅ មិនមែនតែពីរអាទិត្យទេ គេចង់បានន័យបែបហ្នឹងមែនទេ?

"គុនដេ...លោក!"

"យ៉ាងម៉េច? សម្រេចថាយល់ព្រមទៀតទេ?"

"..."

"តែលើកនេះខ្ញុំចង់បានន័យថាឲ្យនាងធ្វើជារៀងរហូត មិនមែនតែពីរអាទិត្យទេ..."

"..."

ហ៊ឺ...ខ្ញុំមុញទ្រាន់ខ្លួនឯងមែនទែន ដែលឥឡូវនេះក្លាយខ្លួនជាមនុស្សដែលមិនសូវចេះបដិសេធនរណាសោះ ។



បន្ទាប់ពីយល់ព្រមបែបចិត្តងាយជាទីបំផុតរួចហើយ ខ្ញុំក៏បានដឹងថា...ការពិត ក្វាងមីន និង សង្សារស្រឡាញ់គ្នាណាស់ គ្មានបញ្ហាប្រែប្រួលណ្ហអ្វីដូចដែលអាម៉ៀហ្នឹង និង ក្វាងមីន ប្រាប់នោះទេ តែព្រោះពីរនាក់ហ្នឹងបានយល់ព្រមដោះដូរគ្នាថា បើ ក្វាងមីន ព្រមធ្វើតាមផែនការគៀងខ្ញុំមកធ្វើជាសង្សារគេបាន គេក៏នឹងយល់ព្រមជួយពន្យល់រឿង ក្វាងមីន ហើយនិងខ្ញុំបន្លំសោតប់គ្នានោះប្រាប់ប្អូនដីដូនមួយដែរ ព្រោះកន្លងមកស្រីម្នាក់ហ្នឹង មិនព្រម សេយ៉េយេស ដាក់ ក្វាងមីន ទេ ព្រោះឮដំណឹងថា ក្វាងមីន សោតប់ខ្ញុំ ទើបសង្ស័យ មិនព្រមឆ្លើយអូខេ ។



"ហ្នឹងបានន័យថា...ដែលលោកធ្លាប់ប្រាប់ថាប្អូនស្រីរបស់លោកនឹងមកកូរ៉េជារឿងកុហកមែនទេ?"

"គេម៉ោមែន គ្រាន់តែអត់មានសង្ស័យរឿងនាងអីទៀតទេ ព្រោះខ្ញុំអធិប្បាយស្អាតអស់ហើយ"

"លោកចំជាប៉ិនកុហកមែន តែមិនអីទេ គ្រាន់តែលោកកុំទៅកុហកបោកអ្នកផ្សេងបែបនេះទៀតទៅបានហើយ ហើយបើហ៊ានម៉ោរៀបផែនការបោកខ្ញុំបែបហ្នឹងទៀតនោះ...ខ្ញុំនឹងជាន់មុំដែលលោកឲ្យខ្ទេចអស់ម្តងទៀតមិនខាន បើមិនជឿចាំមើលចុះ"

"បើអីចឹងខ្ញុំឲ្យ កូតា នាងជាន់ម្ល៉ូមួយម៉េចដែរ?"

"លោកនៅគិតចង់បោកប្រាស់អីខ្ញុំទៀតឬយ៉ាងម៉េច?"

"នាងទាយមិនត្រូវទេ ថាខ្ញុំប្រុងបោកអីនាងទៀងនោះ"

"តែខ្ញុំថា ខ្ញុំទាយត្រូវ!"

"អីចឹងទាយម៉ោ បើត្រូវខ្ញុំប្រាប់ តែបើអត់ត្រូវអត់ប្រាប់!"

"រឿងព័ត៌មាននោះ លោកបោកខ្ញុំ!"

"អ្ហំ អាហ្នឹង...ត្រូវហើយ! ខ្ញុំបោកនាង"

"..."

"ខ្ញុំប្រាប់ចាំឲ្យជួយទៅប្រាប់អ្នកកាសែតឲ្យចុះផ្សាយព័ត៌មានបែបនោះ ព្រោះចង់ដឹងថានាងប្រច័ណ្ឌអត់?"

"..."



"តែមិននឹកស្មានថាវាបានការដល់ថ្នាក់នោះសោះ"

"អ្នកណាទៅដឹងថាអីចឹង!"

"ឥឡូវដឹងហើយមែនទេថាស្រីម្នាក់នោះជានរណា" គេសួរ ព្រមទាំងមើលខ្ញុំដោយខ្សែភ្នែកដែលធ្វើឱ្យបេះដូងខ្ញុំលោតក្នុងខ្លាំង ស្ទើរតែរបូតចេញពីទ្រូង ។

"ដឹ...ដឹងហើយ តែ...ដែលលោកមិនចូលចិត្តម៉ាក់ខ្ញុំ សរុបថាពេលនេះក៏នៅតែមិនចូលចិត្តដដែលមែនទេ?"

"ត្រូវហើយ"

ចម្លើយបែបត្រង់ទៅត្រង់មករបស់គេធ្វើឱ្យខ្ញុំចាប់ផ្តើមកង្វល់ ។

"បើអីចឹង លោកនឹង..."

"អត់ចូលចិត្តម៉ាក់ តែស្រឡាញ់កូនស្រីម៉ាក់ ដូច្នេះអ្នកដែលជាកូនស្រីក៏មិនគួរបារម្ភដែរ" គេនិយាយចេញមកតាមត្រង់ម្តងទៀត ធ្វើឱ្យខ្ញុំទប់មិនចង់ទាន់ ហ្នឹងមែនទេដែលគេធ្លាប់ប្រាប់ថា បើពេលណាគេចង់ឱ្យខ្ញុំយល់ គេនឹងឆ្លើយបែបឱ្យខ្ញុំយល់បានស្រួលៗតែម្តង ។

ហើយមិនទាន់ទាំងបានហារមាត់និយាយអីទៀតផង ក៏ត្រូវគេច្រានចូលទៅក្នុងប្រឡោះតូចចង្អៀតមួយ រួចយកដៃយាំងខ្លួនខ្ញុំឱ្យនៅក្នុងនោះរហូតកម្រើកខ្លួនទៅណាមិនបាន ក្រៅពីបណ្តោយឱ្យគេប្រជៀតខ្លួនចូលមកកាន់តែជិត រហូតដល់គ្មាននៅសល់ប្រឡោះទំនេររវាងខ្ញុំនិងគេឡើយ ។

"នែលោក...ក្រែងថាស្អប់កន្លែងចង្អៀតអ្ហ៎? ឥឡូវហេតុអីបាននាំខ្ញុំមកនៅក្នុងប្រឡោះចង្អៀតបែបនេះ?"

"កាលពីបុណ្យខួបកំណើត មីណាម ដែលវាឱ្យខ្ញុំយកការងារទៅធ្វើនៅបន្ទប់នាង..." សុខៗគេក៏យករឿងកាលពីឆ្នាំមុនមកនិយាយធ្វើឱ្យខ្ញុំតាមគេមិនទាន់ ។

"ហេតុអី?"

"ការពិតក៏ព្រោះ...បន្ទប់នាងធំជាងគេបំផុតនៅក្នុងផ្ទះ ហើយមីណាម ក៏ដឹងដែរថា ខ្ញុំមិនចូលចិត្តកន្លែងចង្អៀត"

"..."





"ពេលនោះខ្ញុំបម្រុងតែប្រាប់នាង តែនាងរត់ចេញទៅបាត់"

"ហ៊ឹស...មិនមែនព្រោះលោកស្រឡាញ់ខ្ញុំទេអ្ហ៎?"

"អាហ្នឹងក៏ជាមូលហេតុមួយដែរ"

"ហើយហេតុអីសុខៗ បានមកប្រាប់ពេលនេះ?"



"ព្រោះពេលនេះ ខ្ញុំមានអារម្មណ៍ថាខ្ញុំចាប់ផ្តើមចូលចិត្តកន្លែងចង្អៀតហើយហ្នឹងណា៎" ថាចប់ បបូរមាត់របស់គេក៏ទម្លាក់ចុះមកព្រមទាំងប្រជ្រៀតខ្លួនចូលមកកាន់តែជិតជាងមុន ជាការអះអាងថា...ពេលនេះគេចាប់ផ្តើមចូលចិត្តកន្លែងចង្អៀតមែនហើយ ។

ហើយមើលទៅគេជាពួកដែលបានមួយចង់បានមួយចម្អាមហើយ ចង់យកមួយហត្ថទៀត ពេលខ្ញុំមានអារម្មណ៍ថាដៃក្តៅឧណ្ហៗរបស់គេកំពុងរំកិលចង់មកក្រវែលៗក្នុងអាវរបស់ខ្ញុំ ទើបត្រូវប្រញាប់ច្រានគេចេញដល់ថ្នាក់គេរអ៊ូរទាំនៅក្នុងបំពង់-កដោយការទាស់ចិត្ត ។

"ហ៊ឺ...សុំលើសបន្តិចបន្តួចក៏មិនបាន អាទិត្យក្រោយខ្ញុំត្រូវទៅប្រកួតនៅសាំងហ្គាពួហើយ ចិត្តថ្លើមចង់ទុកឱ្យទៅទាំងនៅស្ទះតាំងបែបហ្នឹងមែនទេ?"

"ត្រូវហើយ! បើលោកនៅតែហ៊ានធ្វើមិនសមរម្យបែបនេះទៀត ខ្ញុំនឹងប្តឹងម៉ាក់!"

"ម៉ាក់នាងអត់ថាអីទេ...ព្រោះអ្នកដែលគាត់ត្រៀមចាប់នាងរៀបការជាមួយ គឺខ្ញុំហ្នឹងអ្ហែង"

"ស្អីគេ!?"

"ខ្ញុំឱ្យចាំទៅដណ្តឹងនាងពីគាត់ទុកយូរណាស់ហើយ គ្រាន់តែខ្ញុំអត់ប្រាប់អ្នកណា សូម្បីតែ មីណាម ក៏ដោយ"

"បើអីចឹងហេតុអីលោកមិនប្រាប់តាំងពីដំបូង?"

"បើប្រាប់ហើយ នាងយល់ព្រមអ្ហ៎?"

"បើជាលោក ខ្ញុំក៏ប្រហែលជាយល់ព្រម"

"តែនាងគួរតែបានប្រើជីវិត សប្បាយៗមានសេរីភាពជាមួយមិត្តភក្តិខ្លះមុនពេលរៀបការ ពេលត្រឡប់មើលទៅក្រោយវិញបន្ទាប់ពីរៀបការរួច នឹងមិនបាច់ស្តាយក្រោយ"



តើគេគិតទុកសម្រាប់ខ្ញុំអស់ហើយឬ? រំភើបចិត្តមែនទែន គិតត្រូវហើយដែលស្រឡាញ់គេ ។

"តែ...ដែលលោកប្រាប់ថាអាទិត្យក្រោយត្រូវទៅប្រកួតនៅសាំងហ្គាពួ គឺរឿងម៉ូដែលដែលលោកបានធ្វើជាមួយបងប្រុសនៅមហាវិទ្យាល័យអស់មួយអាទិត្យនោះមែនទេ?"

"អាហ្នឹងនៅខែក្រោយ តែអានេះគឺគ្រោងការណ៍សម្ងាត់មួយនោះ!"

"អ្ហ៎...ហើយសម្រេចថាលោកប្រាប់ខ្ញុំបាននៅថាគ្រោងការណ៍សម្ងាត់នោះ ស្អីទៅ?"

"គឺអ្វីដែលខ្ញុំយកឱ្យមើលអម្បាញ់មិញហ្នឹងអ្ហែង!"

"សរុបថាគឺជាគ្រោងការណ៍បន្ទប់គេងអ្ហែស?"

"ប៊ិះត្រូវ..."

"ម៉េចបានត្រឹមតែប៊ិះត្រូវ?"

"សាកមើលមុខខ្ញុំសិន ហើយសឹមឆ្លើយថាជាបន្ទប់គេងអី..."

"អត់ទេ! ខ្ញុំមើលមុខលោកហើយ រឹតតែគិតអត់ចេញ" ថាចប់ទាំងខ្ញុំនិងគេក៏ស្ងាត់ទាំងអស់គ្នាដោយមិនបានណាត់ ។

"..."

"..."

"សរុបទៅ ចង់ឱ្យខ្ញុំឆ្លើយ?"

"ចាប់ឆ្លើយម៉ោ! ប្រាប់លឿនម៉ោថាជាគ្រោងការណ៍បន្ទប់គេងអី?" ខ្ញុំប្រញាប់ធ្វើសម្លេងមាំបន្ថប់ ទាំងការពិតអៀនសឹងតែខម្លាក់ខ្លួនដេកក្បែរជើងគេទៅហើយ ។

"បន្ទប់គេងរបស់អនាគតភរិយា..." គេឆ្លើយដោយសម្លេងស្រទន់ព្រមទាំងសម្លឹងមើលមុខខ្ញុំដោយមានអត្ថន័យ ។

ច្ចូតមែន...នេះគេហ៊ានយកខ្ញុំទៅធ្វើជាម៉ូដែលភរិយានាពេលអនាគតដោយអត់មានសួរយោបល់ខ្ញុំមុនផង ម៉េចក៏ខ្វះសុជីវធម៌ម្លេះ តែមិនអីទេ ទោះគេមិនសួរយោបល់ ក៏ខ្ញុំពេញចិត្តធ្វើជាទីបំផុតដែរ ។

តែថាមួយសន្ទុះក្រោយមក...ខ្ញុំក៏ទឹកឃើញថាបងប្រុសបានយក





គំរូសំនួរចម្លើយនោះទៅឱ្យមីង ហើរ ធ្វើទេតើ...

បញ្ជាក់ថា...បងប្រុសលួចពេញចិត្តមីង ហើរ ឬ?

ទឹកឃើញដូច្នេះហើយ ខ្ញុំក៏ដើរទៅរកបងប្រុសដែលកំពុងអង្គុយមើលធីវីនៅក្នុងបន្ទប់ធំ ។



"ស្លាប់! ម៉េចបានឯងគិតអីចឹង? បងហ្នឹងផ្អែសទៅគិតអកុសលទៅលើមីង ហើរ?" បងប្រុសធ្វើមុខដូចឃើញខ្មោចក្លាមពេលខ្ញុំចោទថាគិតផ្តេសផ្តាសទៅលើមីងសាច់ថ្លៃ ។

"មកពីបងយកគំរូសំនួរចម្លើយទៅឱ្យមីងធ្វើ សម្តែងថាការពិតបងមានផែនការចង់ដណ្តើមមីងពី...អ៊ុំ ម៉េចបានបងគួរឱ្យស្អប់បែបនេះ?!"

"អាច្កួត! ឯងគិតចម្លែកៗបានរហូតហ្នឹងហ្ន៎ ឯងមើលមកបងថាជាមនុស្សយ៉ាងម៉េច បានទៅមានផែនការចង់បានមីងថ្លៃខ្លួនឯង?"

"បើអីចឹងហេតុអីក៏បងយកគំរូសំនួរចម្លើយនោះទៅឱ្យមីងធ្វើ?" ខ្ញុំសួរ ព្រមទាំងសម្លឹងមើលបងប្រុសដោយមិនសូវជាទុកចិត្តប៉ុន្មាន ។

"បងគ្រាន់តែយកមីង ហើរ ធ្វើជាគំរូរបស់ស្រីក្នុងឧត្តមគតិបងប៉ុណ្ណោះ តែឯងបែរជាគិតទៅដល់ណាដល់ណី..."

អ្ហ៎ ការពិតគឺបែបហ្នឹងទេអ្ហី...ប្រហែលជាដូចបុរសខ្លះដែលចង់បានប្រពន្ធដែលមានលក្ខណៈស្រដៀងម្តាយរបស់ខ្លួនហ្នឹងអ្ហែង អាឯងនេះក៏ប្រឡំយល់ខុសតាំងពីយូរ ។

"អ្ហា៎ អ្នកណាទៅដឹង?"

"..."

"ថាទៅវាក៏គ្មានអីប្លែកដែរ ដែលបងយកទៅឱ្យមីងជួយធ្វើនោះព្រោះពេលនេះបងក៏នៅមិនទាន់ពេញចិត្តនរណាជាពិសេសដែរ"

"..."

"តែ...បើបងមិនដឹងថាឱ្យអ្នកណាជួយធ្វើ ម៉េចមិនយកមកឱ្យខ្ញុំធ្វើឱ្យ?"

"បងមានអនាគតពីយ បើហ៊ានតែយកទៅឱ្យឯងធ្វើឱ្យ វាស្មើនឹងបងរៀបផែនការគ្រួសារនាពេលអនាគតឱ្យវាចប់ដោយការរលំ



ភលាយហ្នឹងអ្ហែង"

"ហ្នឹងបងថាឲ្យខ្ញុំភ្លេស?"

"ឬក៏មិនពិត? មើលម៉ារឿងៗដែលឯងធ្វើទៅ ដូចក្មេងមិនចេះធំ"

"..."

"ចំណែកឯង...គុនដេ ប្រាប់តាមត្រង់ចុះថា ខ្ញុំនៅមិនទាន់បាត់ចម្លែកចិត្តទេដែលឯងសម្រេចចិត្តបែបនេះ សួរតាមត្រង់ចុះ ឯងស្រឡាញ់វាទៅកើតដែរ អាក្មេងមិនចេះធំម្នាក់នេះ?"

"បងប្រុស!!!"

"ឯងអត់ដឹងទេភ្លេស មីណាម ថាការពិតទៅ...ខ្ញុំជាមនុស្សដែលស្រឡាញ់ក្មេងណាំ!" ចប់សម្តីប្រច្រឡឹមរបស់គេ បងប្រុសក៏ធ្វើសម្លេងក្អួតភ្លាម...

"អ្ហូយ! ខ្ញុំចង់ក្អួតណាស់ គុនដេ អើយ!"

ជាប់ហើយ ឆ្លើយបែបនេះមិនឲ្យស្រឡាញ់ម៉េចបាន មែនទេ?



Scanned by Pinky Berry
Sept. 12th, '12
www.laksmie26.wordpress.com
www.pinkyberryworld.blogspot.com





**ភាគបញ្ចប់**

**លទ្ធផលនៃការប្រកួតការច្នៃម៉ូតតុបតែងផ្ទះ**

ពិធី Singapore Unique Design Award 20xx

Winner Award

Bed Room's Acting Wife

Designed by : Mr. Han Kun De

From : Korea

**ចប់**